សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Driot et des Sciences Économiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលឃុំវិហារសួគ៌

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **ត័ន្ត្រ សុតានាត**
កញ្ញា **វិន្ទ ដាណេ**

ណែនាំដោយ
សាស្ត្រាចារ្យរងបណ្ឌិត **សឿន សោភ័ណ**

ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី១៧

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ជាបឋម យើងខ្ញុំទាំងពីររូបឈ្មោះ ភ័ក្ត្រ សុភានាត និង រិទ្ធ ដាណេ ជានិស្សិតដែលកំពុងសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញរដ្ឋបាលសាធារណៈ ឆ្នាំទី៤ ឆមាសទី២ ជំនាន់ទី១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២៣-២០២៤។

យើងខ្ញុំទាំងពីររូប សូមសម្តែងនូវការគោរព ដឹងគុណ និងកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅចំពោះ៖

- **លោកឪពុក និងអ្នកម្តាយ** ដែលបានផ្តល់កំណើតដល់កូន និងបានចិញ្ចឹមបីបាច់ថែរក្សាតាំងពីចាប់កំណើតក្នុងផ្ទៃរហូតដល់ធំដឹងក្តី។ ជាពិសេសលោកដ៏មានគុណទាំងពីរ តែងតែយកចិត្តទុកដាក់ទំនុកបម្រុងកូនគ្រប់បែបយ៉ាងប្រកបទៅដោយព្រហ្មវិហារធម៌ ក្នុងការអប់រំទូន្មានប្រៀនប្រដៅឱ្យកូនខិតខំព្យាយាមរៀនសូត្រមិនតែប៉ុណ្ណោះលោកទាំងទ្វេបានទទួលរ៉ាប់រងរាល់កិច្ចការលំបាក និងពុះពាររាល់ឧបសគ្គទាំងឡាយដោយលះបង់កម្លាំងកាយចិត្ត និងទ្រព្យសម្បត្តិដើម្បីបង្កជាលក្ខណៈងាយស្រួលឱ្យកូនសិក្សារៀនសូត្រតាំងពីថ្នាក់បឋមសិក្សារហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្របានដោយជោគជ័យ មានចំណេះដឹង ក្លាយជាកូនល្អ មិត្តល្អ ពលរដ្ឋល្អក្នុងសង្គមនិងមានឱកាសក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិថែមទៀតផង។ឧបការគុណដ៏ធំធេងដែលមិនអាចកាត់ថ្លៃបាននេះធ្វើឱ្យរូបកូនចងចាំជានិច្ច និងមិនអាចបំភ្លេចបានឡើយ។
- **ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ** សាកលវិទ្យាធិការង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង និងលោក លោកស្រីសាស្ត្រាចារ្យគ្រប់មុខវិជ្ជានៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំប្រឹងប្រែងបំពេញតួនាទីភារកិច្ច ដឹកនាំ គ្រប់គ្រង និងជាពិសេសបណ្តុះបណ្តាលនិស្សិតគ្រប់ៗរូបឱ្យក្លាយទៅជាបញ្ញវន្តដែលប្រកបទៅដោយសក្តានុពលភាព។
- **លោកសាស្ត្រាចារ្យរង បណ្ឌិត សឿន សោភ័ណ** ដែលលោកបានចំណាយពេលវេលាបង្រៀន ផ្តល់ជាមតិយោបល់ល្អៗ និងណែនាំយើងទាំងពីរដោយយកចិត្តទុកដាក់ និងជាពិសេសលោកបានលះបង់ទាំងកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃធ្វើការត្រួតពិនិត្យ និងកែតម្រូវនូវចំណុចខ្វះខាតនៃសារណាបញ្ចប់ការសិក្សាមួយនេះរហូតដល់ទទួលបានជោគជ័យ។
- **លោកមេឃុំ ម៉េង ឈាងហេង** សមាជិកក្រុមប្រឹក្សា ស្មៀនឃុំ និង ជំនួយការហិរញ្ញវត្ថុនៃរដ្ឋបាលឃុំវិហារសួគ៌ដែលអនុញ្ញាតឱ្យយើងទាំងពីររូប បានចុះធ្វើការស្រាវជ្រាវឯកសារ និងបានស្វែងយល់អំពីទិដ្ឋភាពជាក់ស្តែងនៃការគ្រប់គ្រងរបស់រដ្ឋបាលឃុំវិហារសួគ៌។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរសូមគោរពជូនពរ និងសូមលើកហត្ថាទាំងទ្វេបួងសួងដល់ទេវតានិងវត្ថុសក្តិសិទ្ធិក្នុងវត្តព្រះវិហារសួគ៌ សូមជួយថែរក្សាលោកអ្នកមានគុណទាំងពីរ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ លោកសាស្ត្រាចារ្យរង បណ្ឌិត សឿន សោភ័ណ និងលោក លោកស្រីទាំងអស់ជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ការសិក្សាស្រាវជ្រាវដែលទាក់ទងទៅនឹងប្រធានបទ" **ការគ្រប់គ្រងរដ្ឋបាលឃុំវិហារសួគ៌** "គឺជាសមិទ្ធផលថ្មីមួយសម្រាប់យើងខ្ញុំទាំងពីររូប បន្ទាប់ពីបានសិក្សាអស់រយៈពេលជិត៤ឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាស្នាដៃមួយដែលបានលេចរូបរាងឡើងដោយកិច្ចខិតខំប្រឹងប្រែង ចំណាយទាំងពេលវេលា កម្លាំងកាយ កម្លាំងចិត្ត និងព្រមទាំងមានការយកចិត្តទុកដាក់យ៉ាងខ្លាំងបំផុតក្នុងការរៀបរៀង និងធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ ហើយយើងខ្ញុំសង្ឃឹមថាសារណាបញ្ចប់ការសិក្សាមួយនេះ នឹងអាចក្លាយទៅជាផ្នែកមួយសម្រាប់និស្សិតគ្រប់រូបដែលមានបំណងចង់សិក្សាស្រាវជ្រាវ និងចង់ស្វែងយល់បន្ថែមទៅលើបញ្ហាដែលពាក់ព័ន្ធទៅនឹងតថភាពជាក់ស្តែងនៃការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់។

ប្រធានបទដែលយើងទាំងពីររូប បានសម្រេចចិត្តជ្រើសរើសយកមកសរសេរជាសារណាបញ្ចប់ការសិក្សានេះគឺជាប្រធានបទមួយដែលកើតចេញពីការសង្កេតឃើញជាក់ស្តែងនិងមានឆន្ទៈចង់សិក្សាស្រាវជ្រាវយ៉ាងខ្លាំង។ ម្យ៉ាងទៀតដោយសង្កេតឃើញថា រាជរដ្ឋាភិបាលកម្ពុជាកំពុងតែយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការធ្វើកំណែទម្រង់នៃការគ្រប់គ្រងតាមបែបវិមជ្ឈការ និងវិសហមជ្ឈការនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ តាមរយៈកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនេះ រដ្ឋបាលឃុំ សង្កាត់នីមួយៗ បានក្លាយជានីតិបុគ្គលនៃនីតិសាធារណៈដែលមានតំណាងជាក្រុមប្រឹក្សាកើតឡើងពីការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋ ព្រមទាំងមានសិទ្ធិអំណាច ធនធាន និងស្វ័យភាពក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចការនានានៅមូលដ្ឋានដើម្បីបម្រើផលប្រយោជន៍និងសេចក្តីត្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ។ ថ្វីត្បិតតែរដ្ឋបាលឃុំ សង្កាត់ជាមណ្ឌលរដ្ឋបាលដែលទាបជាងគេក៏ពិតមែន ប៉ុន្តែរដ្ឋបាលឃុំ សង្កាត់ពិត ជាដើរតួនាទីយ៉ាងសំខាន់ណាស់ក្នុងការជួយឱ្យរដ្ឋបាលថ្នាក់កណ្តាលអាចក្តោបក្តាប់បាននូវព័ត៌មានទាំងអស់របស់ប្រជាពលរដ្ឋពីព្រោះថារដ្ឋបាលឃុំ សង្កាត់គឺជារដ្ឋបាលមូលដ្ឋានដែលនៅជិតនិងកៀកប្រជាពលរដ្ឋធ្វើការផ្ទាល់ជាមួយប្រជាពលរដ្ឋ ដឹងពីសុខទុក្ខ និងដឹងពីតម្រូវការរបស់ប្រជាពលរដ្ឋបានច្បាស់ជាងគេ។ ហេតុដូច្នោះហើយ ទើបយើងខ្ញុំទាំងពីររូបសម្រេចចិត្តជ្រើសរើសប្រធានបទនេះសរសេរជាសារណាបញ្ចប់ការសិក្សាក្នុងគោលបំណង ដើម្បីស្វែងយល់បន្ថែមអំពីដំណើរការគ្រប់គ្រង ការអនុវត្ត ការផ្តល់សេវារដ្ឋបាល និងតួនាទីរបស់រដ្ឋបាលឃុំ សង្កាត់នៅថ្នាក់ក្រោមជាតិឱ្យកាន់តែច្បាស់ក្នុងតថភាពជាក់ស្តែងជាពិសេសនៅរដ្ឋបាលឃុំវិហារសួគ៌ផ្ទាល់តែម្តង។

កំហុសខុសឆ្គងនឹងអាចកើតមានក្នុងកិច្ចការមួយនេះជាក់ជាមិនខាន ដោយសារតែបច្ចេកទេស អក្ខរាវិរុទ្ធ។ ដូច្នេះយើងខ្ញុំទាំងពីរសូមអភ័យទោសទុកជាមុនពីសំណាក់ សម្តេច ទ្រង់ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងមិត្តនិស្សិតអ្នកអានទាំងអស់រាល់កំហុសដែលកើតមាន។ យើងខ្ញុំទាំងពីររូប រីករាយក្នុងការទទួលយកនូវការបំពេញបន្ថែមរបស់លោកសាស្ត្រាចារ្យ ក៏ដូចជាមិត្តៗនិស្សិត ដើម្បីយកមកបំពេញនូវចំណុចខ្វះខាតក្នុងការធ្វើឱ្យស្នាដៃមួយនេះមានលក្ខណៈកាន់តែល្អប្រសើរឡើង។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃរដ្ឋបាលឃុំ សង្កាត់**

**១.១.និយមន័យនៃពាក្យគន្លឹះ** ........ ៦

១.១.១.ការគ្រប់គ្រង ........ ៦

១.១.២.រដ្ឋបាល ........ ៦

១.១.៣.ឃុំ សង្កាត់ ........ ៧

**១.២.សាវតាររដ្ឋបាលឃុំ សង្កាត់** ........ ៧

១.២.១.រដ្ឋបាលឃុំ សង្កាត់ពីឆ្នាំ ១៩០៨ ដល់ឆ្នាំ១៩៥៥ ........ ៧

១.២.២.រដ្ឋបាលឃុំ សង្កាត់ពីឆ្នាំ ១៩៥៥ ដល់ឆ្នាំ១៩៧៩ ........ ៩

១.២.៣.រដ្ឋបាលឃុំ សង្កាត់ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ១៩៩៣ ........ ៩

១.២.៤.រដ្ឋបាលឃុំ សង្កាត់ក្រោយការបោះឆ្នោតជាតិឆ្នាំ១៩៩៣ ........ ១០

**១.៣.តួនាទី មុខងារ និងអំណាចនៃរដ្ឋបាលឃុំ សង្កាត់** ........ ១១

១.៣.១.តួនាទី និង មុខងាររបស់រដ្ឋបាលឃុំ សង្កាត់ ........ ១២

១.៣.២.អំណាចរបស់រដ្ឋបាលឃុំ សង្កាត់ ........ ១២

១.៣.៣.ព្រំដែននៃអំណាច ........ ១៣

**១.៤.ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលឃុំ សង្កាត់** ........ ១៣

១.៤.១.រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់ ........ ១៣

១.៤.២.តួនាទី និងភារកិច្ចរបស់អង្គនីមួយៗ ........ ១៤

**ជំពូកទី២**

**ដំណើរការគ្រប់គ្រងរដ្ឋបាលឃុំវិហារសួគ៌**

**២.១.ទិដ្ឋភាពទូទៅនៃឃុំវិហារសួគ៌** ........ ២៦

២.១.១.ប្រវត្តិឃុំវិហារសួគ៌ ........ ២៦

២.១.២.ស្ថានភាពភូមិសាស្ត្រ ........ ២៦
២.១.៣.ស្ថានភាពប្រជាសាស្ត្រ ........ ២៧
**២.២.រចនាសម្ព័ន្ធរដ្ឋបាលឃុំវិហារសួគ៌** ........ ២៧
២.២.១.សមាសភាពក្រុមប្រឹក្សា ........ ២៧
២.២.២.គណៈកម្មាធិការរបស់ឃុំ ........ ២៨
**២.៣.ផែនការអភិវឌ្ឍន៍ឃុំ** ........ ៣៥
២.៣.១.ដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំ ........ ៣៦
២.៣.២.ការតាមដានត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ ........ ៣៨
**២.៤.កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ** ........ ៣៩
២.៤.១.ដំណើរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ........ ៣៩
២.៤.២.ការតាមដានត្រួតពិនិត្យ និង វាយតម្លៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ........ ៤០
២.៤.៣.គម្រោង សកម្មភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ........ ៤១
**២.៥.ការផ្តល់សេវារដ្ឋបាល** ........ ៤៤
២.៥.១.ការងារអត្រានុកូលដ្ឋាន ........ ៤៤
២.៥.២.ការចេញលិខិតបញ្ជាក់ ........ ៤៤
**២.៦.ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ឃុំ** ........ ៤៥
២.៦.១.ថវិកាឃុំ ........ ៤៥
២.៦.២.ចំណូល និង ចំណាយ ........ ៤៧

## ជំពូកទី៣
## សមិទ្ធផលការងារដែលសម្រេចបានរបស់រដ្ឋបាលឃុំវិហារសួគ៌

**៣.១.កិច្ចការរដ្ឋបាល** ........ ៤៨
៣.១.១.ការដាក់ចេញនូវលិខិតបទដ្ឋាននានា ........ ៤៨
៣.១.២.កិច្ចប្រជុំក្រុមប្រឹក្សា គណៈកម្មាធិការ និង គណៈកម្មការ ........ ៤៨
**៣.២.ការផ្តល់សេវាសាធារណៈ** ........ ៤៩
៣.២.១.ការផ្តល់សេវារដ្ឋបាល ........ ៥០

៣.២.២.ការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត ........ ៥២
៣.២.៣.ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ........ ៥២
៣.២.៤.ការងារសង្គមកិច្ច ........ ៥៤
៣.២.៥.បរិស្ថាន និងធនធានធម្មជាតិ ........ ៥៦
៣.២.៦.ហេដ្ឋារចនាសម្ព័ន្ធ ........ ៥៧
៣.២.៧.វេទិកាសាធារណៈ ........ ៥៧

## ជំពូកទី៤
## បញ្ហាប្រឈម និង ដំណោះស្រាយ

**៤.១.ស្ថានភាពបច្ចុប្បន្ន និង បញ្ហាប្រឈម** ........ ៥៩
៤.១.១.ផ្នែកសេដ្ឋកិច្ច ........ ៥៩
៤.១.២.ផ្នែកសង្គមកិច្ច ........ ៦០
៤.១.៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ ........ ៦១
៤.១.៤.ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ........ ៦២
**៤.២.ដំណោះស្រាយ** ........ ៦៣
៤.២.១.ពង្រឹងវិស័យសេដ្ឋកិច្ច ........ ៦៣
៤.២.២.ពង្រឹងវិស័យសង្គមកិច្ច ........ ៦៤
៤.២.៣.ពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ ........ ៦៥
៤.២.៤.ពង្រឹងការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់ ........ ៦៦
**សេចក្តីសន្និដ្ឋាន** ........ ៦៨
**អនុសាសន៍** ........ ៧០
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

១. **គ.ជ.ប** ៖ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

២. **គ.ផ.ថ** ៖ គណៈកម្មាធិការកសាងផែនការ និងថវិកា

៣. **គ.ក.ន.ក** ៖ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

រដ្ឋបាលឃុំ ឬពាក្យ"ឃុំ"នេះ ត្រូវបានគេលើកឡើងដំបូងនៅក្នុងឆ្នាំ១៩០៨តាមរយៈការដាក់ឱ្យប្រើនូវក្រឹត្យស្តីពីការរៀបចំរដ្ឋបាលឃុំដែលបានចូលជាធរមាននៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩០៨។ ចំណែកពាក្យ"សង្កាត់" ត្រូវបានចាប់ផ្តើមប្រើប្រាស់ជាដំបូងនៅក្នុងឆ្នាំ១៩៦៥ជំនួសពាក្យ"ឃុំ"បន្ទាប់ពីការធ្វើសមាជជាតិលើកទី២០សម្រាប់សម្គាល់ឃុំនៅក្នុងទីក្រុង ហើយការផ្លាស់ប្តូរឈ្មោះនេះ គឺដើម្បីឱ្យស្របនឹងមនោគមន៍វិជ្ជានិយមរាស្ត្ររបស់ចលនាសង្គមរាស្ត្រនិយម។ រហូតមកទល់នឹងបច្ចុប្បន្ននេះទាំងពាក្យឃុំនិងពាក្យសង្កាត់ត្រូវបានយកមកប្រើប្រាស់ នេះបើយោងតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣បានចែងថា ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។[1]គិតត្រឹមខែមករា ឆ្នាំ២០២៤នេះព្រះរាជាណាចក្រកម្ពុជាមានរាជធានី ខេត្តចំនួន២៥ ក្រុង ស្រុក ខណ្ឌចំនួន២០៩ ឃុំ សង្កាត់ចំនួន១៦៥២ និងមានភូមិចំនួន១៤៥៧៧។[2]

ជាការពិតណាស់មុនឆ្នាំ២០០២ រដ្ឋបាលនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិគឺជាអាជ្ញាធរដែលត្រូវបានតែងតាំងឡើង ហើយរដ្ឋបាលទាំងនេះបំពេញការងារក្នុងនាមរាជរដ្ឋាភិបាល និងក្នុងឋានៈជាទីភ្នាក់ងារដែលរាជរដ្ឋាភិបាលបានធ្វើប្រតិភូកម្មឱ្យអនុវត្តសេចក្តីសម្រេច សេចក្តីណែនាំ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល។ ក្រោយមកចាប់តាំងពីរាជរដ្ឋាភិបាលអាណត្តិទី២របស់រដ្ឋសភាមក រាជរដ្ឋាភិបាលបានខិតខំធ្វើកំណែទម្រង់យ៉ាងខ្លាំងទៅលើស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងនោះផងដែររាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើការកែទម្រង់នៃការគ្រប់គ្រងតាមបែបវិមជ្ឈការ និងវិសហមជ្ឈការនៅស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ក្នុងទិសដៅដើម្បីពង្រឹងនូវលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយក្នុងការបង្កិតសេវាសាធារណៈឱ្យកាន់តែខិតទៅជិតប្រជាពលរដ្ឋ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានយករដ្ឋបាលឃុំ សង្កាត់ធ្វើជាចំណុចចាប់ផ្តើមក្នុងការអនុវត្តនូវកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការដែលបានចាប់ផ្តើមអនុវត្តនៅកម្ពុជាក្នុងឆ្នាំ២០០២តាមរយៈការដាក់ឱ្យប្រើប្រាស់ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងឆ្នាំ២០០១។ តាមរយៈច្បាប់នេះ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេសចំនួន១,៦២១ឃុំ សង្កាត់ត្រូវបានរៀបចំឡើងតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនិងបានប្រព្រឹត្តទៅដោយជោគជ័យនៅក្នុងឆ្នាំ២០០២ ព្រមទាំងបានបង្កើតអាជ្ញាធរមូលដ្ឋានមួយយ៉ាងសំខាន់ ដូចនេះចាប់ពីឆ្នាំ២០០២មកការគ្រប់គ្រងនៅថ្នាក់រដ្ឋបាលឃុំ សង្កាត់គឺមានការកែសម្រួលច្រើន។ រដ្ឋបាលដែលបានជ្រើសរើសឡើងតាមការបោះឆ្នោតនេះ

---

[1] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣,មាត្រា១៤៥ថ្មី

[2] អគ្គនាយកដ្ឋានរដ្ឋបាល,*សៀវភៅព័ត៌មានរាជធានី ខេត្ត* (២០២៤),២

គឺជាមធ្យោបាយមួយសម្រាប់អនុវត្តការងារតាមរយៈការផ្ទេរភាពជាម្ចាស់ពីរាជរដ្ឋាភិបាលដើម្បីធានាឱ្យឃុំ សង្កាត់តំណាងឱ្យផលប្រយោជន៍សហគមន៍នៅមូលដ្ឋានរបស់ខ្លួនមានការឆ្លើយតប និងព្រមទាំងមានគណនេយ្យភាពចំពោះសហគមន៍នៅមូលដ្ឋាន។

តាមរយៈកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ រដ្ឋបាលឃុំ សង្កាត់នីមួយៗ បានក្លាយជានីតិបុគ្គលនៃនីតិសាធារណៈដែលមានតំណាងជាក្រុមប្រឹក្សាកើតឡើងពីការបោះឆ្នោត ដោយផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ព្រមទាំងមានសិទ្ធិអំណាច ធនធាន និងស្វ័យភាពក្នុងការគ្រប់គ្រង និងចាត់ចែងកិច្ចការនានានៅមូលដ្ឋានស្របតាមការកំណត់របស់ច្បាប់ ដើម្បីបម្រើផលប្រយោជន៍និងសេចក្តីត្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ។ ក្រុមប្រឹក្សាឃុំ សង្កាត់ គឺជារដ្ឋបាលដែនដីដែលមានកម្រិតទាបជាងគេនៅក្នុងប្រទេសកម្ពុជា និងជារដ្ឋបាលមួយនៅកៀកជិតជាប់នឹងប្រជាពលរដ្ឋបំផុត ដែលផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋនៅក្នុងការទទួលបានសេវាសាធារណៈផ្សេងៗ។ ទន្ទឹមនឹងនេះក្រុមប្រឹក្សាឃុំ សង្កាត់គឺជាអ្នកដែលយល់ច្បាស់អំពីអ្វីដែលប្រជាពលរដ្ឋត្រូវការជាងគេ និងដឹងច្បាស់ថាត្រូវធ្វើអ្វីខ្លះ ដែលជាតម្រូវការអាទិភាពដែលត្រូវធ្វើការឆ្លើយតប ឬធ្វើការអភិវឌ្ឍន៍នៅក្នុងមូលដ្ឋាន ដើម្បីបង្កភាពងាយស្រួលជូនប្រជាពលរដ្ឋគ្រប់ៗរូបដែលរស់នៅក្នុងដែនសមត្ថកិច្ចនៃការគ្រប់គ្រងរបស់ខ្លួន។ រហូតមកទល់ពេលនេះ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នៅតាមឃុំសង្កាត់នីមួយៗនៅទូទាំងប្រទេសបានធ្វើការរៀបចំឡើងចំនួន៥លើក ស្របតាមការកំណត់នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដោយលើកចុងក្រោយបានធ្វើឡើងនៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០២២ និងមានសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ទូទាំងប្រទេសសរុបចំនួន១១,៦២២រូប(ស្រី២,៥៦២)រូប[3] ត្រូវបានទទួលស្គាល់ និងបានចូលកាន់តំណែងនៅតាមឃុំ សង្កាត់ដែលសាមីខ្លួនបានឈរឈ្មោះនិងទទួលបានជោគជ័យនៅក្នុងការបោះឆ្នោត។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីជាជំនួយជួយទៅដល់ការបកស្រាយប្រធានបទ" **ការគ្រប់គ្រងរដ្ឋបាលឃុំវិហារសួគ៌** "ឱ្យកាន់តែស៊ីជម្រៅ ក៏ដូចជាដើម្បីឱ្យកាន់តែមានភាពច្បាស់លាស់បន្ថែមទៀតនោះ យើងខ្ញុំទាំងពីរបានលើកយកបញ្ហាចោទមួយចំនួនមកធ្វើការបកស្រាយដែលបញ្ហាទាំងអស់នោះរួមមាន៖

- តើការគ្រប់គ្រងរដ្ឋបាលឃុំវិហារសួគ៌មានដំណើរការប្រព្រឹត្តទៅយ៉ាងដូចម្តេច? ហើយថាតើរចនាសម្ព័ន្ធរបស់រដ្ឋបាលឃុំវិហារសួគ៌មានលក្ខណៈបែបណា?
- តើប្រភេទនៃសេវារដ្ឋបាលដែលរដ្ឋបាលឃុំវិហារសួគ៌បម្រើជូនប្រជាពលរដ្ឋមានអ្វីខ្លះ?
- តាមរយៈដំណើរការនៃការគ្រប់គ្រងកន្លងមកនេះតើរដ្ឋបាលឃុំវិហារសួគ៌សម្រេចបាននូវសមិទ្ធផលការងារអ្វីខ្លះ?

[3] សាលាជាតិរដ្ឋបាលមូលដ្ឋាន, *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់* (២០២២)

- តើដំណើរការនៃគ្រប់គ្រងរបស់រដ្ឋបាលឃុំវិហារសួគ៌បានជួបប្រទះនូវបញ្ហាប្រឈមអ្វីខ្លះ?
- តើក្រុមប្រឹក្សាឃុំវិហារសួគ៌បានលើកយកនូវដំណោះស្រាយបែបណាខ្លះក្នុងការឆ្លើយតបទៅលើបញ្ហាប្រឈមទាំងនោះដែលបានកើតមានឡើង?

## ៣.គោលបំណងនៃការស្រាវជ្រាវ

គោលបំណងចម្បងដែលជំរុញឱ្យមានការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះគឺដើម្បីៈ

- ស្វែងយល់អំពីដំណើរការគ្រប់គ្រងរបស់រដ្ឋបាលឃុំ សង្កាត់ឱ្យកាន់តែច្បាស់នៅក្នុងតថភាពជាក់ស្តែងជាពិសេសនៅរដ្ឋបាលឃុំវិហារសួគ៌ផ្ទាល់តែម្តង
- ស្វែងយល់អំពីការបែងចែករចនាសម្ព័ន្ធនៃការគ្រប់គ្រងនិងអំពីតួនាទីភារកិច្ចរបស់ឃុំសង្កាត់ លើសពីនេះទៀតនោះ ចង់ស្វែងយល់អំពីកិច្ចដំណើរការអភិវឌ្ឍន៍នៅក្នុងឃុំវិហារសួគ៌ផងដែរ
- ចង់ដឹងអំពីសមិទ្ធផលនានាដែលរដ្ឋបាលឃុំវិហារសួគ៌សម្រេចបានក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន បញ្ហាប្រឈមនានាដែលបានកើតមានឡើងនៅក្នុងការអនុវត្តការងាររបស់ក្រុមប្រឹក្សាឃុំ និងវិធីសាស្ត្រដោះស្រាយបញ្ហារបស់ក្រុមប្រឹក្សា
- ស្វែងយល់ឱ្យកាន់តែច្បាស់អំពីរបៀបនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋរបស់រដ្ឋបាលឃុំជាពិសេសសេវារដ្ឋបាល និង
- ដើម្បីរួមចំណែកក្នុងការកែលម្អនូវចំណុចខ្វះខាតមួយចំនួន ដែលពាក់ព័ន្ធនឹងដំណើរកាគ្រប់គ្រងរដ្ឋបាលឃុំវិហារសួគ៌តាមរយៈការផ្តល់ជាអនុសាសន៍ក្នុងន័យជម្រុញឱ្យឃុំវិហារសួគ៌កាន់តែមានការអភិវឌ្ឍន៍និងកាន់តែមានភាពរីកចម្រើនថែមទៀត។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ"**ការគ្រប់គ្រងរដ្ឋបាលឃុំវិហារសួគ៌**"នេះ មានដែនកំណត់ និងវិសាលភាពគ្របដណ្តប់តែលើសកម្មភាពនៃការអនុវត្តការងាររបស់រដ្ឋបាលឃុំវិហារសួគ៌តែក្នុងឆ្នាំ២០២៣ ប៉ុណ្ណោះ។ ដូចនេះហើយចំពោះប្រធានបទស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំវិហារសួគ៌នេះ យើងខ្ញុំទាំងពីររូបសូមធ្វើការបកស្រាយទៅលើចំណុចមួយចំនួនដែលទាក់ទងជាមួយនឹងដំណើរការគ្រប់គ្រង រចនាសម្ព័ន្ធ តួនាទី ការផ្តល់សេវាសាធារណៈនៅរដ្ឋបាលឃុំជាពិសេសសេវារដ្ឋបាល សមិទ្ធផលការងារដែលសម្រេចបាន បញ្ហាប្រឈម និង ដំណោះស្រាយជាដើម។

## ៥.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

ការលើកយកនូវប្រធានបទស្តីពី"**ការគ្រប់គ្រងរដ្ឋបាលឃុំវិហារសួគ៌**"នេះមកធ្វើការសិក្សាស្រាវជ្រាវគឺពិតជាបានផ្តល់នូវសារៈប្រយោជន៍យ៉ាងសំខាន់ខ្លាំងណាស់ដល់អ្នកសិក្សាស្រាវជ្រាវ ជាពិសេសអ្នកសិក្សាជំនាញ

រដ្ឋបាលសាធារណៈផ្ទាល់តែម្តង។ ជាការពិតណាស់ការសិក្សាតែទៅលើទ្រឹស្តីតែម្យ៉ាងគឺមិនទាន់គ្រប់គ្រាន់នោះទេ វាទាមទារឱ្យមានការអនុវត្តជាក់ស្តែងទៀតទើបជាការល្អប្រសើរ ហើយនេះជាឱកាសដ៏ល្អមួយដែលយើងអាចទៅសិក្សាស្រាវជ្រាវដោយផ្ទាល់ដល់ទីកន្លែងដើម្បីទទួលបាននូវបទពិសោធន៍ជាក់ស្តែង។ ម្យ៉ាងវិញទៀត ការសិក្សាស្រាវជ្រាវនេះបានធ្វើឱ្យយើងខ្ញុំទាំងពីរបានដឹងកាន់តែស៊ីជម្រៅទាក់ទងនឹងស្ថានភាពបច្ចុប្បន្នរបស់ឃុំ ការអភិវឌ្ឍការផ្តល់សេវារដ្ឋបាលនានាពីរដ្ឋបាលឃុំ គម្រោងសកម្មភាពនានាដែលឃុំបានគ្រោងនឹងអនុវត្ត បញ្ហាប្រឈម ក៏ដូចជាដំណោះស្រាយផ្សេងៗដែលក្រុមប្រឹក្សាឃុំដោះស្រាយជាដើម ហើយលទ្ធផលដែលទទួលបានពីការសិក្សាស្រាវជ្រាវនេះអាចជាចំណេះដឹងនិងបទពិសោធន៍ដ៏ល្អប្រសើរសម្រាប់ខ្លួនឯងផ្ទាល់ និងសម្រាប់សង្គមជាតិទាំងមូលតាមរយៈការកែលម្អនូវចំណុចខ្វះខាតនានា ដើម្បីជំរុញឱ្យមានការអភិវឌ្ឍនៅតាមជនបទ និងជាពិសេសអាចបន្សល់ទុកជាឯកសារសម្រាប់សិស្សនិស្សិត ក៏ដូចជាមិត្តអ្នកអានធ្វើការសិក្សាស្រាវជ្រាវបន្ថែមដើម្បីឱ្យពួកគាត់ទទួលបានចំណេះដឹងជាច្រើនទាក់ទងនឹងប្រធានបទមួយនេះ។ លើសពីនេះ ទោះបីជាមិត្តអ្នកអានមិនបានទៅដល់កន្លែងនោះផ្ទាល់ក៏ពិតមែន ប៉ុន្តែតាមរយៈការអាននូវសារណាមួយនេះក៏មិត្តអ្នកអានអាចដឹងច្បាស់អំពីរបៀបរបបដំណើរការការងាររបស់រដ្ឋបាលឃុំវិហារសួគ៌បានយ៉ាងច្បាស់ផងដែរ។

## ៦.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ដើម្បីធ្វើឱ្យសារណាមួយនេះលិចចេញជារូបរាងនិងមានអត្ថន័យខ្លឹមសារកាន់តែស៊ីជម្រៅថែមទៀតនោះក្នុងនោះ យើងបានធ្វើការចងក្រងដោយប្រមូលនូវទិន្នន័យជាច្រើនដែលពាក់ព័ន្ធជុំវិញនឹងប្រធានបទមួយនេះ ដូចខាងក្រោម៖

- ប្រមូលលិខិតបទដ្ឋានគតិយុត្តនានាដូចជា ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស
- ការចុះស្រាវជ្រាវឯកសារជាច្រើននៅសាលាឃុំវិហារសួគ៌ដូចជា ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់ឃុំ កម្មវិធីវិនិយោគបីឆ្នាំរំកិល របាយការណ៍ស្តីពីការអនុវត្តន៍ការងាររបស់រដ្ឋបាលឃុំ និងសៀវភៅថវិកាជាដើម
- បានការពិភាក្សានិងទទួលបានការពន្យល់ផ្ទាល់ពីសំណាក់សាស្ត្រាចារ្យណែនាំ
- ការប្រមូលព័ត៌មាន និងឯកសារនៅក្នុងបណ្ណាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- ការប្រមូលទិន្នន័យនិងឯកសារជាច្រើនផ្សេងទៀតតាមប្រព័ន្ធអ៊ីធើណែតនិងតាមបណ្តាលគេហទំព័រផ្សព្វផ្សាយនានា។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងរចនាសម្ព័ន្ធនៃការស្រាវជ្រាវលើប្រធានបទ"**ការគ្រប់គ្រងរដ្ឋបាលឃុំវិហារសួគ៌**" យើងខ្ញុំទាំងពីរបានធ្វើការបែងចែកជា៤ជំពូកធំៗ ក្នុងនោះរួមមាន៖

**ជំពូកទី១ សញ្ញាណទូទៅនៃរដ្ឋបាលឃុំ សង្កាត់៖** ជំពូកនេះបកស្រាយអំពីអត្ថន័យនៃពាក្យគន្លឹះរបស់ប្រធានបទ សារៈតាររបស់រដ្ឋបាលឃុំ សង្កាត់ តួនាទី ភារកិច្ចនិងអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ និងនិយាយអំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលឃុំ សង្កាត់ដោយរំលិចអំពី រចនាសម្ព័ន្ធនិងតួនាទីរបស់អង្គនីមួយៗ។

**ជំពូកទី២ ដំណើរការគ្រប់គ្រងរដ្ឋបាលឃុំវិហារសួគ៌៖** ជំពូកនេះគឺបានបង្ហាញអំពី ទិដ្ឋភាពទូទៅនៃឃុំវិហារសួគ៌ រចនាសម្ព័ន្ធរបស់រដ្ឋបាលឃុំវិហារសួគ៌ ផែនការអភិវឌ្ឍន៍ឃុំ កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ឃុំ ការផ្តល់សេវារដ្ឋបាល និងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ឃុំវិហារសួគ៌។

**ជំពូកទី៣ សមិទ្ធផលការងារដែលសម្រេចបានរបស់រដ្ឋបាលឃុំវិហារសួគ៌៖** ជំពូកនេះគឺសង្កត់ធ្ងន់ទៅលើការងារដែលរដ្ឋបាលឃុំសម្រេចបានក្នុងឆ្នាំ២០២៣ ក្នុងនោះរួមមាន កិច្ចការរដ្ឋបាល និងលិខិតបទដ្ឋាននានាដែលឃុំបានដាក់ចេញ និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំ។

**ជំពូកទី៤ បញ្ហាប្រឈម និង ដំណោះស្រាយ៖** ជំពូកនេះបង្ហាញអំពី ស្ថានភាពបច្ចុប្បន្ននិងបញ្ហាប្រឈមដែលកើតមានឡើងនៅក្នុងឃុំ និងបង្ហាញអំពីដំណោះស្រាយដែលរដ្ឋបាលឃុំបានឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលកើតមាននោះ។

# ជំពូកទី១
# សញ្ញាណទូទៅនៃរដ្ឋបាលឃុំ សង្កាត់

## ១.១.និយមន័យនៃពាក្យគន្លឹះ

មុននឹងឈានដល់ការបកស្រាយទៅលើប្រធានបទដែលស្តីអំពី "ការគ្រប់គ្រងរដ្ឋបាលឃុំវិហារសួគ៌" ជាដំបូងយើងត្រូវសិក្សាស្វែងយល់នូវនិយមន័យរបស់ពាក្យគន្លឹះនៃប្រធានបទមួយនេះជាមុនសិន ដើម្បីងាយយល់អំពីអត្ថន័យខ្លឹមសាររបស់ប្រធានបទទាំងមូល។

### ១.១.១.ការគ្រប់គ្រង

តាមវចនានុក្រម Oxford Dictionary បានឱ្យនិយមន័យការគ្រប់គ្រង (Management) គឺជាការប្រព្រឹត្តការត្រួតពិនិត្យលើការងារ លើសកម្មភាពផ្ទាល់របស់នរណាម្នាក់ ការទទួលខុសត្រូវក្នុងមុខនាទីម្នាក់ៗ។[4]

### ១.១.២.រដ្ឋបាល

ពាក្យរដ្ឋបាល (administration) ត្រូវបានគេកំណត់ឱ្យនិយមន័យខុសៗគ្នា។ក្នុងនោះរួមមាន ន័យតាមបែបអក្សរសាស្ត្រ ន័យទូលាយបែបបច្ចេកទេស និងន័យចង្អៀតបែបបច្ចេកទេស។

#### ១.១.២.១.ន័យតាមបែបអក្សរសាស្ត្រ

រដ្ឋបាលបានមកពីពាក្យ "រដ្ឋ" និង "បាល"។

- "រដ្ឋ" (បា) : នគរ ប្រទេស ភារា ដែន ខ្មែរច្រើនផ្សំពាក្យនេះជាមួយពាក្យដទៃធ្វើជាសមាសភាពពាក្យ ដូចជា រដ្ឋធម្មនុញ្ញ រដ្ឋាភិបាល រដ្ឋបុរស ជាដើម។
- "បាល" (បា.សំ) : គ្រប់គ្រង ថែរក្សា ការពារ ផ្គត់ផ្គង់បីបាច់ មើលការខុសត្រូវ ត្រួតត្រា។

ឧទាហរណ៍៖ គោបាល = អ្នកគង្វាលគោ ទ្វារបាល = អ្នកយាមទ្វារ អាណាព្យាបាល = អ្នកគ្រប់គ្រងមើលការខុសត្រូវ។[5]

ជារួមមកពាក្យ "រដ្ឋបាល"មានន័យថា អ្នករក្សាដែន ឬប្រទេស។ ឧទាហរណ៍ ក្រសួងរាជការកាន់កាប់កិច្ចការក្នុងប្រទេសជាគូនឹងគ្នាតុលាការ មន្ត្រីខាងរដ្ឋបាល ក្របខណ្ឌខាងរដ្ឋបាល។[6]

#### ១.១.២.២.ន័យទូលាយបែបបច្ចេកទេស

តាមន័យទូលំទូលាយ ពាក្យថា រដ្ឋបាល (administration)ជួនកាលសំដៅលើ "សកម្មភាព" គ្រប់គ្រងជួនកាលសំដៅលើ "អង្គការ" ដែលគ្រប់គ្រង។ ន័យទាំងពីរនេះអាចប្រើបានទាំងខាងវិស័យឯកជន និងទាំងខាងវិស័យសាធារណៈ។

---

[4] កៅ មុយថង,រៀបរៀង,*ប្រព័ន្ធរដ្ឋបាលកម្ពុជា,* បោះពុម្ពលើកទី១( ភ្នំពេញ៖ អង្គរ,២០០៨),១៣០

[5] (សាំង ហាក់ ២០២២)

[6] សម្តេចព្រះសង្ឃរាជ ជួន ណាត, *វចនានុក្រមខ្មែរ* (ភ្នំពេញ៖ពុទ្ធសាសនាបណ្ឌិត្យ,១៩៦៧),៩៧៦

ឧទាហរណ៍៖

- ន័យទី១: តាមសកម្មភាព
  - កិច្ចការរដ្ឋបាលរបស់ក្រុមហ៊ុនកាត់ដេរ (វិស័យឯកជន)
  - កិច្ចការរដ្ឋបាលរបស់ក្រសួងទេសចរណ៍ (វិស័យសាធារណៈ)
- ន័យទី២: តាមអង្គការ
  - ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនអាហ៍រណនិហ៍រណ (វិស័យឯកជន)
  - ក្រសួងទេសចរណ៍ (វិស័យសាធារណៈ)។[7]

**១.១.២.៣.ន័យចង្អៀតបែបបច្ចេកទេស**

តាមន័យចង្អៀតពាក្យ "រដ្ឋបាល" សំដៅដល់វិស័យសាធារណៈតែប៉ុណ្ណោះដែលនៅកម្ពុជា យើងហៅថា "រាជការ"។ តាមន័យនេះ "រដ្ឋបាល" សំដៅដល់ការគ្រប់គ្រងរដ្ឋដែលអាជ្ញាធរធ្វើការរៀបចំ គ្រប់គ្រង ចាត់ចែង ដើម្បីបម្រើប្រជាពលរដ្ឋឱ្យកាន់តែល្អប្រសើរឡើង សំដៅលើកកម្ពស់កម្រិតជីវភាពឆ្ពោះទៅកាន់ភាពរីកចម្រើន។ រដ្ឋបាលគឺជាអង្គការចាត់តាំងសាធារណៈក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលក្នុងសកម្មភាពសាធារណៈ ដែលរួមមានការកំណត់វិធាន ការរកយុត្តិធម៌ ការដឹកនាំ និង ការគ្រប់គ្រង ដើម្បីសម្រេចបាននូវគោលដៅនៃការបម្រើប្រយោជន៍សាធារណៈដោយប្រើមធ្យោបាយពិសេសរបស់រដ្ឋបាលគឺ អំណាចបុព្វសិទ្ធិ និងការបង្ខំធម្មានុរូប។[8]

**១.១.៣.ឃុំ សង្កាត់**

យោងតាមមាត្រា ២ នៃច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ឃុំ សង្កាត់ គឺជានីតិបុគ្គល។ "ឃុំ" គឺជារដ្ឋបាលឃុំដែលសិត្ថក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ។ ចំណែកឯ "សង្កាត់" គឺជារដ្ឋបាលសង្កាត់ដែលសិត្ថក្រោមដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាសង្កាត់។[9]

## ១.២.សាវតាររដ្ឋបាលឃុំ សង្កាត់

ប្រទេសកម្ពុជាមានប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននេះជាយូរណាស់មកហើយដោយប្រព័ន្ធអភិបាលកិច្ចមូលដ្ឋាននេះ មានការប្រែប្រួលពីរបបនយោបាយមួយទៅរបបនយោបាយមួយទៀតដោយផ្អែកទៅតាមស្ថានភាពនយោបាយ ប្រជាសាស្ត្រ ភូមិសាស្ត្រ សេដ្ឋកិច្ច និង សង្គម នៅក្នុងសម័យកាលនីមួយៗ។

**១.២.១.រដ្ឋបាលឃុំ សង្កាត់ពីឆ្នាំ ១៩០៨ ដល់ឆ្នាំ១៩៥៥**

រដ្ឋបាលឃុំ ត្រូវគេបានឮជាលើកដំបូងនៅក្នុងឆ្នាំ១៩០៨ តាមរយៈការដាក់ឱ្យប្រើនូវក្រឹត្យស្តីពីការរៀបចំរដ្ឋបាលឃុំដែលចូលជាធរមាននៅថ្ងៃទី០៥ ខែមិថុនាឆ្នាំ១៩០៨។ ក្រឹត្យនេះបានលុបចោលនូវរបៀបគ្រប់គ្រងដែន

---

[7]បណ្ឌិត សាយ បូរី, *នីតិរដ្ឋបាលទូទៅ,* បោះពុម្ពលើកទី៣ (ភ្នំពេញ៖ប្លុស្សំឡូទឹស,២០០៦),១០,១១

[8] បណ្ឌិត សឿន សោភ័ណ,និង អនុបណ្ឌិត សាឡេះ សុវណ្ណារ៉ា,រៀបរៀង,*នីតិរដ្ឋបាលទូទៅ* (ភ្នំពេញ៖អឹម អូរ អេស,២០២២),៤

[9] សន្ទានុក្រមនៃច្បាប់ស្តីពីការគ្រប់គ្រង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ,២០០៨

ដីដោយស្តេចត្រាញ់ ហើយបានរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងតាមឃុំវិញ។ ផ្អែកតាមស្មារតីក្រឹត្យនេះ ទឹកដីកម្ពុជាចែកជា ខេត្ត ស្រុក ឃុំ និង ភូមិ។ តាមរយៈការរៀបចំថ្មីនេះ អភិបាលដែលពីមុនហៅថា "ចៅហ្វាយស្រុក" បានក្លាយជា"ចៅហ្វាយខេត្ត" ហើយ"មេស្រុក" បានក្លាយជា"មេឃុំ"។ ទន្ទឹមនឹងនេះ ក្រឹត្យនេះបានតម្រូវឱ្យមេឃុំ ត្រូវធ្វើការបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពីសំណាក់ប្រជាជននៅក្នុងឃុំ ដើម្បីបំពេញតួនាទីនៅក្នុងឃុំតាមរយៈមុខងារ និងធនធានដែលផ្តល់ឱ្យដោយក្រឹត្យនេះ។

ក្រឹត្យច្បាប់គ្រប់គ្រងឃុំឆ្នាំ១៩០៨មានភាពខ្វះចន្លោះជាច្រើននៅពេលអនុវត្តជាក់ស្តែង ជាពិសេសការរៀបចំប្រព័ន្ធគ្រប់គ្រងនៅក្នុងក្រឹត្យនេះ គឺមិនអាចធ្វើឱ្យក្រុមប្រឹក្សាឃុំបំពេញតួនាទីប្រកបដោយប្រសិទ្ធភាពបានឡើយព្រោះតែចំនួនដ៏លើសលុបនៃក្រុមប្រឹក្សាឃុំ។ នៅក្នុងឃុំខ្លះទៀត ចំនួនក្រុមប្រឹក្សាជាប់ឆ្នោតបានកើនដល់ ១៥០រូប។ ម្យ៉ាងវិញទៀត ការការពារផលប្រយោជន៍សមូហភាពឬការអភិវឌ្ឍនៅមូលដ្ឋានមិនអាចធ្វើទៅបានប្រសើរឡើយដោយសារហិរញ្ញវត្ថុឃុំមិនមានគ្រប់គ្រាន់។

នៅក្នុងឆ្នាំ១៩១៩ ក្រឹត្យច្បាប់គ្រប់គ្រងឃុំឆ្នាំ១៩០៨ត្រូវបានកែសម្រួលឡើងវិញតាមរយៈការបំពេញបន្ថែមនិងកែលម្អភាពខ្វះចន្លោះដែលមានកន្លងមក។ ក្រឹត្យច្បាប់គ្រប់គ្រងឃុំកែសម្រួលនេះ បានបញ្ជាក់កាន់តែច្បាស់អំពីមុខងារនិងសមត្ថកិច្ចរបស់ឃុំ ព្រមទាំងប្រព័ន្ធត្រួតពិនិត្យអំពីការអនុវត្តមុខងារនិងសមត្ថកិច្ចឃុំ ដោយចៅហ្វាយខេត្តនិងប្រជាជននៅក្នុងឃុំ។ ទន្ទឹមនេះ ក៏បង្កើតឱ្យមានថវិកាឃុំដែលតាមរយៈថវិកាឃុំនេះ មេឃុំអាចធ្វើការជ្រើសរើសបុគ្គលិកមកជួយធ្វើការ ឬបង្ហាត់បង្រៀនជាដើម ដើម្បីអាចធានាបាននូវដំណើរការជាប្រក្រតីនៃកិច្ចការរដ្ឋបាលរបស់ឃុំ។ ចាប់ពីពេលនោះមក មេឃុំមានតួនាទីជាអ្នកធានាចាត់ចែងនិងកាន់កាប់បញ្ជីរដ្ឋបាល និងថែរក្សាឯកសារ លិខិតស្នាមផ្សេងៗរបស់ឃុំដោយមានបុគ្គលិកជាប់កិច្ចសន្យាជួយការងារទូទៅ។ មុខងារពាក់ព័ន្ធនឹងវិស័យអប់រំសាធារណៈត្រូវបានប្រគល់ឱ្យឃុំដែលជាអ្នកគ្រប់គ្រងដោយប្រើប្រាស់ថវិកានិងប្រភពហិរញ្ញវត្ថុផ្សេងៗរបស់ឃុំ ដែលក្នុងនោះឃុំអាចធ្វើការតែងតាំងគ្រូបង្រៀនក៏ដូចជាការសាងសង់សាលារៀនបន្ថែម។ ជារួមការកែសម្រួលនេះបានធ្វើឱ្យប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលឃុំមានលក្ខណៈល្អប្រសើរជាងមុន។

ក្រឹត្យច្បាប់គ្រប់គ្រងឃុំ ត្រូវបានកែសម្រួលឡើងវិញក្នុងឆ្នាំ១៩២៥ ហើយបានចូលជាធរមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩២៦បានបញ្ជាក់កាន់តែច្បាស់អំពីការជ្រើសរើសក្រុមប្រឹក្សាឃុំ មេឃុំ ការចូលកាន់តំណែង ប្រព័ន្ធគ្រប់គ្រង និងរបៀបរបបការងារនៅរដ្ឋបាលឃុំ ការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិឃុំ ព្រមទាំងការងារយុត្តាធិការរបស់ឃុំ។ នៅក្នុងសម័យនោះក្រុមប្រឹក្សាឃុំហៅថា **ក្រុមជំនុំឃុំ**។ មេឃុំ គឺជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តនូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំឃុំ។ នៅពេលនោះ មេឃុំមានអាណត្តិការងារចំនួន០៤ឆ្នាំ។ ការរៀបចំថ្មីនេះមានលក្ខណៈស្រដៀងគ្នាទៅនឹងការរៀបចំប្រព័ន្ធគ្រប់គ្រងឃុំបច្ចុប្បន្នដែរ។ ជារួមមក ការរៀបចំប្រព័ន្ធថ្មីនេះបានធ្វើឱ្យឃុំក្លាយជាថ្នាក់រដ្ឋបាលមួយជាក់លាក់ក្នុងប្រព័ន្ធរដ្ឋបាលកម្ពុជា។ តាមរយៈក្រឹត្យច្បាប់ឆ្នាំ១៩២៦ បានផ្តល់

សិទ្ធិអំណាចនិងធនធានកាន់តែច្រើនដល់ឃុំដើម្បីអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនដោយមានការយកចិត្តទុកដាក់ពីរដ្ឋបាលកណ្តាលក្នុងការពង្រឹងនិងលើកស្ទួយការទទួលខុសត្រូវរបស់ឃុំ។ ប៉ុន្តែចាប់ពីឆ្នាំ១៩៤៣មក ប្រឈមមុខនឹងសង្គ្រាមឈ្លានពានការបោះឆ្នោតនៅថ្នាក់ឃុំត្រូវបានផ្អាកជាបន្តបន្ទាប់ និងត្រូវបានលុបចោលទាំងស្រុងចាប់ពីឆ្នាំ១៩៤៨។ ពេលនោះមេឃុំ និងជំទប់ឃុំត្រូវតែងតាំងដោយអភិបាលខេត្តដោយមានការយល់ព្រមពីរ៉េស៊ីដង់។

**១.២.២.រដ្ឋបាលឃុំ សង្កាត់ពីឆ្នាំ ១៩៥៥ ដល់ឆ្នាំ១៩៧៩**

ក្រោយផ្អាកការបោះឆ្នោតនៅថ្នាក់ឃុំប្រមាណមួយទសវត្ស នៅឆ្នាំ១៩៥៥មានសារាចរណែនាំមួយដែលណែនាំឱ្យរៀបចំការបោះឆ្នោតមេឃុំឡើងវិញ ប៉ុន្តែនៅក្នុងការអនុវត្តពុំសូវទទួលបានលទ្ធផលឡើយមានលក្ខណៈគ្រាន់ជាការបង្គ្រប់កិច្ចតាមច្បាប់ប៉ុណ្ណោះដោយសារតែប្រជាពលរដ្ឋពុំសូវសកម្មក្នុងការចូលរួម និងពុំមានជំនឿទៅលើសមត្ថភាពដឹកនាំរបស់មេឃុំ។ បន្ទាប់មក នៅក្នុងឆ្នាំ១៩៥៩មានព្រះរាជក្រមមួយទៀតដែលតម្រូវឱ្យមានការបោះឆ្នោតជ្រើសរើសក្រុមជំនុំឃុំ ហើយបានផ្តល់ឲ្យឃុំនូវឋានៈជា**នីតិបុគ្គល**ដូចក្នុងឆ្នាំ១៩២៦។ ផ្អែកតាមក្រមនេះមេឃុំ និងជំទប់ត្រូវជ្រើសរើសពីក្នុងក្រុមជំនុំឃុំដែលជាប់ឆ្នោតដោយសំឡេងភាគច្រើន។ ចៅហ្វាយខេត្ត គឺជាអ្នកចេញដីកាខេត្តប្រកាសសុពលភាពហើយតែងតាំងមេឃុំនិងក្រុមជំនុំឃុំ។ ទន្ទឹមនេះ ក្រឹត្យនេះក៏ផ្តល់អំណាចដល់ចៅហ្វាយខេត្តក្នុងការប្រកាសមោឃភាពលិខិតបទដ្ឋានទាំងឡាយរបស់ឃុំដែលមានលក្ខណៈអនីត្យានុកូលភាពផងដែរ។ ប៉ុន្តែមិនដល់រយៈពេលបីខែផង ព្រះរាជក្រមនេះត្រូវបានដាក់ព្យួរតាមរយៈការធ្វើប្រជាមតិនៅថ្ងៃទី២៩ ខែវិច្ឆិកាឆ្នាំ១៩៥៩ហើយមេឃុំចៅសង្កាត់និងជំទប់ត្រូវតែងតាំងតាមរយៈដីកាខេត្តតាមសំណើរបស់អភិបាលស្រុក។

គួរកត់សម្គាល់ថា បន្ទាប់ពីការធ្វើសមាជជាតិលើកទី២០ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៩៦៥ ពាក្យ **សង្កាត់** ត្រូវបានប្រើប្រាស់សម្រាប់ឃុំនៅក្នុងទីក្រុង។ ក្នុងពេលជាមួយគ្នានោះពាក្យ **ចៅហ្វាយខេត្ត ក្រុង ស្រុក** ក៏ត្រូវផ្លាស់ប្តូរដោយប្រើជំនួសវិញនូវពាក្យ **អភិបាល** ។

នៅក្នុងរបបសាធារណៈរដ្ឋខ្មែរ (១៩៧០-១៩៧៥) ទោះបីរដ្ឋធម្មនុញ្ញនាសម័យនោះព្យាយាមធ្វើវិមជ្ឈការនៅគ្រប់ថ្នាក់រដ្ឋបាលនៅថ្នាក់ក្រោមជាតិក៏ដោយ ប៉ុន្តែដោយសារតែសង្គ្រាមស៊ីវិលការបោះឆ្នោតគ្រប់ថ្នាក់នៅមូលដ្ឋានមិនអាចដំណើរការបានឡើយ ហើយមេឃុំនៅតែបន្តតែងតាំងដោយអភិបាលខេត្ត។

ដោយឡែកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) រដ្ឋធម្មនុញ្ញនៃរបបនេះមានតែ២១មាត្រាប៉ុណ្ណោះដែលខ្លឹមសារភាគច្រើនផ្តោតទៅលើអំណាច"យោធា" និង "អង្គការ"។ នៅក្នុងរបបនេះ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល សេដ្ឋកិច្ច និងសង្គមត្រូវបានបំផ្លាញចោលទាំងស្រុង។

**១.២.៣.រដ្ឋបាលឃុំ សង្កាត់ពីឆ្នាំ ១៩៧៩ ដល់ឆ្នាំ១៩៩៣**

បន្ទាប់ពីការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យនាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលត្រូវបានស្តារនិងកសាងឡើងវិញពីចំណុចសូន្យ។ រដ្ឋធម្មនុញ្ញឆ្នាំ ១៩៨១ បានកំណត់ដែនដីរដ្ឋបាលនៅ

កម្ពុជាជាខេត្ត និងក្រុង។ ខេត្តចែកជា ស្រុក។ ស្រុក ចែកជាឃុំ។ ក្រុងចែកជាសង្កាត់។ ដែនដីរដ្ឋបាលនីមួយៗខាងលើគ្រប់គ្រងដោយអង្គការរដ្ឋអំណាចដែលមានឈ្មោះថា"គណៈកម្មាធិការប្រជាជនបដិវត្តន៍មូលដ្ឋាន"។ សមាជិកគណៈកម្មាធិការប្រជាជនបដិវត្តន៍ឃុំ សង្កាត់ ត្រូវជ្រើសតាំងឡើងដោយប្រជាជននៅឃុំ សង្កាត់សាមីតាមរយៈការបោះឆ្នោតជាសកល ដោយស្មើភាព ដោយចំពោះនិងតាមវិធីជ្រើសរើសសន្លឹកឆ្នោតជាសម្ងាត់។

ក្រោយមកទៀតនៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៨៩ រដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានធ្វើវិសោធនកម្មដោយបានកែប្រែឈ្មោះប្រទេសមកជា រដ្ឋកម្ពុជា វិញ។រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩បានធ្វើការកែសម្រួលការបែងចែកទឹកដីដូចខាងក្រោមៈ

- ដែនដីនៃប្រទេសកម្ពុជាចែកជា ខេត្ត និងក្រុង
- ខេត្តបែងចែកជាទីរួមខេត្ត និងស្រុក។ ទីរួមខេត្តបែងចែកជាសង្កាត់។ ស្រុកបែងចែកជាឃុំ។
- ក្រុងបែងចែកជាខណ្ឌ និងស្រុកជាយក្រុង។ ខណ្ឌបែងចែកជា សង្កាត់។ ស្រុកជាយក្រុងបែងចែកជាឃុំ ដូចស្រុកចំណុះខេត្ត។

ចំពោះរចនាសម្ព័ន្ធគ្រប់គ្រង និងអាណត្តិការងារនៅតាមដែនដីរដ្ឋបាលនីមួយៗ គឺវាមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងការរៀបចំនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៨១ដែរ ដោយគ្រាន់តែប្តូរពីឈ្មោះគណៈកម្មាធិការប្រជាជនបដិវត្តន៍ មកជា គណៈកម្មាធិការប្រជាជនវិញ។

### ១.២.៤.រដ្ឋបាលឃុំ សង្កាត់ក្រោយការបោះឆ្នោតជាតិឆ្នាំ១៩៩៣

រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ បានកំណត់បែងចែកដែនដីរដ្ឋបាលដូចខាងក្រោម

- ដែនដីនៃព្រះរាជាណាចក្រកម្ពុជាបែងចែកជាខេត្ត និងក្រុង
- ខេត្តចែកជា ស្រុក។ ស្រុកចែកជា ឃុំ។
- ក្រុងចែកជា ខណ្ឌ។ ខណ្ឌចែកជាសង្កាត់។

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងឡើងវិញនិងធ្វើការបែងចែកមុខតំណែងអភិបាល អភិបាលរងខេត្ត ក្រុងក្នុងចំណោមគណបក្សនយោបាយក្នុងរាជរដ្ឋាភិបាលចម្រុះ ក្នុងនោះមានរាជធានីភ្នំពេញនិងខេត្តចំនួន១០ គណបក្សហ្វ៊ុនស៊ិនប៉ិចទទួលមុខតំណែងជាអភិបាលនិងខេត្តចំនួន១០ទៀតគណបក្សប្រជាជនកម្ពុជាទទួលមុខតំណែងជាអភិបាល។ ការបែងចែកមុខតំណែងអភិបាល អភិបាលរងក្នុងចំណោមគណបក្សនយោបាយក្នុងរាជរដ្ឋាភិបាលចម្រុះនេះ ត្រូវបានបញ្ចប់នៅចុងអាណត្តិទី២និងដើមអាណត្តិទី៣នៃរដ្ឋសភាដោយគណបក្សប្រជាជនកម្ពុជាដែលជាគណបក្សទទួលបានសំឡេងភាគច្រើននៅក្នុងរដ្ឋសភាជាអ្នកទទួលបានមុខតំណែងជាអភិបាលរាជធានី ខេត្តទាំងអស់។

ចំពោះថ្នាក់ស្រុក ខណ្ឌ ឃុំ សង្កាត់វិញក៏បានធ្វើការកែសម្រួលរចនាសម្ព័ន្ធនិងប្រព័ន្ធគ្រប់គ្រងផងដែរ ប៉ុន្តែក្នុងអាណត្តិទី១និងដើមអាណត្តិទី២នៃរាជរដ្ឋាភិបាលចម្រុះគឺមិនមានការចុះសម្រុងគ្នាក្នុងការសម្របសម្រួលនយោបាយដើម្បីបែងចែកអំណាចនៅថ្នាក់រដ្ឋបាលទាំងនេះឡើយ។ដើម្បីដោះស្រាយបញ្ហាប្រឈមនេះគណបក្សប្រជាជនកម្ពុជាបានផ្តួចផ្តើមឱ្យមានការបោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់ ដើម្បីប្រកួតប្រជែងការគ្រប់គ្រងឃុំ សង្កាត់ តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស។គំនិតផ្តើមនេះ ត្រូវបានទទួលយកនិងគាំទ្រដោយគណបក្សហ៊្វុនស៊ិនប៉ិច។

ផ្អែកលើគំនិតផ្តួចផ្តើមនេះ ការសម្របសម្រួលខាងនយោបាយ ដើម្បីរៀបចំក្របខ័ណ្ឌគោលនយោបាយសម្រាប់ការបោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់និងការផ្ទេរវិមជ្ឈការនិងវិសហមជ្ឈការនៅថ្នាក់រដ្ឋបាលនេះ ត្រូវបានរៀបចំឡើងនាឆ្នាំ១៩៩៩ និងឈានទៅរៀបចំច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលត្រូវបានរដ្ឋសភាអនុម័តនាខែមករា ឆ្នាំ២០០១។ នៅឆ្នាំ២០០២ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេសចំនួន១.៦២១ឃុំ សង្កាត់ត្រូវបានរៀបចំឡើងតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ហើយចាប់ពីពេលនោះមកកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ត្រូវបានធ្វើឡើងនៅថ្នាក់ឃុំ សង្កាត់។

ផ្អែកលើតម្រូវការនៃកំណែទម្រង់នេះ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រូវបានធ្វើវិសោធនកម្ម ដើម្បីរៀបចំឡើងវិញនូវដែនដីរដ្ឋបាលនៅព្រះរាជាណាចក្រកម្ពុជាដូចខាងក្រោម៖

- ដែនដីនៃព្រះរាជាណាចក្រកម្ពុជាចែកចេញជា រាជធានីភ្នំពេញ និងខេត្ត
- រាជធានីភ្នំពេញចែកជា ខណ្ឌ។ ខណ្ឌចែកជា សង្កាត់។
- ខេត្តចែកជា ក្រុង និងស្រុក។ ក្រុងចែកជា សង្កាត់។ ស្រុកចែកជាឃុំនិងសង្កាត់។[10]

**សម្គាល់**៖បច្ចុប្បន្ន ប្រព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានចែកចេញជាពីរប្រភេទ គឺ៖

- ➢ ប្រព័ន្ធរដ្ឋបាលខេត្ត ដែលមានចរិតលក្ខណៈជារដ្ឋបាលតំបន់ និង
- ➢ ប្រព័ន្ធរដ្ឋបាលមូលដ្ឋាន ដែលរួមមាន ប្រព័ន្ធ០២ ថ្នាក់ និងប្រព័ន្ធ០៣ ថ្នាក់
    - ប្រព័ន្ធ០២ថ្នាក់៖ ស្រុក-ឃុំ និង ក្រុង-សង្កាត់
    - ប្រព័ន្ធ០៣ថ្នាក់៖ រាជធានី-ខណ្ឌ-សង្កាត់។

## ១.៣.តួនាទី មុខងារ និងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

ផ្អែកតាមបទប្បញ្ញត្តិក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានផ្ទេរឱ្យនូវតួនាទី មុខងារ និងអំណាចមួយចំនួនសម្រាប់បម្រើប្រជាពលរដ្ឋនិងការអភិវឌ្ឍនៅមូលដ្ឋានរបស់ខ្លួន។

[10] ក្រសួងមហាផ្ទៃ, *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា* (២០១៩)

### ១.៣.១.តួនាទី និង មុខងាររបស់រដ្ឋបាលឃុំ សង្កាត់

យោងតាមមាត្រា៤២នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទគឺ៖

១.តួនាទីបម្រើកិច្ចការមូលដ្ឋានសម្រាប់បម្រើផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន។ ក្នុងតួនាទីបម្រើកិច្ចការមូលដ្ឋាន រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចដូចជា៖

- ធានារក្សាសន្តិសុខសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ជម្រុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការពារថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សម្របសម្រួលទស្សនៈរបស់ប្រជាពលរដ្ឋ ដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក
- បំពេញកិច្ចការជាទូទៅ ដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។[11]

២.តួនាទី ជាភ្នាក់ងារតំណាងរដ្ឋក្រោមការចាត់តាំង ឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។ ក្នុងតួនាទីជាភ្នាក់ងារតំណាងរដ្ឋ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធ។ ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូកម្មអំណាចដល់ឃុំ សង្កាត់ដោយភ្ជាប់ជាមួយនូវការបង្កើនសមត្ថភាពនិងផ្តត់ផ្គង់មធ្យោបាយនិងសម្ភារៈថវិកាសម្រាប់អនុវត្ត។[12] ឧទាហរណ៍ដូចជា ការចុះបញ្ជីអត្រានុកូលដ្ឋាននិងការចុះឈ្មោះអ្នកបោះឆ្នោតនៅក្នុងឃុំ សង្កាត់ជាដើម។

### ១.៣.២.អំណាចរបស់រដ្ឋបាលឃុំ សង្កាត់

ដើម្បីអនុវត្តតួនាទីរបស់ខ្លួន រដ្ឋបាលឃុំ សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។[13]

- **អំណាចបញ្ញត្តិ** ត្រូវធ្វើឡើងតាមរយៈដីកាឃុំ សង្កាត់ តាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយមេឃុំ ចៅសង្កាត់សម្រាប់គ្រប់គ្រងកិច្ចការនានាក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។ ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែនៅក្នុងរង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ។ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិដែលព្រះរាជាណាចក្រកម្ពុជាទទួល

[11] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,លេខ នស/រកម/០៣០១/០៥,១៩ មីនា ២០០១,មាត្រា៤៣

[12] យោងតាមច្បាប់ខាងលើ មាត្រា៤៤

[13] យោងតាមច្បាប់ខាងលើ មាត្រា៤៨

ស្គាល់ស្មារតីរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាសនិងលិខិតបទដ្ឋានពាក់ព័ន្ធឡើយ។ បើដីកាណាមួយដែលផ្ទុយនឹងលិខិតបទដ្ឋានគតិយុត្តខាងលើនេះ ដីកានោះត្រូវបានចាត់ទុកជាមោឃៈ

– **អំណាចប្រតិបត្តិ** មានន័យថារដ្ឋបាលឃុំ សង្កាត់មានសិទ្ធិអនុវត្តសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួនដែលច្បាប់បានប្រគល់ឱ្យ។អំណាចប្រតិបត្តិនេះត្រូវបានធ្វើប្រតិភូកម្មឱ្យទៅមេឃុំ ចៅសង្កាត់ជាអ្នកអនុវត្តក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។

### ១.៣.៣.ព្រំដែននៃអំណាច

ក្រុមប្រឹក្សាឃុំ សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ។ ទោះបីជាយ៉ាងនេះក្តី ការបំពេញការងាររបស់ខ្លួន រដ្ឋបាលឃុំ សង្កាត់ ត្រូវស្ថិតនៅក្នុងខ្សែបណ្តោយនៃអំណាចនីតិប្រតិបត្តិរបស់រដ្ឋ។ រដ្ឋបាលឃុំ សង្កាត់អាចធ្វើសកម្មភាពបានតែនៅក្នុងក្របខ័ណ្ឌអំណាច តួនាទី និងមុខងារដែលច្បាប់បានប្រគល់ឱ្យប៉ុណ្ណោះ និងមិនអាចធ្វើសកម្មភាពណាមួយដែលផ្ទុយនឹងគោលការណ៍ និងបទប្បញ្ញត្តិដែលបានកំណត់នៅក្នុងរដ្ឋធម្មនុញ្ញច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាននានានោះឡើយ។

រដ្ឋបាលឃុំសង្កាត់គ្មានអំណាចសម្រេចលើកិច្ចការមួយចំនួនដូចជាៈព្រៃឈើ ប្រៃសណីយ៍និងទូរគមនាគមន៍ ការពារប្រទេស សន្តិសុខជាតិ រូបិយវត្ថុ នយោបាយក្រៅប្រទេស គោលនយោបាយសារពើពន្ធ និងវិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ។[14]

## ១.៤.ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលឃុំ សង្កាត់

### ១.៤.១.រចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់

យោងតាមមាត្រា ២៥ ២៦ ២៧ និង២៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានកំណត់អំពីរចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់ដូចខាងក្រោមៈ

រដ្ឋបាលឃុំ សង្កាត់ត្រូវដឹកនាំគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់។ មេឃុំចៅ សង្កាត់មានជំនួយការពីររូបគឺជំទប់ទី១ឬចៅសង្កាត់រងទី១និងជំទប់ទី២ឬចៅសង្កាត់រងទី២។លើសពីនេះទៀតមេឃុំចៅសង្កាត់មានសិទ្ធិតែងតាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់និងជួយកិច្ចការនានាតាមការចាំបាច់។

ជាមួយគ្នានេះឃុំ សង្កាត់ គឺត្រូវមានបុគ្គលិកក្របខ័ណ្ឌរដ្ឋបាលនៃក្រសួងមហាផ្ទៃមួយរូបធ្វើជាស្មៀនឃុំ សង្កាត់។ ទន្ទឹមនេះ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិនិងជំនួយការភូមិសម្រាប់ភូមិនីមួយៗក្នុងឃុំ សង្កាត់របស់ខ្លួន។ ក្រុមប្រឹក្សាក៏អាចធ្វើការជ្រើសរើសបុគ្គលិក

[14] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,លេខ នស/រកម/០៣០១/០៥,១៩ មីនា ២០០១,មាត្រា៤៥

ក្រៅក្របខ័ណ្ឌរដ្ឋដើម្បីជួយដល់កិច្ចការរបស់ខ្លួនផងដែរ។ (ខាងក្រោមនេះជាគំនូសបំព្រួញនៃរចនាសម្ព័ន្ធរដ្ឋបាលឃុំ សង្កាត់)




### ១.៤.២.តួនាទី និងភារកិច្ចរបស់អង្គនីមួយៗ

#### ១.៤.២.១.ក្រុមប្រឹក្សា

ឃុំ សង្កាត់នីមួយៗត្រូវមានក្រុមប្រឹក្សាមួយហៅថាក្រុមប្រឹក្សាឃុំ សង្កាត់។ក្រុមប្រឹក្សាឃុំ សង្កាត់ជាអង្គការតំណាងប្រជាពលរដ្ឋក្នុងឃុំសង្កាត់របស់ខ្លួន និងមានបេសកកម្មបម្រើផលប្រយោជន៍ក្នុងឃុំសង្កាត់របស់ខ្លួន។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត ដោយប្រជាពលរដ្ឋនៃឃុំ សង្កាត់របស់ខ្លួនស្របទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់មានអាណត្តិ៥ឆ្នាំហើយត្រូវបានផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ សង្កាត់ថ្មីចូលកាន់តំណែង។[15]

❖ **ចំនួនក្រុមប្រឹក្សាឃុំ សង្កាត់**

ក្រុមប្រឹក្សាឃុំ សង្កាត់មានសមាជិកចំនួនពី៥ ទៅ១១រូបផ្អែកតាមប្រជាសាស្ត្រ និងភូមិសាស្ត្ររបស់ខ្លួន។ ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សាតាមឃុំ សង្កាត់នីមួយៗត្រូវបានកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋ

[15] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,លេខ នស/រកម/០៣០១/០៥,១៩ មីនា ២០០១,មាត្រា៩ ១០ និង១១

មន្ត្រីក្រសួងមហាផ្ទៃ។ ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានកំណត់រួចហើយ អាចធ្វើការផ្លាស់ប្តូរបាន ដោយអនុក្រឹត្យតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាស្រ័យនៃការផ្លាស់ប្តូរប្រជាសាស្ត្រ និងភូមិសាស្ត្រ ។[16]

**❖ លក្ខខណ្ឌនៃការឈរឈ្មោះជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់**

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានសិទ្ធិនិងបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបំពេញលក្ខខណ្ឌសំខាន់ៗដូចខាងក្រោម ៖

- មានសញ្ជាតិខ្មែរពីកំណើត
- ចេះអាននិងសរសេរអក្សរខ្មែរ
- បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ដែលខ្លួនមានបំណងឈរឈ្មោះ
- មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកដល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និង
- មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមលក្ខខណ្ឌដែលបានកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។[17]

**❖ ហាមឈរឈ្មោះជាបេក្ខជនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់**

យោងតាមមាត្រា ៣៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ឆ្នាំ២០១៥ បានហាមឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានូវបុគ្គលមួយចំនួនដូចខាងក្រោម ៖

- សមាជិកព្រឹទ្ធសភា រដ្ឋសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម សមាជិករាជរដ្ឋាភិបាលនិងចៅក្រម
- អភិបាល ឬអភិបាលរងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មាធិការរាជធានីខេត្តរៀបចំការបោះឆ្នោត គណៈកម្មាធិការឃុំ សង្កាត់រៀបចំការបោះឆ្នោត គណៈកម្មការការិយាល័យបោះឆ្នោត បុគ្គលិកបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មាធិការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់
- មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិក្នុងមុខតំណែង
- ព្រះសង្ឃ ឬបព្វជិតសាសនានៃសាសនាណាមួយ
- ស្មៀនឃុំ សង្កាត់ណាមួយ។

[16] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,លេខ នស/រកម/០៣០១/០៥,១៩ មីនា ២០០១, មាត្រា១២

[17] យោងតាមច្បាប់ខាងលើ មាត្រា១៤

❖ **ការបាត់បង់សមាជិកភាពក្រុមប្រឹក្សា**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់បាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយក្នុងចំណោមមានករណីដូចខាងក្រោម[18] ៖

- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច
- សាមីខ្លួនសុំលាលែងជាលាយលក្ខណ៍អក្សរពីសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់
- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធធនាគារពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- សមាជិកត្រូវបានបណ្តេញចេញដោយប្រព្រឹត្តផ្ទុយនឹងបទបញ្ជាផ្ទៃក្នុងនៃក្រុមប្រឹក្សាឃុំ សង្កាត់តាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៨៥នៃច្បាប់នេះ
- ក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូលត្រូវរំសាយ
- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន។

កាលបើសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាមួយត្រូវបាត់បង់សមាជិកភាពត្រូវជ្រើសរើសបេក្ខជនដែលមានឈ្មោះបន្ទាប់តាមលេខរៀងក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសដោយមិនចាំបាច់បោះឆ្នោតឡើងវិញឡើយ។

**គ.តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សា**

ក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីសំខាន់មួយចំនួនដូចខាងក្រោម៖

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំយ៉ាងតិចណាស់ចំនួនមួយដងក្នុងមួយខែ[19]
- ក្រុមប្រឹក្សាឃុំ សង្កាត់អាចធ្វើប្រតិភូកម្មអំណាចឱ្យដល់មេឃុំចៅ សង្កាត់តាមសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ[20]
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំអនុម័តនិងអនុវត្តនូវផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធីនិងកិច្ចអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន។[21]ការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ត្រូវចាត់វិធានការដូចតទៅ៖
  - វាយតម្លៃអំពីកម្រិតអត្ថិភាពនៃការអភិវឌ្ឍន៍និងសកម្មភាពអភិវឌ្ឍន៍នៅក្នុងឃុំ សង្កាត់របស់ខ្លួន
  - ប្រមូលផ្តុំសេចក្តីត្រូវការក្នុងឃុំ សង្កាត់និងកំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះដោយផ្អែកទៅលើធនធានទាំងឡាយដែលឃុំ សង្កាត់មាននិងធនធានដែលបានទទួល

[18] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,លេខ នស/រកម/០៣០១/០៥,១៩ មីនា ២០០១,មាត្រា១៦

[19] យោងតាមច្បាប់ខាងលើ មាត្រា២១

[20] យោងតាមច្បាប់ខាងលើ មាត្រា៥១

[21] យោងតាមច្បាប់ខាងលើ មាត្រា៦០

- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានាតាមរយៈការផ្តល់សេវានិងការអភិវឌ្ឍន៍ ហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់
- ផ្តល់សេវានិងការអភិវឌ្ឍន៍ អនុលោមទៅតាមថវិការបស់ខ្លួន
- ពិនិត្យ តាមដាននិងវាយតម្លៃចំពោះលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍
- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតម្លៃអំពីកម្រិតនៃការអភិវឌ្ឍន៍ថ្មីៗក្នុងឃុំ សង្កាត់របស់ខ្លួន
- ធ្វើសេចក្តីរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ជូនប្រជាពលរដ្ឋរបស់ខ្លួន
- ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវដឹកនាំការងារឱ្យស្របទៅនឹងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួន។[22]

• ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើសេចក្តីរាយការណ៍ប្រចាំឆ្នាំអំពី៖
  - កិច្ចការជាអាទិភាព គោលដៅសម្រាប់ផ្តល់សេវានិងគម្រោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់នាឆ្នាំសារពើពន្ធកន្លងមក
  - លទ្ធផលនៃការអនុវត្តចំពោះកិច្ចការជាអាទិភាពគោលដៅសម្រាប់ផ្តល់សេវា និងគម្រោងផែនការអភិវឌ្ឍទាំងនោះរបស់ឃុំ សង្កាត់
  - វិធានការធ្វើឱ្យបានល្អប្រសើរចំពោះវិស័យនានាដែលមានការខ្វះចន្លោះក្នុងការអនុវត្តកន្លងមក
  - កិច្ចការជាអាទិភាព គោលដៅសម្រាប់ផ្តល់សេវានិងគម្រោងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន។[23]

### ខ.តួនាទី និងភារកិច្ចរបស់ប្រធានក្រុមប្រឹក្សា

- ធ្វើជាអធិបតីនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ធានាថា ក្រុមប្រឹក្សាឃុំ សង្កាត់បានប្រជុំយ៉ាងតិចមួយដងក្នុងមួយខែ
- ធានាថា កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានធ្វើឡើងស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- រក្សារបៀបរៀបរយនិងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់។

### គ.តួនាទី និងភារកិច្ចរបស់សមាជិកក្រុមប្រឹក្សា

- ធានាថាក្រុមប្រឹក្សាឃុំ សង្កាត់ប្រើប្រាស់អំណាច តួនាទី និងមុខងារដូចមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ
- ចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់

[22] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,លេខ នស/រកម/០៣០១/០៥,១៩ មីនា ២០០១, មាត្រា៦៣

[23] យោងតាមច្បាប់ខាងលើ មាត្រា៦៩

- ធ្វើកិច្ចសហប្រតិបត្តិការជាមួយប្រជាពលរដ្ឋ។

**១.៤.២.២.មេឃុំ ចៅសង្កាត់**

- មានសិទ្ធិចុះហត្ថលេខាលើដីកា និងសេចក្តីសម្រេចរបស់ឃុំ សង្កាត់របស់ខ្លួន
- មានសិទ្ធិតែងតាំងគណៈកម្មាធិការជំនួយការនានាតាមការចាំបាច់ ដើម្បីផ្តល់យោបល់ឱ្យខ្លួន
- មានសិទ្ធិចុះហត្ថលេខាលើលិខិតស្នើសុំសេវារដ្ឋបាលនៅឃុំ សង្កាត់របស់ខ្លួន
- ធានាថាសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអនុវត្ត
- រាយការណ៍អំពីការបំពេញការងារប្រចាំខែជូនក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្តល់យោបល់ និងជួយក្រុមប្រឹក្សាឃុំ សង្កាត់លើការងារកសាងផែនការ ការងារថវិកា ហិរញ្ញវត្ថុ និងការអនុវត្តអំណាច តួនាទី និងមុខងាររបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ផ្ទេរសិទ្ធិដល់ជំទប់ ចៅសង្កាត់រងតាមឋានានុក្រមពេលខ្លួនអវត្តមាន
- បំពេញភារកិច្ចផ្សេងទៀតដែលក្រុមប្រឹក្សាឃុំ សង្កាត់ប្រគល់ឱ្យ។

**១.៤.២.៣.ជំទប់ទី១ ចៅសង្កាត់រងទី១**

- ទទួលជួយមេឃុំ ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងករណីដែលមេឃុំ ចៅសង្កាត់អវត្តមាន
- នៅពេលទទួលស្តីទី មិនអាចផ្ទេរទៅឱ្យជំទប់ទី២ ចៅសង្កាត់រងទី២បានឡើយ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់មេឃុំ ចៅសង្កាត់។

**១.៤.២.៤.ជំទប់ទី២ ចៅសង្កាត់រងទី២**

- ទទួលជួយមេឃុំ ចៅសង្កាត់ទៅលើការងារផ្នែករដ្ឋបាល សេវាសង្គមកិច្ច សេវាសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ
- បំពេញការងារជាមេឃុំ ចៅសង្កាត់ស្តីទី ក្នុងករណីដែលមេឃុំ ចៅសង្កាត់ និងជំទប់ទី១ឬចៅសង្កាត់រងទី១អវត្តមាន
- នៅពេលទទួលស្តីទី មិនអាចផ្ទេរបន្តបានឡើយ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ឱ្យរបស់មេឃុំ ចៅសង្កាត់។

**១.៤.២.៥.គណៈកម្មាធិការនានា**

មេឃុំ ចៅសង្កាត់មានសិទ្ធិតែងតាំងគណៈកម្មាធិការនានា ដើម្បីផ្តល់យោបល់និងជួយការងារដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងមេឃុំ ចៅសង្កាត់អំពីបញ្ហាជាក់លាក់ណាមួយ។ គណៈកម្មាធិការនីមួយៗមានសមាជិកយ៉ាងតិច០៣នាក់។ រីឯតួនាទី ភារកិច្ចរបស់គណៈកម្មាធិការនានាមាន ដូចខាងក្រោម៖

- ផ្តល់យោបល់ និងជួយការងារជាក់លាក់ណាមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដូចជា ការកសាងផែនការ និងថវិកា
- រាយការណ៍អំពីការវិវត្តការងារប្រចាំខែរបស់ខ្លួន
- ផ្តល់យោបល់អំពីវិធានការត្រូវអនុវត្តដែលពាក់ព័ន្ធទៅនឹងការងារជាសមត្ថកិច្ចរបស់ខ្លួន។

បច្ចុប្បន្នរដ្ឋបាលឃុំ សង្កាត់មានគណៈកម្មាធិការជាកាតព្វកិច្ចចំនួន០៣គឺ គណៈកម្មាធិការកសាងផែនការ និងថវិកា គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ និងគណៈកម្មការលទ្ធកម្ម។[24]

**១.៤.២.៦.ស្មៀន**

បុគ្គលិកក្របខ័ណ្ឌនៅរដ្ឋបាលឃុំ សង្កាត់មានតែម្នាក់គត់គឺស្មៀនឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់ជាមន្រ្តីសិក្ខនៅក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាលរបស់ក្រសួងមហាផ្ទៃ[25]ពោលគឺសិក្ខនៅក្របខ័ណ្ឌ "គ"។ ស្មៀនឃុំ សង្កាត់ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីទៅបំពេញការងារជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឋានៈជាស្មៀនឃុំ សង្កាត់។ ស្មៀនឃុំ សង្កាត់មានតួនាទី និងភារកិច្ចមួយចំនួនដូចជា៖

- ត្រូវធ្វើជាសេនាធិការដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការកត់ត្រា និងការថែរក្សា ការពារចលនវត្ថុ និងអចលនវត្ថុដែលជាទ្រព្យសម្បត្តិសាធារណៈ និងទ្រព្យសម្បត្តិឯកជនរបស់ឃុំ សង្កាត់ ឬជាទ្រព្យសម្បត្តិដែលឃុំ សង្កាត់បានជួល(ដីធ្លី អគារ បឹង ទំនប់ ឬ ព្រៃកជាដើម)
- ត្រូវគ្រប់គ្រងត្រា តែមប៍ និងសំណុំឯកសារនានា និងទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ ( គ្រឿងសង្ហារឹមការិយាល័យ ម៉ាស៊ីន និងគ្រឿងបរិក្ខារ ឧបករណ៍ជាដើម )
- ត្រូវធ្វើសេចក្តីរាយការណ៍ជូនមេឃុំ ចៅសង្កាត់ អំពីរាល់សារពើភណ្ឌនៃទ្រព្យសម្បត្តិប្រចាំឆ្នាំនិងអំពីវិធានការថែរក្សាការពារដែលប្រកបដោយសុវត្ថិភាព និង សន្តិសុខនូវចលនវត្ថុ និងអចលនវត្ថុដែលជាទ្រព្យសម្បត្តិសាធារណៈនិងទ្រព្យសម្បត្តិឯកជនរបស់ឃុំ សង្កាត់ ឬចលនវត្ថុនិងអចលនវត្ថុដែលឃុំ សង្កាត់បានជួល[26]
- ទទួល និងពិនិត្យលិខិត ព្រមទាំងឯកសារគ្រប់ប្រភេទដែលបានផ្ញើមកឃុំ សង្កាត់ហើយត្រូវបែងចែកលិខិត ឬឯកសារទាំងនោះឱ្យបានត្រឹមត្រូវដល់ការិយាល័យឃុំ សង្កាត់ គណៈកម្មាធិការណាមួយរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬគណៈកម្មាធិការណាមួយរបស់មេឃុំ ចៅសង្កាត់ ឬ ប្រធានក្រុមប្រឹក្សា

[24] សាលាជាតិរដ្ឋបាលមូលដ្ឋាន,*ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់* (២០២២)

[25] ប្រកាសរបស់ក្រសួងមហាផ្ទៃស្តីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់,លេខ១៣២៩ប្រ.ក,១៩ ធ្នូ ២០០១,ប្រការ១

[26] យោងតាមប្រកាសខាងលើ ប្រការ៧

ឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ ជំទប់ ចៅសង្កាត់រង សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀនឃុំ សង្កាត់ ឬមន្ត្រីដទៃទៀតដែលបម្រើការងារក្នុងឃុំ សង្កាត់

- ពិភាក្សាជាមួយមេឃុំ ចៅសង្កាត់អំពីលិខិតនិងឯកសារដែលបានទទួល
- ទទួល និងកត់ត្រាសេចក្តីសម្រេចរបស់មេឃុំ ចៅសង្កាត់ និងការចាត់ចែងការងារ ការប្រគល់ភារកិច្ចរបស់មេឃុំ ចៅសង្កាត់ដល់អ្នកដែលត្រូវអនុវត្តការងារទាំងនោះក្នុងឃុំ សង្កាត់
- ជួយដល់មេឃុំ ចៅសង្កាត់ក្នុងការធ្វើសេចក្តីរាយការណ៍ជូនអង្គប្រជុំប្រចាំខែឬអង្គប្រជុំពិសេសរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ អំពីលិខិតនិងសំណុំឯកសារទាំងអស់ដែលបានទទួលនិងវិធានការដែលបានចាត់ចែង ឬដែលបានស្នើដោយមេឃុំ ចៅសង្កាត់[27]
- ត្រូវធ្វើជាសេនាធិការក្នុងការពិនិត្យឡើងវិញនូវលិខិត និងសំណុំឯកសារទាំងអស់ដែលត្រូវបានរៀបចំដោយ ឬក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ មុនពេលឯកសារទាំងនោះផ្ញើចេញ ឬដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មាធិការ ដើម្បីធានាឱ្យលិខិតឬឯកសារទាំងនោះមានលក្ខណៈត្រឹមត្រូវតាមនីតិវិធីនិងច្បាប់[28]
- ត្រូវធ្វើជាសេនាធិការឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ និង តំណាងរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការធ្វើសេចក្តីសម្រេចនានាដោយអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យ ប្រកាស និង លិខិតបទដ្ឋាននានាដែលបានអនុម័តដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- មានភារកិច្ចទទួលខុសត្រូវក្នុងការផ្តល់ព័ត៌មាននិង យោបល់សមស្របដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ឬ តំណាងស្របច្បាប់របស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ត្រូវផ្តល់ព័ត៌មាននិងផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីមុខងារនិងអំណាចដែលក្រុមប្រឹក្សាអនុវត្តបានព្រមទាំងនីតិវិធី និង ប្រព័ន្ធដែលត្រូវអនុវត្តតាមលក្ខខណ្ឌនៃច្បាប់ ឬ អនុក្រឹត្យ ឬ ប្រកាស ឬលិខិតបទដ្ឋាននានាដែលអាចអនុវត្តបាន
- ត្រូវផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និង មេឃុំ ចៅសង្កាត់ អំពីកាតព្វកិច្ចដែលតម្រូវឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ផ្ញើឯកសារឬសេចក្តីរាយការណ៍ទៅរាជរដ្ឋាភិបាល ឬក្រសួង ឬស្ថាប័ននានារបស់រាជរដ្ឋាភិបាល
- ត្រូវជួយដល់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនដើម្បីធានាឱ្យបានថារាល់សេចក្តីសម្រេចឬវិធានការដែលបានធ្វើឡើងក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់តាមរយៈមេឃុំ ចៅសង្កាត់ គណៈកម្មាធិការ ឬតំណាង

[27] ប្រកាសរបស់ក្រសួងមហាផ្ទៃស្តីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់,លេខ១៣២៩ប្រ.ក,១៩ ធ្នូ ២០០១, ប្រការ៨
[28] យោងតាមប្រកាសខាងលើ ប្រការ៩

ដទៃទៀតរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានការអនុវត្តជាមុនតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យ ប្រកាស និង លិខិតបទដ្ឋាននានា ដែលបានអនុម័តដោយគណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់។[29]

**១.៤.២.៧.បុគ្គលិកឃុំ សង្កាត់**

ក្រៅពីស្មៀន ឃុំ សង្កាត់អាចជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋដើម្បីជួយកិច្ចការរបស់ខ្លួនតាមសេចក្តីត្រូវការនិងការចាំបាច់នៃការងារនិងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងអាណត្តិ ហើយអាចបន្តការងារតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិបន្ទាប់។[30]

បុគ្គលិកក្រៅក្របខ័ណ្ឌនៅរដ្ឋបាលឃុំ សង្កាត់ ជាបុគ្គលិកជាប់កិច្ចសន្យា ដែលបច្ចុប្បន្ននៅរដ្ឋបាលឃុំ សង្កាត់បុគ្គលិកជាប់កិច្ចសន្យារួមមានជំនួយការរដ្ឋបាលឃុំ សង្កាត់និងជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់។[31]

**ក.ជំនួយការរដ្ឋបាលឃុំ សង្កាត់**

យោងតាមសេចក្តីណែនាំលេខ០០៥ សណន ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២០ របស់ក្រសួងមហាផ្ទៃស្តីពីនីតិវិធីនៃការជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋរបស់រដ្ឋបាលឃុំ សង្កាត់ រដ្ឋបាលឃុំ សង្កាត់អាចជ្រើសរើសជំនួយការរដ្ឋបាលឃុំ សង្កាត់តាមចំនួនកំណត់ដូចខាងក្រោម៖

- រដ្ឋបាលឃុំ សង្កាត់ដែលមានក្រុមប្រឹក្សាចំនួន០៥រូប ដល់ ០៧រូប អាចជ្រើសរើសជំនួយការរដ្ឋបាលឃុំ សង្កាត់ យ៉ាងច្រើនចំនួន០២រូប
- រដ្ឋបាលឃុំ សង្កាត់ដែលមានក្រុមប្រឹក្សាចំនួន០៩រូប ដល់ ១១រូប អាចជ្រើសរើសជំនួយការរដ្ឋបាលឃុំ សង្កាត់ យ៉ាងច្រើនចំនួន០៣រូប។

រីឯប្រាក់កម្រៃប្រចាំខែរបស់ជំនួយការរដ្ឋបាលឃុំ សង្កាត់ត្រូវកំណត់ដោយក្រុមប្រឹក្សាឃុំ សង្កាត់សាមីអនុលោមតាមបទប្បញ្ញត្តិជាធរមាន។ជំនួយការរដ្ឋបាលឃុំ សង្កាត់មានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភផ្សេងៗស្របតាមច្បាប់និងលិខិតបទដ្ឋានជាធរមាន។

ប្រសិនបើមានតម្រូវការចាំបាច់ និងការគាំទ្រពីប្រភពផ្សេងៗរដ្ឋបាលឃុំ សង្កាត់អាចជ្រើសរើសជំនួយការរដ្ឋបាលឃុំ សង្កាត់បន្ថែមទៀត។

មេឃុំ ចៅសង្កាត់ត្រូវពិគ្រោះពិភាក្សាជាមួយជំទប់ ចៅសង្កាត់រង ដើម្បីផ្តួចផ្តើមកំណត់តម្រូវការជំនួយការរដ្ឋបាលឃុំ សង្កាត់ រួមមាន៖

[29] ប្រកាសរបស់ក្រសួងមហាផ្ទៃស្តីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់,លេខ១៣២៩ប្រ.ក,១៩ ធ្នូ ២០០១,ប្រការ១០,១១
[30] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់,លេខ នស/រកម/០៣០១/០៥,១៩ មីនា ២០០១,មាត្រា២៩
[31] សាលាជាតិរដ្ឋបាលមូលដ្ឋាន,*ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់* (២០២២)

- តម្រូវការជំនួយការរដ្ឋបាលឃុំសង្កាត់ប្រចាំឆ្នាំដោយផ្អែកតាមសេចក្តីត្រូវការនិងការចាំបាច់នៃការងារក្នុងឃុំ សង្កាត់
- ចំនួនមុខតំណែងទៅតាមសេចក្តីត្រូវការ និងទំហំការងារ
- រយៈពេលនៃមុខតំណែងនីមួយៗ
- លក្ខណៈសម្បត្តិនិងជំនាញបច្ចេកទេសសម្រាប់មុខតំណែងនីមួយៗ
- កម្រិតប្រាក់កម្រៃប្រចាំខែសម្រាប់មុខតំណែងនីមួយៗទៅតាមទំហំការងារថ្លៃឈ្នួលជាក់ស្តែងនៅក្នុងមូលដ្ឋានឃុំ សង្កាត់នីមួយៗនិងលទ្ធភាពធនធានហិរញ្ញវត្ថុរបស់រដ្ឋបាលឃុំ សង្កាត់។

ចំពោះការជ្រើសរើសជំនួយការរដ្ឋបាលឃុំ សង្កាត់ ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែងដោយផ្អែកតាមគោលការណ៍ តម្លាភាព យុត្តិធម៌ សមធម៌ និងគុណសម្បត្តិស័ក្តិសម។ ការប្រឡងជ្រើសរើសជំនួយការរដ្ឋបាលឃុំ សង្កាត់ត្រូវផ្តល់អាទិភាពដល់បេក្ខជនជាស្ត្រីជនជាតិដើមភាគតិច ជនមានពិការភាព និងបេក្ខជនមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងឃុំ សង្កាត់ដែលត្រូវជ្រើសរើសបុគ្គលិកនោះ។

ជំនួយការរដ្ឋបាលឃុំ សង្កាត់ត្រូវជ្រើសរើសឱ្យបំពេញការងារសម្រាប់រយៈពេលយ៉ាងតិច០៣ខែនិងយ៉ាងច្រើន១២ខែក្នុងមួយឆ្នាំ ហើយអាចបន្តការងារតាមសេចក្តីត្រូវការរបស់រដ្ឋបាលឃុំ សង្កាត់ឬតាមលិខិតបទដ្ឋាននានាជាធរមាន។

## ខ.ជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់

យោងតាមប្រកាសអន្តរក្រសួងលេខ០០២សហវ.ប្រក របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមហាផ្ទៃ និងក្រសួងមុខងារសាធារណៈស្តីពីការជ្រើសរើសនិងការកំណត់តួនាទីនិងភារកិច្ចរបស់ជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់។ រដ្ឋបាលឃុំ សង្កាត់នីមួយៗត្រូវមានជំនួយការហិរញ្ញវត្ថុចំនួន០១រូប។ រីឯកិច្ចដំណើរការនៃការជ្រើសរើសជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ត្រូវរៀបចំតាមការប្រឡងប្រជែង។

បេក្ខជនជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- ត្រូវមានសញ្ជាតិខ្មែរ
- ត្រូវមានអាយុយ៉ាងតិច១៨(ដប់ប្រាំបីឆ្នាំ)
- ត្រូវមានកម្រិតសិក្សាចាប់ពីបញ្ចប់ថ្នាក់ទី១២
- ត្រូវមានចំណេះដឹងមូលដ្ឋានផ្នែកហិរញ្ញវត្ថុ និងគណនេយ្យ
- ត្រូវមានចំណេះដឹងមូលដ្ឋានផ្នែកកុំព្យូទ័រ
- បេក្ខជនដែលមានទីលំនៅនៅក្នុងឃុំ សង្កាត់សាមី ឬនៅក្នុងឃុំ សង្កាត់ដែលមានព្រំប្រទល់ជាប់គ្នាត្រូវបានផ្តល់អាទិភាព

- មានបទពិសោធន៍ការងារក្នុងវិស័យសាធារណៈ ឬឯកជនលើជំនាញពាក់ព័ន្ធត្រូវបានផ្តល់អាទិភាព
- បេក្ខជនជាស្ត្រី ជនពិការ និងជនជាតិដើមភាគតិច ត្រូវបានផ្តល់អាទិភាព។

ជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ត្រូវបំពេញការងារដោយមានគណនេយ្យភាពចំពោះមេឃុំ ចៅសង្កាត់ និងស្មៀនឃុំ សង្កាត់និងមានតួនាទី ភារកិច្ចដូចខាងក្រោមៈ

- ជារដ្ឋទេយ្យករបុរេប្រទាន
- ជារដ្ឋទេយ្យករចំណូល
- ជាភ្នាក់ងារបើកផ្តល់
- ជាជំនួយការឱ្យមេឃុំ ចៅសង្កាត់ក្នុងការៈ
  - រៀបចំផែនការនិងគម្រោងថវិកាប្រចាំឆ្នាំ
  - គ្រប់គ្រង ពិនិត្យនិងតាមដានការអនុវត្តថវិកា
  - រៀបចំរបាយការណ៍និងប្រព័ន្ធរបាយការណ៍ផ្ទៃក្នុងដើម្បីពិនិត្យតាមដានការអនុវត្តថវិកា
  - រៀបចំរបាយការណ៍ស្តីពីការអនុវត្តថវិកាតាមទម្រង់របាយការណ៍រួមរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  - អនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុដោយគោរពតាមវិធាននិងបទប្បញ្ញត្តិហិរញ្ញវត្ថុសាធារណៈជាធរមាន
- បំពេញការងារពាក់ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុផ្សេងៗទៀតតាមការប្រគល់របស់មេឃុំ ចៅសង្កាត់។

**១.៤.២.៨.ភូមិ**

ភូមិ គឺជាកន្លែងប្រមូលផ្តុំដោយផ្ទះនិងគ្រួសារប្រជារាស្ត្រជាច្រើន។ ភូមិជាច្រើនរួមផ្តុំបង្កើតបានជាឃុំ ឬសង្កាត់មួយ។

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗត្រូវរៀបចំជ្រើសរើសឱ្យមានមេភូមិម្នាក់ សម្រាប់ភូមិនីមួយៗចំណុះឱ្យឃុំ សង្កាត់របស់ខ្លួន។ មេភូមិនេះមិនមែនជាបុគ្គលិកជាប់កិច្ចសន្យា ឬមន្ត្រីរាជការនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈនោះទេ។ ផ្ទុយទៅវិញ ការរៀបចំឱ្យមានមេភូមិសម្រាប់ឃុំ សង្កាត់នីមួយៗនេះ គឺដើម្បីធ្វើជាសេនាធិការឱ្យរដ្ឋបាលឃុំ សង្កាត់នៅក្នុងការគ្រប់គ្រងប្រកបដោយនិរន្តភាពនិងប្រសិទ្ធភាពនៃសេវា។

មេភូមិនេះ ត្រូវរៀបចាំចាត់តាំងឱ្យមានអនុប្រធានភូមិមួយរូប និងសមាជិកមួយរូបជាជំនួយការ។ មេភូមិ អនុប្រធានភូមិនិងសមាជិកភូមិ មិនត្រូវបានកំណត់អាណត្តិការងារឡើយ។

មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិក្នុងមុខតំណែងត្រូវបន្តការងាររហូតដល់មានការតែងតាំង មេភូមិ អនុប្រធានភូមិនិងសមាជិកភូមិថ្មីមកជំនួស។ខាងក្រោមនេះ ជាតួនាទីនិងភារកិច្ចរបស់មេភូមិនិងជំនួយការភូមិ៖

**ក.មេភូមិ**

- ទទួលខុសត្រូវរួមក្នុងភូមិរបស់ខ្លួន
- តំណាងឱ្យប្រជាពលរដ្ឋទាំងអស់ក្នុងភូមិ និងជាខ្សែរយៈចម្បងសម្រាប់ភ្ជាប់ទំនាក់ទំនងរវាងភូមិ និងក្រុមប្រឹក្សាឃុំ សង្កាត់
- បង្កើនការពិគ្រោះយោបល់ទទួលការណែនាំនិងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន
- ចូលរួមក្នុងកិច្ចប្រជុំគណៈកម្មាធិការនានារបស់ឃុំ សង្កាត់ នៅពេលដែលក្រុមប្រឹក្សាឃុំ សង្កាត់តម្រូវដើម្បីផ្តល់យោបល់អំពីកិច្ចការ ដែលពាក់ព័ន្ធក្នុងភូមិរបស់ខ្លួនមានជាអាទិ៍៖
    - ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីតម្រូវការ និងផលប្រយោជន៍របស់ភូមិ
    - ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់អំពីរបៀបបង្កើននិងកសាងសមត្ថភាពនិងធនធានរបស់ភូមិ
    - ផ្តល់យោបល់ដល់គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ សង្កាត់អំពី៖
        - តម្រូវការនិងអាទិភាពរបស់ភូមិ ដើម្បីបញ្ចូលក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់
        - ការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន
        - ការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងភូមិរបស់ខ្លួន
- ត្រូវធ្វើសេចក្តីរាយការណ៍រាល់បញ្ហាពាក់ព័ន្ធនឹងភូមិរបស់ខ្លួន ដើម្បីដាក់បញ្ចូលក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ត្រូវចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងករណីមានសំណូមពរពីក្រុមប្រឹក្សាឃុំ សង្កាត់
- ត្រូវធានាផ្តល់ព័ត៌មានឯកសារជាសាធារណៈ ដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួនជូនទៅដល់ប្រជាពលរដ្ឋរបស់ខ្លួន។ ឯកសារព័ត៌មានទាំងនោះអាចរួមមាន ព័ត៌មានស្តីពីការប្រជុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ផែនការអភិវឌ្ឍន៍និងថវិកាឃុំ សង្កាត់
- ត្រូវទទួលខុសត្រូវអនុវត្តកិច្ចការដែលបានប្រគល់ឱ្យដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។

**ចំណាំ៖** មេភូមិមិនមានសិទ្ធិអំណាចចុះហត្ថលេខាលើកិច្ចសន្យា ឬការផ្ទេរអំណាច ឬការចាត់ចែងដទៃទៀតក្នុងនាមភូមិបានឡើយ។ ក្រៅពីនេះ មេភូមិគឺពុំមានសិទ្ធិអំណាចសម្រេចលើបញ្ហាណាមួយដែលសិត្ថក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ដោយគ្មានការផ្ទេរអំណាចពីក្រុមប្រឹក្សាឃុំ សង្កាត់ស្របតាមប្រកាសរបស់

ក្រសួងមហាផ្ទៃបានឡើយ។ ម៉្យាងវិញទៀត ក្រុមប្រឹក្សាឃុំ សង្កាត់មិនអាចផ្ទេរអំណាចដល់បុគ្គល ឬគណៈកម្មាធិការឬអង្គការណាមួយនៅក្នុងភូមិបាននោះឡើយ លើកលែងតែមានការអនុញ្ញាតដែលបានចែងក្នុងប្រកាសរបស់ក្រសួងមហាផ្ទៃ។[32]

**ខ.ជំនួយការមេភូមិ**

- អនុប្រធានភូមិទទួលការងារជំនួសមេភូមិក្នុងពេលដែលមេភូមិអវត្តមានដោយមាននូវមូលហេតុច្បាស់លាស់ដូចជាមានជំងឺ ឬមានបេសកម្មចេញក្រៅឃុំ សង្កាត់របស់ខ្លួនលើសពីមួយថ្ងៃ។ ក្រៅពីនេះ អនុប្រធានភូមិត្រូវទទួលខុសត្រូវជួយមេភូមិទៅលើការអនុវត្តគម្រោងអភិវឌ្ឍន៍នានាក្នុងភូមិតាមគម្រោងផែនការរបស់ឃុំ សង្កាត់។
- សមាជិកភូមិទទួលជួយធ្វើជាលេខាធិការឱ្យមេភូមិ និងទទួលជួយមេភូមិលើការងារសិត្ថិ ការចុះបញ្ជីប្រជាពលរដ្ឋនិងការរក្សាទុកឯកសារនានារបស់ភូមិ។[33]

[32] សេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃស្តីពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរមេភូមិ ការតែងតាំងជំនួយការមេភូមិ និង តួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ,លេខ០០៤ សណន,១៧ មីនា ២០០៦

[33] នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន,*ការជ្រើសរើសមេភូមិ និងជំនួយការមេភូមិ* (២០០៦)

# ជំពូកទី២
# ដំណើរការគ្រប់គ្រងរដ្ឋបាលឃុំវិហារសួគ៌

## ២.១.ទិដ្ឋភាពទូទៅនៃឃុំវិហារសួគ៌

### ២.១.១.ប្រវត្តិឃុំវិហារសួគ៌

ឃុំវិហារសួគ៌ ជាឃុំមួយដែលមានប្រវត្តិដ៏យូរលង់ណាស់មកហើយ និងមានការពាក់ព័ន្ធចារទុកក្នុងប្រវត្តិពង្សាវតាខ្មែរត្រង់រាជការបក្សីចាំក្រុង។កាលណោះ តា គហេ បាននាំព្រះរាជកុមារដែលជាពូជពង្សក្សត្រមានព្រះបាទដែកងចាក់រត់គេចខ្លួនដែលត្រូវស្តេចផែនដីតាមរកចាប់ខ្លួនយកទៅសម្លាប់ ព្រោះខ្លាចដណ្តើមរាជ្យ តា គហេយកមកលាក់ទុកនៅក្រោមជំរុណាជ្រៃមួយធំ រួចតា គហេក៏បែបន់សូមបារមី និង វត្ថុសក្តិសិទ្ធិនៅទីនេះជួយថែរក្សារាជកុមារសូមជួបតែសេចក្តីសុខ។ ពេលនោះព្រះអាទិត្យបានចាំងពន្លឺចំពីលើព្រះរាជកុមារដែលផ្ទំក្នុងអង្រឹងស្រាប់តែមានបក្សីមួយក្បាលបានមកសំកាំងស្លាបបាំងពន្លឺថ្ងៃ កុំឱ្យចាំងទៅលើព្រះរាជកុមារ។

តា គហេ បានសេចក្តីសុខសាន្តនៅទីនេះហើយក៏បានសាងសង់ព្រះវិហារជាជួរ ដើម្បីលាព្រះបំណន់ក្នុងពេលកើតអាសន្នដែលបានរត់គេចខ្លួនរួចពីការតាមចាប់ខ្លួនដល់រាជកុមារ។ អស់រយៈកាលដ៏យូរលង់មក ពាក្យថា "ព្រះវិហារជួរ" នេះបានក្លាយទៅជា"ព្រះវិហារសួគ៌"វិញ។

ក្រោយមក ដោយការរីកចម្រើនផ្នែកស្ថិតិវិទ្យា ប្រទេសជាតិតម្រូវឱ្យមានការដាក់ឈ្មោះ ភូមិ ឃុំ ស្រុក ខេត្តទើបគេបានដាក់ឈ្មោះទីនេះថា"**ឃុំវិហារសួគ៌**" រហូតមកដល់សព្វថ្ងៃនេះ។[34]

### ២.១.២.ស្ថានភាពភូមិសាស្ត្រ

ឃុំវិហារសួគ៌គឺជាឃុំមួយក្នុងចំណោមឃុំទាំង១២របស់ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាលនិងមានទីតាំងស្ថិតនៅប៉ែកខាងត្បូងនៃទីតាំងសាលាស្រុកមានចម្ងាយប្រមាណ១២ គ.ម ដែលមានព្រំប្រទល់ជាប់នឹងៈ

- ខាងជើងទល់នឹងឃុំ សន្លុង ស្រុកខ្សាច់កណ្តាល
- ខាងត្បូងទល់នឹងសង្កាត់ បារុង របស់ក្រុងអរិយក្សត្រ
- ខាងកើតជាប់នឹង ឃុំសន្លុង និងឃុំស៊ីធរ ស្រុកខ្សាច់កណ្តាល
- ខាងលិចជាប់នឹង សង្កាត់ព្រែកលួង, សង្កាត់ព្រែកអំពិល ក្រុងអរិយក្សត្រ និងឃុំពុកឬស្សី នៃស្រុកខ្សាច់កណ្តាល ។

ឃុំវិហារសួគ៌មានផ្ទៃដីសរុបចំនួន៤៤,០៦គីឡូម៉ែត្រការ៉េនិងមានភូមិចំនួន៨ជាចំណុះរួមមាន ភូមិព្រៃចាស់ ភូមិសេដា ភូមិវិហារសួគ៌ជើង ភូមិវិហារសួគ៌ត្បូង ភូមិព្រៃធំ ភូមិតាកែវ២ ភូមិតាកែវ១ និងភូមិស្វាយមាស។ តាម

[34] គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំវិហារសួគ៌, កម្មវិធីវិនិយោគឃុំឆ្នាំ២០១៩

ភូមិនីមួយៗធ្វើដំណើរដោយផ្លូវលំដីស ផ្លូវចាក់កំទិចថ្ម និងផ្លូវបេតុងដែលកសាងដោយថវិកាមូលនិធិឃុំ និងថវិកា របស់ឯកឧត្តមបណ្ឌិតវង្ស ប៊ុនឥន្ទ្រាវុធ ប្រធានក្រុមការងារថ្នាក់ជាតិចុះជួយឃុំ។[35]

### ២.១.៣.ស្ថានភាពប្រជាសាស្ត្រ

គិតត្រឹមថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅឃុំវិហារសួគ៌មានប្រជាជនរស់នៅប្រមាណជា៤,០៥៤គ្រួសារ (គ្រួសារអចិន្ត្រៃយ៍មានចំនួន៣,៨១៦និងគ្រួសារបណ្ដោះអាសន្នមានចំនួន២៣៨គ្រួសារ)និងមានស្ត្រីជាមេគ្រួសារ មានចំនួន១០១គ្រួសារ។ រីឯប្រជាជនសរុបទាំងអស់មានចំនួន១៧,៤៧៤នាក់ (ស្រីចំនួន៩,០២៣នាក់ និងប្រុស ចំនួន៨,៤៥១នាក់)។ ក្នុងនោះកុមារអាយុក្រោម៦ឆ្នាំមានចំនួន២,០១៥នាក់ ស្រី១,០២៣នាក់។ កុមារអាយុពី៦ ឆ្នាំដល់១៨ឆ្នាំមានចំនួន៥,៤០៣នាក់ ស្រី២,៧៤៩នាក់។ចំណែកប្រជាពលរដ្ឋដែលមានអាយុចាប់ពី១៨ឆ្នាំឡើង ទៅមានចំនួន១២,៥៧៦នាក់ ស្រី៦,៤៣៧នាក់។[36]

ចំណែកឯកំណើនប្រជាជនប្រចាំឆ្នាំមានចំនួន០,៤% និងអត្រាភាពក្រីក្រមានចំនួន១៩%។ រីឯប្រជាជន ងាយរងគ្រោះ ក្នុងនោះរួមមាន ជនពិការមានចំនួន៣៨នាក់ ជនពិការដែលមានអាយុ១៨ឡើងទៅមិនអាចរក ប្រាក់ចំណូលបានមានចំនួន៣% កុមារកំព្រាឪពុកម្ដាយស្លាប់ដោយជម្ងឺអេដស៍មានចំនួន ០៣នាក់ និងមនុស្ស ចាស់ជរាគ្មានទីពឹង(អាយុ៦១ឆ្នាំឡើង)មានចំនួន០១នាក់(ទិន្នន័យឆ្នាំ២០២៣)។[37]

## ២.២.រចនាសម្ព័ន្ធរដ្ឋបាលឃុំវិហារសួគ៌

### ២.២.១.សមាសភាពក្រុមប្រឹក្សា

យោងតាមប្រការ១នៃប្រកាសរបស់ក្រសួងមហាផ្ទៃ លេខ៣០០៨ ប្រក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ស្ដីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សា មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំនៃឃុំវិហារសួគ៌ ស្រុក ខ្សាច់កណ្ដាល ខេត្តកណ្ដាល ក្រុមប្រឹក្សាឃុំវិហារសួគ៌នៅក្នុងអាណត្តិទី៥នេះមានសមាសភាពចំនួន០៩រូប ក្នុង នោះមានរាយនាមដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១.លោក | ម៉េង | ឈាងហេង | ជាប្រធានក្រុមប្រឹក្សាឃុំ |
| ២.លោក | ហេង | ថន | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៣.លោក | ឈុន | លាវ | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៤.លោក | ហុង | បញ្ញា | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៥.លោក | ម៉ៅ | ចូច | ជាសមាជិកក្រុមប្រឹក្សាឃុំ |

[35] គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំវិហារសួគ៌, ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ(២០២៣-២០២៧)

[36] របាយការណ៍ស្ដីពីការអនុវត្តការងាររបស់រដ្ឋបាលឃុំវិហារសួគ៌ប្រចាំឆ្នាំ២០២៣

[37] គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំវិហារសួគ៌, កម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៣-២០២៥)

៦.លោក ស៊ិន យ័ន ជាសមាជិកក្រុមប្រឹក្សាឃុំ

៧.លោកស្រី ឃឹម សម្បត្តិ ជាសមាជិកក្រុមប្រឹក្សាឃុំ

៨.លោក ចុស សុគន្ធ ជាសមាជិកក្រុមប្រឹក្សាឃុំ

៩.លោក ធី សារី ជាសមាជិកក្រុមប្រឹក្សាឃុំ។

យោងតាមប្រការ២នៃប្រកាសរបស់ក្រសួងមហាផ្ទៃ លេខ៣០០៨ប្រក ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សា មេឃុំ ជំទប់ និង សមាជិកក្រុមប្រឹក្សាឃុំនៃឃុំវិហារសួគ៌ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាលនេះដដែលបានទទួលស្គាល់សមាសភាពជា មេឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាលមានរាយនាមដូចខាងក្រោម៖

១. លោក ម៉េង ឈាងហេង ជាមេឃុំ

២. លោក ហេង ថន ជាជំទប់ទី១

៣.លោក ឈុន លាវ ជាជំទប់ទី២។

**២.២.២.គណៈកម្មាធិការរបស់ឃុំ**

យោងតាមមាត្រា២៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មេឃុំ ចៅសង្កាត់ មានសិទ្ធិក្នុងការចាត់តាំងគណៈកម្មាធិការនានាដើម្បីផ្តល់យោបល់និងជួយកិច្ចការនានាតាមការចាំបាច់។

ជាក់ស្តែង រដ្ឋបាលឃុំវិហារសួគ៌មានគណៈកម្មាធិការចំនួន០៥ ក្នុងនោះរួមមាន៖

**២.២.២.១.គណៈកម្មាធិការកសាងផែនការ និងថវិកា**

**ក.សមាសភាព**

គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំវិហារសួគ៌ មានសមាសភាពចំនួន២២រូប ដឹកនាំដោយប្រធាន០១រូប អនុប្រធាន០១រូប និងសមាជិកចំនួន២០រូបផ្សេងទៀត ដែលមានរាយនាមដូចខាងក្រោម[38]៖

| | | | | |
|---|---|---|---|---|
| ១. លោក | ម៉េង | ឈាងហេង | ប្រធានក្រុមប្រឹក្សាឃុំ | ជាប្រធាន |
| ២. លោក | ហេង | ថន | ជំទប់ទី១ | ជាអនុប្រធាន |
| ៣.លោក | ឈុន | លាវ | ជំទប់ទី២ | ជាសមាជិក |
| ៤.លោក | ហុង | បញ្ញា | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៥.លោក | ម៉ៅ | ចូច | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៦.លោក | ស៊ិន | យ័ន | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |

[38] សេចក្តីសម្រេចរបស់រដ្ឋបាលឃុំវិហារសួគ៌ស្តីពីការបង្កើតគណៈកម្មាធិការកសាងផែនការនិងថវិកាឃុំវិហារសួគ៌,លេខ០០៥/២៣ស.ស.រ ,៣០ មករា ២០២៣,ប្រការ១

| | | | | |
|---|---|---|---|---|
| ៧.លោកស្រី | ឃឹម | សម្បត្តិ | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៨.លោក | ចុស | សុគន្ធ | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៩.លោក | សែម | សាយ | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ១០.លោកស្រី | ធីម | យុនអ៊ី | ជនបង្គោលគ.ក.ន.ក | ជាសមាជិក |
| ១១.លោក | អៀ | យឿន | មេភូមិព្រៃចាស់ | ជាសមាជិក |
| ១២.លោក | ឃុយ | ពុង | មេភូមិសេដា | ជាសមាជិក |
| ១៣.លោក | សាត | កាក់ | មេភូមិវិហារសួគ៌ជើង | ជាសមាជិក |
| ១៤.លោក | ស្រ៊ុម | សុខឃាន់ | មេភូមិវិហារសួគ៌ត្បូង | ជាសមាជិក |
| ១៥.លោក | ហឿន | ហៀត | មេភូមិព្រៃធំ | ជាសមាជិក |
| ១៦.លោក | អ៊ុន | អុន | មេភូមិតាកែវ២ | ជាសមាជិក |
| ១៧.លោក | ឈឿន | ឆុន | មេភូមិតាកែវ១ | ជាសមាជិក |
| ១៨.លោក | ជា | ហុន | មេភូមិស្វាយមាស | ជាសមាជិក |
| ១៩.លោក | លោកស្រីអនុប្រធានភូមិទាំង៧ | | | ជាសមាជិក |
| ២០.លោក | លោកស្រីសមាជិកភូមិទាំង៧ | | | ជាសមាជិក |
| ២១.លោកស្រី | ឆន | ឡាក់ឡេង | ស្មៀនឃុំ | ជាលេខាធិការ |
| ២២.លោក | ពង់ | ផល់ | ជំនួយការហិរញ្ញវត្ថុ | ជំនួយការលេខាធិការ។ |

**ខ.ភារកិច្ច**

គណៈកម្មាធិការកសាងផែនការ និង ថវិកាឃុំមានភារកិច្ចទទួលខុសដូចជាៈ

- ត្រូវជួយមេឃុំក្នុងការរៀបចំកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគឃុំនិងរៀបចំថវិកាប្រចាំឆ្នាំរបស់ឃុំ
- គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំត្រូវអនុវត្តនីតិវិធីក្នុងកសាងផែនការអភិវឌ្ឍន៍ និងរៀបចំកម្មវិធីវិនិយោគឃុំនិងរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំតាមអភិក្រមដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ។[39]

[39] សេចក្តីសម្រេចរបស់រដ្ឋបាលឃុំវិហារសួគ៌ស្តីពីការបង្កើតគណៈកម្មាធិការកសាងផែនការនិងថវិកាឃុំវិហារសួគ៌,លេខ០០៥/២៣ស.ស.រ ,៣០ មករា ២០២៣,ប្រការ២

**២.២.២.២.គណៈកម្មការលទ្ធកម្ម**

**ក.សមាសភាព**

គណៈកម្មការលទ្ធកម្មឃុំវិហារសួគ៌ មានសមាសភាពចំនួន០៧រូប ដឹកនាំដោយប្រធាន០១រូប អនុប្រធាន ០១រូប និងសមាជិកចំនួន០៥រូបផ្សេងទៀត ដែលមានរាយនាមដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១. លោក | ម៉េង | ឈាងហេង | ប្រធានក្រុមប្រឹក្សាឃុំ | ជាប្រធាន |
| ២. លោក | ហេង | ថន | ជំទប់ទី១ | ជាអនុប្រធាន |
| ៣.លោក | ឈុន | លាវ | ជំទប់ទី២ | ជាសមាជិក |
| ៤.លោក | ហុង | បញ្ញា | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៥.លោក | ថុស | សុគន្ធ | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៦.លោកស្រី | ឆន | ឡាក់ឡេង | ស្មៀនឃុំ | លេខាធិការ |
| ៧.លោក | ពង់ | ផល់ | ជំនួយការហិរញ្ញវត្ថុ | ជំនួយការលេខាធិការ។[40] |

**ខ.ភារកិច្ច**

គណៈកម្មការលទ្ធកម្ម មានភារកិច្ចទទួលបន្ទុកការងារទាំងឡាយដូចជា៖

- ធ្វើការវាយតម្លៃលើការងារដេញថ្លៃរបស់អ្នកម៉ៅការនិងអ្នកផ្គត់ផ្គង់
- ផ្តល់អនុសាសន៍លើការសម្រេចចុះកិច្ចសន្យា និង
- គណៈកម្មការលទ្ធកម្មត្រូវធានាថា៖
  - លទ្ធកម្មការងារសាងសង់ ការផ្គត់ផ្គង់សម្ភារៈនិងការផ្តល់សេវាប្រព្រឹត្តទៅប្រកបដោយ តម្លាភាព និងសន្សំសំចៃ
  - អ្នកម៉ៅការនិងអ្នកផ្គត់ផ្គង់ ត្រូវធានាឱកាសស្មើៗគ្នាក្នុងការចូលរួមប្រកួតប្រជែងផ្គត់ផ្គង់សម្ភារៈ និងផ្គត់ផ្គង់សេវាក្រោមលក្ខខណ្ឌតែមួយ
  - លទ្ធផលនៃការងារលទ្ធកម្មត្រូវប្រកាសជាសាធារណៈ។[41]

**២.២.២.៣.គណៈកម្មាធិការទទួលបន្ទុក កិច្ចនារីនិងកុមារ**

**ក.សមាសភាព**

គណកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំវិហារសួគ៌មានសមាសភាព១៨រូបដឹកនាំដោយ ប្រធាន០១រូប អនុប្រធាន០១រូប និងសមាជិកចំនួន១៦រូបផ្សេងទៀត ដែលមានរាយនាមដូចខាងក្រោម៖

---

[40] សេចក្តីសម្រេចរបស់រដ្ឋបាលឃុំវិហារសួគ៌ស្តីពី ការបង្កើតគណៈកម្មការលទ្ធកម្ម ឃុំវិហារសួគ៌,លេខ០០៦/២៣ ស.ស.រ,៣០ មករា ២០២៣,ប្រការ១

[41] យោងតាមសេចក្តីសម្រេចខាងលើ ប្រការ២

| | | | | |
|---|---|---|---|---|
| ១. លោក | ម៉េង | ឈាងហេង | ប្រធានក្រុមប្រឹក្សា | ជាប្រធាន |
| ២. លោក | ឈុន | ឈាវ | ជំទប់ទី២ | ជាអនុប្រធាន |
| ៣. លោកស្រី | ធីន | យុនអ៊ី | ជនបង្គោលគ.ក.ន.ក | ជាសមាជិកអចិន្ត្រៃយ៍ |
| ៤. លោក | ឆន | ឡាក់ឡេង | ស្មៀនឃុំ | ជាលេខាធិការ |
| ៥. លោក | ឆីយ | ស៊ីធួន | ប្រធានមណ្ឌលសុខភាពឃុំ | ជាសមាជិក |
| ៦. លោក | លី | មួយលេង | នាយរងប៉ុស្តិ៍រដ្ឋបាលឃុំ | ជាសមាជិក |
| ៧. លោក | គី | ប៊ុនហេង | នាយកអនុវិទ្យាល័យវិហារសួគ៌ | ជាសមាជិក |
| ៨. លោក | ឡុង | សុផល | នាយកបឋមសិក្សាវិហារសួគ៌ | ជាសមាជិក |
| ៩. លោក | ហោង | ហាក់ | នាយបឋមសិក្សាស្វាយមាស | ជាសមាជិក |
| ១០.លោក | រស់ | ឡេង | នាយករងបឋមសិក្សាព្រៃចាស់ | ជាសមាជិក |
| ១១.លោកស្រី | អៀ | យឿន | មេភូមិព្រៃចាស់ | ជាសមាជិក |
| ១២. លោក | យុយ | ពន់ | មេភូមិសេដា | ជាសមាជិក |
| ១៣. លោក | សាត | កាក់ | មេភូមិវិហារសួគ៌ជើង | ជាសមាជិក |
| ១៤. លោក | ស្រ៊ឹម | សុឃាន់ | មេភូមិវិហារសួគ៌ត្បូង | ជាសមាជិក |
| ១៥. លោក | ហឿន | ហៀង | មេភូមិព្រៃធំ | ជាសមាជិក |
| ១៦. លោក | អ៊ុន | អុន | មេតាកែវ២ | ជាសមាជិក |
| ១៧. លោក | ហ៊ន | ហូ | មេភូមិតាកែវ១ | ជាសមាជិក |
| ១៨. លោក | ជា | ហុន | មេភូមិស្វាយមាស | ជាសមាជិក។[42] |

**ខ.តួនាទីភារកិច្ច**

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ មានតួនាទីនិងកិច្ចការដូចជា៖

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គណៈកម្មាធិការជូនក្រុមប្រឹក្សាឃុំអនុម័ត
- ផ្តល់ទីប្រឹក្សាយោបល់ និងជួយក្រុមប្រឹក្សាឃុំ និងមេឃុំចំពោះការងារពាក់ព័ន្ធកិច្ចការនារី និងកុមារឃុំ
- អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យយល់ដឹងអំពីច្បាប់គោលនយោបាយនានារបស់រដ្ឋពាក់ព័ន្ធនឹងសិទ្ធិនារីនិងកុមារនៅឃុំ និងបំផុសចលនាសហគមន៍វិស័យសុខភាព អប់រំកិច្ចការពារ និងការអភិវឌ្ឍកុមារ ព្រមទាំងការចុះបញ្ជីអត្រានុកូលដ្ឋានជូនទារកនិងកុមារ

[42] សេចក្តីសម្រេចរបស់រដ្ឋបាលឃុំវិហារសួគ៌ស្តីពីការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំវិហារសួគ៌,លេខ០០២/២៣ ស.ស.រ,៣០ មករា ២០២៣,ប្រការ១

- ទាក់ទាញការគាំទ្រ ដើម្បីឱ្យនារីបានចូលរួមធ្វើសេចក្ដីសម្រេចលើការអភិវឌ្ឍនៅមូលដ្ឋានឃុំ
- បង្កើន និងពង្រឹងនូវការប្រាស្រ័យទាក់ទងកិច្ចសហការនិងការសម្របសម្រួលរវាងក្រុមប្រឹក្សាឃុំ និងអ្នកផ្ដល់សេវាកម្ម និងអ្នកភូមិដែលធ្វើសកម្មភាពជួយនារីនិងកុមារក្នុងឃុំរបស់ខ្លួន
- ជួយក្រុមប្រឹក្សាឃុំក្នុងការប្រមូល វិភាគព័ត៌មាន ទិន្នន័យ ពាក់ព័ន្ធនឹងបញ្ហានិងតម្រូវការរបស់នារីនិងកុមារដើម្បីដាក់បញ្ចូននៅក្នុងផែនការអភិវឌ្ឍន៍ឃុំ និងកម្មវិធីវិនិយោគឃុំ
- ចូលរួមអនុវត្ត ពិនិត្យ តាមដាន និងវាយតម្លៃផែនការសកម្មភាពឃុំពាក់ព័ន្ធស្ថានភាពនារីនិងកុមារ
- តាមដានស្ថានភាពនារីនិងកុមារក្នុងឃុំនិងធ្វើរបាយការណ៍ទៀងទាត់ជូនក្រុមប្រឹក្សា ព្រមទាំងដាក់បញ្ចូនទៅក្នុងរបាយការណ៍ឃុំ
- មេឃុំ ដែលជាប្រធានគណៈកម្មាធិការត្រូវមានការទទួលខុសត្រូវចំពោះក្រុមប្រឹក្សារបស់ខ្លួន។ មួយវិញទៀត គណៈកម្មាធិការត្រូវសម្របសម្រួលនិងសហការយ៉ាងជិតស្និទជាមួយអ្នកផ្ដល់សេវាកម្មនានាផ្នែកសង្គមកិច្ចអ្នកស្ម័គ្រចិត្តភូមិនិងសហគមន៍នៅក្នុងឃុំ ដើម្បីបំពេញតួនាទីនិងភារកិច្ចខាងលើនោះឱ្យមានប្រសិទ្ធភាពខ្ពស់។[43]

### ២.២.២.៤.គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ

#### ក.សមាសភាព

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយឃុំវិហារសួគ៌មានសមាសភាព២០រូប ដឹកនាំដោយប្រធាន០១រូប អនុប្រធាន០១រូបនិងសមាជិកចំនួន១៨រូបផ្សេងទៀត ដែលមានរាយនាមដូចខាងក្រោមៈ

| | | | | |
|---|---|---|---|---|
| ១.លោក | ម៉េង | ឈាងហេង | ប្រធានក្រុមប្រឹក្សា | ជាប្រធាន |
| ២.លោក | ហេង | ថន | ជំទប់ទី១ | ជាអនុប្រធាន |
| ៣.លោក | ឈុន | លាវ | ជំទប់ទី២ | ជាសមាជិក |
| ៤.លោក | ហុង | បញ្ញា | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៥.លោក | ម៉ៅ | ចូច | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៦.លោក | ស៊ិន | យ៉ន | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៧.លោក | ឃីម | សម្បត្តិ | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៨.លោក | ថុស | សុគន្ធ | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៩.លោក | សែម | សាយ | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |

[43] សេចក្ដីសម្រេចរបស់រដ្ឋបាលឃុំវិហារសួគ៌ស្ដីពីការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំវិហារសួគ៌,លេខ០០២/២៣ ស.ស.រ,៣០ មករា ២០២៣,ប្រការ២

| | | | |
|---|---|---|---|
| ១០.លោកស្រី ធីម | យុនអ៊ី | ជនបង្គោល គ.ក.ន.ក | ជាសមាជិក |
| ១១.លោកស្រី អៀ | យឿន | មេភូមិព្រៃចាស់ | ជាសមាជិក |
| ១២.លោក យុយ | ពន់ | មេភូមិសេដា | ជាសមាជិក |
| ១៣.លោក សាត | កាក់ | មេភូមិវិហារសួគ៌ជើង | ជាសមាជិក |
| ១៤.លោក ស្រ៊ឹម | សុខឃាន់ | មេភូមិវិហារសួគ៌ត្បូង | ជាសមាជិក |
| ១៥.លោក ហឿន | ហៀង | មេភូមិព្រៃធំ | ជាសមាជិក |
| ១៦.លោក អ៊ុន | អុន | មេភូមិតាកែវ២ | ជាសមាជិក |
| ១៧. លោក ហ៊ន | ហូ | មេភូមិតាកែវ១ | ជាសមាជិក |
| ១៨.លោក ជា | ហុន | មេភូមិស្វាយមាស | ជាសមាជិក |
| ១៩.លោកស្រីឆន | ឡាក់ទ្បេង | ស្មៀនឃុំ | ជាលេខាធិការ |
| ២០.លោក ពន់ | ផល់ | ជំនួយការហិរញ្ញវត្ថុ | ជំនួយការលេខាធិការ។[44] |

**ខ.ភារកិច្ច**

គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយមានភារកិច្ចទទួលខុសត្រូវលើការងារដូចជា[45]៖

- អនុវត្តគោលនយោបាយជាតិដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ
- ផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋពីគ្រោះមហន្តរាយជាយថាហេតុ
- ធ្វើរបាយការណ៍ជាបន្ទាន់អំពីការខូចខាតជាក់ស្តែងដល់គណៈកម្មាការគ្រប់គ្រងគ្រោះមហន្តរាយស្រុក ខេត្ត
- លើកគម្រោងប្រើប្រាស់ថវិកា សម្ភារៈ បរិក្ខា មធ្យោបាយប្រើប្រាស់និងកម្លាំងសម្រាប់ធ្វើសកម្មភាព។

**២.២.២.៥.គណៈកម្មការគ្រប់គ្រងគម្រោង**

**ក.សមាសភាព**

គណៈកម្មការគ្រប់គ្រងគម្រោងឃុំវិហាសួគ៌ មានសមាសភាពចំនួន១៩រូប ដឹកនាំដោយប្រធាន០១រូប អនុប្រធាន០១រូប និងសមាជិកចំនួន១៧រូបផ្សេងទៀត ដែលមានរាយនាមដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១.លោក | ម៉េង | ឈាងហេង | ប្រធានក្រុមប្រឹក្សាឃុំ | ជាប្រធាន |
| ២.លោក | ហេង | ថន | ជំទប់ទី១ | ជាអនុប្រធាន |
| ៣.លោក | ឈុន | លាវ | ជំទប់ទី២ | ជាសមាជិក |

[44] សេចក្តីសម្រេចរបស់រដ្ឋបាលឃុំវិហារសួគ៌ស្តីពីការបង្កើតគណៈកម្មាធិការគ្រោះមហន្តរាយ ឃុំវិហារសួគ៌,លេខ០០៣/២៣ ស.ស.រ,៣០ មករា ២០២៣,ប្រការ១

[45] យោងតាមសេចក្តីសម្រេចខាងលើ ប្រការ២

| | | | | |
|---|---|---|---|---|
| ៤.លោក | ហុង | បញ្ញា | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៥.លោក | ម៉ៅ | ចូច | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៦.លោក | ស៊ិន | យ៉ន | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៧.លោកស្រី | ឃឹម | សម្បត្តិ | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៨.លោក | ចុស | សុគន្ធ | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៩.លោក | សែម | សាយ | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ១០.លោកស្រី | ធីម | យុនអ៊ី | ជនបង្គោលគ.ក.ន.ក | ជាសមាជិក |
| ១១.លោកស្រី | អៀ | យឿន | មេភូមិព្រៃចាស់ | ជាសមាជិក |
| ១២.លោក | យុយ | ពន់ | មេភូមិសេដា | ជាសមាជិក |
| ១៣.លោក | សាត | កាក់ | មេភូមិវិហារសួគ៌ជើង | ជាសមាជិក |
| ១៤.លោក | ស្រ៊ឹម | សុខឃាន់ | មេភូមិវិហារសួគ៌ត្បូង | ជាសមាជិក |
| ១៥.លោក | ហឿន | ហៀន | មេភូមិព្រៃធំ | ជាសមាជិក |
| ១៦.លោក | អ៊ុន | អុន | មេភូមិតាកែវ២ | ជាសមាជិក |
| ១៧.លោក | ហ៊ិន | ហូ | មេភូមិតាកែវ១ | ជាសមាជិក |
| ១៨.លោក | ជា | ហុន | មេភូមិស្វាយមាស | ជាសមាជិក |
| ១៩.លោក | ឆន | ឡាក់ឡេង | ស្មៀនឃុំ | ជាលេខាធិការ។[46] |

**ខ.ភារកិច្ច**

គណៈកម្មការគ្រប់គ្រងគម្រោងមានតួនាទីនិងភារកិច្ចដូចជា៖

១).ក្នុងការរៀបចំគម្រោង៖

- ពិនិត្យ និងអនុម័តផែនការសិក្សាគម្រោង
- គ្រប់គ្រងចាត់ចែងដំណើរការសិក្សានិងរៀបចំគម្រោង
- រៀបចំដំណើរការគម្រោងដោយមានជំនួយពីអ្នកជំនួយបច្ចេកទេស
- ពិនិត្យនិងអនុម័តដំណើរគម្រោង

២).ក្នុងការអនុវត្តគម្រោង

- គ្រប់គ្រងចាត់ចែងដំណើរការអនុវត្តគម្រោង

[46]សេចក្តីសម្រេចរបស់រដ្ឋបាលឃុំវិហារសួគ៌ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងឃុំវិហារសួគ៌,លេខ០០៧/២៣ស.ស.រ,៣០មករា ២០២៣,ប្រការ១

- រៀបចំប្រជុំចាប់ផ្តើមនិងបញ្ចប់ការអនុវត្តការងារ រៀបចំប្រជុំពិនិត្យ និងអនុម័តការទូទាត់គម្រោង
- រៀបចំកិច្ចប្រជុំនានានៅក្នុងអំឡុងពេលអនុវត្តគម្រោង ដើម្បីពិនិត្យនិងវាយតម្លៃអនុវត្តគម្រោង។[47]

ក្រៅពីនេះ គណៈកម្មការគ្រប់គ្រងគម្រោងមានតួនាទីត្រូវអនុវត្តនូវរបៀបរបបធ្វើការងារដូចខាងក្រោម៖

- ប្រធានគណៈកម្មការគ្រប់គ្រងគម្រោង គឺជាអ្នកកោះប្រជុំនិងជាអធិបតីអង្គប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោង។ ក្នុងករណីប្រធានអវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរទៅអនុប្រធានជាប្រធានស្តីទី។ ប្រធានស្តីទីជាអ្នកកោះប្រជុំនិងជាអធិបតីនៃអង្គប្រជុំ
- កិច្ចប្រជុំរបស់គណៈកម្មការគម្រោងអាចធ្វើទៅបាន លុះត្រាណាតែមានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃសមាជិកគណៈកម្មការទាំងមូល
- សេចក្តីសម្រេចរបស់អង្គប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោងអាចយកជាការបាន លុះត្រាតែសម្លេងអនុម័តលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការទាំងមូល។ ប្រសិនបើសម្លេងអនុម័តមានចំនួនស្មើគ្នាសម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព
- ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងអាចអញ្ជើញបុគ្គលិកមកពីទីស្នាក់ការនានាឬតំណាងអង្គការសហគមន៍មូលដ្ឋានដែលពាក់ព័ន្ធនឹងគម្រោងដើម្បីចូលរួមកិច្ចប្រជុំគណៈកម្មការក្នុងនាមជាអ្នកសង្កេតការណ៍
- គ្រប់កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោងត្រូវមានកំណត់ហេតុដែលត្រូវរៀបចំឡើងដោយលេខាធិការរបស់គណៈកម្មការនិងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។[48]

## ២.៣.ផែនការអភិវឌ្ឍន៍ឃុំ

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ គឺជាមធ្យោបាយយ៉ាងសំខាន់របស់រដ្ឋបាលឃុំ សង្កាត់ក្នុងការកំណត់អំពីបញ្ហាប្រឈមនិងតម្រូវការជាអាទិភាពរបស់មូលដ្ឋានក៏ដូចយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនោះសំដៅឆ្លើយតបទៅនឹងតម្រូវជាអាទិភាពរបស់ប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាពនិងសិក្តសិទ្ធិភាព។

ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់មានសុពលភាពរយៈពេលប្រាំឆ្នាំ ហើយត្រូវពិនិត្យឡើងវិញជារៀងរាល់ឆ្នាំតាមរយៈការរៀបចំកម្មវិធីវិនិយោគនិងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលឃុំសង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗមានតួនាទីរៀបចំកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់របស់ខ្លួនដែលឆ្លុះបញ្ចាំងអំពីផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សានិងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ។

[47]សេចក្តីសម្រេចរបស់រដ្ឋបាលឃុំវិហារសួគ៌ស្តីពីការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងឃុំវិហារសួគ៌,លេខ០០៧/២៣ស.ស.រ,៣០មករា ២០២៣,ប្រការ២

[48]យោងតាមសេចក្តីសម្រេចខាងលើ ប្រការ៣

តើអ្វីទៅជាផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សានិងកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំ?

- ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំសម្រាប់អាណត្តិរបស់ក្រុមប្រឹក្សា គឺជាផែនការមួយដែលមានចរិតជាទស្សនៈអភិវឌ្ឍន៍រួមរបស់រដ្ឋបាលឃុំ សង្កាត់។
- រីឯកម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេលប្រាំឆ្នាំគឺជារបៀបវារៈ ឬជាកម្មវិធីជាក់ស្តែងដែលរដ្ឋបាលឃុំ សង្កាត់នីមួយៗ ចង់សម្រេចបានក្នុងអាណត្តិរបស់ខ្លួនសម្រាប់បង្ហាញអំពីគណនេយ្យភាពរបស់ខ្លួនចំពោះប្រជាពលរដ្ឋនិងចំពោះរាជរដ្ឋាភិបាល។ កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានមានសមាសភាពចំនួនបី គឺក្របខ័ណ្ឌវិនិយោគ ក្របខ័ណ្ឌផ្តល់សេវាកម្ម និងការដាក់ចេញលិខិតបទដ្ឋានគតិយុត្ត។[49]

យោងស្មារតីនៃប្រកាសអន្តរក្រសួងលេខ២៤២៣ប្រក ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់និងកម្មវិធីវិនិយោគឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់មានកាតព្វកិច្ចក្នុងការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ក្នុងឆ្នាំទីមួយនៃអាណត្តិរបស់ខ្លួន។ ហេតុនេះ បន្ទាប់ពីការប្រកាសចូលកាន់តំណែងមេឃុំ ចៅសង្កាត់ដោយមានស្មៀនឃុំ សង្កាត់ជាសេនាធិការត្រូវចាត់ចែងរៀបចំប្រតិទិនសម្រាប់ការងារនេះឱ្យបានឆាប់ដើម្បីគណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ សង្កាត់ (គ.ផ.ថ) ដំណើរការនីតិវិធីនៃការរៀបចំផែនការអភិវឌ្ឍន៍ដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបានទាន់ពេលវេលាកំណត់។

### ២.៣.១.ដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ឃុំ

ក្រុមប្រឹក្សាឃុំវិហារសួគ៌អាណត្តិទី៥នេះបានរៀបចំផែនការអភិវឌ្ឍន៍៥ឆ្នាំ(២០២៣-២០២៧)ដោយយោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងប្រកាសអន្តរក្រសួងលេខ២៤២៣ ប្រក ចុះថ្ងៃទី៣ ខែកក្កដាឆ្នាំ២០១៧ស្តីពីការកសាងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល។ ផែនការអភិវឌ្ឍន៍ឃុំវិហារសួគ៌នេះត្រូវបានរៀបចំឡើងក្នុងគោលបំណងកំណត់នូវចក្ខុវិស័យ គោលដៅ គោលបំណង សូចនាករជាក់លាក់ និងយុទ្ធសាស្ត្រដែលជាមូលដ្ឋានដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋនិងដើម្បីកាត់បន្ថយនូវភាពក្រីក្ររបស់ប្រជាពលរដ្ឋក្នុងឃុំ ហើយផែនការអភិវឌ្ឍន៍នេះផងដែរ ធ្វើឡើងទុកជាឯកសារយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៍មូលដ្ឋាននិងសម្រាប់ជាមូលដ្ឋានក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលនិងរៀបចំគម្រោងថវិកាប្រចាំឆ្នាំផងដែរ។ហេតុនេះដើម្បីអាចយកផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំនេះទៅប្រើប្រាស់បានស្របតាមគតិច្បាប់រដ្ឋបាលឃុំវិហារសួគ៌បានធ្វើការរៀបចំនិងកសាងផែនការអភិវឌ្ឍន៍ឃុំ ជារួមមាន៣ជំហាន ដោយក្នុងនោះរួមមានៈ

**ជំហានទី១ ការវិភាគស្ថានភាព និងការកំណត់តម្រូវការអភិវឌ្ឍន៍ឃុំ**

[49] សាលាជាតិរដ្ឋបាលមូលដ្ឋាន,*ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់* (២០២២)

ដើម្បីកំណត់បាននូវ បញ្ហា តម្រូវការ និងដំណោះស្រាយជាអាទិភាពរបស់ប្រជាពលរដ្ឋនៅក្នុងឃុំវិហារសួគ៌សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់ក្រុមប្រឹក្សាឃុំ ក្នុងជំហាននេះ៖

គណៈកម្មាធិការកសាងផែនការ និងថវិកាដែលមានលោក ម៉េង ឈាងហេង ជាប្រធាននឹងបើកកិច្ចប្រជុំនៅសាលាឃុំដើម្បីធ្វើការវិភាគទិន្នន័យភូមិ ទិន្នន័យឃុំ ឯកសារព័ត៌មានស្ថានភាពឃុំ ដើម្បីកំណត់អំពីបញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយ រួចស្រង់ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយទាំងនោះដាក់ចូលក្នុងតារាង បញ្ហា តម្រូវការនិងដំណោះស្រាយ។ បន្ទាប់មកទៀត តំណាងគណៈកម្មាធិការកសាងផែនការនិងថវិកាមកពីភូមិនីមួយៗនឹងស្រង់បញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយ ដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួនយកទៅប្រជុំពិភាក្សាជាមួយនឹងប្រជាពលរដ្ឋនៅតាមភូមិនីមួយៗនោះ ដើម្បីធ្វើសុពលភាពដោយប្រើប្រាស់ឧបករណ៍វិភាគផ្សេងៗ។ បន្ទាប់ពីប្រជុំនៅតាមភូមិរួចមក គណៈកម្មាធិការកសាងផែនការ និងថវិកាធ្វើកិច្ចប្រជុំម្តងទៀត ដើម្បីធ្វើការបូកសរុបបញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយដែលបានមកពីបណ្តាភូមិនានា និងពិភាក្សាកំណត់សេចក្តីត្រូវការអភិវឌ្ឍន៍ គោលដៅអភិវឌ្ឍន៍ យុទ្ធសាស្ត្រអភិវឌ្ឍន៍ សកម្មភាពជាអាទិភាព ទំហំគម្រោង ទីតាំងគម្រោង និងតម្លៃប៉ាន់ស្មានគម្រោងជាដើម។

**ជំហានទី២ ការរៀបចំ និងការចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ**

ក្នុងជំហាននេះគណៈកម្មាធិការកសាងផែនការនិងថវិកានឹងធ្វើការចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ។ បន្ទាប់ពីបានរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំរួចរាល់ហើយ កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំត្រូវបានរៀបចំឡើងដើម្បីឱ្យប្រជាពលរដ្ឋនៅក្នុងឃុំនិងអ្នកពាក់ព័ន្ធនានាចូលរួមផ្តល់ជាមតិយោបល់ទៅលើសេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍន៍និងថវិកាដើម្បីធ្វើការរៀបចំឬធ្វើការកែលម្អនូវសេចក្តីព្រាងមួយនេះឱ្យកាន់តែល្អប្រសើរឡើង។បន្ទាប់ពីរៀបចំសេចក្តីព្រាងរួចរាល់ហើយ ក្រុមការងារនឹងដាក់សេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំនោះជូនលោកមេឃុំពិនិត្យនិងផ្តល់យោបល់។

**ជំហានទី៣ ការពិនិត្យ ការអនុម័ត និងការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ឃុំ**

បន្ទាប់ពីការពិនិត្យ ផ្តល់យោបល់និងការកែសម្រួលតាមមតិលោកមេឃុំរួច ក្រុមការងារនឹងធ្វើដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័តតាមរយៈការបើកកិច្ចប្រជុំមួយស្តីពីកិច្ចប្រជុំពិនិត្យនិងពិភាក្សាសេចក្តីព្រាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣ដែលប្រព្រឹត្តទៅនៅសាលាឃុំវិហារសួគ៌ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យនិងអនុម័ត។ ក្រោយការបង្ហាញសេចក្តីព្រាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ ក្រុមប្រឹក្សាបានពិនិត្យ ពិភាក្សា ដោយផ្តោតលើពាក្យនៃឃ្លាប្រយោគរបស់គម្រោងតាមផ្នែកនៃវិស័យនីមួយៗយ៉ាងល្អិតល្អន់និងហ្មត់ចត់ហើយ លោកលោកស្រីសមាជិកនៃអង្គប្រជុំជាក្រុមប្រឹក្សាឃុំ បានធ្វើការអនុម័តដោយ០៩លើ០៩សម្លេងគាំទ្រផែនការអភិវឌ្ឍន៍

រយៈពេល៥ឆ្នាំរបស់ឃុំវិហារសួគ៌។[50] បន្ទាប់ពីអនុម័តផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ(២០២៣-២០២៧) រួចរាល់ លោកមេឃុំវិហារសួគ៌បានរៀបចំចាត់ចែងបញ្ជូនសៀវភៅផែនការអភិវឌ្ឍន៍ដែលបានអនុម័តរួចនោះទៅរដ្ឋបាលខេត្តកណ្ដាលដើម្បីដាក់ជូនអភិបាលខេត្តកណ្ដាល ពិនិត្យនិងផ្ដល់អនុលោមភាព។

បន្ទាប់ពីទទួលបានសៀវភៅផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ(២០២៣-២០២៧)របស់រដ្ឋបាលឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល រដ្ឋបាលខេត្តដោយមានទីចាត់ការផែនការនិងវិនិយោគខេត្ត ជាសេនាធិការបានធ្វើការពិនិត្យយ៉ាងយកចិត្តទុកដាក់ទៅលើខ្លឹមសារទាំងមូល និងបានធ្វើការវាយតម្លៃថាការរៀបចំមានលក្ខណៈសមស្របតាមច្បាប់ បទបញ្ញត្តិ លិខិតបទដ្ឋានគតិយុត្តនានា និងមានសង្គតិភាពជាមួយគោលនយោបាយថ្នាក់ជាតិ ថ្នាក់ខេត្ត និងសេចក្ដីណែនាំនានាដែលមានជាធរមាន។

ឆ្លងតាមរយៈការត្រួតពិនិត្យយ៉ាងហ្មត់ចត់រួចមក រដ្ឋបាលខេត្តបានសម្រេចផ្ដល់អនុលោមភាពលើសេចក្ដីព្រាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ(២០២៣-២០២៧) របស់រដ្ឋបាលឃុំវិហារសួគ៌ ដើម្បីយកទៅប្រើប្រាស់ជាផ្លូវការចាប់ពីថ្ងៃទី ២១ខែ មេសា ឆ្នាំ ២០២៣។[51] បន្ទាប់ពីអភិបាលខេត្តបានផ្ដល់អនុលោមភាពរួច លោកមេឃុំ បានរៀបចំបោះពុម្ពសៀវភៅផែនការអភិវឌ្ឍន៍ដែលបានអនុម័តនោះផ្សព្វផ្សាយជាសាធារណៈ។

### ២.៣.២.ការតាមដានត្រួតពិនិត្យ និង វាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំ

ក្រុមប្រឹក្សាឃុំវិហារសួគ៌បានរៀបចំយន្តការសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍នេះដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធនានា ដោយក្នុងនោះ៖

- ក្រុមប្រឹក្សាឃុំវិហារសួគ៌ ត្រូវរៀបចំរបាយការណ៍ស្ដីពីលទ្ធផលនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ និងរាយការណ៍ជូនអង្គប្រជុំក្រុមប្រឹក្សាឃុំវិហារសួគ៌អំពីវឌ្ឍភាពនៃការអនុវត្តផែនការនេះតាមការកំណត់
- ក្រុមប្រឹក្សាឃុំវិហារសួគ៌ ត្រូវរៀបចំនិងដាក់ជូនក្រុមប្រឹក្សាឃុំនិងអ្នកពាក់ព័ន្ធអំពីរបាយការណ៍ប្រចាំឆ្នាំស្ដីពីការអនុវត្តផែនការអភិវឌ្ឍន៍នេះ
- ក្រុមប្រឹក្សាឃុំវិហារសួគ៌ត្រូវធ្វើការវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍នៅពាក់កណ្ដាលអាណត្តិ និងចុងអាណត្តិរបស់ក្រុមប្រឹក្សាឃុំវិហារសួគ៌អំពីលទ្ធផលសម្រេចបានធៀបនឹងគោលដៅគោលបំណងដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍ឃុំ។[52]

---

[50] កំណត់ហេតុស្ដីពីកិច្ចប្រជុំពិនិត្យ និងពិភាក្សាសេចក្ដីព្រាងសៀវភៅផែនការអភិវឌ្ឍន៍ប្រាំឆ្នាំរបស់រដ្ឋបាលឃុំវិហារសួគ៌ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣

[51] សេចក្ដីជូនដំណឹងរបស់រដ្ឋបាលខេត្តកណ្ដាល,លេខ៥៨៥ សជណ,២១ មេសា ២០២៣

[52] សេចក្ដីសម្រេចរបស់រដ្ឋបាលឃុំវិហារសួគ៌ស្ដីពីការដាក់ឱ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ឃុំវិហារសួគ៌,លេខ០០៤/២៣ ស.ស.វ,៣០ មករា ២០២៣,ប្រការ៣,៤

## ២.៤.កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ គឺជាការធ្វើឱ្យខ្លឹមសារនៃផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ទៅជាគម្រោងសកម្មភាពឬសេវាកម្មជាក់ស្តែងដោយមានភ្ជាប់នូវចំណាយមូលនិធិ សំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍន៍សម្រាប់រយៈពេលបីឆ្នាំ។ កម្មវិធីវិនិយោគនេះត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

### ២.៤.១.ដំណើរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

ក្រុមប្រឹក្សាឃុំ បានរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៣-២០២៥) នេះឡើងដើម្បីប្រមូលផ្តុំនូវសេចក្តីត្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងឃុំនិងធ្វើការកៀរគរធនធាននានាដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការជាអាទិភាពទាំងនេះដែលចូលរួមចំណែកដោយផ្ទាល់ដល់ជីវភាពរស់នៅនិងសុខភាពរបស់ប្រជាពលរដ្ឋ។ កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំនេះ ត្រូវបានរៀបចំឡើងបន្ទាប់ពីមានការប្រជុំប្រមូលតម្រូវការអាទិភាពដោយមានការចូលរួមពីគ.ផ.ថ ជនបង្គោលនានា តំណាងការិយាល័យជំនាញ និងអ្នកពាក់ព័ន្ធនានា ដើម្បីចូលរួមពិនិត្យនិងវិភាគស្ថានភាពទូទៅក្នុងឃុំ។ នៅក្នុងដំណើរការនេះ ក្រុមការងាររៀបចំកម្មវិធីអភិវឌ្ឍន៍ឃុំបានប្រើប្រាស់ឯកសារគោលមួយចំនួនដូចជា៖ ឯកសារគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា, តារាងក្របខណ្ឌអភិវឌ្ឍន៍ប្រចាំឆ្នាំរបស់រដ្ឋបាលស្រុក-ខេត្ត, តារាងបញ្ហា តម្រូវការ និងដំណោះស្រាយកាលពីឆ្នាំកន្លងទៅ, សៀវភៅស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ចឃុំ, ផែនទីរដ្ឋបាលឃុំនិងផែនទីសេវាសង្គមឃុំនិងឯកសារពាក់ព័ន្ធមួយចំនួនទៀត។ ក្នុងនោះដើម្បីធ្វើការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំជារួមមាន៣ជំហានគឺ៖

**ជំហានទី១ ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល**

ជាដំបូង បន្ទាប់ពីចូលរួមប្រជុំណែនាំអំពីការប្រមូលតម្រូវការអាទិភាពនៅថ្នាក់ស្រុករួច លោកមេឃុំបានណែនាំគណៈកម្មាធិការកសាងផែនការនិងថវិកាឱ្យចាប់ផ្តើមដំណើរការរៀបចំតម្រូវការសម្រាប់អភិវឌ្ឍន៍មូលដ្ឋានឃុំ ដោយក្នុងជំហាននេះ គណៈកម្មាធិការកសាងផែនការនិងថវិកាបានរៀបចំប្រជុំនៅសាលាឃុំ ដើម្បីពិនិត្យនិងវិភាគអំពីស្ថានភាពទូទៅរបស់ឃុំដោយប្រើប្រាស់ព័ត៌មាននានាពាក់ព័ន្ធផែនការអភិវឌ្ឍន៍ឃុំ គម្រោងវិនិយោគបីឆ្នាំរំកិលដែលមិនទាន់មានថវិកាគាំទ្រជាដើមសំដៅកំណត់បញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយ។ បន្ទាប់មកមេភូមិនីមួយៗនឹងធ្វើការស្រង់បញ្ហា ទីតាំងនៃបញ្ហា មូលហេតុនៃបញ្ហា តម្រូវការ និងដំណោះស្រាយដែលពាក់ព័ន្ធនឹងភូមិរបស់ខ្លួនយកទៅបង្ហាញ និងធ្វើការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋរួចបញ្ជូនលទ្ធផលមកក្រុមការងារ“គ.ផ.ថ”។ ក្រោយពីប្រជុំតាមភូមិរួច គណៈកម្មាធិការកសាងផែនការ និងថវិកាប្រជុំបូកសរុបដើម្បីផ្ទៀងផ្ទាត់និងកែសម្រួលតារាងបញ្ហា តម្រូវការ និងដំណោះស្រាយ រួចបម្លែងបញ្ហា តម្រូវការ និងដំណោះស្រាយទាំងនោះទៅជាគម្រោងវិនិយោគ។

**ជំហានទី២ ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ**

បន្ទាប់ពីបានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយនៅថ្នាក់ស្រុក ក្រុមការងារគណៈកម្មាធិការកសាងផែនការនិងថវិកានឹងធ្វើការពិនិត្យមើលនិងផ្ទៀងផ្ទាត់ឡើងវិញនូវតម្រូវការគម្រោងសកម្មភាពអាទិភាពរបស់ឃុំមួយណាចាំបាច់និងមួយណាមិនចាំបាច់និងស្វែងរកមូលនិធិគាំទ្រដោយរៀបជាបញ្ជី រួចបញ្ជូនទៅរដ្ឋបាលស្រុកដើម្បីពិនិត្យនិងបូកសរុប និងផ្ញើទៅកាន់មន្ទីរផែនការខេត្តដើម្បីរៀបចំឯកសារព័ត៌មានសម្រាប់ចូលរួមក្នុងការធ្វើវេទិកាពិគ្រោះយោបល់ស្តីពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលថ្នាក់ស្រុក។ បន្ទាប់ពីនេះទៀត មេឃុំនឹងចាត់អ្នកតំណាងឃុំឱ្យទៅចូលរួមសិក្ខាសាលាសមាហរណកម្មនៅថ្នាក់ស្រុក ដោយស្រាយបំភ្លឺខ្លឹមសារអំពីតម្រូវការគម្រោងសកម្មភាពជាអាទិភាពដើម្បីសុំការគាំទ្រថវិកានិងបច្ចេកទេសក្នុងការអនុវត្ត។ ក្រោយពីសិក្ខាសាលាហើយ ក្នុងករណីបញ្ជីគម្រោងវិនិយោគត្រូវកែសម្រួល បន្ទាប់ពីកែរួចមេភូមិនីមួយៗនឹងស្រង់យកឈ្មោះគម្រោង និងសកម្មភាពដែលសិត្ថនៅតាមភូមិរៀងៗខ្លួនយកទៅបង្ហាញនិងពិគ្រោះយោបល់ និងស្រង់មតិយោបល់ពីប្រជាពលរដ្ឋក្នុងភូមិរបស់ខ្លួន រួចបញ្ជូនយោបល់ទាំងនោះមកឃុំវិញពិនិត្យនិងបូកសរុប។ ក្រៅពីនេះ ក្រុមការងារនឹងធ្វើការរៀបចំចងក្រងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំដោយផ្អែកតាមមាតិកានៃសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ។

**ជំហានទី៣ ការពិនិត្យ ការអនុម័ត និងការផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ**

បន្ទាប់ពីទទួលបានសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ ក្រុមប្រឹក្សាឃុំវិហារសួគ៌បានរៀបចំបើកកិច្ចប្រជុំស្តីពីការអនុម័តសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣ នៅសាលាឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ដើម្បីប្រជុំពិនិត្យពិភាក្សានិងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៣-២០២៥) របស់ឃុំវិហារសួគ៌ក្រោមអធិបតីភាពលោក ម៉េង ឈាងហេង ប្រធានក្រុមប្រឹក្សាឃុំនិងជាប្រធានគណៈកម្មការឃុំវិហារសួគ៌។បន្ទាប់ពីបានពិនិត្យនិងពិភាក្សាយ៉ាងល្អិតល្អន់រួច មកអង្គប្រជុំបានអនុម័តយល់ព្រមដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៣-២០២៥) ដោយ០៩លើ០៩សម្លេងគាំទ្រ។[53]បន្ទាប់ពីបានអនុម័តរួចរាល់ហើយនោះ សៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលនឹងតម្កល់ទុកនៅសាលាឃុំ សាលាស្រុក និងផ្ញើជូនទៅទីចាត់ការផែនការនិងវិនិយោគខេត្ត មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត និងជូនទៅអ្នកពាក់ព័ន្ធនានាក្នុងករណីចាំបាច់។

**២.៤.២.ការតាមដានត្រួតពិនិត្យ និងវាយតម្លៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ**

កម្មវិធីវិនិយោគប្រចាំឆ្នាំរបស់ឃុំ គឺជាការអនុវត្តផែនការមួយផ្នែករបស់ផែនការអភិវឌ្ឍន៍ឃុំរយៈពេលប្រាំឆ្នាំក្នុងអាណត្តិរបស់ក្រុមប្រឹក្សាឃុំ។ រីឯការតាមដានត្រួតពិនិត្យ និង វាយតម្លៃនៃការអនុវត្តកម្មវិធីវិនិយោគប្រចាំឆ្នាំរបស់ឃុំ ក៏ជាផ្នែកមួយនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃនៃការអនុវត្តផែនការអភិវឌ្ឍន៍ឃុំផងដែរ។ ក្រុម

[53] កំណត់ហេតុកិច្ចប្រជុំស្តីពីការអនុម័តសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរបស់រដ្ឋបាលឃុំវិហារសួគ៌ថ្ងៃទី២៧ ខែមករា ឆ្នាំ២០២៣

ប្រឹក្សាឃុំដែលមានជនបង្គោលតាមដានត្រួតពិនិត្យនិងវាយតម្លៃឃុំជាជំនួយ និងជាអ្នកទទួលខុសត្រូវការអនុវត្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃនេះជាប្រចាំ ហើយត្រូវឱ្យប្រាកដថាការតាមដានត្រួតពិនិត្យត្រូវធ្វើនៅកន្លែងអនុវត្តគម្រោង(ការដ្ឋាន) ឬទីកន្លែងអនុវត្តជាក់ស្តែង។ ម៉្យាងវិញទៀត ជនបង្គោលត្រួតពិនិត្យនិងវាយតម្លៃឃុំត្រូវទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាពដោយខ្លួនឯង សម្រាប់ចុះត្រួតពិនិត្យជាប្រចាំដូចជាពេលចាប់ផ្តើម ពេលកំពុងអនុវត្ត ពេលបាន៥០% ពេលអនុវត្តគម្រោងហើយ១០០% និងពេលបញ្ចប់កិច្ចសន្យាក្នុងពេលធានា៦ខែទៀតផងដែរ ដើម្បីឱ្យប្រាកដថាអ្នកទទួលការពិតជាអនុវត្តតាមស្តង់ដារបច្ចេកទេសនិងគំរូប្លង់ដែលបានចុះកិច្ចសន្យាលើការអនុវត្តគម្រោងវិនិយោគប្រចាំឆ្នាំគ្រប់ឆ្នាំទាំងអស់និងប្រមូលនូវរាល់ទិន្នន័យ របាយការណ៍ និងឯកសារព័ត៌មានដែលទាក់ទងទៅនឹងការអនុវត្តកម្មវិធីវិនិយោគឃុំ។ លើសពីនេះទៅទៀតនោះ ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំត្រូវរៀបចំរបាយការណ៍ស្តីពីការតាមដានត្រួតពិនិត្យរួមទាំងយោបល់ផ្សេងៗជម្រាបជូនលោកមេឃុំហើយដាក់ជូនក្រុមប្រឹក្សាដើម្បីពិនិត្យ ពិចារណានិងពិភាក្សាក្នុងកិច្ចប្រជុំប្រចាំខែរបស់ឃុំ។

ចំណែកការវាយតម្លៃ ក្រុមប្រឹក្សាឃុំនឹងបង្កើតគណៈកម្មការមួយដើម្បីវាយតម្លៃការអនុវត្តគម្រោងវិនិយោគប្រចាំឆ្នាំដែលមាននៅក្នុងកម្មវិធីវិនិយោគ និង គុណភាពនៃលទ្ធផលរបស់អ្នកទទួលការ ជូនទៅគណៈកម្មាធិការប្រតិបត្តិខេត្ត ដើម្បីជំនួយដល់គណៈកម្មាធិការបុរេលក្ខណៈសម្បត្តិខេត្ត ក្នុងការជ្រើសរើសអ្នកទទួលការក្នុងឆ្នាំក្រោយបន្តទៀត។ គណៈកម្មការនេះដឹកនាំដោយមេឃុំនិងមានសមាសភាពមកពីក្រុមប្រឹក្សាឃុំ ជនបង្គោលតាមដានត្រួតពិនិត្យនិងវាយតម្លៃឃុំ ជនបង្គោលរបស់ឃុំ តំណាងអ្នកទទួលផល និងអ្នកពាក់ព័ន្ធនានាទៀត ។ ចំពោះគណៈកម្មការនេះអាចជ្រើសរើសគម្រោងមួយចំនួន ដើម្បីវាយតម្លៃអាស្រ័យទៅលើចំនួន ប្រភេទ ពេលវេលា និងធនធានដែលឃុំមាន។ រីឯនីតិវិធីលម្អិតតាមដានត្រួតពិនិត្យ និងវាយតម្លៃត្រូវអនុវត្តទៅតាមសៀវភៅណែនាំស្តីពីការតាមដានត្រួតពិនិត្យនិងវាយតម្លៃលើការអភិវឌ្ឍន៍មូលដ្ឋាន។មិនត្រឹមតែប៉ុណ្ណោះការវាយតម្លៃគម្រោងក្នុងពេលកំពុងអនុវត្តគម្រោងអាចផ្តល់ព័ត៌មាន និងគំនិតកែលម្អការអនុវត្ត និងធ្វើវិសោធនកម្មគម្រោងទៀតផង។ រីឯការវាយតម្លៃនៅពេលបញ្ចប់គម្រោងអាចផ្តល់ជាមេរៀន បទពិសោធន៍ ដល់ការរៀបចំ និង កសាងកម្មវិធីវិនិយោគរបស់ឃុំសម្រាប់ឆ្នាំបន្តបន្ទាប់ទៀត ជាមួយគ្នានេះក្រុមប្រឹក្សាឃុំត្រូវត្រួតពិនិត្យនិងអនុម័តរបាយការណ៍តាមដានត្រួតពិនិត្យនេះ រួចហើយផ្សព្វផ្សាយរបាយការណ៍នេះជាសាធារណៈនៅក្នុងមូលដ្ឋានរបស់ខ្លួននិងដល់គ្រប់អ្នកពាក់ព័ន្ធឱ្យបានជ្រាប។[54]

### ២.៤.៣.គម្រោង សកម្មភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ

នៅក្នុងអាណត្តិទី៥នេះ ឃុំមានគម្រោង សកម្មភាពជាច្រើនដែលក្នុងនោះរួមមាន គម្រោងសកម្មភាពឃុំកំពុងដំណើរការ គម្រោងសកម្មភាពវិនិយោគឃុំដែលមានថវិកាគាំទ្រ និង គម្រោងសកម្មភាពអាទិភាពរបស់ឃុំ

[54] គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំវិហារសួគ៌, កម្មវិធីវិនិយោគឆ្នាំ២០១៩

ដែលមិនទាន់មានថវិកាគាំទ្រ។ តាមរយៈតារាង ការសង្ខេបប្រភពមូលនិធិឆ្នាំ២០២៣ឃុំមានគម្រោង សកម្មភាព ទាំងអស់សរុបចំនួន៥គម្រោង សកម្មភាព ដែលមានតម្លៃសរុបចំនួន៣០៣,៥២០,០០០រៀលដោយទុនទាំងនេះ បានមកពីការគាំទ្ររបស់មន្ទីរអប់រំនិងមូលនិធិរបស់រដ្ឋបាលឃុំផ្ទាល់។[55]

### ២.៤.៣.១.គម្រោង សកម្មភាពវិនិយោគឃុំដែលមានថវិកាគាំទ្រ

នៅក្នុងគម្រោងសកម្មភាពវិនិយោគឃុំដែលមានថវិកាគាំទ្រនេះត្រូវបានគេបែងចែកជាពីររួមមាន គម្រោង សកម្មភាពប្រើប្រាស់មូលនិធិឃុំនិង គម្រោងសកម្មភាពដែលទទួលបានការសន្យាគាំទ្រមូលនិធិពីអ្នកពាក់ព័ន្ធ។

**១.គម្រោង សកម្មភាពប្រើប្រាស់មូលនិធិឃុំ**

ក្នុងគម្រោងនេះ យើងអាចធ្វើការបែកចែកជា៤ផ្នែក ដោយរួមមាន ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែក ធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងផ្នែករដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់ សាធារណៈ។

- ផ្នែកសេដ្ឋកិច្ច ៖ក្នុងផ្នែកនេះមានគម្រោង សកម្មភាពតូចៗជាច្រើនដូចជា
  - ឆ្នាំ២០២៣ ជួសជុលផ្លូវបេតុងអាមេដែលមានទីតាំងសិត្ថនៅភូមិព្រៃធំនិងភូមិតាកែវ១ ប្រវែង១៥០០ម
  - ឆ្នាំ២០២៤ ជួសជុលផ្លូវបេតុងអាមេដែលមានទីតាំងសិត្ថនៅភូមិវិហារសួគ៌ត្បូង ប្រវែង ១៥០០ម
  - ឆ្នាំ២០២៥ ជួសជុលផ្លូវបេតុងអាមេដែលមានទីតាំងសិត្ថនៅភូមិសេដានិងភូមិព្រៃចាស់ ប្រវែង១៥០០ម ។
- ផ្នែកសង្គមកិច្ច ៖ ក្នុងផ្នែកនេះមានគម្រោង សកម្មភាពមួយចំនួនដូចជា គាំទ្រការធ្វើដំណើរសម្រាប់ ស្ត្រីក្រីក្រសម្រាលកូននៅមន្ទីរពេទ្យ និងធ្វើការលើកកម្ពស់បញ្ហាសុខភាពនិងអនាម័យ។
- ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ៖ ក្នុងផ្នែកនេះគឺមាននូវ គម្រោង សកម្មភាពមួយចំនួនដូចជាផ្សព្វផ្សាយច្បាប់បរិស្ថាន និងសេវាកម្មសំរាម ផ្សព្វផ្សាយពីច្បាប់ ជលផលនិងវិធានការទប់ស្កាត់បទល្មើសនេសាទ និងធ្វើការផ្សព្វផ្សាយនិងទប់ស្កាត់ការរំលោភយក ដីសាធារណៈ។
- ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ៖ក្នុងផ្នែកនេះមានគម្រោងសកម្មភាពមួយគឺធ្វើ ការផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព។

[55] គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំវិហារសួគ៌, កម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៣-២០២៥)

**២.គម្រោង សកម្មភាពដែលទទួលបានការសន្យាគាំទ្រមូលនិធិពីអ្នកពាក់ព័ន្ធ**

រដ្ឋបាលឃុំវិហារសួគ៌ បានទទួលការគាំទ្រពីបណ្ដាលមន្ទីរអង្គភាពនានានូវគម្រោង សកម្មភាពជាច្រើន ដែលក្នុងនោះរួមមាន៖

- មន្ទីរអប់រំ ៖ រដ្ឋបាលឃុំវិហារសួគ៌បានទទួលការគាំទ្រពីមន្ទីរអប់រំដូចជា អាហារូបករណ៍សម្រាប់សិស្សក្រីក្ររៀនពូកែថ្នាក់បឋមសិក្សា (បឋមព្រៃចាស់,បឋមស្វាយមាស,និង បឋមវិហារសួគ៌) និង អាហារូបករណ៍សម្រាប់សិស្សក្រីក្ររៀនពូកែថ្នាក់មធ្យមសិក្សាបឋមភូមិ(អនុវិទ្យាល័យវិហារសួគ៌)។
- មន្ទីរសុខាភិបាល៖ រដ្ឋបាលឃុំវិហារសួគ៌បានទទួលការគាំទ្រពីមន្ទីរសុខាភិបាលដូចជា សកម្មភាពបង្ការ ថែទាំនិងព្យាបាលអេដស៍ យុទ្ធនាការដាក់ថ្នាំបាណកឃាដអាបេត/ប៊ីធីអាយ កម្មវិធីពន្យាកំណើត សេវាសុខភាពស្ត្រីមានផ្ទៃពោះ ផ្ដល់វ៉ាក់សាំងការពារជំងឺ១២មុខដល់កុមារអាយុក្រោម១ឆ្នាំនិងថ្នាំបង្ការជំងឺតេតាណូសដល់ស្ត្រីមានផ្ទៃពោះនិងស្ត្រីសម្រាលកូន សកម្មភាពស្រាវជ្រាវនិងទប់ស្កាត់ការឆ្លងជំងឺរបេង ផ្ដល់សេវាសម្រាលកូនដោយបុគ្គលិកសុខាភិបាលបានបណ្ដុះបណ្ដាលនៅមូលដ្ឋានសុខាភិបាល(RH,HC) អប់រំផ្សព្វផ្សាយបន្ទុកជំងឺមិនឆ្លង(ជំងឺទឹកនោមផ្អែម មហារីកមាត់ស្បូន សុខភាពភ្នែក) ផ្ដល់សេវាមិនយកកម្រៃដល់ប្រជាពលរដ្ឋក្រីក្រតាមរយៈមូលនិធិសមធម៌សេវាសុខាភិបាលនិងផ្ដល់ការចាក់វ៉ាក់សាំងកូវីដ-១៩ដូសជម្រុញដល់ប្រជាពលរដ្ឋ-កុមារដែលមានដូសមូលដ្ឋាន។

**២.៤.៣.២.គម្រោង សកម្មភាពអាទិភាពឃុំដែលមិនទាន់មានថវិកាគាំទ្រ**

ក្នុងគម្រោងនេះយើងអាចធ្វើការបែកចែកជា៤ផ្នែក ដោយរួមមាន ផ្នែកសេដ្ឋកិច្ច ផ្នែកសង្គមកិច្ច ផ្នែកធនធានធម្មជាតិ បរិស្ថាននិងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងផ្នែករដ្ឋបាលនិងសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ។

- ផ្នែកសេដ្ឋកិច្ច៖ក្នុងផ្នែកនេះមានគម្រោងសកម្មភាពមួយចំនួនដូចជាការធ្វើប្រព័ន្ធលូរំដោះទឹកចេញពីភូមិ បង្កើតក្រុមកសិករអាជីវកម្មបន្លែGAPថ្មី និងកិច្ចសន្យាជួលបង្កើត១០ក្រុម កសិករថ្មីអាជីវកម្មចិញ្ចឹមមាន់។
- ផ្នែកសង្គមកិច្ច ៖ក្នុងផ្នែកនេះមានគម្រោង សកម្មភាពដូចជា ធ្វើការផ្សព្វផ្សាយនិងគាំទ្រសមាគមន៍មនុស្សចាស់ ធ្វើការផ្សព្វផ្សាយច្បាប់អំពើហិង្សាក្នុងគ្រួសារ ធ្វើការផ្សព្វផ្សាយច្បាប់ជួញដូរ និងការកេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារ និងប្រារព្ធពិធីនារីអន្តរជាតិ ៨ មីនា។
- ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ៖ ក្នុងផ្នែកនេះគឺមាននូវគម្រោងសកម្មភាពដូចជា ធ្វើការផ្សព្វផ្សាយច្បាប់បរិស្ថាន និងសេវាកម្មសំរាម ផ្សព្វផ្សាយពីច្បាប់

ជលផលនិង វិធានការទប់ស្កាត់បទល្មើសនេសាទ និងធ្វើការផ្សព្វផ្សាយនិងទប់ស្កាត់ការរំលោភយកដីសាធារណៈ។

- ផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ៖ ក្នុងផ្នែកនេះមានគម្រោង សកម្មភាពដូចជា ពង្រឹង និងចលនាកម្លាំងប្រជាការពារ ធ្វើការផ្សព្វផ្សាយគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព រៀបចំវេទិការនគរបាលជួបជាមួយសហគមន៍ និងធ្វើការផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោក។[56]

## ២.៥.ការផ្តល់សេវារដ្ឋបាល

ដើម្បីធានាបាននូវគុណភាព តម្លាភាព គណនេយ្យភាព សមធម៌ និងបរិយាបន្នក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋ ក្នុងនោះរដ្ឋបាលឃុំវិហារសួគ៌បានធ្វើការផ្តល់សេវារដ្ឋបាលតាមរយៈយន្តការច្រកចេញចូលតែមួយនៅក្នុងឆ្នាំ២០២២[57] ហើយរដ្ឋបាលឃុំវិហារសួគ៌មានផ្តល់ជូននូវប្រភេទសេវារដ្ឋបាលដូចខាងក្រោម៖

### ២.៥.១.ការចេញអត្រានុកូលដ្ឋាន

សេវាអត្រានុកូលដ្ឋានដែលផ្តល់ដោយរដ្ឋបាលឃុំរួមមាន៖

- សំបុត្រកំណើត (ក្នុងរយៈពេល៣០ថ្ងៃ ក្រោយថ្ងៃកើត)
- សំបុត្របញ្ជាក់កំណើត
- សេចក្តីចម្លងសំបុត្រកំណើត ឬបញ្ជាក់កំណើត
- ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍
- សំបុត្រអាពាហ៍ពិពាហ៍(ពលរដ្ឋខ្មែរ ជាមួយពលរដ្ឋខ្មែរ)
- សំបុត្រអាពាហ៍ពិពាហ៍(ជនបរទេស ជាមួយពលរដ្ឋខ្មែរ)
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍
- សំបុត្រមរណភាព
- សេចក្តីចម្លងសំបុត្រមរណភាព។

### ២.៥.២.ការចេញលិខិតបញ្ជាក់

សេវាចេញលិខិតបញ្ជាក់ផ្សេងៗនៅរដ្ឋបាលឃុំ រួមមាន៖

- លិខិតបញ្ជាក់ភាពនៅលីវ មេម៉ាយ ឬពោះម៉ាយ
- លិខិតបញ្ជាក់ទីលំនៅ
- លិខិតបញ្ជាក់លើកិច្ចសន្យាខ្ចីប្រាក់

[56] គណៈកម្មាធិការកសាងផែនការ និងថវិកាឃុំវិហារសួគ៌, កម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៣-២០២៥)

[57] ពង់ ផល់ (ជំនួយការហិរញ្ញវត្ថុ),ទំនាក់ទំនងផ្ទាល់ខ្លួនតាមតេឡេក្រាម,១៤ កក្កដា ២០២៤

- លិខិតបញ្ជាក់ប្រវត្តិដីធ្លី
- លិខិតបញ្ជាក់ទាយាទ
- លិខិតបញ្ជាក់កិរិយាមាយាទ
- លិខិតបញ្ជាក់ប្រវត្តិរូបសង្ខេប
- លិខិតបញ្ជាក់ទិញលក់សត្វពាហនៈ(គិតក្នុង១ក្បាល)
- លិខិតបញ្ជាក់តបណ្តាញអគ្គិសនី
- លិខិតបញ្ជាក់តបណ្តាញទឹកស្អាត
- លិខិតបញ្ជាក់ជួលដី ផ្ទះ តូប យានជំនិះ
- លិខិតបញ្ជាក់ផ្ទះជួលបន្ទប់ស្នាក់នៅ
- បញ្ជាក់លើលិខិតស្នាមផ្សេងៗទៀត(ដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ)។[58]

## ២.៦.ការគ្រប់គ្រងហិរញ្ញវត្ថុរបស់ឃុំ

មាត្រា៧៣នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់បានកំណត់ឱ្យរដ្ឋបាលឃុំមានហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិផ្ទាល់។ យោងតាមមាត្រានេះ យើងអាចនិយាយបានថា រដ្ឋបាលឃុំវិហារសួគ៌ជានីតិបុគ្គលដែលមានស្វ័យភាពទាំងផ្នែកហិរញ្ញវត្ថុ ធនធាន និងទ្រព្យសម្បត្តិសម្រាប់ឆ្លើយតបទៅនឹងកិច្ចអភិវឌ្ឍន៍នានានៅក្នុងមូលដ្ឋានរបស់ខ្លួន។ ជាមួយគ្នានេះ ឃុំ សង្កាត់ក៏មានសិទ្ធិទទួលចំណូលផ្ទាល់(ចំណូលដែលបានមកពីចំណូលសារពើពន្ធ ចំណូលមិនមែនសារពើពន្ធនិងកម្រៃសេវាផ្សេងៗ) ចំណូលពីថ្នាក់ជាតិនិងចំណូលពីការអនុវត្តមុខងារជាភ្នាក់ងារជាដើម។

### ២.៦.១.ថវិកាឃុំ

ថវិកាឃុំគឺជាលិខិតគតិយុត្តដែលគ្រោងនិងអនុញ្ញាតចំណូលនិងចំណាយផ្អែកលើមូលដ្ឋានឆ្នាំ។[59] ក្រុមប្រឹក្សាឃុំ សង្កាត់មានសិទ្ធិពេញលេញក្នុងការគ្រោងចំណូល ចំណាយ និងអនុវត្តចំណូល ចំណាយតាមថវិកាដែលបានគ្រោងទុក។ជាទូទៅឃុំសង្កាត់ត្រូវរៀបចំនិងអនុម័តថវិការបស់ខ្លួនជារៀងរាល់ឆ្នាំដោយថវិកាឃុំ សង្កាត់ត្រូវមានតុល្យភាពរវាងចំណូល និងចំណាយសរុប។ ថវិកាឃុំ សង្កាត់ត្រូវឆ្លុះបញ្ចាំងអំពីអាទិភាព និងសេចក្តីត្រូវការនៃផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់។

[58] តារាងតម្លៃសេវាសម្រាប់យន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលឃុំ

[59] អនុក្រឹត្យស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់,លេខ២៦ អនក្រ.បក,០២ មេសា ២០០២,មាត្រា៣

### ២.៦.១.១.ការរៀបចំ និង ការអនុម័តគម្រោងថវិកា

គម្រោងថវិការបស់ឃុំវិហារសួគ៌ គឺត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំក្រោមការទទួលខុសត្រូវរបស់មេឃុំវិហារសួគ៌និងដោយមានជំនួយការពីគណៈកម្មាធិការកសាងផែនការ និងថវិកាមុននឹងដាក់ជូនក្រុមប្រឹក្សាអនុម័ត គណៈកម្មាធិការកសាងផែនការនិងថវិកា បានរៀបចំកិច្ចប្រជុំពិគ្រោះយោបល់គម្រោងថវិកាឃុំជាមួយនឹងប្រជាពលរដ្ឋនៅសាលាឃុំវិហារសួគ៌។ បន្ទាប់មក ក្រុមការងារនឹងបញ្ជូនទៅក្រុមប្រឹក្សាដើម្បីពិនិត្យនិងអនុម័ត។ ក្រោយពីអនុម័តរួចប្រធានក្រុមប្រឹក្សានឹងបញ្ជូនគម្រោងថវិកានេះដោយធ្វើសំណើសុំបញ្ជាក់ទទួលស្គាល់គម្រោងថវិកាឆ្នាំ២០២៣ តាមរយៈលិខិតជាលាយលក្ខណ៍អក្សរទៅអភិបាលខេត្តកណ្តាលដើម្បីពិនិត្យអនុលោមភាព និងបញ្ជាក់ទទួលស្គាល់។

ក្រោយពីបានពិនិត្យនិងឯកភាពរួច អភិបាលខេត្តកណ្តាលបានចេញសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរមួយដោយបញ្ជាក់ទទួលស្គាល់លើគម្រោងថវិកានេះជូនទៅប្រធានក្រុមប្រឹក្សាឃុំវិហារសួគ៌វិញនិងចម្លងជូនទៅមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារខេត្តកណ្តាល។

### ២.៦.១.២.គម្រោងថវិកា

យោងតាមអនុសារណៈស្តីពីការរៀបចំគម្រោងថវិកាឆ្នាំ២០២៣របស់រដ្ឋបាលឃុំវិហារសួគ៌ នៃស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល បានបង្ហាញគម្រោងថវិកាឆ្នាំ២០២៣របស់រដ្ឋបាលឃុំវិហារសួគ៌ ក្នុងនោះរួមមាន៖

១.ចំណូលថវិកាសរុប: ៨០៥,៩៦៦,២៣៧ រៀល

- ចំណូលចរន្ត: ៨០៥,៩៦៦,២៣៧ រៀល ដោយក្នុងនោះមាន
  - ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និងសេវា សរុបចំនួន ១,៥០០,០០០រៀល
  - ការឧបត្ថម្ភ និងអំណោយ សរុបចំនួន ៨០៤,៤៦៦២៣៧រៀល
    - ឧបត្ថម្ភធនពីថ្នាក់ជាតិ ចំនួន: ២៩១,០០០,០០០រៀល
    - ការចូលរួមធនធានពីសមាសភាគអភិវឌ្ឍមូលដ្ឋាន ចំនួន ៣៥,៨៧០,០០០រៀល
    - មូលនិធិបម្រុង ចំនួន: ៦៩,២៦៦,២៣៧រៀល
    - ឧបត្ថម្ភធនពីថ្នាក់ជាតិសម្រាប់ចំណាយវិនិយោគ ចំនួន ៣៤៤,១៣០,០០០រៀល
    - ឧបត្ថម្ភធនរវាងរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ចំណាយវិនិយោគ ចំនួន ៦៤,០០០,០០០រៀល
    - ចំណូលពីការរួមចំណែករបស់ប្រជាជនមូលដ្ឋានក្នុងការអនុវត្តគម្រោង ចំនួន ២០០,០០០រៀល
- ចំណូលមូលធនៈ ០០ រៀល

២.ចំណាយថវិកាសរុបៈ ៨០៥,៩៦៦,២៣៧ រៀល

- ចំណាយចរន្តៈ ៨០៥,៩៦៦,២៣៧ រៀល ដោយក្នុងនោះមាន
  - ការទិញ សរុបចំនួនៈ ២៩,១២០,០០០រៀល
  - សេវាកម្ម សរុបចំនួនៈ ៥៣៣,៩៦៦,៥០៥រៀល
  - បន្ទុកបុគ្គលិក សរុបចំនួនៈ ២២១,៩៥០,០០០រៀល
  - អត្ថប្រយោជន៍សង្គម សរុបចំនួនៈ ៨,៩២៩,៧៣២រៀល
  - ចំណាយមិនបានគ្រោងទុក សរុបចំនួនៈ ១២,០០០,០០០រៀល
- ចំណាយមូលធនៈ ០០ រៀល។

**២.៦.២.ចំណូល និង ចំណាយ**

យោងតាមរបាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលឃុំវិហារសួគ៌ប្រចាំឆ្នាំ២០២៣ចំណុច១.៣.៣. ការអនុវត្តថវិកា ឃុំវិហារសួគ៌មានស្ថានភាពចំណូល ចំណាយដូចខាងក្រោមៈ

**២.៦.២.១.ប្រភពចំណូល**

ឃុំវិហារសួគ៌មានចំណូលជាក់ស្តែងសរុបចំនួន៦០៨,៦២២,៥០០រៀលចំណូលនេះជាចំណូលដែលបានមកពីការឧបត្ថម្ភ និងអំណោយ។

**២.៦.២.២.ចំណាយ**

ឃុំវិហារសួគ៌បានចំណាយថវិកាជាក់ស្តែងសរុបចំនួន ៤៣៦,៨៣៣,២៤០ រៀលទៅលើសកម្មភាពមួយចំនួនដូចជាៈ

១.ការទិញ សរុបចំនួន១៤,៥៣០,០០០រៀល

២.សេវាកម្ម សរុបចំនួន ២៧០,៨៧៣,៥០៨រៀល

៣.បន្ទុកបុគ្គលិក សរុបចំនួន១៤៦,៥០០,០០០រៀល និង

៤.អត្ថប្រយោជន៍សង្គម សរុបចំនួន៤,៩២៩,៧៣២រៀល។

# ជំពូកទី៣
# សមិទ្ធផលការងារដែលសម្រេចបានរបស់រដ្ឋបាលឃុំវិហារសួគ៌

ជាការពិតណាស់ ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំអាណត្តិមុនៗ យើងសង្កេតឃើញថាឃុំវិហារសួគ៌មានការរីកចម្រើនពីមួយឆ្នាំទៅមួយឆ្នាំគួរឱ្យកត់សម្គាល់និងមានសមិទ្ធផលជាច្រើនបានលិចឡើងជាបន្តបន្ទាប់។ ក្នុងនោះយើងកត់សម្គាល់ឃើញដែរថា រដ្ឋបាលឃុំវិហារសួគ៌ទទួលបាននូវការកសាងពីផ្លូវលំដីសទៅជាផ្លូវបេតុងបានប្រមាណជា៦០%នៃផ្លូវប្រវែងសរុបក្នុងឃុំ និងមានការអភិវឌ្ឍន៍ស្ទើរគ្រប់កន្លែង ស្ពាន ព្រែក ប្រឡាយ ធ្វើទ្វារទឹក បានកសាងសាលារៀន មណ្ឌលសុខភាពឃុំ មានសេវាព្យាបាលមិនយកប្រាក់ចំពោះប្រជាពលរដ្ឋក្រីក្រ មានបណ្តាញអគ្គិសនី និងមានទឹកស្អាតប្រើប្រាស់គ្រប់ទីកន្លែងក្នុងមូលដ្ឋាន។ ទាំងនេះសុទ្ធសឹងតែជាសមិទ្ធផលដែលកើតចេញពីការខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់ក្រុមប្រឹក្សាអាណត្តិមុនៗក្នុងការបម្រើផលប្រយោជន៍ជូនប្រជាជននៅក្នុងមូលដ្ឋានឱ្យមានជីវភាពធូរធារនិងល្អប្រសើរជាងមុន។

ក្រឡេកមកវិញក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាឃុំវិហារសួគ៌អាណត្តិទី៥ក្នុងឆ្នាំ២០២៣នេះ រដ្ឋបាលឃុំវិហារសួគ៌បានអនុវត្តនូវសកម្មភាពនិងសម្រេចបានលទ្ធផលការងារជាច្រើនមិនថាជាការងាររដ្ឋបាល និងការផ្តល់សេវាសាធារណៈផ្សេងៗជូនប្រជាពលរដ្ឋនៅក្នុងឃុំនោះទេ។ ខាងក្រោមនេះសុទ្ធសឹងតែជាសមិទ្ធផលការងារដែលរដ្ឋបាលឃុំវិហារសួគ៌សម្រេចបានដើម្បីបម្រើផលប្រយោជន៍ជូនប្រជាពលរដ្ឋនៅក្នុងឃុំវិហារសួគ៌៖

## ៣.១.កិច្ចការរដ្ឋបាល

### ៣.១.១.ការដាក់ចេញនូវលិខិតបទដ្ឋាននានា

នៅក្នុង២០២៣នេះ រដ្ឋបាលឃុំវិហារសួគ៌បានទទួលនិងដាក់ចេញលិខិតមួយចំនួនដូចខាងក្រោម៖

- លិខិតចូល សរុបចំនួន១០២ ច្បាប់
- ដីកាដែលបានដាក់ចេញ សរុបចំនួន ០១ ច្បាប់
- សេចក្តីសម្រេចដែលបានដាក់ចេញ សរុបចំនួន ០៣ ច្បាប់
- លិខិតរដ្ឋបាលដែលបានដាក់ចេញ (មិនរាប់បញ្ចូលលិខិតបញ្ជាក់នានាឡើយ) សរុបចំនួន១១៥០ច្បាប់។

### ៣.១.២.កិច្ចប្រជុំក្រុមប្រឹក្សា គណៈកម្មាធិការ និង គណៈកម្មការ

- កិច្ចប្រជុំក្រុមប្រឹក្សាឃុំ ៖ក្នុងឆ្នាំ២០២៣ រដ្ឋបាលឃុំវិហារសួគ៌បានបើកកិច្ចប្រជុំដូចតទៅ
    - កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា សរុបចំនួន ១២លើក
    - កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា សរុបចំនួន ១៥លើក
    - កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា សរុបចំនួន ០០លើក។
- កិច្ចប្រជុំគណៈកម្មាធិការ និង គណៈកម្មការ

- គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់ "គ.ក.ន.ក"សរុបចំនួន១២លើក
- គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ សង្កាត់ " គ.ផ.ថ." សរុបចំនួន០៣លើក
- គណៈកម្មការលទ្ធកម្ម សរុបចំនួន ០៥លើក។

## ៣.២.ការផ្តល់សេវាសាធារណៈ

សេវាសាធារណៈ សំដៅដល់រាល់សកម្មភាពទាំងឡាយដែលធ្វើឡើងដោយស្ថាប័នមានសមត្ថកិច្ច និងស្ថាប័នទទួលសមត្ថកិច្ចក្នុងគោលដៅបម្រើផលប្រយោជន៍រួមឬផលប្រយោជន៍សាធារណៈ។ ក្នុងនោះស្ថាប័នមានសមត្ថកិច្ចសំដៅដល់ស្ថាប័នរដ្ឋ ឬភ្នាក់ងាររដ្ឋ ឬអាជ្ញាធរគ្រប់លំដាប់ថ្នាក់ទាំងអស់របស់រដ្ឋដែលបំពេញការងារតាមដែនសមត្ថកិច្ចរបស់ខ្លួន។ ដោយឡែកស្ថាប័នទទួលសមត្ថកិច្ចសំដៅដល់ផ្នែកឯកជននិងសង្គមស៊ីវិលដែលទទួលបានសិទ្ធិនិងភារកិច្ចពីរដ្ឋហើយស្ថិតក្រោមការគ្រប់គ្រងនិងត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ។

សេវាសាធារណៈនៅកម្ពុជាត្រូវបានកំណត់និងបែងចែកជា០៧ចង្កោមធំៗរួមមាន៖

- ចង្កោមសេវាទី១ ពាក់ព័ន្ធអធិបតេយ្យភាពរដ្ឋ
- ចង្កោមសេវាទី២ ពាក់ព័ន្ធផ្នែកសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គម
- ចង្កោមសេវាទី៣ ពាក់ព័ន្ធយុត្តិធម៌ និងអាជ្ញាកណ្តាល
- ចង្កោមសេវាទី៤ ពាក់ព័ន្ធការលើកកម្ពស់កិច្ចការពាណិជ្ជកម្ម សហគ្រាសធុនតូចនិងមធ្យម បរិស្ថានវិនិយោគនិងការចូលរួមរបស់ផ្នែកឯកជនក្នុងការកសាងនិងការថែទាំហេដ្ឋារចនាសម្ព័ន្ធ
- ចង្កោមសេវាទី៥ ពាក់ព័ន្ធសង្គមកិច្ច វប្បធម៌ និងកិច្ចការនារី
- ចង្កោមសេវាទី៦ ពាក់ព័ន្ធការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង
- ចង្កោមសេវាទី៧ ពាក់ព័ន្ធការប្រមូលចំណូល ការធ្វើវិចារណកម្មចំណាយនិងការបើកផ្តល់។

ដោយឡែករដ្ឋបាលឃុំ សង្កាត់ គឺជាស្ថាប័នមានសមត្ថកិច្ចមួយដែលដឹកនាំដោយក្រុមប្រឹក្សាកើតពីការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋក្នុងមូលដ្ឋានរបស់ខ្លួន។ ក្នុងន័យនេះ ក្រុមប្រឹក្សាឃុំ សង្កាត់មានសមត្ថកិច្ចផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។ ក្របខណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗដែលកំណត់អំពីការផ្តល់សេវាសាធារណៈដោយរដ្ឋបាលឃុំ សង្កាត់មានដូចជា ៖

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- អនុក្រឹត្យលេខ២២អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមជ្ឈការ អំណាច តួនាទីនិងភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់
- គោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ឆ្នាំ២០២១

- អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយនៅថ្នាក់ក្រោមជាតិ
- ប្រកាសលេខ៣៨៤០ ប្រក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់
- សេចក្តីណែនាំលេខ០១៨ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២២ របស់ក្រសួងមហាផ្ទៃ ស្តីពីបែបបទ និងនីតិវិធីនៃការផ្តល់សេវារដ្ឋបាលតាមយន្តការច្រកចេញចូលតែមួយនៃរដ្ឋបាលឃុំ សង្កាត់
- លិខិតបទដ្ឋាននិងឯកសារពាក់ព័ន្ធផ្សេងៗទៀត។

ផ្អែកតាមលិខិតបទដ្ឋានខាងលើ ការផ្តល់សេវាសាធារណៈដោយរដ្ឋបាលឃុំ សង្កាត់ ជារួមអាចធ្វើការបែងចែកដូចជា៖ សេវារដ្ឋបាល ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ការងារសង្គមកិច្ច ការងារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈនិងសុវត្ថិភាពសង្គម ការងារបរិស្ថាន និងអន្តរវិស័យ។

បើទោះជាសេវាសាធារណៈផ្តល់ដោយរដ្ឋបាលឃុំសង្កាត់មិនបានបែងចែកជាក់លាក់ជាចង្កោមសេវាទាំង៧ដូចបានរៀបរាប់ខាងលើ ប៉ុន្តែសេវាសាធារណៈដែលផ្តល់ដោយរដ្ឋបាលឃុំ សង្កាត់ត្រូវបានសង្កេតឃើញថាគ្របដណ្តប់លើចង្កោមសេវាទាំង០៧។[60]

យ៉ាងណាមិញ បើយើងក្រឡេកមកមើលរដ្ឋបាលឃុំវិហារសួគ៌វិញ យើងកត់សម្គាល់ឃើញថារដ្ឋបាលឃុំបានផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋជាច្រើនដោយក្នុងនោះរួមមាន សេវារដ្ឋបាល ការសម្របសម្រួលពាក់ព័ន្ធនឹងការងារបោះឆ្នោត ការងារសង្គមកិច្ច និងការងារសន្តិសុខសណ្តាប់ធ្នាប់ជាដើម។

### ៣.២.១.ការផ្តល់សេវារដ្ឋបាល

ជាទូទៅសេវារដ្ឋបាលដែលបម្រើនៅតាមរដ្ឋបាលឃុំ សង្កាត់នីមួយៗមានពីរប្រភេទរួមមានសេវាតម្រូវការ និងសេវាសំណូមពរ។

សេវាតម្រូវការ ជាសេវាដែលប្រជាពលរដ្ឋគ្រប់រូបមានតម្រូវការចាំបាច់នៅក្នុងជីវភាពរស់នៅរបស់ខ្លួន រួមមាន ឯកសារអត្រានុកូលដ្ឋាន សៀវភៅស្នាក់នៅ និងសៀវភៅគ្រួសារជាដើម។ សេវាតម្រូវការត្រូវបានផ្តល់ជូនប្រជាពលរដ្ឋដោយឥតគិតថ្លៃ។

សេវាសំណូមពរ ជាសេវាដែលប្រជាពលរដ្ឋមួយចំនួនត្រូវការក្នុងកាលៈទេសៈណាមួយ និងឬក្នុងគោលបំណងជាក់លាក់ណាមួយដែលរួមមានដូចជា លិខិតបញ្ជាក់ភាពនៅលីវ លិខិតបញ្ជាក់ទីលំនៅជាដើម។

[60] សាលាជាតិរដ្ឋបាលមូលដ្ឋាន,*ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់* (២០២២)

### ៣.២.១.១.សេវាអត្រានុកូលដ្ឋាន

នៅក្នុងឆ្នាំ២០២៣មានប្រជាពលរដ្ឋជាច្រើនមកទទួលសេវាអត្រានុកូលដ្ឋានពីខាងឃុំក្នុងនោះរដ្ឋបាលឃុំវិហារសួគ៌បានផ្តល់នូវសេវាអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋបានចំនួនដូចខាងក្រោមៈ

- សំបុត្រកំណើត ចំនួន ៣៥៤ សន្លឹក
- សំបុត្របញ្ជាក់កំណើត ចំនួន ១៤៣ សន្លឹក
- សេចក្តីចម្លងសំបុត្រកំណើត ចំនួន ៣៧០ សន្លឹក
- សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ចំនួន ១៦៦ សន្លឹក
- សំបុត្រអាពាហ៍ពិពាហ៍ (ខ្មែរ និងខ្មែរ) ចំនួន ៧៦ សន្លឹក
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ (ខ្មែរ និងខ្មែរ) ចំនួន ៦២ សន្លឹក
- សំបុត្រអាពាហ៍ពិពាហ៍ (ខ្មែរ និងបរទេស) ចំនួន ០៤ សន្លឹក
- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ (ខ្មែរ និងបរទេស) ចំនួន ០៨ សន្លឹក
- សំបុត្រមរណភាព ចំនួន ៩២ សន្លឹក
- សេចក្តីចម្លងសំបុត្រមរណភាព ចំនួន ១០៨សន្លឹក។

### ៣.២.១.២.សេវាសំណុំរឿង

នៅក្នុងឆ្នាំ២០២៣ រដ្ឋបាលឃុំវិហារសួគ៌បានផ្តល់សេវាចេញលិខិតបញ្ជាក់ជូនប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋានបានចំនួនដូចខាងក្រោមៈ

- លិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ ចំនួន ៩២ សន្លឹក
- លិខិតបញ្ជាក់លំនៅ ចំនួន ៥៩ សន្លឹក
- លិខិតបញ្ជាក់លើកិច្ចសន្យាខ្ចីប្រាក់ ចំនួន ១៣៥សន្លឹក
- លិខិតបញ្ជាក់ពីប្រវត្តិដីធ្លី ចំនួន ១៥៧សន្លឹក
- លិខិតបញ្ជាក់ទាយាទ ចំនួន ៤៨ សន្លឹក
- លិខិតបញ្ជាក់កិរិយាមាយាទ ចំនួន ២៩ សន្លឹក
- លិខិតបញ្ជាក់ប្រវត្តិរូបសង្ខេប ចំនួន ៧១ សន្លឹក
- លិខិតបញ្ជាក់ទិញលក់សត្វពាហនៈ (គិតជាក្បាល) ចំនួន ០៦ សន្លឹក
- លិខិតបញ្ជាក់តបណ្តាញអគ្គិសនី ចំនួន ០០ សន្លឹក
- លិខិតបញ្ជាក់តបណ្តាញទឹកស្អាត ចំនួន ០០ សន្លឹក
- លិខិតបញ្ជាក់ជួលដី ផ្ទះ តូប យានជំនិះ ចំនួន ៣១ សន្លឹក

- លិខិតបញ្ជាក់ផ្ទះជួលបន្ទប់ស្នាក់នៅ ចំនួន ២០ សន្លឹក
- បញ្ជាក់លើលិខិតស្នាមផ្សេងៗទៀត(លិខិតដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ) ចំនួន០០សន្លឹក។

**៣.២.២.ការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត**

យោងតាមមាត្រា៥០នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គ.ជ.ប.ត្រូវធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ឱ្យបំពេញតួនាទីជាតំណាងរបស់ខ្លួនក្នុងការពិនិត្យបញ្ជីឈ្មោះនិងការចុះឈ្មោះបោះឆ្នោតនិងសៀវភៅបញ្ជីបោះឆ្នោត។ ដើម្បីជួយគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់អនុវត្តតួនាទីនិងការទទួលខុសត្រូវនេះ ក្រុមចុះឈ្មោះបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗត្រូវបានចាត់តាំងដោយ គ.ជ.ប ដែលមានសមាសភាពដូចខាងក្រោម៖

- ប្រធានមួយរូបដែលចាត់តាំងដោយ គ.ជ.ប
- អនុប្រធានមួយរូបជាស្មៀនឃុំ សង្កាត់សាមី
- សមាជិកមួយតាមការកំណត់របស់គ.ជ.ប

ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះនិងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំស្របតាមច្បាប់បោះឆ្នោត និងបទបញ្ជានិងនីតិវីធីសម្រាប់ការបោះឆ្នោត។

យោងតាមស្មារតីមាត្រា៥០នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ យើងអាចនិយាយបានថាក្រុមប្រឹក្សាឃុំវិហារសួគ៌មានភារកិច្ចអនុវត្តតួនាទីក្នុងនាមគ.ជ.បក្នុងការពិនិត្យបញ្ជីឈ្មោះដោយធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបោះឆ្នោតនិងការចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត។ ជាមួយគ្នានេះ គិតត្រឹមថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្នុងឃុំវិហារសួគ៌មាន៖

- ប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោត (ចាស់និងថ្មី) សរុបចំនួន១០១៨៧នាក់ ក្នុងនោះមានស្រីចំនួន៥៣៨៤នាក់
- ប្រជាពលរដ្ឋដែលនឹងត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះបោះឆ្នោតឆ្នាំ២០២៣(ស្លាប់ និងផ្ទេរចេញ) សរុបចំនួន៣៤នាក់ក្នុងនោះមានស្រីចំនួន១២នាក់។

**៣.២.៣.ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម**

**៣.២.៣.១.សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**

ដើម្បីធានាឱ្យឃុំវិហារសួគ៌មានសន្តិសុខសណ្តាប់ធ្នាប់និងរបៀបរាបរយល្អប្រសើរ ក្នុងនោះឃុំវិហារសួគ៌មានប៉ុស្តិ៍នគរបាលរដ្ឋបាលមួយដែលមានតួនាទីក្នុងការការពារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គមក្នុងឃុំផ្ទាល់។ ជាមួយគ្នានេះ ប៉ុស្តិ៍នគរបាលរដ្ឋបាលវិហារសួគ៌មានកងកម្លាំងសរុបចំនួន៦រូប(ស្រី០១រូប)

និងប្រជាការពារក្នុងភូមិទាំង៨សរុបចំនួន១២៦រូបដែលជាកម្លាំងស្នូលយ៉ាងសំខាន់ក្នុងការថែរក្សាសន្តិសុខនៅក្នុងឃុំសំដៅធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋានប្រកបដោយសុខសុវត្ថិភាព។

កន្លងមកនេះ តាមរយៈកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្មក្នុងការបំពេញការងារ រដ្ឋបាលឃុំវិហារសួគ៌បានទទួលជ័យលាភីប្រភេទលេខ១ចំនួនបួនឆ្នាំជាប់គ្នាដោយចាប់ពីឆ្នាំ២០១៩ដល់២០២២ដែលមានស្នាដៃល្អក្នុងការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព។ លើសពីនេះ យើងកត់សម្គាល់ឃើញដែរថាក្រោមការខិតខំប្រឹងប្រែង និងយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបំពេញការងាររបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំវិហារសួគ៌នៅក្នុងឆ្នាំ២០២៣នេះបានសម្រេចនូវលទ្ធផលការងារជាច្រើនក្នុងនោះរួមមាន៖

- ការផ្តល់សេវារបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំវិហារសួគ៌៖ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំវិហារសួគ៌បានធ្វើ
  - សៀវភៅស្នាក់នៅជូនប្រជាពលរដ្ឋសរុបចំនួន ១២៣ ក្បាល
  - សៀវភៅគ្រួសារជូនប្រជាពលរដ្ឋសរុបចំនួន ១៩ ក្បាល
  - អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋសរុបចំនួន ១៤១២ សន្លឹក។
- ការងារផ្សព្វផ្សាយ ៖ ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំវិហារសួគ៌បាន
  - អប់រំផ្សព្វផ្សាយច្បាប់ភូមិបាលសរុបចំនួន ០២លើក
  - ផ្សព្វផ្សាយច្បាប់អំពើហិង្សាក្នុងគ្រួសារសរុបចំនួន ០២វគ្គ
  - ជម្រុញសកម្មភាពទប់ស្កាត់ល្បែងស៊ីសងសរុបចំនួន ០១លើក
  - បង្កើតការត្រួតពិនិត្យ គ្រប់គ្រងជនខិលខូចសរុបចំនួន ០១លើក
  - បង្កើត ពង្រឹងសកម្មភាពក្រុមប្រជាការពារក្នុងមូលដ្ឋានសរុបចំនួន ០២លើក
  - លុបបំបាត់គ្រឿងញៀននិងល្បែងស៊ីសងសរុបចំនួន ០៩លើក។
- ការងារផ្សេងៗ
  - កម្លាំងប៉ុស្តិ៍ចុះល្បាតតាមគោលដៅសំខាន់ៗជាច្រើន
  - កម្លាំងប៉ុស្តិ៍ចុះសម្រួលចរាចរណ៍ជូនកម្មកររោងចក្រនៅចំណុចមុខច្រកចូលសាលាROTA
  - កម្លាំងប៉ុស្តិ៍បានចុះចែកសៀវភៅស្នាក់នៅ និងសៀវភៅគ្រួសារបានចំនួន១១ក្បាល
  - កម្លាំងប៉ុស្តិ៍បានចុះធ្វើវេទិកាសាធារណៈបានចំនួន០៦លើក ចំនួនអ្នកចូលរួម៣៩៨នាក់ ស្រី១៦២នាក់។

### ៣.២.៣.២.ការសម្រុះសម្រួល និងការដោះស្រាយវិវាទនៅមូលដ្ឋាន

វិវាទនៅមូលដ្ឋាន សំដៅទៅលើវិវាទដែលមានលក្ខណៈឯកជនរវាងប្រជាពលរដ្ឋដែលសិត្ថនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាជាមួយគ្នាឬដែលសិត្ថក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាផ្សេងគ្នា។ការដោះស្រាយវិវាទ

ត្រូវផ្អែកតាមពាក្យបណ្ដឹងរបស់ភាគីណាមួយ ឬភាគីទាំងសងខាងនៅក្នុងវិវាទទៅក្រុមប្រឹក្សាដែលភាគីនោះស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានោះ។

ការដោះស្រាយវិវាទនៅមូលដ្ឋាន គឺជាសមាសភាពមួយក្នុងសមាសធាតុទាំងប្រាំពីរនៃគោលនយោបាយភូមិឃុំ មានសុវត្ថិភាពដែលត្រូវបានដាក់ឱ្យប្រើប្រាស់ក្នុងឆ្នាំ២០២១។ តាមរយៈគោលនយោបាយនេះ រដ្ឋបាលឃុំសង្កាត់ត្រូវយកចិត្តទុកដាក់ក្នុងការជម្រុញការដោះស្រាយវិវាទនៅមូលដ្ឋានក្រៅប្រព័ន្ធតុលាការ ដើម្បីកាត់បន្ថយការចំណាយធនធាននិងពេលវេលារបស់ភាគីពាក់ព័ន្ធទាំងអស់។

ជាក់ស្ដែងនៅក្នុងឆ្នាំ២០២៣រដ្ឋបាលឃុំវិហារសួគ៌ បានទទួលដោះស្រាយវិវាទនៅមូលដ្ឋានសរុបចំនួន៩៤ករណីក្នុងនោះករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយឃុំមានចំនួន៧៦ករណីនិងករណីដែលបានបញ្ជូនទៅសមត្ថកិច្ចបន្តឬស្ថាប័នដែលពាក់ព័ន្ធមានចំនួន ១០ករណី។[61]

### ៣.២.៤.ការងារសង្គមកិច្ច

ដើម្បីលើកកម្ពស់សុខមាលភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនរដ្ឋបាលឃុំវិហារសួគ៌បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអនុវត្តនូវការងារសង្គមកិច្ចសំខាន់ៗ ដូចជា៖

- បានចុះសម្ភាសន៍គ្រួសារក្រីក្រធ្វើប័ណ្ណសមធម៌ចំនួន២១០គ្រួសារ ហើយគិតត្រឹមខែកក្កដាឆ្នាំ២០២៤ នេះ រដ្ឋបាលឃុំវិហារសួគ៌បានចេញប័ណ្ណសមធម៌ជូនគ្រួសារក្រីក្រសរុបចំនួន ៩៥៣គ្រួសារក្នុងនោះ ក្រ១មានចំនួន៣៦០គ្រួសារ ក្រ២មានចំនួន៣៧៧គ្រួសារ និងងាយរងហានិភ័យមានចំនួន២១៦ គ្រួសារ[62]
- បានចុះអប់រំដល់គ្រួសារដែលប្រើបង្គន់រួម បើមានលទ្ធភាពឱ្យធ្វើបង្គន់បែកចេញពីឪពុកម្ដាយ បងប្អូន បានចំនួន ១២គ្រួសារ
- បានចុះអប់រំតាមគ្រួសារឱ្យចេះមានអនាម័យបរិស្ថាននិងនៅតាមលំនៅឋាន និងទុកដាក់សំរាមឱ្យបានត្រឹមត្រូវនៅតាមភូមិចំនួន ០៧គ្រួសារ
- បានចុះពន្យល់ដល់ស្ត្រីមានផ្ទៃពោះឱ្យទៅពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាពបានចំនួន ១១នាក់
- បានបើកថវិកា គ.ក.ន.ក ជូនដល់កុមារមានពិការភាពសម្រាប់ដឹកជញ្ជូនទៅសាលារៀនប្រចាំខែ ចំនួន០៣នាក់ក្នុងម្នាក់ទទួលបាន៥០,០០០រៀលសរុបបីនាក់អស់ ១៥០,០០០រៀលក្នុងមួយខែនិង
- បានចុះសួរសុខទុក្ខស្ត្រីសម្រាលកូនរួចបានចំនួន១១នាក់អប់រំឱ្យចេះថែទាំសុខភាពម្ដាយ និងកូនឱ្យបានល្អ។

[61] របាយការណ៍ស្ដីពីការអនុវត្តការងាររបស់រដ្ឋបាលឃុំវិហារសួគ៌ប្រចាំឆ្នាំ២០២៣

[62] ពង់ ផល់ (ជំនួយការហិរញ្ញវត្ថុ),ទំនាក់ទំនងផ្ទាល់ខ្លួនតាមតេឡេក្រាម,១៤ កក្កដា ២០២៤

លើសពីនេះ រដ្ឋបាលឃុំវិហារសួគ៌បានអនុវត្តនូវគម្រោងមូលនិធិឃុំ សង្កាត់ (ថវិកាវិភាជន៍ពីរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងសប្បុរសជន)ដែលសិក្តនៅក្នុងផ្នែកសង្គមកិច្ចជាច្រើនដូចជា៖

- កម្មវិធីពន្យាកំណើត គ្រោង២០%បានអនុវត្តជាក់ស្តែងចំនួន ២០% អ្នកទទួលផលសរុប២៧៥នាក់ ស្រី២៧៥នាក់
- សេវាសុខភាពស្ត្រីមានផ្ទៃពោះ គ្រោង១០០%បានអនុវត្តជាក់ស្តែង ៨០% អ្នកទទួលផលសរុប ៣៨០នាក់ ស្រី៣៨០នាក់
- វគ្គអប់រំចំណេះដឹងអំពីជំងឺអេដស៍ គ្រោង១០០% បានអនុវត្តជាក់ស្តែង៨០% អ្នកទទួលផលសរុប ១៧៣៧១នាក់ ក្នុងនោះស្រី ៨៩៦៥នាក់
- ផ្តល់ការចាក់វ៉ាក់សាំងដល់កុមារការពារជំងឺ១២មុខ គ្រោង០២លើក បានអនុវត្តជាក់ស្តែងចំនួន០២ លើក អ្នកទទួលផលសរុប១៦០០នាក់ ក្នុងនោះស្រី៩៣០នាក់
- សកម្មភាពស្រាវជ្រាវ និងទប់ស្កាត់ការឆ្លងរាលដាលជំងឺរបេងDOTS គ្រោង៩០% បានអនុវត្តជាក់ស្តែង ៧០% អ្នកទទួលផលសរុប៥០០នាក់ ក្នុងនោះស្រី២៥០នាក់
- យុទ្ធនាការដាក់ថ្នាំអាំបែត BTI គ្រោង៩០% បានអនុវត្តជាក់ស្តែង៧០% អ្នកទទួលផលសរុប ៣០០០នាក់ ក្នុងនោះស្រី១៥០០នាក់
- ការអប់រំផ្សព្វផ្សាយបន្ទុកជំងឺមិនឆ្លង (លើសឈាម ទឹកនោមផ្អែម សុខភាពភ្នែក សុខភាពមាត់ធ្មេញ) គ្រោង៩០% បានអនុវត្តជាក់ស្តែង៧០% អ្នកទទួលផលសរុប៥០០នាក់ ក្នុងនោះស្រី២៥០នាក់
- ផ្តល់សេវាព្យាបាលដោយមិនយកកម្រៃដល់ប្រជាពលរដ្ឋក្រីក្រតាមរយៈប័ណ្ណសមធម៌គ្រោង១០០% បានអនុវត្តជាក់ស្តែង ៨០% អ្នកទទួលផលសរុប ២៥០នាក់ ក្នុងនោះស្រី១០០នាក់
- ប្រត្តិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាល គ្រោង១០០% បានអនុវត្តជាក់ស្តែង៨០% អ្នកទទួលផលសរុប២៥០នាក់ ក្នុងនោះស្រី១០០នាក់
- អាហារូបករណ៍សិស្សក្រីក្ររៀនពូកែ គ្រោង១៤១នាក់ អ្នកទទួលបានជាក់ស្តែងមានចំនួន៧៨នាក់ ក្នុងនោះមានស្រី៥៦នាក់
- គម្រោងសាងសង់ផ្តល់សម្ភារៈបង្គន់អនាម័យ គ្រោង៣៥បង្គន់ ទទួលបានជាក់ស្តែង៣៥បង្គន់ អ្នកទទួលផលសរុប៦០នាក់ ស្រី២៤នាក់
- ផ្សព្វផ្សាយអំពីសិទ្ធិស្ត្រី និងកុមារ គ្រោង០២វគ្គ បានអនុវត្តជាក់ស្តែងចំនួន០២វគ្គ អ្នកទទួលផលសរុបចំនួន១០០នាក់ ស្រី១០០នាក់

- រៀបចំទិវាអន្តរជាតិ ៨ មីនា គ្រោង៣០០នាក់ ជាក់ស្តែងអ្នកចូលរួមសរុបចំនួន ៣០០នាក់ក្នុងនោះមាន ប្រុស ១២០នាក់ និងស្រី៦៥នាក់
- បណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្ត្រីដែលគ្មានការងារធ្វើ គ្រោង០២វគ្គ បានអនុវត្តជាក់ស្តែងចំនួន០២វគ្គ អ្នកទទួលផលសរុបចំនួន៥០នាក់ ក្នុងនោះមានស្រីចំនួន២៥នាក់
- ការជម្រុញសកម្មភាពកីឡានៅមូលដ្ឋាន គ្រោង០២ក្រុម ជាក់ស្តែងមានចំនួន០២ក្រុម អ្នកទទួលផលសរុបចំនួន ២៥០០នាក់ ក្នុងនោះមានស្រីចំនួន ១២០០នាក់។

### ៣.២.៥.បរិស្ថាន និងធនធានធម្មជាតិ

ដើម្បីលើកកម្ពស់អនាម័យ សោភណភាពនិងបរិស្ថានល្អនៅមូលដ្ឋាន រដ្ឋបាលឃុំវិហារសួគ៌បានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអនុវត្តនូវការងារបរិស្ថានសំដៅធ្វើយ៉ាងណាឱ្យភូមិឃុំមានសោភណភាពល្អ គ្មានសំរាម និងធ្វើឱ្យការរស់នៅរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានប្រកបដោយផាសុកភាព។

កន្លងមកនេះតាមរយៈកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្ម រដ្ឋបាលឃុំវិហារសួគ៌គឺបានទទួលជ័យលាភីលេខ២សម្រាប់ការប្រឡងប្រណាំងផ្ទៃក្នុងភូមិ ឃុំមានសុវត្ថិភាពក្នុងវិស័យបរិស្ថានខេត្តកណ្តាលឆ្នាំ២០២២។

យ៉ាងណាមិញបើយើងក្រឡេកមកមើលក្នុងឆ្នាំ២០២៣នេះវិញយើងសង្កេតឃើញថារដ្ឋបាលឃុំវិហារសួគ៌ក៏បានសម្រេចលទ្ធផលការងារផ្នែកបរិស្ថានជាច្រើនផងដែរ ក្នុងនោះមានដូចជា៖

- នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២៣ សមាជិកក្រុមប្រឹក្សាឃុំ និងលោកមេភូមិរងនៃភូមិវិហារសួគ៌ត្បូង បានចុះពិនិត្យទីតាំងដាក់ស្លាក (ហាមចោលសំរាម) នៅចំណុចក្រោយសាលាលិចទឹកក្នុងភូមិវិហារសួគ៌ត្បូង
- នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៣លោក លោកស្រីសមាជិកក្រុមប្រឹក្សាឃុំវិហារសួគ៌ និងកងកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាល និងលោកនាយកសាលាវិហារសួគ៌បានចុះធ្វើការណែនាំដល់អ្នកលក់ចំណីអាហារក្នុងទីធ្លាសាលារៀនណែនាំឱ្យគាត់ផ្អាកលក់ចំណីអាហារនិងភេសជ្ជៈមួយណាដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពរបស់កូនសិស្សដោយគោរពតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា
- នៅថ្ងៃទី២៨ ខែ កញ្ញា ឆ្នាំ២០២៣ លោក យ៉ាន់ រឿនអភិបាលរង តំណាងលោក ចេង ឌីណា អភិបាលនៃគណៈអភិបាលស្រុកបានដឹកនាំកម្លាំងប៉ុស្តិ៍ ក្រុមប្រឹក្សាឃុំ និង មេភូមិ ចុះធ្វើអនាម័យបរិស្ថាននៅតាមទីសាធារណៈរៀបចំសណ្តាប់ធ្នាប់ចរាចរណ៍នៅផ្សារវិហារសួគ៌ និងវត្តព្រះវិហារសួគ៌
- នៅថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០២៣ រដ្ឋបាលឃុំវិហារសួគ៌ដែលមានការសហការចូលរួមពីសំណាក់លោក លោកស្រី ក្រុមប្រឹក្សាឃុំ កម្លាំងប៉ុស្តិ៍រដ្ឋបាលឃុំ លោក លោកស្រីមេភូមិទាំង៨ លោកនាយកសាលាបឋមទាំង៣ ក្នុងឃុំវិហារសួគ៌លោកគ្រូ អ្នកគ្រូនៃសាលាអនុវិទ្យាល័យវិហារសួគ៌ កម្លាំងប្រជា

ការពារភូមិទាំង៨និងប្អូនៗសិស្សានុសិស្សនៃសាលាហ៊ុនសែនROTAខ្សាច់កណ្ដាល បានចូលរួមធ្វើការកាប់ព្រៃ និងសម្អាត បរិស្ថានតាមដងផ្លូវជាតិលេខ៨ ចេញពីចំណុចសាលាROTAទៅដល់ចំណុចស្ពានព្រះគន្លងដែលដឹកនាំដោយលោក ជា គឹមឡេង អភិបាលរងស្រុក និង លោក លឹម ស៊ីលាង អភិបាលរងស្រុក តំណាងលោកចេង ឌីណា អភិបាលនៃគណៈអភិបាលស្រុកខ្សាច់កណ្ដាល និងមន្ត្រីសាលាស្រុកមួយចំនួនទៀត

- នៅថ្ងៃទី ២៩ ខែតុលា ឆ្នាំ២០២៣ ដោយមានការចង្អុលបង្ហាញពីលោក ស្រ៊ឹម សុខឃាន់ មេភូមិវិហារសួគ៌ត្បូង និងដឹកនាំដោយអនុប្រធានភូមិ រួមជាមួយប្រជាការពារភូមិបានសម្អាតបរិស្ថាននៅបរិវេណសាលាលិចទឹកដោយធ្វើការកាត់ស្មៅកាប់ព្រៃនិងដុតសំរាមដែលនៅរាយប៉ាយជិតសាលា។

លើសពីនេះ រដ្ឋបាលឃុំវិហារសួគ៌បានអនុវត្តនូវគម្រោងមូលនិធិឃុំ សង្កាត់ (ថវិកាវិភាជន៍ពីរដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ និងសប្បុរសជន)ដែលសិត្ថនៅក្នុងផ្នែកធនធានធម្មជាតិ និង បរិស្ថានជាច្រើនដូចជា៖

- អប់រំផ្សព្វផ្សាយច្បាប់ជលផល គ្រោង១វគ្គ បានអនុវត្តជាក់ស្តែងចំនួន១វគ្គ អ្នកទទួលផលសរុប ១៧៣៧១នាក់ ក្នុងនោះស្រី៨៩៦៥នាក់
- អប់រំប្រយោជន៍ ព្រៃឈើ ព្រៃលិចទឹកគ្រោង០២វគ្គ បានអនុវត្តជាក់ស្តែងចំនួន ០២វគ្គ អ្នកទទួលផលសរុប១៧៣៧១នាក់ ក្នុងនោះស្រី៨៩៦៥នាក់
- ពង្រឹងវិធានការទប់ស្កាត់បទល្មើសនេសាទ គ្រោង០៨កន្លែង បានអនុវត្តជាក់ស្តែងចំនួន០៦កន្លែង អ្នកទទួលផលសរុប១៧៣៧១នាក់ ក្នុងនោះស្រី៨៩៦៥នាក់
- អប់រំផ្សព្វផ្សាយច្បាប់ការពារសត្វព្រៃគ្រោង០២លើកបានអនុវត្តជាក់ស្តែងចំនួន០២លើក អ្នកទទួលផលសរុប១៧៣៧១នាក់ក្នុងនោះស្រី៨៩៦៥នាក់។

### ៣.២.៦.ហេដ្ឋារចនាសម្ព័ន្ធ

នៅក្នុងឆ្នាំ២០២៣ រដ្ឋបាលឃុំវិហារសួគ៌បានបញ្ចប់គម្រោងកែលម្អផ្លូវបេតុងអាមេ ចំនួន០១ខ្សែនិងមានប្រវែង២,១៨៤ម៉ែត្រដែលមានទីតាំងសិត្ថនៅភូមិព្រៃធំនិងភូមិតាកែវ១ ដោយប្រើប្រាស់មូលនិធិឃុំឆ្នាំ២០២៣។ គម្រោងនេះដែរត្រូវបានសិក្សាដោយលោក មួង ឌុល មន្ត្រីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្តប្រចាំស្រុក និងប្រើប្រាស់វិធីសាស្ត្រលទ្ធកម្មតាមរយៈការដេញថ្លៃនិងចំណាយទឹកប្រាក់សរុបចំនួន ៤៣៧,០០០,០០០រៀល។[63]

### ៣.២.៧.វេទិកាសាធារណៈ

ជាការពិតណាស់ វេទិកាសាធារណៈដែលរៀបចំឡើងដោយរដ្ឋបាលឃុំវិហារសួគ៌ជាវេទិកាមួយដែលធ្វើឡើងក្នុងគោលបំណងដើម្បីជួបផ្ទាល់ និងធ្វើការសំណេះសំណាលជាមួយនឹងប្រជាពលរដ្ឋដោយទទួលយកនូវ

[63]របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលឃុំវិហារសួគ៌ប្រចាំឆ្នាំ២០២៣

បញ្ហាប្រឈម ក៏ដូចជាសំណូមពរផ្សេងៗរបស់ប្រជាពលរដ្ឋដែលរស់នៅមូលដ្ឋានផ្ទាល់បានលើកឡើងដើម្បីយកមកធ្វើការពិចារណានិងធ្វើការដោះស្រាយជូនប្រជាពលរដ្ឋក្នុងករណីខាងឃុំមានលទ្ធភាពអាចធ្វើទៅបាន។ វេទិកានេះធ្វើមួយខែម្តង ហើយគេធ្វើម្តងមួយភូមិៗ។ ចំណែកឯតួអង្គសំខាន់ៗដែលចូលរួមក្នុងវេទិកានេះរួមមាន ខាងរដ្ឋបាលស្រុក រដ្ឋបាលឃុំ ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំនិងអ្នកផ្តល់សេវាផ្សេងៗទៀតដូចជា ខាងមណ្ឌលសុខភាព សាលារៀន ក្រុមហ៊ុនប្រមូលសំរាម ក្រុមហ៊ុនទឹកស្អាត និងក្រុមហ៊ុនអគ្គិសនីជាដើម។[64]ក្នុងការអនុវត្តជាក់ស្តែងរបស់រដ្ឋបាលឃុំវិហារសួគ៌កន្លងមកនេះ យើងអង្កេតឃើញថាវេទិកាសាធារណៈរបស់រដ្ឋបាលឃុំបានធ្វើឡើងស្របជាមួយនឹងវេទិកាផ្សព្វផ្សាយគោលនយោបាយ"ភូមិ ឃុំមានសុវត្ថិភាព"ពោលគឺបន្ទាប់ពីបានធ្វើការផ្សព្វផ្សាយគោលនយោបាយ"ភូមិ ឃុំមានសុវត្ថិភាព"រួចរាល់ហើយនោះ កម្មវិធីបន្ទាប់គឺជាការបើកឱ្យប្រជាពលរដ្ឋដែលបានមកចូលរួមលើកឡើងនូវមតិយោបល់ ចម្ងល់ឬបញ្ហាផ្សេងៗជូនដល់អង្គពិធីបានជ្រាបនិងដោះស្រាយជូនផងដែរ។

[64] ពង់ ផល់(ជំនួយការហិរញ្ញវត្ថុឃុំ),ទំនាក់ទំនងផ្ទាល់ខ្លួនតាមតេឡេក្រាម,១៧ កក្កដា ២០២៤

# ជំពូកទី៤
# បញ្ហាប្រឈម និង ដំណោះស្រាយ

យោងតាមការពិនិត្យទៅលើផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ (២០២៣-២០២៧) កម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៣-២០២៥)របស់ឃុំវិហារសួគ៌និងតាមរយៈការអង្កេតផ្ទាល់នៅក្នុងមូលដ្ឋាន យើងសង្កេតឃើញថាក្រោមការគ្រប់គ្រងរបស់ក្រុមប្រឹក្សាឃុំវិហារសួគ៌អាណត្តិទី៥ក្នុងឆ្នាំ២០២៣ រដ្ឋបាលឃុំវិហារសួគ៌បានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដែលបង្កឱ្យមានការរាំងស្ទះដល់ការអភិវឌ្ឍក្នុងនោះរួមមានៈ

## ៤.១.ស្ថានភាពបច្ចុប្បន្ន និង បញ្ហាប្រឈម

### ៤.១.១.ផ្នែកសេដ្ឋកិច្ច

រដ្ឋបាលឃុំវិហារសួគ៌ស្ថិតនៅក្នុងស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល។ ប្រជាជនរស់នៅក្នុងឃុំភាគច្រើនប្រកបរបរកសិកម្មជាចម្បងសម្រាប់រកចំណូលដោះស្រាយជីវភាពគួបផ្សំរបរបន្ទាប់បន្សំមួយចំនួនផ្សេងទៀតដូចជាៈកម្មករកម្មការិនីរោងចក្រ អ្នកលក់ដូរបន្តិចបន្តួចតាមផ្ទះ និងចិញ្ចឹមសត្វតាមលក្ខណៈគ្រួសារជាដើម។ ម្យ៉ាងទៀតប្រជាពលរដ្ឋមួយចំនួនគាត់ធ្វើជាមន្ត្រីរាជការ បុគ្គលិកក្រុមហ៊ុន អង្គការ ជាងផ្ទះនិងកម្មករសំណង់ជាដើម។ ក្នុងនោះឃុំមានផ្សារចំនួន៣កន្លែង គឺមានផ្សារព្រៃចាស់ ផ្សារវិហារសួគ៌ និងថ្នល់កែង។

ទោះបីមានការអភិវឌ្ឍន៍លើវិស័យកសិកម្មបានមួយចំនួនហើយក៏ដោយក៏ប្រជាកសិករនៅតែជួបការលំបាកក្នុងការបង្កបង្កើនផលដោយជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនមានដូចជា ការប្រែប្រួលអាកាសធាតុ ដំណាំកើតជម្ងឺ សត្វល្អិតបំផ្លាញ និងកត្តាដីខ្ពស់ទាបមិនរាបស្មើជាដើម។មួយវិញទៀតដោយផ្ទៃដីនៅតំបន់នេះធ្វើបានតែស្រូវប្រាំង ដូច្នេះត្រូវពឹងផ្អែកទាំងស្រុងទៅលើប្រព័ន្ធធារាសាស្ត្រដូចជា ទំនប់ អាងស្តុបទឹក ប្រឡាយ និងទ្វារទឹក ក៏ប៉ុន្តែប្រព័ន្ធធារាសាស្ត្រដែលជាសេចក្តីត្រូវការនោះ គឺនៅពុំទាន់អាចដោះស្រាយតាមសេចក្តីត្រូវការបានគ្រប់នៅឡើយទេ។ ម៉្យាងវិញទៀត ប្រព័ន្ធធារាសាស្ត្រដូចជាទំនប់ អាងស្តុកទឹក ត្រូវបានសឹករិចរឹល និងគោកស្ទះមិនអាចបំពេញសេចក្តីត្រូវការបានឡើយ ដូច្នេះត្រូវស្តារឡើងវិញដើម្បីធានាការស្រោចស្រពទឹកក្នុងវិស័យកសិកម្ម។ ទន្ទឹមនឹងនេះដែរក៏ត្រូវការនូវបច្ចេកទេសកសិកម្មដូចជា ការប្រើប្រាស់ពូជនិងការប្រើប្រាស់ជីគីមីជាដើម។

ចំពោះបញ្ហាគមនាគមន៍វិញ ថ្វីត្បិតតែមានការអភិវឌ្ឍន៍លើបញ្ហាផ្លូវតាមបណ្តាភូមិនៅក្នុងអាណត្តិមុនៗត្រូវបានជួសជុលមួយចំនួនហើយក៏ដោយ ក៏នៅតែមិនទាន់គ្រប់គ្រាន់តាមសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋបាននៅឡើយទេ។ ជាក់ស្តែងផ្លូវតាមបណ្តាភូមិ គឺនៅមានសភាពលំបាក នៅរដូវវស្សាមានភ្លៀងធ្លាក់ម្តងៗធ្វើឲ្យមានទឹក ដក់ ភក់ជ្រាំ រអិល ពិបាកក្នុងការធ្វើដំណើរ។ បញ្ហាសំខាន់ដែលត្រូវចោទខ្លាំងចំពោះមុខគឺ កំណើន ប្រជាជនពីមួយឆ្នាំទៅមួយឆ្នាំមានការកើនឡើងជាលំដាប់ ប្រជាជនគ្មានការងារធ្វើក៏មានការកើនឡើងជាលំដាប់ ចំណែកផ្ទៃដីសម្រាប់បង្កបង្កើនផលមានតិចតួច ។

### ៤.១.២.ផ្នែកសង្គមកិច្ច

រដ្ឋបាលឃុំវិហារសួគ៌ មានមណ្ឌលសុខភាពមួយកន្លែងដែលសិត្ថនៅភូមិវិហារសួគ៌ជើងប្រជាជនបានទៅទទួលយកសេវាសុខភាពដោយមានការយកចិត្តទុកដាក់ពីបុគ្គលិកនៅមណ្ឌលសុខភាព ចំពោះប្រជាជនក្រីក្រទទួលបានសេវាព្យាបាលដោយមិនបង់ថ្លៃ។ ចំពោះបញ្ហាផ្នែកសុខាភិបាល អ្វីដែលជាបញ្ហាប្រឈមនោះគឺមានប្រជាពលរដ្ឋមួយចំនួនពុំបានយល់ដឹងទៅលើការសម្អាតអនាម័យ ការប្រើប្រាស់បង្គន់អនាម័យ ហើយប្រជាជនមួយចំនួនតូចពុំទាន់មានបង្គន់អនាម័យប្រើប្រាស់នៅឡើយទេនិងមានស្ត្រីមានផ្ទៃពោះមួយចំនួនតូចមិនទៅពិនិត្យផ្ទៃពោះសោះ។ ពិសេសជាងនេះទៅទៀតនោះបញ្ហាសម្រាលកូនដោយពេទ្យឆ្មប គឺនៅមានកម្រិតមូលហេតុដោយមណ្ឌលសុខភាពឃុំមានពេទ្យឆ្មបជំនាញតែម្នាក់ពុំអាចបម្រើការសម្រាលកូនបានទាន់ពេលវេលានោះទេ។ រីឯបញ្ហាប្រឈមមួយទៀតនោះ គឺមណ្ឌលសុខភាពឃុំមិនមានរថយន្តសម្រាប់ដឹកជញ្ជូនអ្នកជម្ងឺដែលត្រូវសង្គ្រោះបន្ទាន់ទេ។

រីឯការអប់រំវិញ យោងតាមទិន្នន័យឆ្នាំ២០២៣នៃកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ (២០២៣-២០២៥) បានបង្ហាញថាកុមារអាយុ៣-៥ឆ្នាំបានចូលរៀន៤៣.៣%, កុមារអាយុ៦ឆ្នាំបានចូលរៀន១០០%, កុមារអាយុ៦-១១ឆ្នាំបានចូលរៀន៨៨.១%, និងកុមារអាយុ១២-១៤ឆ្នាំបានចូលរៀន៩៩.៦%។ ចំណែកឯអ្នកចេះអក្សរអាយុ១៥-១៧ឆ្នាំមាន៩៧.៣% និងអ្នកចេះអក្សរអាយុ១៨-៤៥ឆ្នាំមាន៩៤.៩%។ ជាមួយគ្នានេះ ក្នុងឃុំមានភូមិចំនួន០៨ភូមិមានសាលារៀនសម្រាប់ឱ្យកុមារចូលរៀនចាប់ពីសាលាមត្តេយ្យ បឋមសិក្សា អនុវិទ្យាល័យ ដែលនៅក្នុងនោះរួមមានសាលាបឋមសិក្សាចំនួន០៣កន្លែងដូចជា សាលាបឋមសិក្សាវិហារសួគ៌ សាលាបឋមសិក្សាស្វាយមាសនិងសាលាបឋមសិក្សាព្រៃចាស់ និងមានសាលាអនុវិទ្យាល័យចំនួន០១កន្លែងគឺសាលាអនុវិទ្យាល័យវិហារសួគ៌។ តែក៏នៅមានការខ្វះខាតដោយសារកំណើនសិស្សមានការកើនឡើងជារៀងរាល់ឆ្នាំ ទើបបណ្តាលឱ្យខ្វះខាតអគារសិក្សាទាំងបឋមសិក្សានិងអនុវិទ្យាល័យដែលជាបញ្ហាប្រឈមតម្រូវឱ្យយើងធ្វើការដោះស្រាយជាចាំបាច់។ ម៉្យាងវិញទៀត គឺបញ្ហាមានក្មេងខ្លះមិនបានចូលរៀន ក្មេងខ្លះឈប់រៀន បញ្ហានេះភាគច្រើនជាកូនរស់នៅក្នុងគ្រួសារក្រីក្រដែលស្ត្រីជាមេគ្រួសារ និងគ្រួសារងាយរងគ្រោះដើម្បីជួយធ្វើការងារឪពុកម្តាយឬនៅផ្ទះជួយមើលប្អូនជាដើម។

ចំណែកឯបញ្ហាស្ត្រី និងកុមារ ដោយមានការខិតខំប្រឹងប្រែងពីសំណាក់ក្រុមប្រឹក្សាឃុំនិងគណៈកម្មការនានា ពិសេសគណៈកម្មការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ បញ្ហាសង្គមគ្រួសារពាក់ព័ន្ធរវាងបុរសនិងស្ត្រីឃើញថាបច្ចុប្បន្នរស់នៅក្នុងគ្រួសារបញ្ជាក់បានច្រើនពីភាពស្មើគ្នានូវសិទ្ធិតួនាទី និងការសម្រេចចិត្តផ្សេងៗជាហេតុធ្វើឲ្យមានការកាត់បន្ថយអំពើហឹង្សាក្នុងគ្រួសារជាបណ្តើរៗ តែទន្ទឹមនឹងភាពជោគជ័យនេះឃុំនៅមានបញ្ហាប្រឈមមួយចំនួនទៀតដោយសារបុរសខ្លះនៅយកគ្រឿងស្រវឹងធ្វើជាត្រីមុខដោយខ្វះការយល់ដឹង ហើយប្រព្រឹត្តអំពើមិនគប្បីទៅលើស្ត្រីនិងមានការគាបសង្កត់ផ្សេងៗក្នុងការប្រើប្រាស់សិទ្ធិរបស់ស្ត្រី។ ម៉្យាងទៀតដោយសារ

សមត្ថភាពនារីភូមិនិងគណៈកម្មការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ ក្នុងការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារកុំឱ្យរីករាលដាលក្នុងមូលដ្ឋាននៅមានកម្រិត។ លើសពីនេះទៅទៀតឃុំក៏បានលើកកម្ពស់ស្ត្រីឱ្យមានតួនាទីនៅក្នុងឃុំដែរជាពិសេសការបោះឆ្នោតជ្រើសរើសមេភូមិនិងជំនួយការភូមិកន្លងមកនេះ ក្រុមប្រឹក្សាឃុំបានជ្រើសរើសយកស្ត្រីឱ្យមានតួនាទីដឹកនាំនៅគ្រប់ភូមិឃុំផងដែរ ។

ក្រៅពីនេះ នៅក្នុងឃុំវិហារសួគ៌មានវត្តចំនួន០២កន្លែងរួមមាន វត្តព្រះវិហារសួគ៌ និងវត្តព្រៃលាក់ម្ចាស់ សម្រាប់ឱ្យប្រជាពលរដ្ឋគោរពបូជាទៅតាមប្រពៃណីទំនៀមទម្លាប់តាំងពីដើមរៀងមក ហើយប្រជាជនភាគច្រើនដែលរស់នៅក្នុងឃុំប្រកាន់យកព្រះពុទ្ធសាសនានិងប្រកាន់យកគ្រឹះសាសនាបន្តិចបន្តួច។

### ៤.១.៣.ផ្នែកធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ

ឃុំវិហារសួគ៌មានទន្លេ បឹង អូរ ព្រែក និងព្រៃលិចទឹក និងដីស្រែសម្រាប់ឱ្យប្រជាពលរដ្ឋ បង្កបង្កើនផល និងនេសាទជាលក្ខណៈគ្រួសារដើម្បីទ្រទ្រង់ជីវភាពប្រចាំថ្ងៃបានស្ទើរពេញមួយឆ្នាំ។ប៉ុន្តែអ្វីដែលជាបញ្ហាចោទនោះគឺពីមួយឆ្នាំទៅមួយឆ្នាំស្ថានភាពជាក់ស្តែងនៅក្នុងឃុំមានការប្រែប្រួលឥតឈប់ឈរនិងទទួលរងនូវផលប៉ះពាល់ដោយសារៈ

- ការកាប់បំផ្លាញរុក្ខជាន ព្រៃលិចទឹកដែលជាជម្រកមច្ឆាជាតិ
- ការនេសាទដោយប្រើឧបករណ៍ខុសច្បាប់ ការចាប់កូនត្រីនៅពុំទាន់បំបាត់ចោលអស់ទាំងស្រុងនៅឡើយទេ
- ការចិញ្ចឹមសត្វ ការប្រើថ្នាំពុលនិងការប្រើប្រាស់ជីគីមីនៅមិនទាន់យល់ច្បាស់ពីបរិស្ថានដែលប្រជាជនមួយចំនួនទុកដាក់និងចោលលាមកសត្វគ្មានអនាម័យធ្វើឱ្យប៉ះពាល់ដល់អ្នករស់នៅជិតខាង ខ្លះទៀតប្រើប្រាស់ថ្នាំពុលហើយបោះចោលសំបកពាសវាលពាសកាលមិនទុកដាក់ឱ្យត្រឹមត្រូវទេ ម្យ៉ាងទៀតបាញ់ថ្នាំលើដំណាំនៅក្នុងភូមិធ្វើឱ្យប៉ះពាល់ដល់សុខភាពប្រជាជនដែលរស់នៅក្បែរនោះ
- ការបង្ហូរកាកសំណល់និងផ្សែងពីរោងចក្រ
- ការបោះសំរាមចោលពាសវាលពាសកាលនៅតែបន្តមាន ជាពិសេសតាមដងផ្លូវនិងមាត់ព្រែកជាដើម បើទោះបីជាបច្ចុប្បន្ននេះក្នុងឃុំមានសេវាប្រមូលសំរាមតាមភូមិនិងបានដាក់ស្លាកអប់រំណែនាំក៏ដោយ។

កត្តាអវិជ្ជមានទាំងនេះគឺបណ្តាលមកពីការខ្វះការយល់ដឹងពីច្បាប់បរិស្ថាន និងច្បាប់នានា ចំណែកឯការផ្សព្វផ្សាយច្បាប់ទាំងនេះក៏នៅមិនទាន់បានទូលំទូលាយនិងស៊ីជម្រៅដល់ប្រជាពលរដ្ឋដោយផ្ទាល់នៅឡើយទេ។

### ៤.១.៤.ផ្នែកសេវាកម្មរដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ

ការផ្តល់សេវាជូនប្រជាពលរដ្ឋ រដ្ឋបាលឃុំវិហារសួគ៌បាននឹងកំពុងបម្រើការជាប្រចាំជាពិសេសនោះឃុំមានសាលាឃុំមួយដែលជាអំណោយរបស់រាជរដ្ឋាភិបាលកម្ពុជាផ្តល់ជូនក្រុមប្រឹក្សាឃុំ មិនតែប៉ុណ្ណោះសប្បុរសជនក៏បានជួយសាងសង់របងធ្វើអំពីថ្មដ៏ល្អឥតខ្ចោះជូនក្រុមប្រឹក្សាឃុំថែមទៀត។ លើសពីនេះ ក្រុមប្រឹក្សាឃុំវិហារសួគ៌បានទទួលវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពយ៉ាងច្រើនថែមទៀតពីស្ថាប័ននានារបស់រាជរដ្ឋាភិបាល ក៏ដូចជាដៃគូអភិវឌ្ឍន៍តាមរយៈទីប្រឹក្សាស្រុក មន្ត្រីបច្ចេកទេសនិងមន្ត្រីគាំទ្រឃុំ សង្កាត់ក្នុងការគាំទ្រនិងជួយតម្រង់ទិសដៅលើការអភិវឌ្ឍន៍លើគ្រប់វិស័យជូនសហគមន៍មូលដ្ឋាន។

ទោះបីជាមានការគាំទ្រទាំងសម្ភារៈនិងស្មារតីជាច្រើនយ៉ាងនេះក្តី ក៏ឃុំនៅតែជួបការលំបាកដូចជាការផ្សព្វផ្សាយលិខិតបទដ្ឋាននានា ការទទួលព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋមិនទាន់បានល្អប្រសើរឡើយ ប្រជាការពារមិនទាន់មានវគ្គបណ្តុះបណ្តាលស្តីពីតួនាទីនិងភារកិច្ចនៅឡើយទេ។ចំណែកការងារគ្រប់គ្រងប្រជាពលរដ្ឋមិនទាន់បានល្អ ដោយសារការផ្លាស់ចេញចូលរបស់ប្រជាពលរដ្ឋមិនមានការបញ្ជាក់របស់អាជ្ញាធរមូលដ្ឋានឱ្យបានគ្រប់ៗគ្នា ម៉្យាងដោយការយល់ដឹងរបស់មន្ត្រីនៅមានកម្រិតនៅឡើយ។ រីឯបញ្ហាអត្រានុកូលដ្ឋានមកដល់ពេលនេះ ប្រជាពលរដ្ឋមួយចំនួនតូចមិនទាន់បានចុះបញ្ជីបញ្ជាក់កំណើតនិងអាពាហ៍ពិពាហ៍ ទារកទើបកើតមួយចំនួនតូចមិនបានចុះសំបុត្រកំណើតទាន់ពេលរហូតដល់ពេលចូលរៀនទើបក្រុមគ្រួសារមកចុះដើម្បីបានចូលរៀនរីឯការទុកដាក់ថែរក្សាឯកសារអត្រានុកូលដ្ឋានវិញពួកគាត់មិនបានទុកដាក់ឱ្យបានគត់មុតល្អនោះទេ ទាំងនេះគឺបណ្តាលមកពីពួកគាត់មិនមានការយល់ដឹងពីសារៈសំខាន់របស់ឯកសារនៅឡើយ។ រីឯឃុំក៏ពុំមានឯកសារជាមូលដ្ឋានដែលអាចបញ្ជាក់ថាគាត់បានចុះហើយឬនៅទេ។

ដោយឡែកចំពោះបញ្ហាសន្តិសុខសណ្តាប់ធ្នាប់ អំពើហឹង្សាក្នុងគ្រួសារនៅកើតមានម្តងម្កាល ករណីក្មេងទំនើងនៅមានតិចតួច ល្បែងស៊ីសងនៅមានលួចលេងជាច្រើន ចោរកម្ម លួចទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋពេលយប់ក៏នៅតែមានជារឿយដែលអំពើទាំងនេះ ជាបច្ច័យអាក្រក់ដែលធ្វើឱ្យរាំងស្ទះដល់ការអភិវឌ្ឍន៍ និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋ។ ទោះបីជាមានកិច្ចទប់ស្កាត់ពីកម្លាំងសមត្ថកិច្ចនិងប្រជាការពារក៏ដោយក៏សកម្មភាពទាំងនេះមិនទាន់បានលុបបំបាត់ទាំងស្រុងនៅឡើយនោះទេ។ ទន្ទឹមនឹងនេះ កម្លាំងរបស់ប៉ុស្តិ៍នគរបាលរដ្ឋបាលមានតិចតួចបើធៀបទៅនឹងចំនួនប្រជាជនដែលរស់នៅក្នុងឃុំគឺមានចំនួនច្រើន ដូចនេះវាធ្វើឱ្យពួកគាត់មិនអាចគ្រប់គ្រងបានល្អនោះទេ ហើយមួយវិញទៀតសម្ភារៈដែលសម្រាប់ប្រើប្រាស់ក្នុងប្រតិបត្តិការនៅមានការខ្វះខាតមិនទាន់គ្រប់គ្រាន់និងខ្វះការសហការណ៍ពីសំណាក់ប្រជាពលរដ្ឋថែមទៀតផង។

## ៤.២.ដំណោះស្រាយ

ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមដូចដែលបានរៀបរាប់ខាងលើនោះ ក្រុមប្រឹក្សាឃុំវិហារសួគ៌បានខិតខំយ៉ាងសស្រាក់សស្រាំក្នុងការពិចារណា និងរិះរកមធ្យោបាយគ្រប់វិធីសំដៅធ្វើយ៉ាងណាដើម្បីបំពេញនូវសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋានដោយក្នុងនោះរួមមានៈ

### ៤.២.១.ពង្រឹងវិស័យសេដ្ឋកិច្ច

ជាការពិតណាស់ នៅក្នុងឃុំវិហារសួគ៌ប្រជាជនភាគច្រើននិយមប្រកបមុខរបរកសិកម្មដូចជា ធ្វើស្រូវ ដាំឈូក ដាំបន្លែបង្កាផ្សេងៗនិងចិញ្ចឹមសត្វដូចជា ជ្រូក គោ មាន់ ទាជាដើម។ហេតុនេះហើយទើប មុខរបរទាំងនេះពិតជាសំខាន់ខ្លាំងណាស់សម្រាប់ពួកគាត់ក្នុងការផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។ ទន្ទឹមនឹងនេះ ដើម្បីធ្វើការឆ្លើយតបនឹងបញ្ហានៅក្នុងវិស័យកសិកម្ម ក្រុមប្រឹក្សាឃុំវិហារសួគ៌ក៏បានរៀបចំវគ្គបណ្តុះបណ្តាលពីបច្ចេកទេសកសិកម្មលើការដាំដុះនិងការចិញ្ចឹមសត្វដល់ប្រជាកសិករដែលរស់នៅក្នុងឃុំ ដើម្បីឱ្យពួកគាត់បានយល់ដឹងកាន់តែច្បាស់អំពីរបៀបធ្វើកសិកម្ម។ មួយវិញទៀតយើងសង្កេតឃើញដែរថា ក្រុមប្រឹក្សាឃុំបានខិតខំយ៉ាងសកម្មក្នុងការអនុវត្តលើគម្រោងជាច្រើនដើម្បីឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋពិសេសពាក់ព័ន្ធនឹងផ្នែកជាច្រើនដូចជា ការកសាងនិងស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រសម្រាប់ឱ្យប្រជាជនបង្កបង្កើនផល កែលម្អផ្លូវគមនាគមន៍សម្រាប់ឆ្លងកាត់ទៅវិញទៅមកជាដើម។ ជាក់ស្តែងតាមរយៈការអនុវត្តផែនការអភិវឌ្ឍន៍ឃុំកន្លងមកនេះ ក្រុមប្រឹក្សាឃុំអាណត្តិមុនសម្រេចបានជួសជុលទំនប់បានចំនួន៤កន្លែងមានប្រវែង១៤៣៥៩ម៉ែត្រនិងជួសជុលផ្លូវលំដីសបានចំនួន០៣ខ្សែប្រវែង៥៦១១ម៉ែត្រ។ម្យ៉ាងវិញទៀតដើម្បីឆ្លើយតបទៅនឹងបញ្ហាគមនាគមន៍ដូចដែលយើងបានដឹងហើយថាឱ្យតែចូលដល់រដូវវស្សាដែលជារដូវមួយតែងតែមានភ្លៀងធ្លាក់ខ្លាំងជោគជាំ ផ្លូវលំមួយចំនួនតូចនៅក្នុងឃុំត្រូវរងនូវការខូចខាតលិចទឹក រអិល និងពិបាកធ្វើដំណើរឆ្លងកាត់ណាស់។រីឯផ្លូវបេតុងមួយចំនួនតូចទៀតមានដក់ទឹកតាមដងផ្លូវពេលដែលភ្លៀងបានបង្អុលរួចម្តងៗ នេះដោយសារតែផ្លូវបេតុងខ្លះនៅក្នុងឃុំពេលដែលធ្វើគេមិនបានដាក់លូដើម្បីរំដោះទឹកនោះទេពោលគឺធ្វើផ្លូវចាក់តែមេតុងតែម្តងហើយរួមផ្សំជាមួយផ្ទះនៅសងខាងផ្លូវខ្លះធ្វើខ្ពស់ៗទៀតគឺវាធ្វើឱ្យទឹកមិនទៅណាទេវាគ្រាំនៅនឹង ហេតុនេះដើម្បីដោះស្រាយបញ្ហាទាំងនេះ ក្រុមប្រឹក្សាឃុំវិហារសួគ៌មានការគិតគូរនិងយកចិត្តទុកដាក់យ៉ាងខ្លាំងដើម្បីបញ្ចៀសនូវបញ្ហានេះ ក្នុងនោះផងដែរក្រុមប្រឹក្សាឃុំបានធ្វើការសហការជាមួយមេភូមិក្នុងភូមិដែលមានបញ្ហានោះកើតឡើងចុះធ្វើការរំដោះទឹកភ្លាមៗ ដើម្បីកុំឱ្យមានទឹកជនលិចផ្លូវរហូតដល់អាចបណ្តាលឱ្យផ្លូវទាំងនោះរងការខូចខាតជាទម្ងន់ និងអាចធ្វើឱ្យប្រជាពលរដ្ឋពិបាកធ្វើដំណើរឆ្លងកាត់ថែមទៀតផង។ ក្រៅពីនេះ ផ្លូវលំនៅតាមបណ្តាលភូមិមានច្រើនខ្សែណាស់ ហើយផ្លូវទាំងនោះឱ្យតែរដូវវស្សាចូលមកដល់គឺដឹងតែរអិល ដក់ទឹក បែកភក់ ពិបាកធ្វើដំណើរ ហេតុនេះដើម្បីឆ្លើយតបនឹងសភាពការណ៍នេះ យើងសង្កេតឃើញថាតាមរយៈការយកចិត្តទុកដាក់របស់មេភូមិតាមភូមិនីមួយៗនៅពេលពួកគាត់ពិនិត្យឃើញថា ផ្លូវលំតូចៗ

មួយខ្សែណាមានការខូចខាត ហើយផ្លូវនោះមានអ្នកធ្វើដំណើរឆ្លងកាត់ច្រើនជាញឹកញប់ មេភូមិនឹងលើកជាគំនិត ឬមតិយោបល់កែលម្អផ្លូវទាំងនោះដោយចាក់ដីឈូសឆាយផ្លូវ ឬក្រាលកម្ទេចថ្មជាដើម ដើម្បីបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋក្នុងការធ្វើដំណើរ។ ពិតណាស់ដើម្បីកែលម្អបាននោះ គឺត្រូវប្រើប្រាស់ថវិកាហើយថវិកាទាំងអស់នោះគឺបានមកពីការចូលរួមគាំទ្រពីសំណាក់ប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិផ្ទាល់ដើម្បីរួមចំណែកអភិវឌ្ឍន៍ភូមិ ឃុំឱ្យមានសោភណភាពល្អនិងមានផ្លូវល្អដែលអាចងាយស្រួលធ្វើដំណើរទាំងអស់គ្នា។

**៤.២.២.ពង្រឹងវិស័យសង្គមកិច្ច**

ឃុំមានមណ្ឌលសុខភាពមួយកន្លែង សម្រាប់បម្រើព្យាបាលជូនប្រជាពលរដ្ឋនិងជួយផ្សព្វផ្សាយការថែទាំសុខភាព ការកំចាត់មូសខ្លា ជម្ងឺអេដស៍ ផ្តាសាយបក្សី និងចាក់ថ្នាំការពារ៨មុខដល់កុមារជាដើម។ ជាការពិតណាស់បញ្ហាសុខភាពរបស់ប្រជាពលរដ្ឋគឺជាកត្តាចម្បងនិងសំខាន់បំផុតដែលឃុំត្រូវយកចិត្តទុកដាក់ ធ្វើការអប់រំផ្សព្វផ្សាយឱ្យពួកគាត់រស់នៅស្អាតនិងហូបស្អាតប្រកបដោយអនាម័យ។ ក្នុងនោះផងដែរ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមខាងលើ ក្រុមប្រឹក្សាឃុំនិងមណ្ឌលសុខភាពបានយកចិត្តទុកដាក់ជាខ្លាំងលើស្ត្រីនិងកុមារពិសេសស្ត្រីក្រីក្រ គ្រួសារងាយរងគ្រោះត្រូវទទួលបានការឧបត្ថម្ភថវិកាពីឃុំ និងមានការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋក្នុងការរស់នៅស្អាតប្រកបដោយអនាម័យគិតគូរពីសុខភាព គោរពតាមការណែនាំរបស់គ្រូពេទ្យស្ត្រីមានផ្ទៃពោះត្រូវពិនិត្យផ្ទៃពោះតាមការកំណត់របស់គ្រូពេទ្យនិងទៅសម្រាលកូននៅមណ្ឌលសុខភាព។ រីឯទឹកស្អាតវិញឃុំបានយកចិត្តទុកដាក់ធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យប្រើប្រាស់ទឹកស្អាត និងទឹកឆ្អិនជាដើម។ មួយវិញទៀត ដោយមានការគាំទ្រពីមន្ទីរសុខាភិបាល និងអង្គការទស្សនៈពិភពលោកកន្លងមកនេះបានជួយចាក់ថ្នាំការពារជម្ងឺ៨មុខដល់កុមារ កម្មវិធីពន្យាកំណើតដល់ស្ត្រីរៀបការរួច ធ្វើបង្គន់អនាម័យ និងអណ្តូងទឹកស្អាតផងដែរ។

ចំណែកឯការងារអប់រំវិញ យើងឃើញថានាពេលបច្ចុប្បន្ននេះការអប់រំពិតជាដើរតួនាទីសំខាន់ណាស់សម្រាប់បណ្តុះបណ្តាលដល់យុវជននិងយុវនារីឱ្យក្លាយទៅជាធនធានមនុស្សដ៏ល្អនិងជាសសរទ្រូងដ៏រឹងមាំរបស់ជាតិនាពេលអនាគត។ ដោយឡែកដើម្បីជម្រុញឱ្យប្រជាពលរដ្ឋនៅក្នុងឃុំអាចទទួលបានការអប់រំគ្រប់ៗគ្នា និងដើម្បីកាត់បន្ថយនូវអនក្ខរជននៅក្នុងឃុំឱ្យមកនៅត្រឹមកម្រិតទាប ឬឈានទៅដល់ការលុបបំបាត់ទាំងស្រុងនោះជារៀងរាល់ឆ្នាំឱ្យតែជិតដល់ពេលបើកបវេសនកាលឆ្នាំសិក្សាថ្មី ខាងសាលាក៏ដូចជាខាងឃុំតែងតែសហការគ្នាធ្វើការផ្សព្វផ្សាយឱ្យអាណាព្យាបាលនាំកុមារដែលមានអាយុចាប់ពី៦ឆ្នាំឡើងទៅចុះឈ្មោះចូលរៀន តាមរយៈការប្រើប្រាស់នូវឧឃោសនៈសព្ទ ដើម្បីធ្វើការផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋនៅក្នុងភូមិបានដឹង ហើយនាំកូនដែលគ្រប់អាយុមកចុះឈ្មោះចូលរៀនឱ្យបានគ្រប់ៗគ្នា។ លើសពីនេះ រដ្ឋបាលឃុំក៏ទទួលបានការគាំទ្រពីសំណាក់មន្ទីរអប់រំតាមរយៈការផ្តល់នូវអាហារូបករណ៍សិស្សក្រីក្ររៀនពូកែបឋមសិក្សា និងមធ្យមសិក្សាជូនដល់កុមារក្រីក្រជាដើម។

មួយវិញទៀត ដើម្បីដោះស្រាយបញ្ហាស្រីនិងកុមារ ឃុំមានការយកចិត្តទុកដាក់យ៉ាងខ្លាំងទៅស្ត្រីនិងកុមារ ក្នុងនោះដើម្បីឈានដល់ការលុបបំបាត់នូវអំពើហិង្សាក្នុងគ្រួសារដែលជាមូលហេតុមួយនាំឱ្យស្ត្រី និងកុមារមួយចំនួនត្រូវរងគ្រោះពីការវាយដំ ធ្វើបាប ឃុំនៅតែបន្តជម្រុញផ្សព្វផ្សាយអំពីច្បាប់អំពើហិង្សាក្នុងគ្រួសារដល់ប្រជាពលរដ្ឋឱ្យពួកគាត់បានដឹង និងយល់កាន់តែច្បាស់អំពីច្បាប់ ជាពិសេសផលប៉ះពាល់ដែលបង្កមកពីការប្រើប្រាស់អំពើហិង្សាក្នុងគ្រួសារ និងព្រមទាំងមានការតាមដានជាប្រចាំផងដែរនូវករណីទាំងនេះតាមភូមិនីមួយៗដើម្បីចាត់វិធានការអប់រំទប់ស្កាត់ឱ្យខានតែបាន។ ក្រៅពីនេះ ឃុំក៏មានបើកវគ្គធ្វើការផ្សព្វផ្សាយអំពីសិទ្ធិស្ត្រីនិងកុមារផងដែរ។

### ៤.២.៣.ពង្រឹងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន និងការប្រែប្រួលអាកាសធាតុ

ដើម្បីដោះស្រាយបញ្ហាបរិស្ថាន ក្រុមប្រឹក្សាឃុំវិហារសួគ៌អាណត្តិទី៥នេះបានគិតគូរយ៉ាងខ្លាំងទៅលើបញ្ហានេះដោយខិតខំស្វែងរកការគាំទ្រពីសំណាក់ស្ថាប័នជំនាញពាក់ព័ន្ធនានាដើម្បីមានវិធានការអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋឱ្យមានការយល់ដឹងកាន់តែទូលំទូលាយ និងស៊ីជម្រៅជាងនេះទៅទៀត។ ជាក់ស្តែងនៅក្នុងផ្នែកនេះ ឃុំមានការគាំទ្រពីមន្ទីរជំនាញបានធ្វើការផ្សព្វផ្សាយពីការទប់ស្កាត់បទល្មើសនេសាទច្បាប់បរិស្ថានទូទៅ ការធ្វើទិវាអនាម័យ និងការផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋចេះស្រឡាញ់បរិស្ថាន និងចេះថែរក្សាសម្បត្តិធនធានធម្មជាតិផងដែរ។ ចំពោះបញ្ហាសំរាមនៅតាមដងផ្លូវនៅក្នុងភូមិមួយចំនួន ជារឿយៗខាងឃុំតែងតែមានការសហការជាមួយនាយកសាលាបឋមសិក្សា និងអនុវិទ្យាល័យក្នុងឃុំដឹកនាំកូនសិស្សចូលរួមរើសសំរាមសម្អាតបរិស្ថាននៅតាមដងផ្លូវ ដើម្បីឱ្យសោភណភាពតាមដងផ្លូវនៅក្នុងឃុំកាន់តែមានភាពស្រស់ស្អាតនិងមានជាសុកភាពល្អជាដើម។ មួយវិញទៀត ប៉ុន្មានឆ្នាំចុងក្រោយនេះ ឃុំមានសេវាប្រមូលសំរាមនៅតាមភូមិដោយឃុំបានធ្វើការសហការជាមួយក្រុមហ៊ុនបៃតងប្រមូលសំរាម។ អ្វីដែលជាបញ្ហាចោទនោះ គឺប្រជាពលរដ្ឋមួយចំនួនមិនប្រើប្រាស់សេវាប្រមូលសំរាមទេ ពោលគឺនៅតែបន្តសកម្មភាពចោលសំរាមពាសវាលពាសកាល ជាពិសេសតាមប្រឡាយ ព្រៃ និងតាមផ្លូវមួយចំនួនតូចដែលវាសឹងតែក្លាយទៅជាទម្លាប់ដែលមិនអាចកែប្រែបានភ្លាមៗនោះទេ ពោលគឺត្រូវការពេលវេលាដើម្បីកែប្រែ។ ចំពោះបញ្ហាសំរាមទាំងនេះក្រុមប្រឹក្សាឃុំវិហារសួគ៌បានយកចិត្តទុកដាក់យ៉ាងខ្លាំងដោយក្នុងនោះឃុំបានចេញនូវវិធានមួយចំនួនដើម្បីឆ្លើយតបនឹងបញ្ហានេះរួមមាន ឃុំបានធ្វើការអប់រំណែនាំដល់ប្រជាពលរដ្ឋអំពីច្បាប់បរិស្ថាន ធ្វើការលើកស្លាកអប់រំណែនាំដោយប្រើពាក្យថា(ហាមចោលសំរាម)តាមដងផ្លូវមួយចំនួនតូច និងថែមទាំងដាក់នៅកន្លែងដែលប្រជាពលរដ្ឋចូលចិត្តចោលសំរាមជាងគេទៀតផង។ បន្ថែមទៀតនោះ ខាងឃុំក៏បានចុះទៅអប់រំណែនាំនិងផ្សព្វផ្សាយដល់កុមារនៅតាមបណ្តាលសាលាបឋមសិក្សានិងអនុវិទ្យាល័យក្នុងឃុំក្រោមប្រធានបទស្តីពីថ្ងៃនេះខ្ញុំមិនប្រើប្លាស្ទិកទេ។ លើសពីនេះទៀតឃុំក៏បានដាក់ចេញនូវវិធានការមួយចំនួនទៀត ដោយធ្វើការពិន័យទៅលើបុគ្គលណាដែលបោះសំរាមចោលតាមទីសាធារណៈ

តាមដងផ្លូវ ប្រឡាយ និងព្រៃកជាដើម។ល។និងត្រូវទទួលពិន័យជាប្រាក់ពី ២០០,០០០រៀល ដល់ ៤០០,០០០ រៀល ក្នុងករណីមិនរៀងចាលត្រូវទទួលទោសទៅតាមច្បាប់ជាធរមាន និងមានការផ្សព្វផ្សាយតាមរយៈការចាក់ឧឃោសនៈសព្ទជាសារធារណៈ ដើម្បីឱ្យប្រជាពលរដ្ឋនៅក្នុងឃុំបានជ្រាបពីវិធានការមួយនេះ។ យ៉ាងណាមិញ ការធ្វើបែបនេះក៏ព្រោះតែរដ្ឋបាលឃុំវិហារសួគ៌ចង់ឱ្យប្រជាពលរដ្ឋនៅក្នុងឃុំចូលរួមប្រើប្រាស់សេវាប្រមូលសំរាមទាំងអស់គ្នា ដើម្បីចៀសវាងការយកសំរាមបោះចោលតាមទីសាធារណៈ និងការដុតសំរាមចោលនៅតាមផ្ទះដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាននិងសុខភាពបងប្អូនផងដែរ។ចំពោះការបង្ហូរកាកសំណល់និងទឹកពីរោងចក្រវិញ ក្រុមប្រឹក្សាឃុំក៏បានព្យាយាមខិះខំរកគ្រប់មធ្យោបាយដើម្បីការពារថែរក្សាក្នុងគោលបំណងធានានូវនិរន្តភាព ជីវភាព សុខភាពនិងការរស់នៅប្រកបដោយបរិស្ថានល្អ និងបរិសុទ្ធ។

### ៤.២.៤.ពង្រឹងការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់

ដើម្បីចូលរួមឱ្យការផ្តល់សេវានៅថ្នាក់ក្រោមជាតិមានការរីកចម្រើន និងកាន់តែល្អប្រសើរក្នុងនោះរដ្ឋបាលឃុំបានសហការជាមួយអង្គការអ្នកអភិវឌ្ឍន៍សហគមន៍ (NAS) អនុវត្តគម្រោងមួយដែលគម្រោងនោះ ជាគម្រោងរបស់រាជរដ្ឋាភិបាលតាមរយៈអង្គការក្នុងការបង្កើនការយល់ដឹងអំពីសិទ្ធិពលរដ្ឋ និងការដាក់ពិន្ទុទៅលើអ្នកផ្តល់សេវាថ្នាក់ក្រោមជាតិទាំងបីដែលតម្រូវឱ្យមានការដាក់ពិន្ទុផ្ទាល់ពីប្រជាពលរដ្ឋដែលរួមមានដូចជា សេវារដ្ឋបាលឃុំសង្កាត់ សេវាមណ្ឌលសុខភាព និងសេវាសាលាបឋមសិក្សា ដោយមានការចូលរួមពីសំណាក់បងប្អូនប្រជាពលរដ្ឋ និងសិស្សានុសិស្សថ្នាក់បឋមសិក្សាក្នុងឃុំដើម្បីស្វែងយល់ពីចំណុចខ្លាំងនិងចំណុចមិនទាន់ល្អដែលត្រូវនាំគ្នាប្រជុំពិភាក្សានិងធ្វើការកែលម្អដើម្បីទទួលបានសេវាកម្មល្អ និងមានភាពស្រុះស្រួល និងស្និទ្ធស្នាលគ្នារវាងអ្នកផ្តល់សេវានិងអ្នកទទួលសេវា តាមរយៈអង្គការអ្នកអភិវឌ្ឍសហគមន៍ (NAS) ដែលមានការចុះអនុវត្តការងារផ្ទាល់ដោយអ្នកស្ម័គ្រចិត្តសម្របសម្រួលសហគមន៍ក្នុងឃុំ។ លើសពីនេះទៀតនោះ រដ្ឋបាលឃុំក៏បានបន្តជម្រុញផ្សព្វផ្សាយការងារអត្រានុកូលដ្ឋាន ការធ្វើសៀវភៅស្នាក់នៅ សៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណឱ្យបានកាន់តែទូលំទូលាយដើម្បីឱ្យប្រជាពលរដ្ឋបានយល់ដឹងហើយមកទទួលយកសេវាឱ្យបានគ្រប់ៗគ្នាផងដែរ។

ដោយឡែកដើម្បីឆ្លើយតបនឹងបញ្ហាសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ប្រជាពលរដ្ឋនៅក្នុងឃុំរស់នៅមានសុខសុវត្ថិភាព ដោយមានការគិតគូរដល់ប្រជាពលរដ្ឋរស់នៅក្នុងភូមិនីមួយៗ យើងឃើញថាភូមិនីមួយៗនៃឃុំវិហារសួគ៌មានបំពាក់នូវអំពូលភ្លើងសូឡាតាមដងផ្លូវស្ទើរគ្រប់ទីកន្លែង ដើម្បីបង្កជាលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋធ្វើដំណើរពេលយប់ ហើយអំពូលភ្លើងទាំងនោះគឺបានមកពីការឧបត្ថម្ភពីសប្បុរសជននានា។ ក្រៅពីនេះ ដើម្បីធ្វើការដោះស្រាយបញ្ហាសន្តិសុខ ក្មេងទំនើង បញ្ហាបងធំបងតូច ល្បែងស៊ីសង អំពើហិង្សា ចោរកម្ម និងលួចទ្រព្យសម្បត្តិជាដើមនោះ ប៉ុន្តែរដ្ឋបាលឃុំវិហារសួគ៌និងកម្លាំងប្រជាការពារបានសហការគ្នាចុះបង្ក្រាបបទល្មើសគ្រប់ប្រភេទដែលកើតមានឡើងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មិនថាគ្រឿងញៀន ល្បែងស៊ីសង និងកន្ទុយ

លេខនោះទេ។ លើសពីនេះ ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំនៅតែបន្តធ្វើការផ្សព្វផ្សាយឱ្យកាន់តែទូលំទូលាយដល់ប្រជាពលរដ្ឋអំពីគោលនយោបាយភូមិ ឃុំមានសុវត្ថិភាពទាំង៧ចំណុច និងច្បាប់អំពើហិង្សាក្នុងគ្រួសារ និងធ្វើការចែកលេខទូរស័ព្ទរបស់កម្លាំងប៉ូលីសជូនដល់ប្រជាពលរដ្ឋក្នុងភូមិនីមួយៗដើម្បីងាយស្រួលទំនាក់ទំនងក្នុងករណីមានបញ្ហាណាមួយកើតឡើង ប្រជាពលរដ្ឋអាចធ្វើការរាយការណ៍ទៅសមត្ថកិច្ចបានទាន់ពេលវេលាជាដើម។ មួយវិញទៀត ដោយសារនៅក្នុងឃុំវិហារសួគ៌មានតំបន់អភិវឌ្ឍន៍7NG ដោយនៅតំបន់នេះមានអ្នកថ្មីៗផ្លាស់មករស់នៅទីនេះច្រើន អ្វីដែលបញ្ហាចោទគឺយើងអត់អាចដឹងទាំងអស់ថា អ្នកណាល្អ អ្នកណាអាក្រក់នោះទេ ហេតុនេះ ដើម្បីដោះស្រាយរឿងនេះ ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំបានយកចិត្តទុកដាក់ត្រួតពិនិត្យ និងតាមដានយ៉ាងខ្លាំងដើម្បីកំណត់នូវមុខសញ្ញា ហើយធ្វើការគ្រប់គ្រងជនខិលខូចទាំងនោះឱ្យទាន់ពេលវេលាជៀសវាងអ្នកទាំងនោះបង្កភាពអសន្តិសុខដល់អ្នករស់នៅក្នុងឃុំនិងអ្នកធ្វើដំណើរតាមផ្លូវជាដើម។ ក្នុងករណីខ្លះតាមរយៈការទទួលបានព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋអំពីជនខិលខូចដែលបានធ្វើសកម្មភាពនៅកន្លែងណាមួយ ប៉ុស្តិ៍នឹងធ្វើការចាត់កម្លាំងភ្លាមៗដើម្បីតាមដាន ត្រួតពិនិត្យនិងឈានដល់ការគ្រប់គ្រងនូវជនខិលខូចទាំងនោះ។ ជាក់ស្តែងកន្លងមកនេះក្រោយពីបានព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋដែលបានរាយការណ៍កម្លាំងប៉ុស្តិ៍រដ្ឋបាលឃុំវិហារសួគ៌បានធ្វើការតាមដានរហូតឈានដល់មានការចាប់ខ្លួនជនខិលខូចទាំងនោះបានដោយជោគជ័យផងដែរ។

# សេចក្ដីសន្និដ្ឋាន

ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទស្ដីពី"**ការគ្រប់គ្រងរដ្ឋបាលឃុំវិហារសួគ៌**"រួចមក យើងអាចសន្និដ្ឋានបានថា ឃុំ សង្កាត់ជានីតិបុគ្គលនៃនីតិសាធារណៈ ដូច្នោះ រដ្ឋបាលឃុំ សង្កាត់នេះ មិនមែនជាមណ្ឌលរដ្ឋបាលដូចពីមុនទៀតនោះទេ ។ ផ្ទុយទៅវិញ ឃុំ សង្កាត់នាពេលសព្វថ្ងៃនេះបានក្លាយទៅជាសមូហភាពដែនដីមួយដែលមានស្វ័យភាពក្នុងការដឹកនាំ ចាត់ចែងកិច្ចការនានាក្នុងការបម្រើសេវាសាធារណៈនិងការអភិវឌ្ឍមូលដ្ឋាន សំដៅឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពជាក់ស្ដែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។ យោងតាមបញ្ញត្តិរបស់រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ត្រង់មាត្រា១៤៥ថ្មីបានបង្ហាញថា ឃុំ សង្កាត់ជាមណ្ឌលរដ្ឋបាលមួយដែលមានកម្រិតទាបជាងគេនៅព្រះរាជាណាចក្រកម្ពុជា។ ថ្វីត្បិតតែ រដ្ឋបាលឃុំ សង្កាត់គឺជាមណ្ឌលរដ្ឋបាលមួយដែលមានរចនាសម្ព័ន្ធទាបជាងគេក៏ពិតមែន ប៉ុន្តែរដ្ឋបាលឃុំ សង្កាត់ពិតជាដើរតួនាទីយ៉ាងសំខាន់ណាស់ ក្នុងការជួយឱ្យរដ្ឋបាលថ្នាក់កណ្ដាលអាចក្ដោបក្ដាប់បាននូវព័ត៌មានទាំងអស់របស់ប្រជាពលរដ្ឋ ពីព្រោះថារដ្ឋបាលឃុំសង្កាត់គឺជារដ្ឋបាលមូលដ្ឋានមួយដែលនៅជិតនិងកៀកប្រជាពលរដ្ឋ ធ្វើការផ្ទាល់ជាមួយប្រជាពលរដ្ឋ ដឹងច្បាស់ពីសុខទុក្ខ និងដឹងពីតម្រូវការរបស់ប្រជាពលរដ្ឋបានច្បាស់ជាងគេ។ ម៉្យាងវិញទៀត រដ្ឋបាលឃុំ សង្កាត់នាពេលបច្ចុប្បន្ននេះត្រូវបានគ្រប់គ្រងតាមនយោបាយវិមជ្ឈការ ដោយក្នុងនោះរដ្ឋបាលឃុំសង្កាត់ត្រូវដឹកនាំដោយក្រុមប្រឹក្សាមួយមានអាណត្តិ៥ឆ្នាំដែលក្រុមប្រឹក្សានោះកើតឡើងដោយការបោះឆ្នោតជាសកល និងដោយផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាននិងមានសមាជិកពី០៥ទៅ១១រូបដោយផ្អែកតាមភូមិសាស្ត្រនិងប្រជាសាស្ត្ររបស់ខ្លួន ។

យ៉ាងណាមិញ បើយើងក្រឡេកមកមើលរដ្ឋបាលឃុំវិហារសួគ៌ក្នុងអាណត្តិទី៥នេះវិញ ត្រូវបានគ្រប់គ្រងនិងដឹកនាំដោយក្រុមប្រឹក្សាមួយ ដែលសមាសភាពរបស់ក្រុមប្រឹក្សានីមួយៗត្រូវបានប្រកាសទទួលស្គាល់ឱ្យចូលកាន់តំណែងជាផ្លូវការតាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រោយពីបានបិទបញ្ចប់ការបោះឆ្នោតនៅឆ្នាំ២០២២ ក្នុងនោះក្រុមប្រឹក្សាឃុំវិហារសួគ៌មានសមាជិកសរុបចំនួន០៩រូបដែលមាន០១រូបជាប្រធានក្រុមប្រឹក្សានិង០២រូបទៀតជាជំទប់ទី១និងជំទប់ទី២ និងមានសមាជិកផ្សេងទៀតចំនួន០៦រូប ដែលជាក្បាលម៉ាស៊ីនធ្វើការដឹកនាំរដ្ឋបាលឃុំវិហារសួគ៌ក្នុងអាណត្តិទី៥នេះឱ្យឆ្ពោះទៅរកការអភិវឌ្ឍ និងភាពសម្បូររុងរឿងក្នុងឃុំវិហារសួគ៌ផ្ទាល់តែម្ដង។ បន្ទាប់ពីបានចូលកាន់តំណែងរួចមក ក្រុមប្រឹក្សាឃុំវិហារសួគ៌បានខិតខំប្រឹងប្រែង និងគិតគូរយ៉ាងខ្លាំងក្នុងការកំណត់នូវបញ្ហាមួយណាដែលជាតម្រូវការអាទិភាពត្រូវធ្វើមុនគេ និងបញ្ហាមួយណាដែលជាតម្រូវការបន្ទាប់បន្សំដែលត្រូវធ្វើការដោះស្រាយដោយលើកជាយុទ្ធសាស្ត្រដើម្បីមានភាពងាយស្រួលក្នុងការរៀបចំផែនការសំដៅធ្វើយ៉ាងណាឱ្យឃុំមានអភិវឌ្ឍនិងកាន់តែរីកចម្រើន ប្រជាពលរដ្ឋរស់នៅប្រកបដោយជីវភាពធូរធារ និងល្អប្រសើរជាងមុន។ លើសពីនេះទៀត ដើម្បីឱ្យផែនការនេះឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ ក្នុងនោះប្រជាពលរដ្ឋដែលរស់នៅឃុំវិហារសួគ៌ទទួលបានសិទ្ធិយ៉ាងទូលំទូលាយនៅក្នុងការចូលរួមផ្ដល់ជាមតិ

យោបល់និងលើកឡើងពីបញ្ហាក៏ដូចជាតម្រូវការរបស់ពួកគាត់ផ្ទាល់ក្នុងន័យដើម្បីរួមចំណែកអភិវឌ្ឍក្នុងមូលដ្ឋានឃុំឱ្យកាន់តែមានការរីកចម្រើនថែមទៀត។ ក្រៅពីនេះ ផ្អែកតាមរបាយការណ៍ស្ដីពីការអនុវត្តការងាររបស់រដ្ឋបាលឃុំវិហារសួគ៌អាណត្តិទី៥ក្នុងឆ្នាំ២០២៣ បានបង្ហាញថាក្រុមប្រឹក្សាឃុំបានខិតខំបំពេញភារកិច្ចរបស់ខ្លួនយ៉ាងយកចិត្តទុកដាក់ ជាពិសេសក្នុងការផ្ដល់សេវាសាធារណៈផ្សេងៗជូនដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងមូលដ្ឋានមិនថាជាសេវារដ្ឋបាលដែលមានសេវាអត្រានុកូលដ្ឋាននិងការចេញលិខិតបញ្ជាក់ផ្សេងៗ ការសម្របសម្រួលការងារចុះឈ្មោះបោះឆ្នោត ការងារសង្គមកិច្ចដែលមានដូចជាការងារគាំពារសង្គមដោយមានការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រនិងការចេញប័ណ្ណសមធម៌ជូនគ្រួសារក្រីក្រ លើកកម្ពស់ការសិក្សាអប់រំ និងការងារទឹកស្អាតនិងអនាម័យ ការថែរក្សាសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈក្នុងមូលដ្ឋាន ការសម្របសម្រួលដោះស្រាយវិវាទនៅមូលដ្ឋាននិងការងារបរិស្ថានជាដើម ព្រមទាំងខិតខំរិះរកមធ្យោបាយនានាដើម្បីដោះស្រាយនូវបញ្ហាប្រឈម និងទុកលំបាកនានាដែលបានកើតមានឡើងនៅក្នុងឃុំមិនថាទាំង ផ្នែកសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន និងសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈជូនដល់ប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា។ ទាំងនេះគឺសុទ្ធសឹងតែជាសមិទ្ធផលដែលកើតចេញពីការខិតខំប្រឹងប្រែងយ៉ាងសកម្មរបស់ក្រុមប្រឹក្សាឃុំវិហារសួគ៌ ដើម្បីឆ្លើយតបទៅនឹងគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ។

# អនុសាសន៍

ឆ្លងតាមរយៈការសិក្សាស្រាវជ្រាវនិងធ្វើសេចក្ដីសន្និដ្ឋានទៅលើប្រធានបទនេះរួចមក យើងខ្ញុំបានសង្កេតឃើញថាការអនុវត្តការងាររបស់រដ្ឋបាលឃុំវិហារសួគ៌នៅផ្នែកខ្លះ គឺមិនទាន់បានគ្រប់ជ្រុងជ្រោយនៅឡើយនោះទេ ពោលគឺនៅមានចំណុចខ្វះខាតមួយចំនួនដែលត្រូវបំពេញបន្ថែម ដើម្បីឱ្យការអនុវត្តការងាររបស់រដ្ឋបាលឃុំវិហារសួគ៌កាន់តែមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងកាន់តែល្អប្រសើរជាងមុន។ ដូចនេះ ក្នុងនាមយើងទាំងពីររូបជានិស្សិតដែលបានសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ យើងខ្ញុំសូមឆ្លៀតឱកាសដ៏មានតម្លៃនេះដើម្បីធ្វើការផ្ដល់ជាគំនិតយោបល់និងអនុសាសន៍មួយចំនួនក្នុងន័យស្ថាបនាដើម្បីឱ្យឃុំវិហារសួគ៌កាន់តែមានការរីកចម្រើនតទៅមុខទៀតដូចខាងក្រោម៖

- សូមឱ្យអាជ្ញាធរឃុំគួរតែធ្វើការរៀបចំវេទិកាសាធារណៈឱ្យបានទៀងទាត់ហើយប្រសិនបើធ្វើម្ដងមួយភូមិៗគប្បីតែអញ្ជើញប្រជាពលរដ្ឋដែលរស់នៅក្នុងភូមិនោះមកចូលរួមឱ្យបានគ្រប់ៗគ្នា មិនគួរធ្វើការអញ្ជើញប្រជាពលរដ្ឋឱ្យមកចូលរួមចន្លោះៗនោះទេ ព្រោះការធ្វើបែបនេះអាចធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនតូចគាត់អាចគិតថាគាត់ត្រូវបានគេបំបិទសិទ្ធិមិនមានសិទ្ធិពេញលេញក្នុងការចូលរួមបញ្ចេញមតិយោបល់ លើកឡើងពីបញ្ហានិងតម្រូវការរបស់គាត់ផ្ទាល់នោះទេ
- ជាក់ស្ដែងនៅក្នុងឃុំវិហារសួគ៌មានតំបន់អភិវឌ្ឍន៍7NG ហេតុនេះទើបមានរោងចក្រជាច្រើនតាំងទីនៅទីនេះ ធ្វើឱ្យប្រជាពលរដ្ឋជាច្រើននៅក្នុងឃុំមានការងារធ្វើនិងមានប្រាក់ចំណូលសម្រាប់ចិញ្ចឹមជីវិត ប៉ុន្តែទន្ទឹមនឹងភាពវិជ្ជមានទាំងនេះ ក៏មានផលអវិជ្ជមានមួយចំនួនកើតមានឡើងដូចជាការបញ្ចេញផ្សែងពីរោងចក្រដែលអាចធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន និងខ្យល់ដ៏ល្អបរិសុទ្ធដែលអ្នករស់នៅក្បែរនោះស្រូបយកជារៀងរាល់ថ្ងៃផងដែរ។ហេតុនេះ អាជ្ញាធរឃុំគប្បីតែដាំដើមឈើឱ្យបានច្រើនដោយធ្វើការរៀបចំនិងប្រារព្ធទិវាដាំដើមឈើនៅក្នុងសហគមន៍ ដើម្បីលើកកម្ពស់បរិស្ថាន សុខមាលភាពរបស់ប្រជាជននិងអាចបណ្ដុះស្មារតីស្រឡាញ់បរិស្ថាននិងធនធានធម្មជាតិដល់កុមារនិងយុវជនជំនាន់ក្រោយផងដែរ
- កន្លងមកនេះពាក់ព័ន្ធនឹងបញ្ហាសំរាម ឃុំបានដាក់ចេញនូវយុទ្ធសាស្ត្រជាច្រើនដើម្បីឆ្លើយតបតែហាក់បីដូចជាទទួលបាននូវលទ្ធផលតិចតួចនៅឡើយ ក្នុងនោះបន្ថែមពីលើយុទ្ធសាស្ត្រដែលឃុំបានអនុវត្តស្រាប់យើងគិតថាអាជ្ញាធរឃុំគួរតែធ្វើជាខិតបណ្ណផ្សព្វផ្សាយដែលមានភ្ជាប់ជារូបភាព ដោយបង្កប់នូវអត្ថន័យខ្លឹមសារអប់រំណែនាំ និងការពិន័យទៅលើជនណាបោះសំរាមចោលដែលរដ្ឋបាលឃុំបានដាក់ចេញរួចធ្វើការចែកជូនដល់ក្រុមគោលដៅដែលបានកំណត់ទុក។ ការប្រើប្រាស់នូវមធ្យោបាយបែបនេះគឺអាចបញ្ជ្រាបចំណេះដឹងពីបរិស្ថានដល់ប្រជាពលរដ្ឋ ព្រមទាំងអាចធ្វើឱ្យប្រជាពលរដ្ឋរស់នៅក្នុងភូមិងាយយល់និងឆាប់ចាប់បាន

- ស្ថាប័នដែលពាក់ព័ន្ធគួរតែរៀបចំបើកវគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេសបន្ថែមទៅដល់ក្រុមប្រឹក្សា និងបុគ្គលិកឃុំឱ្យច្រើនដើម្បីបង្កើនប្រសិទ្ធភាពការធ្វើកិច្ចការងារព្រោះតាមរយៈការចុះស្រាវជ្រាវទិន្នន័យមួយចំនួនតូចនៅក្នុងសៀវភៅដែលបានចងក្រងឡើងគឺមិនដូចនឹងទិដ្ឋភាពជាក់ស្តែងអាចនិយាយបានថាជាការយកគំរូតាមប៉ុន្តែអត់បានកែសម្រួលឱ្យវាត្រឹមត្រូវស្របទៅតាមបរិបទក្នុងឃុំវិហារសួគ៌
- ជាការពិតណាស់ ការផ្តល់សេវារបស់រដ្ឋបាលឃុំគឺល្អ ហើយដើម្បីឱ្យការផ្តល់សេវានេះកាន់តែត្រឹមត្រូវនឹងស្របតាមស្តង់ដារទៀតនោះ អាជ្ញាធរឃុំគួរតែប្រើប្រាស់កន្លែងផ្តល់សេវាតាមរយៈយន្តការច្រកចេញចូលតែមួយដែលឃុំបានរៀបចំឡើងនោះទៅកុំទុកវាចោលអី។

# ឯកសារយោង

## ក.ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

១.រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣

២.ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១

៣.ច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥

៤.ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥

៥.អនុក្រឹត្យលេខ ២២ អនក្រ.បក ស្តីពីការផ្ទេរមជ្ឈការអំណាច តួនាទី ភារកិច្ចទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២

៦.អនុក្រឹត្យលេខ ២៦ អនក្រ.បក ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ២០០២

៧.ប្រកាសលេខ ១៣២៩ ប្រ.ក ស្តីពីតួនាទី ភារកិច្ច និងសិទ្ធិរបស់ស្មៀនឃុំ សង្កាត់ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ ២០០១

៨.ប្រកាសអន្តរក្រសួងលេខ ២៤២៣ ប្រ.ក ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧

៩.ប្រកាសអន្តរក្រសួងលេខ០០២ សហវ.ប្រក ស្តីពីការជ្រើសរើស និងការកំណត់តួនាទី និងភារកិច្ចរបស់ជំនួយការហិរញ្ញវត្ថុរដ្ឋបាលឃុំ សង្កាត់ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២

១០.ប្រកាសលេខ ៣០០៨ ប្រ.ក ស្តីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ និង សមាជិកក្រុមប្រឹក្សាឃុំ នៃឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២

១១. សេចក្តីណែនាំលេខ ០០៤ ស.ណ.ន ស្តីពីបែបបទ នីតិវិធីនៃការជ្រើសរើសមេភូមិ ការចូលកាន់តំណែង ការផ្លាស់ប្តូរ មេភូមិ ការតែងតាំងជំនួយការមេភូមិ និងតួនាទី ភារកិច្ច របៀបរបបធ្វើការងាររបស់ភូមិ ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០០៦

១២.សេចក្តីណែនាំលេខ ០៥៥ ស.ណ.នស្តីពីនីតិវិធីនៃការជ្រើសរើសបុគ្គលិកក្រៅក្របខ័ណ្ឌរដ្ឋរបស់រដ្ឋបាល ឃុំ សង្កាត់ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០២២

## ខ.សៀវភៅសំខាន់ៗ

១៣.សម្តេចព្រះសង្ឃរាជ ជួន ណាត.១៩៦៧. *វចនានុក្រមខ្មែរ*. ភ្នំពេញ៖ពុទ្ធសាសនាបណ្ឌិត្យ

១៤.បណ្ឌិត សាយ បូរី.២០០៦.*នីតិរដ្ឋបាលទូទៅ*. បោះពុម្ពលើកទី៣.ភ្នំពេញ៖ប្លុស្សំទ្បូទឹស

១៥.នាយកដ្ឋានរដ្ឋបាលមូលដ្ឋាន.២០០៦. *ការជ្រើសរើសមេភូមិ និងជំនួយការមេភូមិ*

១៦.កៅ មុយថង,រៀបរៀង.២០០៨. *ប្រព័ន្ធរដ្ឋបាលកម្ពុជា* .បោះពុម្ពលើកទី១.ភ្នំពេញ៖ អង្គរ

១៧.ឯកឧត្តម ឥត ឃឿន.២០១៨. *ស្ថាប័នរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា* .បោះពុម្ពលើកទី៣.ភ្នំពេញ

១៨.ក្រសួងមហាផ្ទៃ.២០១៩. *ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៅកម្ពុជា*

១៩.សាស្ត្រាចារ្យ ហៀង សាង.២០១៩.*នីតិរដ្ឋបាលទូទៅ*. បោះពុម្ពលើកទី៥. ភ្នំពេញ៖ ស៊ី ហេង

២០.ព្រេង ភារុន.២០២០. *អត្ថបទជំនួយស្មារតីស្តីពីរដ្ឋបាលឃុំ សង្កាត់*

២១.បណ្ឌិត សឿន សោភ័ណ និងអនុបណ្ឌិត សាឡេះ សុវណ្ណារ៉ា,រៀបរៀង.២០២២.*នីតិរដ្ឋបាលទូទៅ*. ភ្នំពេញ៖ អឹម អូរ អេស

២២.សាលាជាតិរដ្ឋបាលមូលដ្ឋាន.២០២២. *ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់*

២៣.អគ្គនាយកដ្ឋានរដ្ឋបាល.២០២៤.*សៀវភៅព័ត៌មានរាជធានី ខេត្ត*

**គ.ឯកសារផ្សេងៗ**

២៤.សន្ធានុក្រមនៃច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

២៥.កម្មវិធីវិនិយោគឆ្នាំ២០១៩

២៦.កម្មវិធីវិយោគបីឆ្នាំរំកិលឆ្នាំ (២០២៣-២០២៥) របស់ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

២៧.ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ(២០២៣-២០២៧) របស់ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

២៨.របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលឃុំវិហារសួគ៌ប្រចាំឆ្នាំ២០២៣

២៩.អនុសារណៈស្តីពីការៀបចំគម្រោងថវិកាឆ្នាំ២០២៣

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

## ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
## ប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

# ឧបសម្ព័ន្ធទី២

# ផែនទីឃុំវិហារសួគ៌


ផែនទីឃុំវិហារសួគ៌
N
W
E
S
0.5
Kilometers
បន្ទីរពេទ្យ
វត្ត
សាលាបឋមសិក្សា
ទួល
ទំនប់
ព្រែកធំ
ព្រែកតូច

# ឧបសម្ព័ន្ធទី៣

## ប្រកាសលេខ ៣០០៨ ប្រ.ក ស្តីពីការទទួលស្គាល់សមាសភាព
## ប្រធានក្រុមប្រឹក្សាឃុំ មេឃុំនិងសមាជិកក្រុមប្រឹក្សានៃឃុំវិហារសួគ៌
## ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ : ៣០០៨ ប្រក

# ប្រកាស

## ស្តីពីការទទួលស្គាល់សមាសភាពប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំ នៃឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៧/០១២ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៦៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២១ ស្តីពីការកំណត់ចំនួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥
- យោងលទ្ធផលនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅឃុំវិហារសួគ៌ លេខកូដ ០៨-០៥៣ នៃខេត្តកណ្តាល (ទម្រង់បែបបទ១១១៨) របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២២

## សម្រេច

**ប្រការ១.-**

ទទួលស្គាល់សមាសភាពជាប្រធានក្រុមប្រឹក្សាឃុំ និងសមាជិកក្រុមប្រឹក្សាឃុំ**វិហារសួគ៌** ស្រុក**ខ្សាច់កណ្តាល** ខេត្ត**កណ្តាល** ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | លោក | ម៉េង ឈាងហេង | ជាប្រធានក្រុមប្រឹក្សាឃុំ |
| ២- | លោក | ហេង ថន | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៣- | លោក | ឈុន លាវ | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៤- | លោក | ហុង បញ្ញា | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៥- | លោក | ម៉ៅ ចូច | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៦- | លោក | ស៊ិន យ៉ន | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៧- | លោកស្រី | ឃឹម សម្បត្តិ | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៨- | លោក | ថុស សុគន្ធ | ជាសមាជិកក្រុមប្រឹក្សាឃុំ |
| ៩- | លោកស្រី | ធី សាវី | ជាសមាជិកក្រុមប្រឹក្សាឃុំ។ |

**ប្រការ២.-**

ទទួលស្គាល់សមាសភាពជាមេឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំ**វិហារសួគ៌** ស្រុក**ខ្សាច់កណ្តាល** ខេត្ត**កណ្តាល** ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- | លោក | ម៉េង ឈាងហេង | ជាមេឃុំ |
| ២- | លោក | ហេង ថន | ជាជំទប់ទី១ |
| ៣- | លោក | ឈុន លាវ | ជាជំទប់ទី២។ |

**ប្រការ៣.-**

ការអនុវត្តការងារប្រធានក្រុមប្រឹក្សាឃុំ មេឃុំ ជំទប់ និងសមាជិកក្រុមប្រឹក្សាឃុំ នៃឃុំ**វិហារសួគ៌** ត្រូវអនុវត្តតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៥.-**

ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៣រោច ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អង្គភាពប្រឆាំងអំពើពុករលួយ
  " ដើម្បីជូនជ្រាប "
- រដ្ឋបាលខេត្ត ស្រុក ឃុំ សាមី
- ដូចក្នុងប្រការ១
  " ដើម្បីមុខការ "
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៤
# សេចក្តីសម្រេចស្តីពីការបង្កើត
# គណៈកម្មាធិការនានារបស់រដ្ឋបាលឃុំវិហារសួគ៌

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តកណ្តាល

សាលាស្រុកខ្សាច់កណ្តាល

រដ្ឋបាលឃុំវិហារសួគ៌

លេខ: 003....ស.ស.រ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មាធិការកសាងផែនការ និងថវិកា ឃុំវិហារសួគ៌

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- យោងអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី ភារកិច្ច ទៅឲ្យក្រុមប្រឹក្សាឃុំ-សង្កាត់
- យោងអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ឃុំ-សង្កាត់
- យោងប្រកាសលេខ ៣៣១ សហវ.ប្រ.ក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងអនុវត្តថវិកាឃុំ-សង្កាត់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងប្រកាសអន្តរក្រសួងលេខ ២៤៣២ ប្រ.ក ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ ឃុំ-សង្កាត់ និងកម្មវិធីវិនិយោគ ឃុំ-សង្កាត់ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ
- យោងប្រកាសអន្តរក្រសួងលេខ ៣៤៤០ ប្រ.ក ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៩ ស្តីពីការកែប្រែប្រការ ៦ នៃប្រកាសអន្តរក្រសួងលេខ ២៤២៣ ប្រ.ក ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ ឃុំ-សង្កាត់ និងកម្មវិធីវិនិយោគ ឃុំ-សង្កាត់ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ
- យោងប្រកាសលេខ ៨០៦០ ប្រ.ក ចុះថ្ងៃពុធ ៣កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ រាជធានីភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ស្តីពីការទទួលស្គាល់សមាស ភាពសមាជិកក្រុមប្រឹក្សាឃុំ ប្រធានក្រុមប្រឹក្សាឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំវិហារសួគ៌
- យោងតាមកំណត់ហេតុប្រជុំក្រុមប្រឹក្សាឃុំវិហារសួគ៌ នាថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០២២
- យោងតាមការចាំបាច់របស់ក្រុមប្រឹក្សាឃុំវិហារសួគ៌។

## សម្រេច

**ប្រការ១:_**

បង្កើតគណៈកម្មាធិការកសាងផែនការ និងថវិកា ឃុំវិហារសួគ៌ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | | |
|---|---|---|---|---|
| ១- | លោក | **ម៉េង ឈាងហេង** | ប្រធានក្រុមប្រឹក្សាឃុំ | ជាប្រធាន |
| ២- | លោក | **ហេង ថន** | ជំទប់ទី១ | ជាអនុប្រធាន |
| ៣- | លោក | **ឈុន លាវ** | ជំទប់ទី២ | ជាសមាជិក |
| ៤- | លោក | **ហុង បញ្ញា** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៥- | លោក | **ម៉ៅ ចូច** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៦- | លោក | **ស៊ិន យ៉ន** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៧- | លោកស្រី | **ឃឹម សម្បត្តិ** | កក្រុមប្រឹក្សាឃុំ | ជាសមាជិក |

| | | | |
|---|---|---|---|
| ៨- លោក | **ថុស សុគន្ធ** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៩- លោក | **សែម សាយ** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ១០-លោកស្រី | **ធីម យុនអ៊ី** | ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ | ជាសមាជិក |
| ១១-លោក | **អឿ យឿន** | មេភូមិព្រៃចាស់ | ជាសមាជិក |
| ១២-លោក | **ឃុយ ពង់** | មេភូមិសេដា | ជាសមាជិក |
| ១៣-លោក | **សាត ភាត់** | មេភូមិវិហារសួគ៌ជើង | ជាសមាជិក |
| ១៤-លោក | **ស្រ៊ឹម សុខឃាន់** | មេភូមិវិហារសួគ៌ត្បូង | ជាសមាជិក |
| ១៥-លោក | **ហឿង ហៀត** | មេភូមិព្រៃធំ | ជាសមាជិក |
| ១៦-លោក | **អ៊ុន អុន** | មេភូមិតាកែវ២ | ជាសមាជិក |
| ១៧-លោក | **ឈឿន ឆុន** | មេភូមិតាកែវ១ | ជាសមាជិក |
| ១៨-លោក | **ជា ហុន** | មេភូមិស្វាយមាស | ជាសមាជិក |
| ១៩-លោក | **លោកស្រីអនុប្រធានភូមិទាំង៧** | | ជាសមាជិក |
| ២០-លោក | **លោកស្រីសមាជិកភូមិទាំង៧** | | ជាសមាជិក |
| ២០-លោកស្រី | **ឆន ឡាក់ឡេង** | ស្មៀនឃុំ | ជាលេខាធិការ |
| ២១-លោក | **ពង់ ផល់** | ជំនួយការហិរញ្ញវត្ថុ | ជំនួយការលេខាធិការ |

**ប្រការ២:_**

- គណ:កម្មាធិការ ខាងលើមានភារកិច្ច ទទួលខុសត្រូវជួយមេឃុំ ក្នុងការរៀបចំកសាងផែនការអភិវឌ្ឍន៍ឃុំ និងរៀបចំថវិកាប្រចាំឆ្នាំរបស់ឃុំ
- គណ:កម្មាធិការកសាងផែនការ និងថវិកាឃុំអនុវត្តនីតិវិធី កសាងផែនការអភិវឌ្ឍន៍ កម្មវិធីវិនិយោគឃុំ និងរៀបចំគម្រោងថវិកាប្រចាំឆ្នាំរបស់ឃុំ តាមអភិក្រមដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ។

**ប្រការ៣ :_**

គណ:កម្មាធិការកសាងផែនការ និងថវិកា ត្រូវអនុវត្តនូវរបៀបរបបធ្វើការ ទៅតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ។

**ប្រការ៤ :_**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្ដីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥:_**

សមាសភាពដូមមានចែងក្នុងប្រការ១ និងអ្នកពាក់ព័ន្ធ ត្រូវអនុវត្តសេចក្ដីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃជន្ទ ៩កើត ខែមាឃ ឆ្នាំខាល ចត្វាស័កព.ស ២៥៦៦
វិហារសួគ៌ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣
**មេឃុំវិហារសួគ៌**

**ម៉េង ឈាងហេង**

*ចម្លងជូន:*
-សាលាខេត្តកណ្ដាល(អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត)
-មន្ទីរផែនការខេត្ត
-សាលាស្រុកខ្សាច់កណ្ដាល
*(ដើម្បីជូនជ្រាប)*
-ដូចប្រការ៥ "ដើម្បីអនុវត្ត"
-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តកណ្តាល
សាលាស្រុកខ្សាច់កណ្តាល
រដ្ឋបាលឃុំវិហារសួគ៌
លេខ: 006/២៣ស.ស.រ

# សេចក្តីសម្រេច
## ស្តីពីការបង្កើតគណៈកម្មការលទ្ធកម្ម ឃុំវិហារសួគ៌

- បានឃើញអនុក្រឹត្យលេខ ៦០ អ.ន.ក្រ ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៦ អ.ន.ក្រ ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឃុំ-សង្កាត់
- យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- បានឃើប្រកាសអន្តរក្រសួងលេខ ០៨៨ ប្រ.ក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ស្តីពីការកសាងផែនការ អភិវឌ្ឍន៍ឃុំ-សង្កាត់
- បានឃើញប្រកាសលេខ ៨០៦០ ប្រ.ក ចុះថ្ងៃពុធ ៣កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ រាជធានីភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការទទួល ស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សា ឃុំវិហារសួគ៌
- ផ្អែកតាមស្មារតីអង្គប្រជុំរបស់ក្រុមប្រឹក្សាឃុំវិហារសួគ៌ នាថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣
- យោងតាមការចំបាច់របស់ឃុំវិហារសួគ៌។

### សម្រេច

**ប្រការ១:**_

បង្កើតគណៈកម្មការលទ្ធកម្មរបស់ឃុំ មួយដែលមានសមាសភាពដូចខាងក្រោម:

| | | | | |
|---|---|---|---|---|
| ១- | លោក | **ម៉េង ឈាងហេង** | ប្រធានក្រុមប្រឹក្សាឃុំ | ជាប្រធាន |
| ២- | លោក | **ហេង ថន** | ជំទប់ទី១ | ជាអនុប្រធាន |
| ៣- | លោក | **ឈុន លាង** | ជំទប់ទី២ | ជាសមាជិក |
| ៤- | លោក | **ហុង បញ្ញា** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៥- | លោកស្រី | **ថុស សុគន្ធ** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៦- | លោកស្រី | **ឆន ឡាក់ឡេង** | ស្មៀនឃុំ | លេខាធិការ |
| ៧- | លោក | **ពង់ ផល់** | ជំនួយការហិរញ្ញវត្ថុ | ជំនួយការលេខាធិការ |

**ប្រការ២:**_

- គណៈកម្មការក្នុងប្រការ១ មានភារកិច្ចទទួលបន្ទុកការងារទាំងឡាយមាន:

១- ធ្វើការវាយតំលៃលើការការងារដេញថ្លៃ របស់អ្នកម៉ៅការ និងអ្នកផ្គត់ផ្គង់

២- ផ្ដល់អនុសាសន៍ លើការសម្រេចចុះកិច្ចសន្យា។

**ប្រការ៣ :_**

គណៈកម្មការលទ្ធកម្មត្រូវធានា:

១- លទ្ធកម្មការងារសាងសង់ ការផ្គត់ផ្គង់សម្ភារៈ និងការផ្ដល់សេវា ប្រព្រឹត្តទៅប្រកបដោយ តម្លាភាព និងសន្សំសំចៃ

២- អ្នកម៉ៅការ និងអ្នកផ្គត់ផ្គង់ ត្រូវធានានិកាសស្មើៗគ្នា ក្នុងការចូលរួមប្រគួតប្រ ប្រជែង ផ្គត់ផ្គង់សម្ភារៈ និងផ្គត់ផ្គង់សេវាក្រោមល័ក្ខណ្ឌតែមួយ

៣- លទ្ធផលនៃការងារលទ្ធកម្មត្រូវប្រកាសជាសាធារណៈ។

**ប្រការ៤ :_**

ស្នាក់ការអចិន្ត្រៃយ៍ របស់គណៈកម្មការលទ្ធកម្ម ស្ថិតនៅសាលាឃុំ។

**ប្រការ៥ :_**

គណៈកម្មការក្នុងប្រការ១នេះ មានសិទ្ធប្រើប្រាស់ត្រារបស់ឃុំ។

**ប្រការ៦:_**

គណៈកម្មការក្នុងប្រការ១ និងស្មៀន ត្រូវអនុវត្តក្នុងសេចក្ដីសម្រេចនេះ ឲ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៩កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦

វិហារសួគ៌ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣

**មេឃុំវិហារសួគ៌**

**ម៉េង ឈាងហេង**

*ចម្លងជូន:*

-សាលាខេត្តកណ្ដាល(អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត)

-មន្ទីរផែនការខេត្ត

-មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត

-មន្ទីរនានាជុំវិញខេត្ត

-សាលាស្រុកខ្សាច់កណ្ដាល

*(ដើម្បីជូនជ្រាប)*

-ដូចប្រការ៦ "ដើម្បីអនុវត្ត"

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តកណ្ដាល
សាលាស្រុកខ្សាច់កណ្ដាល
រដ្ឋបាលឃុំវិហារសួគ៌
លេខ: ០០២...ស.ស.រ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំវិហារសួគ៌

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- យោងអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្ដីពីការធ្វើវិមជ្ឈការអំណាច តួនាទី ភារកិច្ច ទៅឲ្យក្រុមប្រឹក្សាឃុំ-សង្កាត់
- យោងអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ ស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ-សង្កាត់
- យោងសេចក្ដីណែនាំលេខ ០៨២ ស ណ ន/ គ ជ វ វ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៧ ស្ដីពីការរៀបចំ និងការបង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ នៅគ្រប់ឃុំ សង្កាត់ ទូទាំងប្រទេស
- យោងប្រកាសលេខ ៨០៦០ប្រ.ក ចុះថ្ងៃពុធ ៣កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ រាជធានីភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ស្ដីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាឃុំ ប្រធានក្រុមប្រឹក្សាឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំវិហារសួគ៌
- យោងតាមកំណត់ហេតុប្រជុំក្រុមប្រឹក្សាឃុំវិហារសួគ៌ នាថ្ងៃទី០៥ ខែមករា ឆ្នាំ ២០២២។

## សម្រេច

**ប្រការ១:**_

បង្កើតគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំវិហារសួគ៌ ដែលមានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- លោក | **ម៉េង ឈាងហេង** | ប្រធានក្រុមប្រឹក្សាឃុំ | ជាប្រធាន |
| ២- លោក | **ឈុន ណាច** | ជំទប់ទី២ | ជាអនុប្រធាន |
| ៣- លោកស្រី | **ធីម យុនអ៊ី** | ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ | ជាសមាជិកអចិន្ត្រៃយ៍ |
| ៤- លោក | **នន ឡាក់ឡេង** | ស្មៀនឃុំ | ជាលេខាធិការ |
| ៥- លោក | **ធីយ ស៊ីធួន** | ប្រធានមណ្ឌលសុខភាពឃុំ | ជាសមាជិក |
| ៦- លោក | **លី មួយឡេង** | នាយរងប៉ុស្ដិ៍រដ្ឋបាលឃុំ | ជាសមាជិក |
| ៧- លោក | **គី ប៊ុនហេង** | យកអនុវិទ្យាល័យវិហារសួគ៌ | ជាសមាជិក |
| ៨- លោក | **ឡុង សុផល** | នាយកបឋមសិក្សាវិហារសួគ៌ | ជាសមាជិក |
| ៩- លោក | **ហេង ហាក់** | នាយកបឋមសិក្សាស្វាយមាស | ជាសមាជិក |
| ១០-លោក | **រស់ ឡេង** | នាយករងបឋមសិក្សាព្រៃចាស់ | ជាសមាជិក |
| ១១-លោកស្រី | **អៀ យឿន** | មេភូមិព្រៃចាស់ | ជាសមាជិក |
| ១២-លោក | **ឃុយ ពង់** | មេភូមិសេដា | ជាសមាជិក |
| ១៣-លោក | **សាត ភាក់** | មេភូមិវិហារសួគ៌ជើង | ជាសមាជិក |

| | | | |
|---|---|---|---|
| ១៤-លោក | **ស្រីម សុខឃាន់** | មេភូមិវិហារសួគ៌ត្បូង | ជាសមាជិក |
| ១៥-លោក | **ហឿន ហឿន** | មេភូមិព្រៃធំ | ជាសមាជិក |
| ១៦-លោក | **អ៊ុន អុន** | មេភូមិតាកែវ២ | ជាសមាជិក |
| ១៧-លោក | **ហ៊ិន ហូ** | មេភូមិតាកែវ១ | ជាសមាជិក |
| ១៨-លោក | **ជា ហុន** | មេភូមិស្វាយមាស | ជាសមាជិក |

**ប្រការ២**_

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់គណៈកម្មាធិការ ជូនក្រុមប្រឹក្សាឃុំអនុម័ត
- ផ្តល់ទីប្រឹក្សាយោបល់ និងជួយក្រុមប្រឹក្សាឃុំ និងមេឃុំ ចំពោះការងារពាក់ព័ន្ធ កិច្ចការនារី និងកុមារឃុំ
- អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ឲ្យយល់ដឹងអំពីច្បាប់ គោលនយោបាយនានារបស់រដ្ឋ ពាក់ព័ន្ធសិទ្ធិនារី និងកុមារនៅឃុំ និងបំផុសចលនាសហគមន៍លើវិស័យសុខភាព អប់រំកិច្ចការពារ និងការអភិវឌ្ឍន៍កុមារ ព្រមទាំងការចុះបញ្ជីអត្រានុកូលដ្ឋានជូនទារក និងកុមារ
- ទាក់ទាញការគាំទ្រ ដើម្បីឲ្យនារីបានចូលរួមធ្វើសេចក្តីសម្រេច លើការអភិវឌ្ឍន៍នៅមូលដ្ឋានឃុំ
- បង្កើន និងពង្រឹងនូវការប្រាស្រ័យទាក់ទងកិច្ចសហការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាឃុំ និងអ្នកផ្តល់សេវាកម្ម និងអ្នកភូមិ ដែលធ្វើសកម្មភាពជួយនារី និងកុមារក្នុងឃុំរបស់ខ្លួន
- ជួយក្រុមប្រឹក្សាឃុំក្នុងការប្រមូល វិភាគព័ត៌មាន ទិន្នន័យ ពាក់ព័ន្ធនឹងបញ្ហា និងតម្រូវការរបស់នារី និងកុមារ ដើម្បីដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ និងកម្មវិធីវិនិយោគឃុំ
- ចូលរួមអនុវត្ត ពិនិត្យ តាមដាន និងវាយតម្លៃផែនការសកម្មភាពឃុំ ពាក់ព័ន្ធស្ថានភាពនារី និងកុមារ
- តាមដានស្ថានភាពនារី និងកុមារក្នុងឃុំ និងធ្វើរបាយការណ៍ទៀងទាត់ ជូនក្រុមប្រឹក្សាឃុំ ព្រមទាំងដាក់បញ្ចូលទៅក្នុងរបាយការណ៍ឃុំ
- មេឃុំដែលជាប្រធានគណៈកម្មាធិការ ត្រូវមានការទទួលខុសត្រូវចំពោះក្រុមប្រឹក្សារបស់ខ្លួន។ គណៈកម្មាធិការត្រូវសម្របសម្រួល និងសហការយ៉ាងជិតស្និទជាមួយអ្នកផ្តល់សេវាកម្មនានា ផ្នែកសង្គមកិច្ច អ្នកស្ម័គ្រចិត្តភូមិ និងសហគមន៍នៅក្នុងឃុំ ដើម្បីបំពេញតួនាទី ភារកិច្ច ខាងលើឲ្យមានប្រសិទ្ធភាពខ្ពស់។

**ប្រការ៣** :_

គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ ត្រូវអនុវត្តនូវរបៀបរបបធ្វើការតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាឃុំ។

**ប្រការ៤** :_

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥**:_

សមាសភាពដូមមានចែងក្នុងប្រការ១ និងអ្នកពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ៩កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

វិហារសួគ៌ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣

**មេឃុំវិហារសួគ៌**

**ម៉េង ឈានហេង**

*ចម្លងជូន:*

- សាលាខេត្តកណ្តាល
- សាលាស្រុកខ្សាច់កណ្តាល
- ការិយាល័យកិច្ចការនារីស្រុក
  *(ដើម្បីជូនជ្រាប)*
- ដូចប្រការ៥ "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្តកណ្ដាល
សាលាស្រុកខ្សាច់កណ្ដាល
រដ្ឋបាលឃុំវិហារសួគ៌
លេខ: 003/23 ស.ស.រ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មាធិការគ្រោះមហន្តរាយឃុំវិហារសួគ៌

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- យោងអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្ដីពីការធ្វើវិមជ្ឈការអំណាច តួនាទី ភារកិច្ច ទៅឲ្យក្រុមប្រឹក្សាឃុំ-សង្កាត់
- យោងប្រកាសអន្តរក្រសួងលេខ ០៩៨ ប្រក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ស្ដីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ
- យោងប្រកាសលេខ ៨០៦០ប្រ.ក ចុះថ្ងៃពុធ ៣កើត ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស.២៥៦១ រាជធានីភ្នំពេញ ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ស្ដីពីការទទួលស្គាល់សមាស ភាពសមាជិកក្រុមប្រឹក្សាឃុំ ប្រធានក្រុមប្រឹក្សាឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំវិហារសួគ៌
- យោងតាមកំណត់ហេតុប្រជុំក្រុមប្រឹក្សាឃុំវិហារសួគ៌ នាថ្ងៃទី២៧ ខែមករា ឆ្នាំ ២០២៣
- យោងតាមការចាំបាច់របស់ឃុំវិហារសួគ៌។

## សម្រេច

**ប្រការ១:_**

ត្រូវបានង្កើតគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយឃុំវិហារសួគ៌ ដែលមានសមាសភាពដូចខាងក្រោម:

| | | | |
|---|---|---|---|
| ១- លោក | **ម៉េង ឈាងហេង** | ប្រធានក្រុមប្រឹក្សាឃុំ | ជាប្រធាន |
| ២- លោក | **ហេង ថន** | ជំទប់ទី១ | ជាអនុប្រធាន |
| ៣- លោក | **ឈុន ណាវ** | ជំទប់ទី២ | ជាសមាជិក |
| ៤- លោក | **ហុង បញ្ញា** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៥- លោក | **ម៉ៅ ចូច** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៦- លោក | **ស៊ិន យ៉ន** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៧- លោកស្រី | **យឹម សម្បត្តិ** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៨- លោក | **ថុស សុគន្ធ** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៩- លោក | **សែម សាយ** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ១០-លោកស្រី | **ធីម យុនអ៊ី** | ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ | ជាសមាជិក |
| ១១-លោកស្រី | **អឿ យឿន** | មេភូមិព្រៃចាស់ | ជាសមាជិក |

| | | | |
|---|---|---|---|
| ១២-លោក | **ឃុយ ពន់** | មេភូមិសេដា | ជាសមាជិក |
| ១៣-លោក | **សាត ភាក់** | មេភូមិវិហារសួគ៌ជើង | ជាសមាជិក |
| ១៤-លោក | **ស្រ៊ឹម សុខឃាន់** | មេភូមិវិហារសួគ៌ត្បូង | ជាសមាជិក |
| ១៥-លោក | **ហឿន ហៀន** | មេភូមិព្រៃធំ | ជាសមាជិក |
| ១៦-លោក | **អ៊ុន អុន** | មេភូមិតាកែវ២ | ជាសមាជិក |
| ១៧-លោក | **ហ៊ិន ហូ** | មេភូមិតាកែវ១ | ជាសមាជិក |
| ១៨-លោក | **ជា ហុន** | មេភូមិស្វាយមាស | ជាសមាជិក |
| ១៩-លោកស្រី | **ឆន ឡាក់ឡេន** | ស្មៀនឃុំ | ជាលេខាធិការ |
| ២០-លោក | **ពន់ ផល់** | ជំនួយការហិរញ្ញវត្ថុ | ជំនួយការលេខាធិការ |

**ប្រការ២_**

គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយមានភារកិច្ចដូចខាងក្រោម៖

១- អនុវត្តគោលនយោបាយជាតិ ដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងគ្រោះមហន្តរាយ

២- ផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ ពីគ្រោះមហន្តរាយជាយថាហេតុ

៣- ធ្វើរបាយការណ៍ជាបន្ទាន់អំពីការខូចខាត ជាក់ស្តែងដល់គណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយ ស្រុក ខេត្ត

៤- លើកគម្រោងប្រើប្រាស់ថវិកា សម្ភារៈ បរិក្ខា មធ្យោបាយប្រើប្រាស់ និងកម្លាំងសម្រាប់ធ្វើសកម្មភាព។

**ប្រការ៣ :_**

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៤:_**

សមាសភាពដូមមានចែងក្នុងប្រការ១ និងអ្នកពាក់ព័ន្ធ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៩កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

វិហារសួគ៌ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣

**មេឃុំវិហារសួគ៌**

**ម៉េង ឈានឆេង**

*ចម្លងជូន:*

-សាលាខេត្តកណ្តាល

-សាលាស្រុកខ្សាច់កណ្តាល

*(ដើម្បីជូនជ្រាប)*

-ដូចប្រការ៤ "ដើម្បីអនុវត្ត"

-ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៚៚❀៛៛

ខេត្តកណ្តាល
សាលាស្រុកខ្សាច់កណ្តាល
រដ្ឋបាលឃុំវិហារសួគ៌
លេខ: ..007../23 ស្ល.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការគ្រប់គ្រងគម្រោង ឃុំវិហារសួគ៌

## ក្រុមប្រឹក្សាឃុំវិហារសួគ៌

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមុខងារអំណាច តួនាទី និងភារកិច្ចទៅឲ្យក្រុមប្រឹក្សាឃុំ សង្កាត់
- យោងសេចក្តីសម្រេចលេខ.................ចុះថ្ងៃទី.........ខែ.........ឆ្នាំ២០១៧ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពីការដាក់ឲ្យប្រើប្រាស់សៀវភៅណែនាំការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់
- យោងតាមកំណត់ហេតុប្រជុំក្រុមប្រឹក្សាឃុំវិហារសួគ៌ នាថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០២៣

## សម្រេច

**ប្រការ១:_**

បង្កើតគណៈកម្មការគ្រប់គ្រងគម្រោង ឃុំវិហារសួគ៌ ដែលមានសមាសភាពដូចខាងក្រោម:

| | | | | |
|---|---|---|---|---|
| ១- | លោក | **ម៉េង ឈាងហេង** | ប្រធានក្រុមប្រឹក្សាឃុំ | ជាប្រធាន |
| ២- | លោក | **ហេង ថន** | ជំទប់ទី១ | ជាអនុប្រធាន |
| ៣- | លោក | **ឈុន លាវ** | ជំទប់ទី២ | ជាសមាជិក |
| ៤- | លោក | **ហុង បញ្ញា** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៥- | លោក | **ម៉ៅ ចូច** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៦- | លោក | **ស៊ិន យ៉ន** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |

| | | | | |
|---|---|---|---|---|
| ៧- | លោកស្រី | **ឃឹម សម្បត្តិ** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៨- | លោក | **ថុស សុគន្ធ** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ៩- | លោក | **សែម សាយ** | សមាជិកក្រុមប្រឹក្សាឃុំ | ជាសមាជិក |
| ១០- | លោកស្រី | **ឆឹម យុនអ៊ី** | ជនបង្គោលទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ | ជាសមាជិក |
| ១១- | លោកស្រី | **អឿ យឿន** | មេភូមិព្រៃចាស់ | ជាសមាជិក |
| ១២- | លោក | **ឃុយ ពង់** | មេភូមិសេដា | ជាសមាជិក |
| ១៣- | លោក | **សាត ភាក់** | មេភូមិវិហារសួគ៌ជើង | ជាសមាជិក |
| ១៤- | លោក | **ស្រ៊ីម សុខឃាន់** | មេភូមិវិហារសួគ៌ត្បូង | ជាសមាជិក |
| ១៥- | លោក | **ហឿង ហៀង** | មេភូមិព្រៃធំ | ជាសមាជិក |
| ១៦- | លោក | **អ៊ុន អុន** | មេភូមិតាកែវ២ | ជាសមាជិក |
| ១៧- | លោក | **ហ៊ិន ហូ** | មេភូមិតាកែវ១ | ជាសមាជិក |
| ១៨- | លោក | **ជា ហុន** | មេភូមិស្វាយមាស | ជាសមាជិក |
| ១៩- | លោកស្រី | **ឆន ឡាក់ឡេង** | ស្មៀនឃុំ | ជាលេខាធិការ |

**ប្រការ២:_**

- គណៈកម្មការគ្រប់គ្រងគម្រោង មានតួនាទី ភារកិច្ចដូចខាងក្រោម៖

ក).ក្នុងការរៀបចំគម្រោង៖

- ពិនិត្យ និងអនុម័តផែនការសិក្សាគម្រោង
- គ្រប់គ្រងតាត់ចែងដំណើការសិក្សា និងរៀបចំគម្រោង
- រៀបចំសំណើគម្រោងដោយមានជំនួយពីអ្នកជំនួយបច្ចេកទេស
- ពិនិត្យ និងអនុម័តសំណើគម្រោង។

ខ).ក្នុងការអនុវត្តគម្រោង៖

- គ្រប់គ្រងចាត់ចែងដំណើរការអនុវត្តគម្រោង
- រៀបចំប្រជុំចាប់ផ្តើម និងបញ្ចប់នៃការអនុវត្តការងារ រៀបចំប្រជុំពិនិត្យ និងអនុម័តការទូទាត់គម្រោង
- រៀបចំកិច្ចប្រជុំនានា នៅក្នុងអំឡុងពេលអនុវត្តគម្រោង ដើម្បីពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោង។

**ប្រការ៣ :_**

គណៈកម្មការគ្រប់គ្រងគម្រោង ត្រូវអនុវត្តនូវរបៀបរបបធ្វើការងារដូចខាងក្រោម៖

- ប្រធានគណៈកម្មការគ្រប់គ្រងគម្រោង ជាអ្នកកោះប្រជុំ និងជាអធិបតី នៃអង្គប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោង។ ក្នុងករណីប្រធានអវត្តមានត្រូវផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរទៅឲ្យអនុប្រធាន ជាប្រធានស្តីទីប្រធានស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ
- កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោងអាចប្រព្រឹត្តទៅបានលុះត្រាតែមានវត្តមានសមាជិក លើសពីពាក់កណ្តាល នៃសមាជិកគណៈកម្មការទាំងមូល

- សេចក្ដីសម្រេចរបស់អង្គប្រជុំគណៈកម្មការគ្រប់គ្រងគម្រោងអាចយកជាការបាន លុះត្រាតែមានសម្លេងអនុម័តលើសពីពាក់កណ្ដាល នៃចំនួនសមាជិកគណៈកម្មការទាំងមូល។ ប្រសិនបើសម្លេងអនុម័តមានចំនួនស្មើគ្នា សម្លេងរបស់អធិបតីនៃអង្គប្រជុំមានឧត្តមានុភាព
- ប្រធានគណៈកម្មការគ្រប់គ្រងគម្រោងអាចអញ្ជើញបុគ្គលិកមកពីទីភ្នាក់ងារនានា ឬតំណាងអង្គការ សហគមន៍មូលដ្ឋានដែលពាក់ព័ន្ធ និងគម្រោងដើម្បីចូលរួមកិច្ចប្រជុំគណៈកម្មការក្នុងនាមជាអ្នកសង្កេតការ
- គ្រប់កិច្ចប្រជុំរបស់គណៈកម្មការគ្រប់គ្រងគម្រោង ត្រូវមានកំណត់ហេតុដែលរៀបចំដោយលេខាធិការរបស់គណៈកម្មការ និងត្រូវចុះហត្ថលេខាដោយអធិបតី នៃអង្គប្រជុំ។

**ប្រការ៤:_**

សមាសភាពដូមមានចែងក្នុងប្រការ១ និងអ្នកពាក់ព័ន្ធនានា ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៩កើត ខែមាឃ ឆ្នាំខាល ចត្វាស័កព ព.ស ២៥៦៦

វិហារសួគ៌ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣

**មេឃុំវិហារសួគ៌**

ម៉េង ឈាងហេង

*ចម្លងជូន:*

-សាលាខេត្តកណ្ដាល(អង្គភាពរដ្ឋបាលមូលដ្ឋានខេត្ត)
-មន្ទីរផែនការខេត្ត
-សាលាស្រុកខ្សាច់កណ្ដាល
*(ដើម្បីជូនជ្រាប)*
-ដូចប្រការ៤ "ដើម្បីអនុវត្ត"
-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៥
# របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាល
# ឃុំវិហារសួគ៌ប្រចាំឆ្នាំ ២០២៣

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានី ខេត្តកណ្តាល

ក្រុង ស្រុកខ្សាច់កណ្តាល

រដ្ឋបាលឃុំ វិហារសួគ៌

# របាយការណ៍

## ស្តីពី

## ការអនុវត្តការងាររបស់រដ្ឋបាលឃុំ វិហារសួគ៌

## ប្រចាំឆ្នាំ ឆ្នាំ២០២៣

ព.ស.២៥៦៧

ឆ្នាំ២០២៣

## មាតិកានុក្រម

ទំព័រ


សេចក្តីផ្តើម..........................................................................................................

ផ្នែកទី១៖លទ្ធផលការងារសម្រេចបាន ..........................................................................

១.១-ការងាររដ្ឋបាល បុគ្គលិក និងក្រុមប្រឹក្សា..................................................................

១.១.១-លិខិតបទដ្ឋាន.......................................................................................

១.១.២-ស្ថិតិប្រជាពលរដ្ឋ ..................................................................................

១.១.៣-បុគ្គលិកនិងក្រុមប្រឹក្សា

១.១.៤-កិច្ចប្រជុំក្រុមប្រឹក្សា គណៈកម្មាធិការ និងគណៈកម្មការ ..........................................

១.២-ការងារផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគ និងគម្រោងឃុំ សង្កាត់.......................................

១.២.១-ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ ...............................

១.២.២-ការអនុវត្តគម្រោងឃុំ សង្កាត់.......................................................................

១.៣-ការងារថវិកានិងទ្រព្យសម្បត្តិរបស់រដ្ឋបាលឃុំ សង្កាត់......................................................

១.៣.១-ការរៀបចំនិងការអនុម័តថវិកា ......................................................................

១.៣.២-មូលនិធិឃុំ សង្កាត់ .................................................................................

១.៣.៣-ការអនុវត្តថវិកាឃុំ សង្កាត់

១.៣.៤-ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលឃុំ សង្កាត់.................................................

១.៤-ការងារបង្កើតភូមិ បង្រួមភូមិ រំសាយភូមិ និងជ្រើសរើសមេភូមិនិងជំនួយការមេភូមិ .................................

១.៤.១-ការបង្កើតភូមិ ការបង្រួមភូមិ និងការរំសាយភូមិ ...................................................

១.៤.២-ការជ្រើសរើសនិងការតែងតាំងមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ.................................

១.៥-ការងារផ្តល់សេវាសាធារណៈ.........................................................................................

១.៥.១-អត្រានុកូលដ្ឋាននិងអត្តសញ្ញាណកម្ម ..............................................................

១.៥.២-ការចេញលិខិតបញ្ជាក់....................................................................................

១.៥.៣-ការលើកកម្ពស់វិស័យសេវាសង្គមឃុំ សង្កាត់ ...........................................................

១.៥.៤-សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ...................................................................

១.៥.៥-បរិស្ថាននិងធនធានធម្មជាតិ.............................................................................

១.៥.៦-គ្រោះមហន្តរាយនិងជំងឺរាតត្បាត .........................................................................

១.៥.៧-ការសម្រុះសម្រួលនិងការដោះស្រាយវិវាទនៅមូលដ្ឋាន.................................................

១.៥.៨-ការពិនិត្យបញ្ជីឈ្មោះបោះឆ្នោតនិងការចុះឈ្មោះបោះឆ្នោត...............................................

១.៥.៩-កិច្ចសហការជាមួយនឹងសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន ..................

ផ្នែកទី២៖បញ្ហាប្រឈម និងសំណើដោះស្រាយ........................................................................

ផ្នែកទី៣៖ទិសដៅការងារចម្បងៗសម្រាប់អនុវត្តនៅខែបន្ទាប់......................................................

ឧបសម្ពន្ធ៖

ឧបសម្ពន្ធទី១៖ស្ថិតិប្រជាពលរដ្ឋ

ឧបសម្ពន្ធទី២៖ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់

ឧបសម្ពន្ធទី៣៖ឈ្មោះភូមិនិងមគ្គុទ្ទេសក៍សហគមន៍

ឧបសម្ពន្ធទី៤៖ការលើកកម្ពស់វិស័យសេវាសង្គមឃុំ សង្កាត់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកណ្តាល
រដ្ឋបាលស្រុកខ្សាច់កណ្តាល
រដ្ឋបាលឃុំវិហារសួគ៌
លេខ..025/24........រ.ប.ក

ថ្ងៃ................ ខែ.......... ឆ្នាំថោះបញ្ចស័ក ព.ស.២៥៦៧
វិហារសួគ៌,ថ្ងៃទី.15.. ខែ....8....... ឆ្នាំ២០២៣

**របាយការណ៍**
**ស្តីពី**
**ការអនុវត្តការងាររបស់រដ្ឋបាលឃុំ វិហារសួគ៌**
**ប្រចាំឆ្នាំ ឆ្នាំ២០២៣**

**សេចក្តីផ្តើម**

ឃុំវិហារសួគ៌ ជាឃុំមួយក្នុងចំណោមទាំង១២ របស់ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល មានផ្ទៃដីចំនួន ៧០៤,៤០ហិកតា មានព្រំប្រទល់ខាងលិចទល់នឹងសង្កាត់ព្រែកលួង ក្រុងអរិយក្សត្រ ខាងកើតទល់នឹងឃុំសន្លុង ស៊ីធរ ខាងជើងទល់ឃុំសន្លុង និងខាងត្បូងទល់នឹងសង្កាត់បារ៉ែង ក្រុងអរិយក្សត្រ ។

ផ្អែកតាមមុខងាររបស់រដ្ឋបាលឃុំ វិហារសួគ៌ ក្នុងការបម្រើកិច្ចការមូលដ្ឋាននិងផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រដ្ឋបាលឃុំ សង្កាត់បានអនុវត្តសកម្មភាពនិងសម្រេចបានលទ្ធផល ដូចខាងក្រោម៖

**ផ្នែកទី១-លទ្ធផលការងារសម្រេចបាន**

**១.១-ការងាររដ្ឋបាល បុគ្គលិក និងក្រុមប្រឹក្សា**

១.១.១-លិខិតបទដ្ឋាន

ក្នុងឆ្នាំ២០២៣ នេះ រដ្ឋបាលឃុំ វិហារសួគ៌បានទទួលលិខិត និងដាក់ចេញលិខិតមួយចំនួន ដូចខាងក្រោម ៖

តារាងទី១៖លិខិតបទដ្ឋាននានា

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | លិខិតចូល | 89 | 13 | 102 |
| ២ | ដីកាដែលបានដាក់ចេញ | 01 | 00 | 01 |
| ៣ | សេចក្តីសម្រេចដែលបានដាក់ចេញ | 03 | 00 | 03 |
| ៤ | លិខិតរដ្ឋបាលដែលបានដាក់ចេញ (មិនរាប់បញ្ចូលលិខិតបញ្ជាក់នានាឡើយ) | 1092 | 58 | 1150 |

១.១.២-ស្ថិតិប្រជាពលរដ្ឋ

តារាងទី២៖ស្ថិតិប្រជាពលរដ្ឋ

| ល.រ. | ការបរិយាយ | សរុប | ស្រី | ផ្សេងៗ |
|---|---|---|---|---|
| ១ | គ្រួសារសរុប | 4,054 | | |
| ២ | គ្រួសារអេចិន្ត្រៃយ៍ | 3,816 | | |
| ៣ | គ្រួសារបណ្តោះអាសន្ន | 238 | | |
| ៤ | ស្ត្រីជាមេគ្រួសារ | 101 | | |
| ៥ | ប្រជាពលរដ្ឋសរុប | 17,475 | 9,023 | |
| ៦ | កុមារអាយុក្រោម៦ឆ្នាំ | 2,015 | 1,023 | |
| ៧ | កុមារអាយុពី៦ឆ្នាំដល់១៨ឆ្នាំ | 5,403 | 2,749 | |
| ៨ | ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង | 12,576 | 6,437 | |
| ៩ | ប្រជាពលរដ្ឋចំណាកស្រុកក្នុងប្រទេស | 238 | 94 | |
| ១០ | ប្រជាពលរដ្ឋចំណាកស្រុកក្រៅប្រទេស | 123 | 98 | |
| ព័ត៌មានខាងលើនេះ គិតត្រឹមថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣៕ | | | | |

**១.១.៣-បុគ្គលិកនិងក្រុមប្រឹក្សា**

ក-ការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ( គ្មាន )

ខ-ការជ្រើសរើសបុគ្គលិកក្រៅក្របខណ្ឌរដ្ឋ (គ្មាន )

តារាងទី៣៖ស្ថិតិសមាជិកក្រុមប្រឹក្សានិងបុគ្គលិក

| ល.រ. | ការបរិយាយ | សរុប | ស្រី | ផ្សេងៗ |
|---|---|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ | 09 | 01 | |
| ២ | មេឃុំ ចៅសង្កាត់ | 01 | 00 | |
| ៣ | ជំទប់ទី១ ចៅសង្កាត់រងទី១ | 01 | 00 | |
| ៤ | ជំទប់ទី២ ចៅសង្កាត់រងទី២ | 01 | 00 | |
| ៥ | ចំនួនសមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរ( បានចេញប្រកាសផ្លូវការ ) | 00 | 00 | |
| ៦ | ស្មៀនឃុំ សង្កាត់ | 01 | 01 | |
| ៧ | បុគ្គលិកក្រៅក្របខណ្ឌរដ្ឋ( បុគ្គលិកកិច្ចសន្យា ) | 04 | 02 | |
| | -ជំនួយការរដ្ឋបាល | 03 | 02 | |
| | -ជំនួយការហិរញ្ញវត្ថុ | 01 | 00 | |
| | -គ្រូមត្តេយ្យសិក្សាសហគមន៍ | 00 | 00 | |
| | -..................... | | | |
| ព័ត៌មានខាងលើនេះ គិតត្រឹមថ្ងៃទី១៣ខែវិច្ឆិកា ឆ្នាំ២០២៣៕ | | | | |

**១.១.៤-កិច្ចប្រជុំក្រុមប្រឹក្សា គណៈកម្មាធិការ និងគណៈកម្មការ**

**ក-កិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់**

តារាងទី៤៖កិច្ចប្រជុំក្រុមប្រឹក្សា

| ល.រ. | ការបរិយាយ | ចំនួនកិច្ចប្រជុំ | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | 11 | 01 | 12 |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | 12 | 03 | 15 |

| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | 00 | 00 | 00 |
|---|---|---|---|---|

**ខ-កិច្ចប្រជុំគណៈកម្មាធិការនិងគណៈកម្មការ និងក្រុមប្រឹក្សាឃុំ**

- បានចូលរួមប្រជុំប្រចាំខែកញ្ញា របស់គ ក ន ក ឃុំវិហារសួគ៌នៅថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០២៣ អ្នកចូលរួមមាន ២៧នាក់ស្រី ១២នាក់។
- បានចូលរួមប្រជុំប្រចាំខែកញ្ញា របស់ក្រុមប្រឹក្សាឃុំនៅថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០២៣ អ្នកចូលរួមមានចំនួន ៣៤នាក់ស្រី ១១នាក់។
- បានចូលរួមប្រជុំវិសាមញ្ញស្តីពីសំណើសុំសម្ភាសន៍គ្រួសារក្រីក្រសម្រាប់កំណត់អត្តសញ្ញាណគ្រួសារក្រីក្រ នៅថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២៣ សរុបអ្នកចូលរួម ១៨នាក់ស្រី ០៥នាក់។
- បានចូលរួមប្រជុំប្រជុំប្រចាំខែរបស់គ ក ស ក ស្រុកប្រចាំខែកញ្ញា ក្រោមអធិបតីភាពលោកស្រី ម៉ៅ ចំរើន សរុបអ្នកចូលរួម ៣១នាក់ស្រី ២៦នាក់។
- បានចូលរួមប្រជុំពិភាក្សា គម្រោងសកម្មភាពជាអទ្វិភាពជាមួយអង្គការ CAS នៅថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០២៣ ស្តីពីការងារគណនេយ្យភាពសង្គម ក្នុងមូលដ្ឋានភូមិ ឃុំ សាលារៀន មណ្ឌលសុខភាព អ្នកចូលរួម ១២នាក់ ស្រី ០៦នាក់។
- បានចូលរួមប្រជុំជាមួយអង្គការAARជប៉ុន នៅសាលាព្រៃធំ ឃុំសន្លុងស្តីពីការអប់រំថ្នាក់សមាហរណកម្ម លើវិស័យពិការភាពនៃសមាគមន៍សម្រាប់ជំនួយសង្គ្រោះនៃប្រទេសជប៉ុន អ្នកចូលរួម ១២នាក់ស្រី ០៧នាក់។
- នៅថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០២៣ រដ្ឋបាលឃុំវិហារសួគ៌បានបើកកិច្ចប្រជុំស្តីពីការងារ គ ក ន ក ប្រចាំខែតុលា ឆ្នាំ២០២៣សរុបអ្នកចូលរួម ២៩នាក់ស្រី ១១នាក់ ។
- នៅថ្ងៃទី ១២ ខែតុលា ឆ្នាំ២០២៣រដ្ឋបាលឃុំវិហារសួគ៌បានបើកកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាឃុំលើកទី ១៦ អាណត្តិទី៥ សរុបអ្នកចូលរួម ២៦នាក់ស្រី០៧នាក់។
- នៅថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣រដ្ឋបាលឃុំវិហារសួគ៌បានរៀបចំកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាឃុំស្តីពីការវាយតម្លៃការអនុវត្តការងាររបស់អ្នកទទួលគម្រោងមូលនិធិឃុំឆ្នាំ២០២៣។
- នៅថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០២៣រដ្ឋបាលឃុំបានបើកកិច្ចប្រជុំប្រចាំត្រីមាសស្តីពីការងារគណនេយ្យភាពសង្គមសរុបអ្នកចូលរួមមាន ២៥នាក់ស្រី ០៦នាក់។
- នៅថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០២៣ បានចូលរួមប្រជុំស្តីពីការចុះអង្កេត អនាម័យ បរិស្ថានទឹកស្អាតនៅក្នុងសហគមន៍(អូនីអេសផ្តើស កំរិតខ្ពស់)ក្រោមការសម្របសម្រួលរបស់លោក ញ៉ែម រិទ្ធិ មន្រ្តីសាលាស្រុកខ្សាច់កណ្តាល អ្នកចូលរួម ១៨នាក់ ស្រី០៣នាក់ ។

តារាងទី៥៖កិច្ចប្រជុំគណៈកម្មាធិការនិងគណៈកម្មការ

| ល.រ. | ការបរិយាយ | ចំនួនកិច្ចប្រជុំ | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារីនិងកុមារឃុំ សង្កាត់"គ.ក.ន.ក." | 11 | 01 | 12 |
| ២ | គណៈកម្មាធិការកសាងផែនការនិងថវិកាឃុំ សង្កាត់"គ.ផ.ថ." | 03 | 00 | 03 |
| ៣ | គណៈកម្មាធិការលទ្ធកម្ម | 05 | 00 | 05 |
| ៤ | ............................... | | | |

**១.២-ការងារផែនការអភិវឌ្ឍន៍និងកម្មវិធីវិនិយោគ និងគម្រោងឃុំ សង្កាត់**

១.២.១-ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

- ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

តារាងទី៦៖ផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

| ជំហាន | លទ្ធផលជាក់ស្តែង |
|---|---|
| ជំហានទី១៖ការវិភាគស្ថានភាពនិងការកំណត់តម្រូវការអភិវឌ្ឍន៍ឃុំ សង្កាត់ | • បានរៀបចំរួចរាល់ |
| ជំហានទី២៖ការរៀបចំនិងការចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ | • បានរៀបចំរួចរាល់ |
| ជំហានទី៣៖ការពិនិត្យ ការអនុម័ត និងការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ | • បានរៀបចំរួចរាល់ |

- វិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

តារាងទី៧៖កម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់

| ជំហាន | លទ្ធផលជាក់ស្តែង |
|---|---|
| ជំហានទី១៖ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ | • បានរៀបចំរួចរាល់ និងបញ្ជូនទៅរដ្ឋបាលស្រុកខ្សាច់កណ្តាល |
| ជំហានទី២៖ការរៀបចំសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ | • មិនទាន់បានដំណើរការ |
| ជំហានទី៣៖ការពិនិត្យ ការអនុម័ត និងការផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលឃុំ សង្កាត់ | • មិនទាន់បានដំណើរការ |

១.២.២-ការអនុវត្តគម្រោងឃុំ សង្កាត់

តារាងទី៨៖ការអនុវត្តគម្រោងឃុំ សង្កាត់

| ល.រ. | ផ្នែក | សរុបគម្រោង | ចំនួនគម្រោងបានបញ្ចប់ | | |
|---|---|---|---|---|---|
| | | | ការសិក្សាគម្រោង | វិធីសាស្រ្តលទ្ធកម្ម | ការអនុវត្តកិច្ចសន្យា |
| ១ | សេដ្ឋកិច្ច | 1គម្រោង ស្ថិតនៅភូមិព្រៃធំ និងភូមិតាកែវ១ | ដោយលោក មួង ឌុល មន្រ្តីបច្ចេកទេសហេដ្ឋារចនាសម្ព័ន្ធខេត្តប្រចាំស្រុក | ដេញថ្លៃ | បានបញ្ចប់ |
| ២ | សង្គមកិច្ច | 17គម្រោង | | | |

**១.៣-ការងារថវិកានិងទ្រព្យសម្បត្តិរបស់រដ្ឋបាលឃុំ សង្កាត់**

១.៣.១-ការរៀបចំនិងការអនុម័តថវិកា

១.៣.២-មូលនិធិឃុំ សង្កាត់

តារាងទី៩៖មូលនិធិឃុំ សង្កាត់

| ល.រ. | ការបរិយាយ | សរុបប្រចាំឆ្នាំ | ថវិកាបានទទួល(គិតជាលានរៀល) | | |
|---|---|---|---|---|---|
| | | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | មូលនិធិផ្នែករដ្ឋបាល | 279 | 139.5 | 139.5 | 279 |
| ២ | មូលនិធិផ្នែកអភិវឌ្ឍន៍ | 211 | 105.5 | 105.5 | 211 |
| សរុបរង | | 490 | 245 | 245 | 490 |
| ៣ | ថវិកាវិនិយោគឬមូលនិធិបន្ថែមផ្នែកអភិវឌ្ឍន៍ | 12 | 6 | 6 | 12 |

| ល.រ. | ការបរិយាយ | សរុបប្រចាំឆ្នាំ | ថវិកាបានទទួល(គិតជាលានរៀល) | | |
|---|---|---|---|---|---|
| | | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ៤ | ថវិកាពីប្រភពផ្សេងៗទៀត | 00 | 00 | 00 | 00 |
| | សរុបរង | 12 | 6 | 6 | 12 |
| | សរុបរួម | 502 | 251 | 251 | 502 |

១.៣.៣-ការអនុវត្តថវិកាឃុំ សង្កាត់

តារាងទី១០៖ស្ថានភាពចំណូលចំណាយ

| ជំពូក | ចំណាត់ថ្នាក់ | ឥណទានអនុញ្ញាត | ជាក់ស្តែង (បូកយោង) | ភាគរយ |
|---|---|---|---|---|
| ផ្នែកចំណូល | | | | |
| 70 | ចំណូលសារពើពន្ធក្នុងស្រុក | 00 | 00 | 0% |
| 72 | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | 00 | 00 | 0% |
| 73 | ផលទុនពីការលក់ ជួលទ្រព្យសម្បត្តិ និងសេវា | 00 | 00 | 0% |
| 74 | ចំណូលពីការដាកពិន័យនិងការដាក់ទណ្ឌកម្ម | 00 | 00 | 0% |
| 75 | ការឧបត្ថម្ភ និងអំណោយ | 608,622,500 | 608,622,500 | 75.69% |
| 76 | ផលហិរញ្ញវត្ថុ | 00 | 00 | 0% |
| 77 | ផលផ្សេងៗ និងផលពិសេស | 00 | 00 | 0% |
| | សរុបចំណូល | 608,622,500 | 608,622,500 | 75.69% |
| ផ្នែកចំណាយ | | | | |
| 60 | ការទិញ | 14,530,000 | 14,530,000 | 49.90% |
| 61 | សេវាកម្ម | 270,873,508 | 270,873,508 | 50.73% |
| 64 | បន្ទុកបុគ្គលិក | 146,500,000 | 146,500,000 | 66.01% |
| 66 | បន្ទុកហិរញ្ញវត្ថុ | 00 | 00 | 0% |
| 62 | អត្ថប្រយោជន៍សង្គម | 4,929,732 | 4,929,732 | 55.21% |
| 65 | ឧបត្ថម្ភធន | 00 | 00 | 0% |
| 63 | ពន្ធនិងអាករ | 00 | 00 | 0% |
| 67 | បន្ទុកពិសេស | 00 | 00 | 0% |
| 68 | ទាយជ្ជទានឱ្យដល់រំលស់អចលកម្ម | 00 | 00 | 0% |
| 69 | ចំណាយមិនបានគ្រោងទុក | 00 | 00 | 0% |
| 20 | អចលកម្មអរូបី | 00 | 00 | 0% |
| 21 | អចលកម្មរូបី | 00 | 00 | 0% |
| 23 | អចលកម្មកំពុងដំណើរការ | 00 | 00 | 0% |
| | សរុបចំណាយ | 436,833,240 | 436,833,240 | 54.20% |

១.៣.៤-ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលឃុំ សង្កាត់

តារាងទី១១៖ទ្រព្យសម្បត្តិរបស់រដ្ឋបាលឃុំ សង្កាត់

| ល.រ. | ការបរិយាយ | ឯកតា | ចំនួន | | | ស្ថានភាព |
|---|---|---|---|---|---|---|
| | | | ដើមគ្រា | ក្នុងគ្រា | បូកយោង | |
| ១-អចលនទ្រព្យ | | | | | | |
| | - ដី | កន្លែង | 04 | 04 | 04 | |
| | - អគារ | ទីតាំង | 01 | 01 | 01 | |
| ២-ឧបករណ៍ សម្ភារៈ និងបរិក្ខារ( យានយន្ត ម៉ាស៊ីន ត ...) | | | | | | |
| | - ទោចក្រយានយន្ត | គ្រឿង | 01 | 01 | 01 | មានសភាពចាស់ |
| | - សម្ភារ និងសង្ហារឹម | គ្រឿង | 34 | 34 | 34 | |

**១.៤-ការងារបង្កើតភូមិ បង្រួមភូមិ រំសាយភូមិ និងជ្រើសរើសមេភូមិនិងជំនួយការមេភូមិ**

១.៤.១-ការបង្កើតភូមិ ការបង្រួមភូមិ និងការរំសាយភូមិ

១.៤.២-ការជ្រើសរើសនិងការតែងតាំងមេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ

នៅក្នុង ឆ្នាំ២០២៣ ឃុំវិហារសួគ៌បានធ្វើការផ្លាស់ប្តូរមេភូមិរងចំនួន ០១រូបនៅក្នុងភូមិស្វាយមាស បានប្តូរពីលោក កើត កឿន ទៅលោក ផាន់ ស្រឿន វិញ ។

តារាងទី១២៖មេភូមិ អនុប្រធានភូមិ និងសមាជិកភូមិ

| ល.រ. | ការបរិយាយ | សរុប | ស្រី | ផ្សេងៗ |
|---|---|---|---|---|
| ១ | មេភូមិ | 08 | 01 | |
| ២ | អនុប្រធានភូមិ | 08 | 02 | |
| ៣ | សមាជិកភូមិ | 08 | 07 | |
| ព័ត៌មានខាងលើនេះគិតត្រឹមថ្ងៃទី១៣ខែវិច្ឆិកា ឆ្នាំ២០២៣៕ | | | | |

**១.៥-ការងារផ្តល់សេវាសាធារណៈ**

១.៥.១-អត្រានុកូលដ្ឋាននិងអត្តសញ្ញាណកម្ម

តារាងទី១៣៖អត្រានុកូលដ្ឋាននិងអត្តសញ្ញាណកម្ម

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| | អត្រានុកូលដ្ឋាន | | | |
| ១ | សំបុត្រកំណើត | 314 | 40 | 354 |
| ២ | សេចក្តីចម្លងសំបុត្រកំណើត | 320 | 50 | 370 |
| ៣ | សំបុត្របញ្ជាក់កំណើត | 135 | 08 | 143 |
| ៤ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | 156 | 10 | 166 |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍( ខ្មែរនិងខ្មែរ) | 71 | 05 | 76 |
| ៦ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍( ខ្មែរនិងខ្មែរ) | 76 | 05 | 81 |
| ៧ | សំបុត្រអាពាហ៍ពិពាហ៍( ខ្មែរនិងបរទេស) | 03 | 01 | 04 |
| ៨ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍( ខ្មែរនិងបរទេស) | 05 | 03 | 08 |
| ៩ | សំបុត្រមរណភាព | 86 | 06 | 92 |
| ១០ | សេចក្តីចម្លងសំបុត្រមរណភាព | 102 | 06 | 108 |
| អត្តសញ្ញាណកម្ម( ករណីមានការផ្តល់សេវាពីប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់) | | | | |

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | សៀវភៅស្នាក់នៅ(ក២) | 108 | 15 | 123 |
| ២ | សៀវភៅគ្រួសារ(ក៤) | 14 | 05 | 19 |
| ៣ | អត្តសញ្ញាណបណ្ណ | 1362 | 50 | 1412 |
| | សរុប | | | |

១.៤.២-ការចេញលិខិតបញ្ជាក់

តារាងទី១៤៖ការចេញលិខិតបញ្ជាក់

| ល.រ. | បរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | លិខិតបញ្ជាក់ភាពនៅលីវ ឬមេម៉ាយ ឬពោះម៉ាយ | 90 | 02 | 92 |
| ២ | លិខិតបញ្ជាក់លំនៅ | 57 | 02 | 59 |
| ៣ | លិខិតបញ្ជាក់លើកិច្ចសន្យាខ្ចីប្រាក់ | 125 | 10 | 135 |
| ៤ | លិខិតបញ្ជាក់ពីប្រវត្តិដីធ្លី | 152 | 05 | 157 |
| ៥ | លិខិតបញ្ជាក់ទាយាទ | 48 | 00 | 48 |
| ៦ | លិខិតបញ្ជាក់កិរិយាមាយាទ | 23 | 06 | 29 |
| ៧ | លិខិតបញ្ជាក់ប្រវត្តិរូបសង្ខេប | 67 | 04 | 71 |
| ៨ | លិខិតបញ្ជាក់ទិញលក់សត្វពាហនៈ(គិតជាក្បាល) | 06 | 00 | 06 |
| ៩ | លិខិតបញ្ជាក់តបណ្តាញអគ្គិសនី | 00 | 00 | 00 |
| ១០ | លិខិតបញ្ជាក់តបណ្តាញទឹកស្អាត | 00 | 00 | 00 |
| ១១ | លិខិតបញ្ជាក់ជួលដី ផ្ទះ តូប យានជំនិះ | 31 | 00 | 31 |
| ១២ | លិខិតបញ្ជាក់ផ្ទះជួលបន្ទប់ស្នាក់នៅ | 19 | 01 | 20 |
| ១៣ | បញ្ជាក់លើលិខិតស្នាមផ្សេងៗទៀត(លិខិតដែលមិនមែនជាសមត្ថកិច្ចរបស់ស្ថាប័នណាមួយ) | 00 | 00 | 00 |

១.៤.៣-ការលើកកម្ពស់វិស័យសេវាសង្គមឃុំ សង្កាត់

- បានចូលរួមជាមួយអង្គការមេត្រីអន្តរជាតិ ចុះទៅភូមិព្រៃចាស់បាននាំយកស្ត្រីដែលរស់នៅមណ្ឌល របស់អង្គការមកជួបឪពុកម្តាយ នៅចំណុច7NGអោយធ្វើកិច្ចសន្យារបស់ស្ត្រី ត្រូវជាកូនរបស់គាត់បាន ចាកចេញពីអង្គការទៅធ្វើការក្រៅមណ្ឌលអង្គការ(ចូលបំរើជាកម្មកររោងចក្រ) ហើយអង្គការបានជួយឧបត្ថម្ភថ្លៃជួលផ្ទះរស់នៅក្នុង០១ខែ១០ដុល្លារ ក្នុងនោះដែលអង្គការមានសម្ភារៈមួយចំនួន ជូនដល់ឪពុកម្តាយរបស់ស្ត្រីនោះមាន អង្ករ១០គ ក ទឹកត្រីចៀកកាំ០១យួរ សាប៊ូម្សៅ១កញ្ចប់ធំ ប៊ីចេង០១កញ្ចប់ ដុំស៊ុបខ្នរ ០១ប្រអប សរុបជាទឹកប្រាក់ ៨៥,០០០រៀល។
- បានចូលរួមជាមួយអង្គការ ការីតាស់ចុះភូមិស្វាយមាសបាននាំយកស្រីឈ្មោះ ឈន ធារី អាយុ ២២ឆ្នាំបានវិលត្រឡប់ពីប្រទេសចិនមករួមរស់ជាមួយក្រុមគ្រួសារឪពុកម្តាយវិញ ។
- បានឧបតកថម្ភថវិកាគ ក ន កចំនួន៥០,០០០រៀលជួយដល់ស្ត្រីក្រីក្រមានផ្ទៃពោះគ្រប់ខែសម្រាលតែខ្ទះ ឈាម នៅភូមិព្រៃចាស់។
- បានបើកថវិកា គ ក ន កឃុំ ជូនដល់កុមារមានពិការភាព០២នាក់ចំនួន ១០០,០០០រៀលសម្រាប់ថ្លៃដេកជញ្ជូនទៅសាលាព្រៃធំ ឃុំសន្លុង។

បានចូលរួមជាមួយអង្គការ HAGAR យកស្ត្រីឈ្មោះ ឃន កញ្ញា អាយុ២១ឆ្នាំ ដែលបានវិលត្រឡប់ពីប្រទេសចិន អោយមករស់នៅជាមួយគ្រួសារវិញហើយអង្គការបានឧបត្ថម្ភអង្ករ ២៥គ ក ព្រមទាំងសម្ភារៈប្រើប្រាស់មួយចំនួនជូនដល់ក្រុមគ្រួសារស្ត្រីនោះផងដែរ។

- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការលើកកម្ពស់ភាពជាអ្នកដឹកនាំ ស្ត្រីធ្វើមក្នុងវិស័យទឹកស្អាត និងអនាម័យប្រកបដោយបរិយាបន្ន នៅថ្ងៃទី ៧ -៨ ខែកញ្ញា ឆ្នាំ២០២៣ នៅសាលាស្រុកខ្សាច់កណ្តាលអ្នកចូលរួម ៤២នាក់ ។
- បានចុះជម្រុញដល់ប្រជាពលរដ្ឋដែលប្រើបង្គន់រួមបើមានលទ្ធិភាពសូមអោយធ្វើបង្គន់ផ្ទាល់ខ្លួន ដាច់ដោយឡែកពីឪពុកម្តាយ បានចំនួន ០៥គ្រួសារ។
- បានចុះអប់រំតាមគ្រួសារអោយចេះមានអនាម័យបរិស្ថាន និងនៅតាមលំនៅដ្ឋាន និងទុកដាក់សម្រាមអោយបានត្រឹមត្រូវនៅតាមភូមិ បានចំនួន ០៧គ្រួសារ។
- បានចុះពន្យល់ដល់ស្ត្រីមានផ្ទៃពោះអោយទៅពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាពបានចំនួន ០៥នាក់។
- បានចុះសួរសុខទុកស្ត្រីឆ្លងទន្លេច អប់រំអោយចេះថែទាំសុខភាពម្តាយនិងកូន បានចំនួន ០៥នាក់។
- បានបើកថវិកាគ ក ន ក ជូនដល់កុមារមានពិការភាពសំរាប់ដឹកជញ្ជូនទៅសាលារៀនប្រចាំខែចំនួន ៣នាក់ក្នុងម្នាក់៥០,០០០រៀលសរុបបីនាក់អស់ ១៥០,០០០រៀលក្នុង១ខែ។
- បានចុះអប់រំដល់គ្រួសារដែលប្រើប្រាស់បង្គន់រួម បើមានលទ្ធភាពអោយធ្វើបង្គន់បែកចេញពីឪពុកម្តាយបងប្អូនបានចំនួន ៧គ្រួសារ។
- បានចុះសួរសុខទុក្ខស្ត្រីសំរាលកូនរួចបានចំនួន៦នាក់ អប់រំអោយចេះថែរទាំសុខភាពម្តាយនិងកូនអោយបានល្អ។
- បានចុះជម្រុញស្ត្រីមានផ្ទៃពោះអោយទៅពិនិត្យផ្ទៃពោះនៅមណ្ឌលសុខភាពបានចំនួន ០៦នាក់។
- បានចុះអប់រំអំពីអនាម័យបរិស្ថាន ការទុកដាក់សម្រាមអោយបានត្រឹមត្រូវនិងនៅតាមដងផ្លូវអោយចេះសំអាតអោយបានល្អ ជៀសវាងការចោលសម្រាមពាសវាលពាសកាល។

១.៥.៤-សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ

- នៅថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០២៣ ឧត្តមសេនីយត្រី នាន់ បូរ៉េន នាយករងនាយកដ្ឋានវិស្វកម្មក្រសួងការពារជាតិ និងលោកវរសេនីយ៍ឯក ហៀង គឹមម៉េង មេបញ្ជាការរង កងវិស្វកម្មលេខ ១៧៩ ស្ពាន-ថ្នល់ ក្រសួងការពារជាតិ បានចុះពិនិត្យមើលផ្លូវបេតុងមួយខ្សែ និងលូប្រអប់សងខាងផ្លូវមានប្រវែង ៧៧០ម ទទឹង ៦ម ជាគម្រោងផែនការឆ្នាំ២០២៣ ត្រូវបានបញ្ចប់ការសាងសង់១០០% ស្ថិតនៅភូមិវិហារសួគ៌ត្បូង។ហើយលោកក៏បានបន្តចុះសិក្សាលើសំណើគម្រោងកែលម្អផ្លូវបេតុងអាមេចំនួន២ខ្សែ សម្រាប់ផែនការគម្រោង ឆ្នាំ២០២៤ ស្ថិតនៅភូមិសេដា និងភូមិស្វាយមាស ។
- នៅថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០២៣ លោក មួង ឌុល មន្ត្រីបច្ចេកទេសខេត្តនិងមន្ត្រីជំនាញថ្នាក់ស្រុក បានចុះពិនិត្យផ្លូវបេតុងអាមេគម្រោងមូលនិធិឃុំឆ្នាំ២០២៣ ជំហ៊ានទី២ ដែលមានប្រវែង២,១៨៤ម ទទឹង៥ម កម្រាស់០,១៥ម ស្ថិតក្នុងភូមិព្រៃធំ និងភូមិតាកែវ១ ។
- នៅថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០២៣ លោកស្រី ឡុង ណារី អភិបាលរងស្រុក តំណាងលោកចេង ឌីណា អភិបាលនៃគណៈអភិបាលស្រុកខ្សាច់កណ្តាលរួមជាមួយលោក ស្រឿន រដ្ឋា អនុប្រធានការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថានស្រុក ក្រុមប្រឹក្សាឃុំវិហារសួគ៌ លោកគ្រូនាយក នយករង សាលាអនុវិទ្យាល័យ និងបឋមសិក្សាវិហារសួគ៌ លោកគ្រូ អ្នកគ្រូ នៃសាលាទាំងពីរបានចុះអប់រំផ្សព្វផ្សាយដល់ប្អូនៗ សិស្សានុសិស្សទាំងអស់ អំពីគុណវិបត្តិនៃថង់ប្លាស្ទិក និងការកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិកនៅតាមមូលដ្ឋាន និងទីសាធារណៈក្រោមប្រធានបទ"ថ្ងៃនេះខ្ញុំមិនប្រើប្រាស់ថង់ប្លាស្ទិកទេ និង រួមគ្នាកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទិក" ព្រមទាំងចុះអប់រំណែនាំ និងត្រួតពិនិត្យការលក់ចំណីអាហារនៅតាម

សាលាទាំង៣កម្រិតមានមត្តេយ្យសិក្សា បឋមសិក្សា និងអនុវិទ្យាល័យវិហារសួគ៌ ។

- នៅថ្ងៃទី ០១ ខែតុលា ឆ្នាំ២០២៣ លោក ម៉េង ឈាងហេង មេឃុំវិហារសួគ៌បានចុះពិនិត្យមើលផ្លូវគម្រោងមូលនិធិឃុំឆ្នាំ២០២៣ ស្ថិតនៅភូមិតាកែវ១។
- នៅថ្ងៃទី ០៦ ខែតុលា ឆ្នាំ២០២៣លោក ផុន គីម បានឧបត្ថម្ភជួងចំនួន០១គ្រឿងដល់សាលាបឋមសិក្សាវិហារសួគ៌( សាលាលិចទឹក )។
- នៅថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០២៣លោក យ៉ាន់ រឿន អភិបាលរងស្រុកខ្សាច់កណ្តាលបានចុះពិនិត្យមើលសកម្មភាព បូមទឹករបស់ប្រជាពលរដ្ឋទាំងពីរភូមិមានភូមិសេដា និងភូមិព្រៃចាស់ ប្រជាជនរងគ្រោះដោយទឹកលិចស្រូវនៅចំណុចទុងហើរ មានចំនួន ៣៨ហិចតា បានដំណើរការអស់រយៈពេល០២ថ្ងៃ ក្នុងនោះដែលលោកអភិបាលរង យ៉ាន់ រឿន បានឧបត្ថម្ភប្រេងម៉ាសូតចំនួន ១០កាន ដោយមានការសហការជាមួយក្រុមហ៊ុន 7NG ផងដែរ។
- នៅថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០២៣ លោកស្រីអភិបាលរងស្រុក និងលោកប្រធានការិយាល័យសុខាភិបាលស្រុកចូលរួមជាមួយក្រុមគ្រូពេទ្យមណ្ឌលសុខភាពវិហារសួគ៌បានចុះចាក់វ៉ាក់សាំងការពារជំងឺមហារីក មាត់ស្បូនជូនកុមារីនៅក្នុងសាលាបឋមសិក្សាវិហារសួគ៌។
- នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៣លោក យ៉ាន់ រឿន អភិបាលរងស្រុកតំណាងលោក ចេង ឌីណាអភិបាលនៃគណៈអភិបាលស្រុកខ្សាច់កណ្តាល ក្រុមប្រឹក្សាឃុំ លោកស្រីមេភូមិព្រៃចាស់ បាននាំយកថវិការបស់លោកអភិបាលស្រុកដើម្បីចុះសួរសុខទុក្ខយុវតីថ្នាក់ទី៨ (ឃ) ម្នាក់នៃអនុវិទ្យាល័យសន្លុងដែលរស់នៅក្នុងភូមិព្រៃចាស់ដែលបានជួបគ្រោះថ្នាក់ចរាចរណ៍ពេលកំពុងត្រឡប់មកពីធ្វើពលកម្មសម្អាតបរិស្ថានតាមដងផ្លូវជាតិលេខ៨ថវិការួមមាន លោកអភិបាលស្រុក ១០០,០០០រៀល និងលោកស្រី ណេង ដាលីស មេឃុំសន្លុង ៥០,០០០រៀល ។

តារាងទី១៥៖សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ

| ល.រ. | បរិយាយ | ចំនួនគិតជាករណី | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | គ្រោះថ្នាក់ចរាចរណ៍ | 02 | 01 | 03 |
| ២ | គ្រោះថ្នាក់ផ្សេងៗ | 01 | 01 | 02 |
| ៣ | បទល្មើសគ្រឿងញៀន | 04 | 00 | 04 |
| ៤ | បទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ | 00 | 00 | 00 |
| ៥ | បទល្មើសសេដ្ឋកិច្ច | 00 | 00 | 00 |
| ៦ | ល្បែងស៊ីសង | 00 | 00 | 00 |
| ៧ | ក្មេងទំនើង | 02 | 00 | 02 |
| ៨ | បទល្មើសផ្សេងៗ | 14 | 01 | 15 |
| ៩ | ........................ | | | |
| | ........................ | | | |

១.៤.៥-បរិស្ថាននិងធនធានធម្មជាតិ

- នៅថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ២០២៣ សមាជិកក្រុមប្រឹក្សាឃុំនិងលោកមេភូមិរង ភូមិវិហារសួគ៌ត្បូងបានចុះពិនិត្យទីតាំងដាក់ស្លាក (ហាមចោលសម្រាម)នៅចំណុចក្រោយសាលាលិចទឹកក្នុងភូមិវិហារសួគ៌ត្បូង។
- នៅថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២៣ លោក លោកស្រីសមាជិកក្រុមប្រឹក្សាឃុំវិហារសួគ៌ និងកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាល និងលោកនាយកសាលាវិហារសួគ៌បានចុះធ្វើការណែនាំអ្នកលក់ចំណីអាហារក្នុងទីធ្លា

សាលារៀនណែនាំអោយគាត់ផ្អាកលក់ចំណីអាហារនិងភេសជ្ជៈដែលធ្វើអោយប៉ះពាល់ដល់សុខភាពរបស់កូនសិស្សដោយគោរពតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

- នៅថ្ងៃទី ២៨ ខែកញ្ញាឆ្នាំ២០២៣ លោក យ៉ាន់ រឿន អភិបាលរង តំណាងលោក ចេង នីណា អភិបាលនៃគណៈអភិបាលស្រុកបានដឹកនាំកម្លាំងប៉ុស្តិ៍ ក្រុមប្រឹក្សាឃុំ មេភូមិ ចុះធ្វើអនាម័យបរិស្ថាន តាមទីសាធារណៈ រៀបចំសន្តិសុខសណ្តាប់ធ្នាប់ ចរាចរណ៍នៅផ្សារវិហារសួគ៌ និងវត្តព្រះវិហារសួគ៌។
- នៅថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០២៣រដ្ឋបាលឃុំវិហារសួគ៌ ដែលមានការសហការចូលរួមពីសំណាក់លោក លោកស្រី ក្រុមប្រឹក្សាឃុំ កម្លាំងប៉ុស្តិ៍រដ្ឋបាលឃុំ លោក លោកស្រីមេភូមិទាំង៨ លោកនាយកសាលាបឋមទាំង៣ក្នុងឃុំវិហារសួគ៌លោកគ្រូ អ្នកគ្រូនៃសាលាអនុវិទ្យាល័យវិហារសួគ៌ កម្លាំងប្រជាការពារភូមិទាំង៨ និងប្អូនៗសិស្សានុសិស្សនៃសាលាហ៊ុន សែន ROTA ខ្សាច់កណ្តាល បានចូលរួមធ្វើការកាប់ព្រៃ សម្អាតបរិស្ថានតាមដងផ្លូវជាតិលេខ៨ ចេញពីចំណុចសាលាROTA ទៅដល់ចំណុចស្ពានព្រះគន្លង ដែលដឹកនាំដោយលោក ជា គឹមឡេង អភិបាលរងស្រុកនិងលោក លឹម ស៊ីលាង អភិបាលរងស្រុក តំណាងលោកចេង នីណា អភិបាលនៃគណៈអភិបាលស្រុកខ្សាច់កណ្តាល និងមន្ត្រីសាលាស្រុកមួយចំនួន។
- នៅថ្ងៃទី ២៩ខែតុលា ឆ្នាំ២០២៣ ដោយមានការចង្អុលបង្ហាញពីលោកស្រីម សុខឃាន់ មេភូមិវិហារសួគ៌ត្បូងនិងដឹកនាំដោយរូបខ្ញុំបាទអនុប្រធានភូមិរួមជាមួយប្រជាការពារភូមិបានធ្វើការសម្អាតបរិស្ថាននៅ បរិវេនសាលាលិចទឹកដោយធ្វើការកាត់ស្មៅ កាប់ព្រៃ និងដុតសម្រាមដែលនៅរាយប៉ាយជិតសាលា។

### ១.៥.៦-គ្រោះមហន្តរាយនិងជំងឺរាតត្បាត

នៅក្នុងឃុំវិហារសួគ៌ប្រជាជនបានជួបប្រទះនិងជំងឺគ្រុនឈាមមានច្រើនទាំងចាស់ទាំងក្មេង រីឯជំងឺភ្នែកក្រហមមានតិចតួច។

### ១.៥.៧-ការសម្រុះសម្រួលនិងការដោះស្រាយវិវាទនៅមូលដ្ឋាន

តារាងទី១៦៖ការដោះស្រាយវិវាទនៅមូលដ្ឋាន

| ល.រ. | ការបរិយាយ | ចំនួន | | |
|---|---|---|---|---|
| | | ដើមគ្រា | ក្នុងគ្រា | បូកយោង |
| ១ | ចំនួនករណីទំនាស់ដែលឃុំ សង្កាត់បានទទួល | 88 | 06 | 94 |
| ២ | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយឃុំ សង្កាត់ | 72 | 04 | 76 |
| ៣ | ករណីដែលបានបញ្ជូនទៅសមត្ថកិច្ចបន្ត ឬស្ថាប័នពាក់ព័ន្ធ | 10 | 00 | 10 |

### ១.៥.៨-ការពិនិត្យបញ្ជីឈ្មោះបោះឆ្នោតនិងការចុះឈ្មោះបោះឆ្នោត

ឃុំវិហារសួគ៌ប្រជាជនបានចុះឈ្មោះនៅក្នុងបញ្ជី គ ជ ប សម្រាប់ ខែតុលា ឆ្នាំ២០២២មានដូចក្នុងតារាងខាងក្រោម៖

តារាងទី១៧៖ការចុះឈ្មោះអ្នកបោះឆ្នោត

| ល.រ. | បរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | ប្រជាពលរដ្ឋគ្រប់អាយុបោះឆ្នោតមិនទាន់បានចុះឈ្មោះបោះឆ្នោត | | |
| ២ | ប្រជាពលរដ្ឋដែលបានចុះឈ្មោះថ្មីក្នុងបញ្ជីបោះឆ្នោត | | |
| ៣ | ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីចុះឈ្មោះអ្នកបោះឆ្នោត | | |
| ៤ | ប្រជាពលរដ្ឋសរុបដែលមានឈ្មោះក្នុងបញ្ជីចុះឈ្មោះបោះឆ្នោត | 10,013 | 5,295 |
| សម្គាល់៖ព័ត៌មានខាងលើនេះ គិតត្រឹមថ្ងៃទី.....ខែ..... ឆ្នាំ២០២... ។ | | | |

### ១.៥.៩- កិច្ចសហការជាមួយនឹងសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន

### ១.៥.១០- ការអនុវត្តការងាររបស់គូមិនិងអង្គភាពពាក់ព័ន្ធ

- ភូមិព្រៃចាស់

នៅក្នុងខែតុលាឆ្នាំ២០២៣ ប៉ុស្តិ៍នគបាលវិហារសួគ៌បានចុះបង្ក្រាបក្មេងទំនើងចំនួន ២នាក់បានបញ្ជូនទៅសាលាខេត្តតាខ្មៅ។ក្រុមការងាររាជរដ្ឋាភិបាលចុះជួយភូមិព្រៃចាស់បានដឹកនាំដោយលោក ស៊ាង ដារ៉ា និងសហការីបានយកថវិកាមកចូលបុណ្យសពឈ្មោះ សឿន ឈិន ភេទប្រុស ចំនួនថវិកា ១០០,០០០រៀល។ នៅថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០២៣លោក យ៉ាន រឿន អភិបាលរងស្រុកខ្សាច់កណ្តាលបានជួយឧបត្ថម្ភប្រេងម៉ាសូត៣០០លីត្រដើម្បីបូមទឹកបញ្ចេញទឹកភ្លៀងដែលទឹកលិចស្រូវប្រជាពលរដ្ឋនៅចំណុចទួលនឹម ។បានចុះសម្ភាសន៍គ្រួសារក្រីក្របានចំនួន ១៤៣នាក់ និងបានចុះឈ្មោះបោះឆ្នោតថ្មីក្នុងឆ្នាំ២០២៣ បានចំនួន ២៥នាក់ស្រី១៧នាក់ផ្ទេរចូលចំនួន ០៤នាក់ស្រី ០៣នាក់។

- ភូមិសេដា

នៅក្នុងភូមិសេដាអំពើហិង្សាគ្មាន ល្បែងស៊ីសង់នៅមានបន្តិចបន្តួច មានករណីចោរកម្ម០១ករណីឈ្មោះ ពង់ ផល្លី ភេទស្រី អាយុ៤៣ឆ្នាំរស់នៅភូមិសេដា ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល បានធ្វើដំណើរទៅផ្សារវិហារសួគ៌ជិតដល់ចំណុចផ្លូវឆ្លងចូលភូមិវិហារសួគ៌ជើងត្រូវបានចោរឆក់កាបូបលុយបណ្តាលអោយដួលរងរបួសធ្ងន់បាក់ឆ្អឹងជង់កាំបិត ហេតុការណ៍បានកើតនៅថ្ងៃ ៣១ ខែតុលា ឆ្នាំ២០២៣ វេលាម៉ោង ៤:៣០នាទីទាបភ្លឺ។បានចុះសម្ភាសន៍គ្រួសារក្រីក្របានចំនួន ១៣២កគ្រួសារ និងបានចុះឈ្មោះបោះឆ្នោតថ្មីខែតុលា ឆ្នាំ២០២៣បានចំនួន ២៨នាក់ស្រី ១៧នាក់ ផ្ទេរចូល១នាក់។ក្រុមការងាររាជរដ្ឋាភិបាលចុះជួយភូមិសេដាបាននាំយកថវិកាចំនួន ១,០០០,០០០រៀលជូនលោក យុយ ពង់ មេភូមិសេដាដែលបានសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យ។

- ភូមិវិហារសួគ៌ជើង

ក្នុងភូមិវិហារសួគ៌ជើង នៅរដូវវស្សាធ្វើស្រូវ៥ហិចតា ឈូក៤ហិចតា សន្តិសុខសណ្តាប់ធ្នាប់បានល្អ ល្បែងស៊ីសង់នៅមាន ការផ្សព្វផ្សាយ សម្អាតបរិស្ថាននៅក្នុងភូមិនិងតាមដងផ្លូវបានល្អប្រសើរ គ្រឿងញៀននៅមាន។ ពេលភ្លៀងផ្លូវលំលិចទឹកគ្រប់ផ្លូវបានប្រជាជននៅតាមដងផ្លូវជួយកាយប្រឡាយ បង្ហូរទឹកទៅព្រែកដើម្បីរំដោះទឹកបានល្អ។

- ភូមិវិហារសួគ៌ត្បូង

ក្នុងខែតុលា ឆ្នាំ២០២៣ នេះសន្តិសុខសណ្តាប់ធ្នាប់នៅក្នុងភូមិមានសភាពល្អបន្តិចឡើងវិញ ដោយសារប៉ូលីសនិងប្រជាការពារបានចាប់បានក្រុមចោរលួចម៉ាស៊ីនបូមទឹករបស់ប្រជាពលរដ្ឋ បានបញ្ជូនទៅអធិការដ្ឋានស្រុកខ្សាច់កណ្តាល ។នៅក្នុងខែតុលានេះមានផ្ទះប្រជាពលរដ្ឋបានលិចដោយសារជំនន់ទឹកភ្លៀងចំនួន១៣ខ្នងផ្ទះ ។ បានចូលរួមចែកអង្ករជូនស្ត្រីសម្រាលកូន០១នាក់និងគ្រួសារសព ០២នាក់ ។លោកស្រីស្មៀនឃុំបានចុះសម្ភាសន៍គ្រួសារក្រីក្រដើម្បីធ្វើប័ណ្ណសមធម៌សាថ្មីចំពោះអ្នកដែលផុតសុពលភាព។ ប្រជាពលរដ្ឋសុំសំណូមពរដល់នាយប៉ុស្តិ៍នគរបាលឃុំវិហារសួគ៌ចុះបិទល្បែងឡូតូតាមទូរទស្សន៍នៅភូមិវិហារសួគ៌ត្បូង។ ប្រជាពលរដ្ឋសំណូមពរលោកមេឃុំជួយធ្វើផ្លូវបេតុងក្នុងភូមិវិហារសួគ៌ត្បូងបន្ថែមទៀត ពីព្រោះផ្លូវលំក្នុងភូមិនៅមានច្រើនខ្សែទៀត។

- ភូមិព្រៃធំ

ប្រជាពលរដ្ឋក្នុងភូមិព្រៃធំធ្វើស្រូវនិងឈូកមានចំនួន ១៨ហិចតា គ្រឿងញៀននិងល្បែងស៊ីសង់មានបន្តិចបន្តួចដូចគ្នា ។ក្រុមការងាររាជរដ្ឋាភិបាលនិងក្រុមប្រឹក្សាឃុំបានសហការគ្នាជួយឧបត្ថម្ភថវិកាដល់យុវជនឈ្មោះ ហាក់ សេងហ័ន ដែលបានគ្រោះថ្នាក់ចរាចរណ៍កាលពីថ្ងៃ ១៩ ខែកញ្ញា ឆ្នាំ២០២៣ មានលោកស៊ិន ចន្ទកក្កដា ១០០,០០០រៀល ,លោកម៉ាច ដារ៉ា ១០០,០០០រៀល,លោកពុន ហង្សេន ១០០,០០០រៀល,លោក ខៀវ ស៊ីណា ១២០,០០០រៀល,លោកជា សុជាតិ ១០០,០០០រៀល,លោកម៉ៅ ចូច

១០០,០០០រៀល,លោក ហឿង ហៀង ១០០,០០០រៀល,លោកស្រៀន កុសល់ ៥០,០០០រៀល,លោក ចាប លិញ ២០,០០០រៀល សរុបថវិកាចំនួន ៧៥០,០០០រៀល។

- ភូមិតាកែវ២

ក្នុងភូមិតាកែវ២ប្រជាពលរដ្ឋបានចុះឈ្មោះបោះឆ្នោតសម្រាប់ឆ្នាំ២០២៣បានចំនួន ១៥នាក់។បានចុះសម្ភាសន៍គ្រួសារក្រីក្រធ្វើប័ណ្ណសមធម៌បានចំនួន ៨៤គ្រួសារ។បានស្រង់ឈ្មោះប្រជាពលរដ្ឋដែលមិនទាន់បានប្តូរប្រព័ន្ធចំនួន ១៤គ្រួសារ។

- ភូមិតាកែវ១

នៅក្នុងភូមិតាកែវ១អំពើហិង្សា ចោរកម្មគ្មាន ល្បែងស៊ីសង់មានឆ្នោត កន្ទុយលេខមានតិចតួច មានករណីក្មេងអាយុ១៧ឆ្នាំលង់ទឹកស្លាប់ម្នាក់។ប្រជាជនបានចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០២៣ មាន១៧នាក់។បានចូលរួមចុះសម្ភាសន៍គ្រួសារក្រីក្រមានចំនួន ២០គ្រួសារ។បានទិញកម្ទេចថ្មយកមកចាក់តាមផ្លូវអស់ចំនួន ០៤ រ៉ឺម៉ក់ អស់ទឹកប្រាក់១៦០,០០០រៀល។

- ភូមិស្វាយមាស

សភាពការណ៍ទូទៅនៅក្នុងភូមិស្វាយមាស សម្រាប់ខែវិច្ឆិកាឆ្នាំ២០២៣រួមមាន ល្បែងស៊ីសង់នៅតែមានបន្តិចតួច។នៅថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០២៣ នៅវេលាម៉ោង១២យប់មានជនសង្ស័យបានចូលផ្ទះ លីម សុ មិនបានយករបស់អ្វីបានទេ ហើយជនសង្ស័យបានទៅចូលផ្ទះ ផុន សើ មួយទៀត យកបានទូរស័ព្ទដៃ ១គ្រឿង ។នៅថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០២៣ក្រុមសុរិយោដីស្រុកបានចុះវាស់វែងដីប្លុកZ ស្ថិតនៅក្នុងភូមិស្វាយមាស មកដល់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២៣ សរុបបានចំនួន ៣២២ក្បាលដី ៦៥៤ឡូត៍។នៅថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ប្រជាជនភូមិស្វាយមាសចំនួន ១៣គ្រួសារបានចូលរួមវាស់ដីដែលពាក់ព័ន្ធឡូលបុរាណមកជាកម្មសិទ្ធតាមគ្រួសារវិញ។បញ្ហាប្រឈម ដីចំនួន ១១៨ហិចតាពាក់ព័ន្ធចំនួន ៣៦គ្រួសារដែលគ្រប់លិចទឹកហើយបង្កបង្កើនផលមិនបាន។សំណូមពរ ធ្វើជាប្រឡាយមួយអោយទឹកចេញ ចូលជាលក្ខណៈធម្មជាតិ។

- ផ្នែកសុខាភិបាល
  - ស្ត្រីមានផ្ទៃពោះសរុប( គិតត្រឹមខែនេះ ) ២៥៥នាក់
  - ស្ត្រីមានផ្ទៃពោះបានទទួលការពិនិត្យផ្ទៃពោះ ២០៣៦នាក់
  - ស្ត្រីមានផ្ទៃពោះសម្រាលកូនសរុប ១០៦នាក់
  - ស្ត្រីមានផ្ទៃពោះបានសម្រាលកូនដោយឆ្មបជំនាញនៅកន្លែងផ្តល់សេវាសុខាភិបាល( មណ្ឌល សុខភាព សម្ភព មន្ទីរពេទ្យ ) ១០៦នាក់
  - ស្ត្រីមានផ្ទៃពោះសម្រាលកូនដោយឆ្មបជំនាញ នៅតាមផ្ទះ ០០នាក់
  - ស្ត្រីមានផ្ទៃពោះសម្រាលកូនដោយឆ្មប បុរាណ នៅតាមផ្ទះ ០០នាក់
  - ស្ត្រីមានផ្ទៃពោះស្លាប់ពេលមានផ្ទៃពោះ ពេលសម្រាល និងក្រោយសម្រាល ០០នាក់
  - កុមារអាយុក្រោម១ឆ្នាំសរុប ២៤៨នាក់
  - កុមារអាយុក្រោម១ឆ្នាំទទួលបានការចាក់ថ្នាំ បង្ការជំងឺកញ្ជ្រិល ៦៧០នាក់
  - កុមារអាយុក្រោម៥ឆ្នាំសរុប ១៤៩៤នាក់
  - កុមារអាយុក្រោម៥ឆ្នាំទទួលមរណៈភាពក្នុងអំឡុងខែមុន ០០នាក់
- ផ្នែកប៉ុស្តិ៍រដ្ឋបាលឃុំវិហារសួគ៌
  - កម្លាំងប៉ុស្តិ៍ចុះល្បាតតាមគោលដៅសំខាន់ៗជាប្រចាំ
  - កម្លាំងប៉ុស្តិ៍ចុះសម្រួលចរាចរណ៍ជូនកម្មកររោងចក្រនៅចំណុចមុខច្រកចូលសាលាROTA

- កម្លាំងប៉ុស្តិ៍បានចុះចែកសៀវភៅស្នាក់នៅ និងសៀវភៅគ្រួសារបានចំនួន ១១ក្បាល
- កម្លាំងប៉ុស្តិ៍បានចុះធ្វើវេទិការសាធារណៈបានចំនួន ០៦លើកចំនួនអ្នកចូលរួម៣៩៨នាក់ ស្រី១៦២នាក់។

- ការហារអន្តោរប្រវេសន៍
  - អ្នកចំណាកស្រុកក្នុងប្រទេសមានចំនួន ២១៣នាក់ ស្រី ១៣២នាក់
  - អ្នកចំណាកស្រុកក្រៅប្រទេសមានចំនួន ១២៣នាក់ ស្រី ៩៨នាក់
  - សំដៅលើការរំលោភបំពានលើពលកម្មកុមារ គ្មាន ។

## ផ្នែកទី២÷បញ្ហាប្រឈមចម្បងៗ និងសំណើដោះស្រាយ

| ល.រ. | បញ្ហាប្រឈមសំខាន់ៗ | សំណើដោះស្រាយ |
|---|---|---|
| ១ | ការសាងសង់សំណង់ផ្សេងៗរំលោភលើដីសាធារណៈ | ស្នើរសុំថ្នាក់លើដែលពាក់ព័ន្ធដោះស្រាយ |
| ២ | ការជួញដូរគ្រឿងញៀននិងល្បែងស៊ីសង់គ្រប់ប្រភេទ | ថ្នាក់លើបង្ក្រាប និងអប់រំណែនាំ |
| ៣ | ការពង្រីកផ្លូវជាតិលេខ៨ | ស្នើរសុំថ្នាក់លើដែលពាក់ព័ន្ធដោះស្រាយ |
| ៤ | ក្មេងទំនើង | ស្នើរសុំមន្ត្រីប៉ុស្តិ៍ជួយចាត់វិធានការ |

## ផ្នែកទី៣÷ទិសដៅការងារចម្បងៗសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់

បន្តអនុវត្តន៍របៀបរបបរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យកាន់តែមានប្រសិទ្ធិភាព បន្តការងារចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទជូនប្រជាពលរដ្ឋ បន្តការងារគ្រប់គ្រងរដ្ឋបាល និងសន្តិសុខក្នុងដែនសមត្ថកិច្ចរបស់ឃុំ បន្តដោះស្រាយទំនាស់នានាដែលកើតមាននៅក្នុងឃុំ បន្តបង្ក្រាបបទល្មើសគ្រប់ប្រភេទ បន្តបង្ក្រាបបទល្មើសគ្រឿងញៀន ល្បែងស៊ីសង ល្បែងកន្ទុយលេខ បន្តសម្អាតបរិស្ថានតាមទីសាធារណៈ អោយស្អាតជានិច្ច ពង្រឹងការបំរើសេវាសុខភាពជូនប្រជាជនតាមរយៈមូលនិធិសមធម៌ដល់ប្រជាជន ដែលមានប័ណ្ណសមធម៌ បន្តជំរុញលើការងារបង្កបង្កើនផលរបស់ប្រជាកសិករ បន្តដោះស្រាយបណ្តឹងជូនប្រជាពលរដ្ឋអោយបានទាន់ពេល បន្តផ្តល់វ៉ាក់សាំងដល់កុមារ និងស្ត្រីមានផ្ទៃពោះ បន្តការអប់រំទប់ស្កាត់ការជួញដូរកុមារ និងស្ត្រី បន្តតាមដានសិស្សគេចសាលា និងបន្តពង្រឹងគុណភាពការសិក្សាដល់សិស្សជាប្រចាំរៀលរាល់ខែ និងបន្តចុះផ្សព្វផ្សាយភូមិ ឃុំ ទាំង៩ចំណុច ។

របាយការណ៍ប្រចាំឆ្នាំ ត្រូវបានអនុម័តដោយក្រុមប្រឹក្សាឃុំ នាថ្ងៃទី១០ ខែ វិច្ឆិកា ឆ្នាំ២០២៣។

មេឃុំទិព្វារស្គី

ឧបសម្ពន្ធទី១៖ស្ថិតិប្រជាពលរដ្ឋ

| ល.រ. | ឈ្មោះភូមិ | ចំនួនគ្រួសារ | | | ប្រជាពលរដ្ឋទូទៅ | | | | | | ប្រជាពលរដ្ឋ១៨ឆ្នាំឡើង | | | | | | ចំណាកស្រុក | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | សរុប | ស្រី | អចិន្ត្រៃយ៍ | | បណ្ដោះអាសន្ន | | សរុប | ស្រី | អចិន្ត្រៃយ៍ | | បណ្ដោះអាសន្ន | | | |
| | | សរុប | អចិន្ត្រៃយ៍ | បណ្ដោះអាសន្ន | | | សរុប | ស្រី | សរុប | ស្រី | | | សរុប | ស្រី | សរុប | ស្រី | ក្នុង | ក្រៅ |
| ១ | ព្រៃចាស់ | | 663 | | | | 3216 | 1570 | | | | | 2102 | 1073 | | | 43 | 08 |
| ២ | សេដា | | 585 | | | | 2633 | 1244 | | | | | 1697 | 903 | | | 22 | 13 |
| ៣ | វិហារសួគ៌ជើង | | 675 | | | | 3120 | 1769 | | | | | 2237 | 1121 | | | 39 | 15 |
| ៤ | វិហារសួគ៌ត្បូង | | 546 | | | | 2202 | 1167 | | | | | 1774 | 904 | | | 42 | 21 |
| ៥ | ព្រៃធំ | | 213 | | | | 888 | 500 | | | | | 697 | 375 | | | 19 | 0 |
| ៦ | តាកែវ២ | | 307 | | | | 1191 | 621 | | | | | 875 | 486 | | | 18 | 11 |
| ៧ | តាកែវ១ | | 241 | | | | 1046 | 483 | | | | | 780 | 391 | | | 25 | 09 |
| ៨ | ស្វាយមាស | | 670 | | | | 3066 | 1608 | | | | | 2414 | 1184 | | | 30 | 46 |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | | | | | | | | | | | | | | | | | | |
| | សរុប | | 3900 | | | | 17362 | 8962 | | | | | 12576 | 6437 | | | 238 | 123 |

ព័ត៌មានខាងលើនេះ គិតត្រឹមថ្ងៃទី............ខែ............ឆ្នាំ២០...។

*[សេចក្ដីពន្យល់៖ ធ្វើបច្ចុប្បន្នភាពតារាងស្ថិតិដោយផ្អែកតាមទិន្នន័យជាក់ស្ដែងរបស់រដ្ឋបាលឃុំ សង្កាត់នីមួយៗ]*

ឧបសម្ពន្ធទី២៖ការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់(ថវិកាវិភាជពីរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសប្បុរសជន)

| ល.រ. | ឈ្មោះគម្រោង | គ្រោង ជាក់ស្តែង | លទ្ធផលគម្រោង | តម្លៃ (លានរៀល) | ទីតាំងអនុវត្ត | អ្នកទទួលផល ប្រុស | អ្នកទទួលផល ស្រី | វិធីសាស្ត្រលទ្ធកម្ម | អ្នកទទួលការ | % អនុវត្ត | ប្រភពថវិកា |
|---|---|---|---|---|---|---|---|---|---|---|---|
| **ក-ផ្នែកសេដ្ឋកិច្ច** | | | | | | | | | | | |
| ១ | កែលម្អផ្លូវបេតុងអាមេ | គ្រោង | 800ម | 437 | ភូមិព្រៃធំ និង ភូមិតាកែវ១ | 1933 | 1376 | ការដេញថ្លៃ | ជា មករា | 100% | មូលនិធិឃុំឆ្នាំ2023 |
| | | ជាក់ស្តែង | 2,184ម | 437 | | 1933 | 1376 | | | | |
| **ខ-ផ្នែកសង្គមកិច្ច** | | | | | | | | | | | |
| ១ | កម្មវិធីពន្យាកំណើត | គ្រោង | 25% | | ឃុំវិហារសួគ៌ | 300 | 300 | | | | |
| | | ជាក់ស្តែង | 20% | | | 275 | 275 | | | | |
| ២ | សេវាសុខភាពស្ត្រីមានផ្ទៃពោះ | គ្រោង | 100% | | ឃុំវិហារសួគ៌ | 400 | 400 | | | | |
| | | ជាក់ស្តែង | 80% | | | 380 | 380 | | | | |
| ៣ | វគ្គអប់រំចំណេះដឹងពីជំងឺអេដស៍ | គ្រោង | 100% | | ឃុំវិហារសួគ៌ | 17371 | 8965 | | | | |
| | | ជាក់ស្តែង | 80% | | | 17371 | 8965 | | | | |
| ៤ | ផ្តល់ការចាក់វ៉ាក់សាំងដល់កុមារការពារជំងឺ១២មុខ | គ្រោង | 21លើក | | ឃុំវិហារសួគ៌ | 1600 | 930 | | | | |
| | | ជាក់ស្តែង | 21លើក | | | 1600 | 930 | | | | |
| ៥ | ផ្តល់សេវាសម្រាលកូនដោយបុគ្គលិកសុខាភិបាលដែលបានបណ្តុះបណ្តាលនៅមូលដ្ឋានសុខាភិបាល (HC,RH) | គ្រោង | 90% | | ឃុំវិហារសួគ៌ | | | | | | |
| | | ជាក់ស្តែង | 70% | | | | | | | | |
| ៦ | សកម្មភាពស្រាវជ្រាវ និងទប់ស្កាត់ការឆ្លងរោគជាលជំងឺរបេង DOTS | គ្រោង | 90% | | ឃុំវិហារសួគ៌ | 500 | 250 | | | | |
| | | ជាក់ស្តែង | 70% | | | 500 | 250 | | | | |
| ៧ | យុទ្ធនាការដាក់ថ្នាំអាបែត BTI | គ្រោង | 90% | | ឃុំវិហារសួគ៌ | 3000 | 1500 | | | | |
| | | ជាក់ស្តែង | 70% | | | 3000 | 1500 | | | | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ៨ | ការអប់រំផ្សព្វផ្សាយបន្ទុកជំងឺមិនឆ្លង(លើសឈាម ទឹកនោមផ្អែម សុខភាពភ្នែក សុខភាពមាត់ធ្មេញ | គ្រោង | 90% | | ឃុំវិហារសួគ៌ | 500 | 250 | | | | |
| | | ជាក់ស្តែង | 70% | | | 500 | 250 | | | | |
| ៩ | ផ្តល់សេវាព្យាបាលដោយមិនយកកម្រៃដល់ប្រជាពលរដ្ឋក្រីក្រតាមរយៈប័ណ្ណសមធម៌ | គ្រោង | 100% | | ឃុំវិហារសួគ៌ | 250 | 100 | | | | |
| | | ជាក់ស្តែង | 80% | | | 250 | 100 | | | | |
| ១០ | ប្រតិបត្តិការពង្រឹងគុណភាព និងលើកកម្ពស់សមធម៌សេវាសុខាភិបាល | គ្រោង | 100% | | ឃុំវិហារសួគ៌ | 250 | 100 | | | | |
| | | ជាក់ស្តែង | 80% | | | 250 | 100 | | | | |
| ១១ | អាហារូបករណ៍សិស្សក្រីក្ររៀនពូកែ | គ្រោង | 141នាក់ | | ឃុំវិហារសួគ៌ | 141 | 90 | | | | |
| | | ជាក់ស្តែង | 78នាក់ | | | 78 | 56 | | | | |
| ១២ | គម្រោងសាងសង់ផ្តល់សម្ភារៈបង្គន់អនាម័យ | គ្រោង | 35បង្គន់ | | ឃុំវិហារសួគ៌ | 69 | 25 | | | | |
| | | ជាក់ស្តែង | 35បង្គន់ | | | 60 | 24 | | | | |
| ១៣ | ផ្សព្វផ្សាយអំពីសិទ្ធស្ត្រី និងកុមារ | គ្រោង | 2វគ្គ | | ឃុំវិហារសួគ៌ | 100 | 100 | | | | |
| | | ជាក់ស្តែង | 2វគ្គ | | | 100 | 100 | | | | |
| ១៤ | រៀបចំទិវាអន្តជាតិ ៨ មីនា | គ្រោង | 300នាក់ | | ឃុំវិហារសួគ៌ | 120 | 65 | | | | |
| | | ជាក់ស្តែង | 300នាក់ | | | 120 | 65 | | | | |
| ១៥ | ជ្រើសរើសឧបត្ថម្ភគាំទ្រគ្រូពេទ្យគ្រូថែទាំកុមារ | គ្រោង | 3នាក់ | | ឃុំវិហារសួគ៌ | 120 | 65 | | | | |
| | | ជាក់ស្តែង | 3នាក់ | | | 120 | 65 | | | | |
| ១៦ | បណ្តុះបណ្តាលវិជ្ជាជីវៈដល់ស្ត្រីដែលគ្មានការងារធ្វើ | គ្រោង | 2វគ្គ | | ឃុំវិហារសួគ៌ | 50 | 25 | | | | |
| | | ជាក់ស្តែង | 2វគ្គ | | | 50 | 25 | | | | |
| ១៧ | ការជំរុញសកម្មភាពកីឡានៅមូលដ្ឋាន | គ្រោង | 2ក្រុម | | ឃុំវិហារសួគ៌ | 2500 | 1200 | | | | |
| | | ជាក់ស្តែង | 2ក្រុម | | | 2500 | 1200 | | | | |
| **គ-ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ** | | | | | | | | | | | |
| ១ | អប់រំផ្សព្វផ្សាយច្បាប់ដីធ្លី | គ្រោង | 1វគ្គ | | ទូទាំងឃុំ | 17371 | 8965 | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ជាក់ស្តែង | 1វគ្គ | | | | 17371 | 8965 | | | | |
| ២ | អប់រំប្រយោជន៍ ព្រៃឈើ ព្រៃលិចទឹក | គ្រោង | 2វគ្គ | | | ខុទាំងឃុំ | 17371 | 8965 | | | | |
| | | ជាក់ស្តែង | 2វគ្គ | | | | 17371 | 8965 | | | | |
| ៣ | ពង្រឹងផែនការទប់ស្កាត់បទល្មើសនេសាទ | គ្រោង | 6កន្លែង | | | ខុទាំងឃុំ | 17371 | 8965 | | | | |
| | | ជាក់ស្តែង | 6កន្លែង | | | | 17371 | 8965 | | | | |
| ៤ | អប់រំផ្សព្វផ្សាយច្បាប់ការពារសត្វព្រៃ | គ្រោង | 2លើក | | | ខុទាំងឃុំ | 17371 | 8965 | | | | |
| | | ជាក់ស្តែង | 2លើក | | | | 17371 | 8965 | | | | |
| ៥ | ពង្រឹងសកម្មភាពការពារគ្រោះធម្មជាតិ ( ខ្យល់ព្យុះ ទឹកជំនន់ គ្រោះរាំងស្ងួត ) | គ្រោង | 2វគ្គ | | | ខុទាំងឃុំ | 17371 | 8965 | | | | |
| | | ជាក់ស្តែង | 2វគ្គ | | | | 17371 | 8965 | | | | |

## ឃ-ផ្នែករដ្ឋបាល សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ១ | អប់រំផ្សព្វផ្សាយច្បាប់ភូមិបាល | គ្រោង | 3លើក | | | ខុទាំងឃុំ | | | | | | |
| | | ជាក់ស្តែង | 2លើក | | | | | | | | | |
| ២ | ជំរុញសកម្មភាពទប់ស្កាត់ល្បែងស៊ីសង | គ្រោង | 1លើក | | | ខុទាំងឃុំ | | | | | | |
| | | ជាក់ស្តែង | 1លើក | | | | | | | | | |
| ៣ | បង្កើតការត្រួតពិនិត្យ គ្រប់គ្រងជនខិលខូច | គ្រោង | 1លើក | | | ខុទាំងឃុំ | | | | | | |
| | | ជាក់ស្តែង | 1លើក | | | | | | | | | |
| ៤ | ពង្រឹងសកម្មភាពការពារគ្រោះទឹកជំនន់ | គ្រោង | 3លើក | | | ខុទាំងឃុំ | | | | | | |
| | | ជាក់ស្តែង | 2លើក | | | | | | | | | |
| ៥ | បង្កើត ពង្រឹងសកម្មភាពក្រុមប្រជាការពារក្នុងមូលដ្ឋាន | គ្រោង | 3លើក | | | ខុទាំងឃុំ | | | | | | |
| | | ជាក់ស្តែង | 2លើក | | | | | | | | | |
| ៦ | ពង្រឹងការស្រង់ទិន្នន័យភូមិ ឃុំ | គ្រោង | 2លើក | | | ខុទាំងឃុំ | | | | | | |
| | | ជាក់ស្តែង | 2លើក | | | | | | | | | |
| ៧ | លុបបំបាត់គ្រឿងញៀន និងល្បែងស៊ីសង | គ្រោង | 12លើក | | | ខុទាំងឃុំ | | | | | | |
| | | ជាក់ស្តែង | 9លើក | | | | | | | | | |
| ៨ | ផ្សព្វផ្សាយការងារអត្រានុកូលដ្ឋាន | គ្រោង | 12ខែ | | | ខុទាំងឃុំ | | | | | | |
| | | ជាក់ស្តែង | 9ខែ | | | | | | | | | |
| ៩ | ផ្សព្វផ្សាយច្បាប់អំពើហឹង្សាក្នុងគ្រួសារ | គ្រោង | 2វគ្គ | | | ខុទាំងឃុំ | | | | | | |
| | | ជាក់ស្តែង | 2វគ្គ | | | | | | | | | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ១០ | ពង្រឹងសមត្ថភាពការងារ គ.ក.ន .ក | គ្រោង | 300នាក់ | | ទូទាំងឃុំ | | | | | | |
| | | ជាក់ស្តែង | 250នាក់ | | | | | | | | |
| ១១ | [illegible] | គ្រោង | 28នាក់ | | ទូទាំងឃុំ | | | | | | |
| | | ជាក់ស្តែង | 19នាក់ | | | | | | | | |

ព័ត៌មានខាងលើនេះ គិតត្រឹមថ្ងៃទី...............ខែ............ឆ្នាំ២០...។

# ឧបសម្ព័ន្ធទី៦

# អនុសារណៈស្តីពីការរៀបចំគម្រោងថវិកាឆ្នាំ២០២៣

# ឧបសម្ព័ន្ធទី៧

# សេចក្តីជូនដំណឹងលេខ៥៨៥ ស.ជ.ណាស្តីពីការ

# ផ្តល់អនុលោមភាពលើសៀវភៅផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ

# (២០២៣-២០២៧)

# របស់ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកណ្តាល**
លេខៈ [illegible]

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦

កណ្តាល, ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ ២០២៣

**អភិបាល នៃគណៈអភិបាលខេត្តកណ្តាល**
**សូមជម្រាបមក**
**លោកមេឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល**

**កម្មវត្ថុៈ** ស្តីពីការផ្តល់អនុលោមភាព លើសៀវភៅផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ (២០២៣-២០២៧) របស់រដ្ឋបាលឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល ។

**យោងៈ** -ព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃព្រហស្បតិ៍ ៤រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-ប្រកាសអន្តរក្រសួងលេខ ០៧៤ ផក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ឃុំ

-លិខិតលេខ ០៨០ ផក ចុះថ្ងៃទី០២ ខែ មីនា ឆ្នាំ២០១៧ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ ប្រកាសអន្តរក្រសួងស្តីពីការដាក់អោយ ប្រើប្រាស់លើសេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

-លិខិតលេខ ០០១ វហស ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣ របស់រដ្ឋបាលឃុំវិហារសួគ៌ ស្តីពីសំណើសុំអនុលោមភាពលើផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ (២០២៣-២០២៧) ។

តបតាមកម្មវត្ថុ និងយោងខាងលើ សូមជម្រាបជូនលោកមេឃុំជ្រាបថា រដ្ឋបាលខេត្ត ដោយមានទីចាត់ការផែនការ និងវិនិយោគខេត្ត ជាសេនាធិការ បានធ្វើការពិនិត្យយ៉ាងយកចិត្តទុកដាក់ទៅលើខ្លឹមសារទាំងមូល ដែលជារួមសេចក្តីព្រាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំនេះ បានធ្វើការវាយតម្លៃថា ការរៀបចំមានលក្ខណៈសមស្របតាមច្បាប់ បទបញ្ញត្តិ លិខិតបទដ្ឋានគតិយុត្តនានា និងមានសង្គតិភាពជាមួយគោលនយោបាយថ្នាក់ជាតិ ថ្នាក់ខេត្ត និងសេចក្តីណែនាំនានាដែលមានជាធរមាន។ ជាមួយគ្នានេះ ដំណើរការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំនេះ ក៏បានអនុវត្តស្របតាមសេចក្តីណែនាំបច្ចេកទេស ស្តីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំរបស់រដ្ឋបាលឃុំ ផងដែរ។

ដូចនេះរដ្ឋបាលខេត្តសូមប្រកាសផ្តល់អនុលោមភាពលើសេចក្តីព្រាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ (២០២៣-២០២៧) របស់រដ្ឋបាលឃុំវិហារសួគ៌ ដើម្បីយកទៅប្រើប្រាស់ជាផ្លូវការ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

អាស្រ័យហេតុនេះ សូមលោកមេឃុំ ជ្រាប និងចាត់ចែងឱ្យមានប្រសិទ្ធភាពខ្ពស់។

**អភិបាលខេត្ត**

**គង់ សោភ័ណ្ឌ**

# ឧបសម្ព័ន្ធទី៨

# កំណត់ហេតុស្តីពីកិច្ចប្រជុំពិនិត្យ និងពិភាក្សា សេចក្តីព្រាងសៀវភៅផែនការអភិវឌ្ឍន៍ប្រាំឆ្នាំរបស់ រដ្ឋបាលឃុំវិហារសួគ៌

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

## កំណត់ហេតុ
## ស្តីពីកិច្ចប្រជុំពិនិត្យ និងពិភាក្សាសេចក្តីព្រាង
## សៀវភៅផែនការអភិវឌ្ឍន៍ ប្រាំឆ្នាំ របស់រដ្ឋបាលឃុំវិហារសួគ៌

ឆ្នាំពីរពាន់ម្ភៃបី ខែមករា ថ្ងៃទីម្ភៃប្រាំពីរ វេលាម៉ោងប្រាំបីព្រឹក នៅសាលាឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តក ណ្តាល បានរៀបចំកិច្ចប្រជុំពិនិត្យ និងពិភាក្សាសេចក្តីព្រាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ របស់រដ្ឋបាលឃុំវិហារសួគ៌ ស្រុក ខ្សាច់កណ្តាល ខេត្តកណ្តាល ក្រោមអធិបតីភាពលោក ម៉េង ឈាងហេង ប្រធានក្រុមប្រឹក្សាឃុំ។

**I.អង្គរុំ និងសមាសភាពចូលរួមប្រជុំ:**

សមាជិក សមាជិកា នៃក្រុមប្រឹក្សាឃុំ ដែលបានអញ្ជើញចូលរួមប្រជុំមានចំនួន ០៩ លើ ០៩រូប អង្គប្រជុំអាចដំ ណើរការបាន។

ក្រៅពីនេះ មានស្មៀនឃុំ ជំនួយការរដ្ឋបាលឃុំ នារីឃុំ ប្រធាន អនុប្រធាន និងសមាជិកភូមិ នាយប៉ុស្តិ៍រដ្ឋបាលឃុំ លោកនាយកអនុវិទ្យាល័យ នាយកបឋមសិក្សា ប្រធានមណ្ឌលសុខភាព និងប្រជាការពារ (ដូចមានបញ្ជីវត្តមានជូនភ្ជាប់ ជាមួយ) ។

**II.របៀបវារៈនៃកិច្ចប្រជុំរួមមាន:**

១. មតិថ្លែងបើកអង្គប្រជុំក្រុមប្រឹក្សាឃុំវិហារសួគ៌ (ដោយលោកប្រធានអង្គប្រជុំ)

២. ពិនិត្យ ពិភាក្សា និងអនុម័តសេចក្តីព្រាងផែនការអភិវឌ្ឍន៍រយៈពេល ប្រាំឆ្នាំ របស់រដ្ឋបាលឃុំវិហារសួគ៌

៣. បញ្ហាផ្សេងៗ

៣. មតិបូកសរុប និងបិទអង្គប្រជុំក្រុមប្រឹក្សាឃុំ (ដោយលោកប្រធានអង្គប្រជុំ)

**III.ខ្លឹមសារនៃកិច្ចប្រជុំ**

របៀបវារៈទី១ ៖

ជាកិច្ចចាប់ផ្តើមនៃអង្គប្រជុំលោក ម៉េង ឈាងហេង ប្រធានក្រុមប្រឹក្សាឃុំវិហារសួគ៌ បានប្រកាសបើកកិច្ចប្រជុំ និង ស្រាបជូនអង្គប្រជុំជ្រាបថាៈ ក្រោយពីវគ្គបណ្តុះបណ្តាល ស្តីពីការងារកសាងផែនការអភិវឌ្ឍន៍ ៥ឆ្នាំ និងកម្មវិធីវិនិ យោគបីឆ្នាំរំកិលរួចមកក្រុមការងារកសាងផែនការរបស់ឃុំ បានបំពេញការងាររបស់ខ្លួនយ៉ាងមមាញឹក កសាងបាន នូវសេចក្តីព្រាងផែនការអភិវឌ្ឍន៍ ៥ឆ្នាំ ដាក់ជូនក្រុមប្រឹក្សាឃុំធ្វើការពិនិត្យ និងអនុម័តនាពេលនេះ សូមថ្លែងអំណរ គុណ លោក លោកស្រីសមាជិកក្រុមប្រឹក្សាឃុំ បានចូលរួមជួយពិភាក្សា និងរៀបចំកសាងផែនការឃុំ សហការជា មួយ លោកមេភូមិគ្រប់ភូមិ អ្នកពាក់ព័ន្ធនានា និងបងប្អូនប្រជាពលរដ្ឋក្នុងឃុំវិហារសួគ៌ទាំងមូល ដើម្បីបំពេញក្នុងតារាងសម្រាប់ បញ្ចូលក្នុងផែនការអភិវឌ្ឍន៍ ៥ឆ្នាំ របស់ឃុំបានរួចរាល់ និងទាន់ពេលវេលា។

របៀបវារៈទី២ ៖

លោក ម៉េង ឈាងហេង ប្រធានក្រុមប្រឹក្សាឃុំ បានធ្វើការបង្ហាញសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ៥ឆ្នាំ ២០២៣-២០២៧) របស់រដ្ឋបាលឃុំវិហារសួគ៌ តាមលំដាប់លំដោយដូចខាងក្រោមៈ

I-អំពីទិដ្ឋភាពទូទៅនៃការកសាងផែនការអភិវឌ្ឍន៍ឃុំ មាន៣ជំហានគឺ:

១.ការវិភាគស្ថានភាព និងការកំណត់តម្រូវការអភិវឌ្ឍន៍ឃុំ

២.ការរៀបចំ និងចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ

៣.ការពិនិត្យ អនុម័ត និងការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ឃុំ

II-ការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ មាន៤ជំពូក សំខាន់ៗគឺ:

-ជំពូកទី១៖ ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ចៈ ដែលផ្តោតសំខាន់ទៅលើស្ថានភាពព័ត៌មានទូទៅរបស់ឃុំ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម។

-ជំពូកទី២៖ ក្របខ័ណ្ឌអភិវឌ្ឍន៍រយៈពេល ប្រាំឆ្នាំរបស់អាណត្តិក្រុមប្រឹក្សាឃុំ: បង្ហាញអំពីចក្ខុអភិវឌ្ឍន៍ គោលបំណងអភិវឌ្ឍន៍ គោលដៅអភិវឌ្ឍន៍ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់ឃុំ។

-ជំពូកទី៣៖ កម្មវិធីអភិវឌ្ឍន៍មូលដ្ឋានរយៈពេល៥ឆ្នាំៈ គឺការរៀបចំក្របខ័ណ្ឌវិនិយោគ ក្របខ័ណ្ឌផ្តល់សេវាការដាក់ចេញលិខិតបទដ្ឋានគតិយុត្តិនានា ។

-ជំពូកទី៤៖ ការតាមដាន និងវាយតម្លៃការអនុវត្តន៍ផែនការអភិវឌ្ឍន៍: គឺជាការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើផែនការអភិវឌ្ឍន៍ បានលំអិតជាតារាងសេចក្តីព្រាងយុទ្ធសាស្ត្រតាមដាន ត្រួតពិនិត្យ វាយតម្លៃ ដោយផ្អែកតាមសូចនាករ និងតារាងក្របខ័ណ្ឌអភិវឌ្ឍន៍។

បន្ទាប់ពីរៀបចំឯកសាររួច ក្រុមការងារដាក់ជូនក្រុមប្រឹក្សាពិនិត្យ កែសម្រួលផ្តល់យោបល់ទើបក្រុមប្រឹក្សាប្រ ជុំពិនិត្យ និងអនុម័តពេលនេះ ដើម្បីចងក្រងជាសៀវភៅកម្រងឯកសារផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ របស់ឃុំ។

ក្រោយការបង្ហាញសេចក្តីព្រាង ផែនការអភិវឌ្ឍន៍៥ឆ្នាំ ក្រុមប្រឹក្សាបានពិនិត្យ ពិភាក្សា ដោយផ្តោតលើពាក្យ នៃឃ្លាប្រយោគរបស់គម្រោង តាមផ្នែកវិស័យនីមួយៗ យ៉ាងល្អិតល្អន់ និងហ្មត់ចត់ ហើយលោក លោកស្រីសមាជិក នៃអង្គប្រជុំជាក្រុមប្រឹក្សាឃុំ បានធ្វើការអនុម័ត ០៩ លើ ០៩សម្លេងគាំទ្រ ផែនការអភិវឌ្ឍន៍រយៈពេល ៥ឆ្នាំ របស់ឃុំហៃរស្លគ៌។

របៀបវារៈទី៣ ៖ បញ្ហាផ្សេងៗ (គ្មាន)

របៀបវារៈទី៤ ៖

ជាទីបញ្ចប់លោកប្រធានអង្គប្រជុំធ្វើការបូកសរុបលទ្ធផល នៃកិច្ចប្រជុំពិនិត្យពិភាក្សា និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ នាពេលនេះប្រកបដោយស្មារតីគិតគូរយកចិត្តទុកដាក់ជាខ្លាំងលើការដឹកនាំកសាងមូលដ្ឋានឲ្យអភិវឌ្ឍន៍ឈានឡើង និងបានផ្តល់មតិយោបល់ កែសម្រួលពាក្យពេជន៍ ឃ្លាប្រយោគ ធ្វើឲ្យគម្រោងផែនការអភិវឌ្ឍន៍របស់ឃុំកាន់តែត្រឹមត្រូវតាមស្ថានភាពជាក់ស្តែងរបស់ឃុំ។

សូមថ្លែងអំណរគុណ ចំពោះសមាជិក សមាជិកាដែលបានអញ្ជើញចូលរួមបញ្ចេញមតិយ៉ាងផុលផុសនៅថ្ងៃនេះ។ សូមជូនពរលោក លោកស្រីបានសម្រេចនូវពរជ័យទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ជានិច្ចនិរន្តរ៍ និងសូមបានសម្រេចដោយជោគជ័យគ្រប់ភារកិច្ចការងារ។

កិច្ចប្រជុំបានបញ្ចប់នៅម៉ោងដប់មួយ និងសាមសិបនាទី នាថ្ងៃ ខែ ឆ្នាំដដែល ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

**លេខាកត់ត្រា**

ឆេង ឡាក់ឡេង

**ប្រធានក្រុមប្រឹក្សាឃុំ**

ម៉េង ឈានហេង

# ឧបសម្ព័ន្ធទី៩

## សេចក្តីសម្រេចលេខ០០៤/២៣ ស.ស.រ ស្តីពីការដាក់ឲ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំរបស់រដ្ឋបាលឃុំវិហារសួគ៌

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាខេត្តកណ្តាល
សាលាស្រុកខ្សាច់កណ្តាល
រដ្ឋបាលឃុំវិហារសួគ៌
លេខ: 004/២៣ស.ស.រ

# សេចក្តីសម្រេច

## ស្តីពី

## ការដាក់ឲ្យប្រើប្រាស់ផែនការអភិវឌ្ឍន៍ឃុំវិហារសួគ៌

## ក្រុមប្រឹក្សាឃុំវិហារសួគ៌

- យោងព្រះរាជក្រមលេខ នស/រ.ក.ម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១៨ ដែប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងព្រះរាជក្រមលេខ នស/រ.ក.ម/០៥០៨/០១៨ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- យោងព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់
- យោងអនុក្រឹត្យលេខ ២២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០០២ ស្តីពីការផ្ទេរមជ្ឈការអំណាច តួនាទី ភារកិច្ច ទៅឲ្យក្រុមប្រឹក្សាឃុំ-សង្កាត់
- យោងអនុក្រឹត្យលេខ ២១៩អនក្រ.បក ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា ១២ នៃអនុក្រឹត្យ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងប្រកាសអន្តរក្រសួងលេខ ២៤១៧ ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងប្រកាសលេខ ៨០៦០ ប្រ.ក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាឃុំ ប្រធានក្រុមប្រឹក្សាឃុំ ជំទប់ទី១ និងជំទប់ទី២ នៃឃុំវិហារសួគ៌
- យោងតាមកំណត់ហេតុប្រជុំក្រុមប្រឹក្សាឃុំវិហារសួគ៌ នាថ្ងៃទី២៧ ខែ មករា ឆ្នាំ ២០២២៣

## សម្រេច

**ប្រការ១:**_

ត្រូវបានដាក់ឲ្យប្រើប្រាស់ នូវផែនការអភិវឌ្ឍន៍ ០៥ឆ្នាំ ២០២៣-២០២៧ របស់ឃុំវិហារសួគ៌ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាឃុំវិហារសួគ៌ នាកិច្ចប្រជុំលើកទី០៧ នៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០២២ ។

**ប្រការ២:**_

ក្រុមប្រឹក្សាឃុំវិហារសួគ៌ ត្រូវចាត់ចែងផ្សព្វផ្សាយផែនការអភិវឌ្ឍន៍នេះ ដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា នៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលឃុំវិហារសួគ៌។

ក្រុមប្រឹក្សាឃុំវិហារសួគ៌ ត្រូវចាត់ចែងសម្របសម្រួល និងចលនាគៀងគរធនធាននានា ក្នុងការអនុវត្តផែនការនេះប្រកបដោយ ការចូលរួម តម្លាភាព គណនេយ្យភាព និងប្រសិទ្ធិភាពខ្ពស់។

**ប្រការ៣ :**_

ក្រុមប្រឹក្សាឃុំវិហារសួគ៌ ត្រូវរៀបចំយន្តការសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍នេះ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធនានា។

ក្រុមប្រឹក្សាឃុំវិហារសួគ៌ ត្រូវរៀបចំរបាយការណ៍ស្តីពីលទ្ធផល នៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍នេះ និងរាយការណ៍ជូនអង្គប្រជុំក្រុមប្រឹក្សាឃុំវិហារសួគ៌ អំពីវឌ្ឍនភាពនៃការអនុវត្តផែនការនេះទៅតាមការកំណត់។

ក្រុមប្រឹក្សាឃុំវិហារសួគ៌ ត្រូវរៀបចំ និងដាក់ជូនក្រុមប្រឹក្សាឃុំ និងអ្នកពាក់ព័ន្ធអំពីរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការអនុវត្តផែនការអភិវឌ្ឍន៍នេះ។

**ប្រការ៤ :**_

ក្រុមប្រឹក្សាឃុំវិហារសួគ៌ ត្រូវធ្វើការវាយតម្លៃការអនុវត្ត ផែនការអភិវឌ្ឍន៍នេះនៅពាក់កណ្តាលអាណត្តិ និងចុងអាណត្តិរបស់ក្រុមប្រឹក្សាឃុំវិហារសួគ៌ អំពីលទ្ធផលសម្រេចបានធៀបនឹងគោលដៅ គោលបំណង ដែលបានកំណត់ក្នុងផែនការអភិវឌ្ឍន៍ឃុំ។

**ប្រការ៥:**_

ក្រុមប្រឹក្សាឃុំវិហារសួគ៌ មេភូមិ និងស្ថាប័នពាក់ព័ន្ធទាំងអស់ក្នុងឃុំវិហារសួគ៌ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឲ្យមានប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃចន្ទ ៩កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស២៥៦៦
វិហារសួគ៌ ថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣
**មេឃុំវិហារសួគ៌**

ម៉េង ឈាងហេង

***ចម្លងជូន:***
- រដ្ឋបាលខេត្តកណ្តាល
- មន្ទីរផែនការខេត្តកណ្តាល
- សាលាស្រុកខ្សាច់កណ្តាល
  (ដើម្បីជូនជ្រាប)
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១០
# កំណត់ហេតុប្រជុំស្តីពីការអនុម័តសៀវភៅ
# កម្មវិធីវិនិយោគបីឆ្នាំរំកិល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## កំណត់ហេតុប្រជុំ

### ស្តីពីការអនុម័តសៀវភៅកម្មវិធីវិនិយោគ បីឆ្នាំរំកិល

ឆ្នាំពីរពាន់ម្ភៃបី ខែមករា ថ្ងៃទីម្ភៃប្រាំពីរ វេលាម៉ោងប្រាំបីព្រឹក នៅសាលាឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល បានបើកកិច្ចប្រជុំពិនិត្យពិភាក្សា និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៣-២០២៥) របស់ឃុំវិហារសួគ៌ ក្រោមអធិបតីភាពលោក ម៉េង ឈាងហេង ប្រធានក្រុមប្រឹក្សាឃុំ និងជាប្រធានគណៈកម្មការឃុំវិហារសួគ៌ ។

I. **មាសភាពចូលរួមប្រជុំ:**

១-លោក លោកស្រី សមាជិកក្រុមប្រឹក្សាឃុំវិហារសួគ៌

២-លោក លោកស្រី ប្រធាន អនុប្រធាន និងសមាជិកភូមិ

៣-ស្មៀនឃុំ ជនបង្គោលនារីឃុំ និងជំនួយការរដ្ឋបាលឃុំ

II. **របៀបវារៈនៃកិច្ចប្រជុំរួមមាន:**

១.មតិថ្លែងបើកអង្គប្រជុំ (ដោយលោកប្រធានអង្គប្រជុំ)

២.ពិនិត្យ ពិភាក្សា និងអនុម័តសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២៣-២០២៥) របស់ឃុំវិហារសួគ៌

៣.បញ្ហាផ្សេងៗ

៤.មតិបូកសរុប និងបិទអង្គប្រជុំ (ដោយលោកប្រធានអង្គប្រជុំ)

បន្ទាប់ពីសមាជិក សមាជិកា នៃអង្គប្រជុំបានជួបជុំគ្នារួចមក លោក ម៉េង ឈាងហេង ប្រធានក្រុមប្រឹក្សាឃុំ វិហារសួគ៌ បានថ្លែងអំណរគុណចំពោះវត្តមានរបស់សមាជិក សមាជិកា ហើយបានអនុញ្ញាតឲ្យលោកស្រី ធន ឡាក់ឡេង ស្មៀនឃុំ ពិនិត្យមើលកូរ៉ុមឃើញថាមានចំនួន ០៩ រូប លើ ០៩រូប គ្រប់កូរ៉ុមអង្គប្រជុំអាចដំណើរការបាន។ ជា បន្តលោកប្រធានបានប្រកាសបើកអង្គប្រជុំ ហើយឲ្យលោកស្រី ធន ឡាក់ឡេង អានសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគ បីឆ្នាំរំកិល (២០២៣-២០២៥) ទាំងស្រុង ដើម្បីឲ្យសមាជិក សមាជិកា នៃអង្គប្រជុំធ្វើការពិនិត្យ ពិភាក្សា និង បំពេញបន្ថែមនូវចំណុចខ្វះខាត។

បន្ទាប់ពីបានពិនិត្យ និងពិភាក្សាយ៉ាងល្អិតល្អន់រួចមក អង្គប្រជុំបានអនុម័តយល់ព្រមដាក់ឲ្យប្រើប្រាស់ ជាផ្លូវការនូវកម្មវិធីវិនិយោគបីឆ្នាំរំកិល(២០២៣-២០២៥) ដោយសម្លេងចំនួន ០៩ លើ ០៩រូប សម្លេងគាំទ្រ។

ជាការបូកសរុបបិទអង្គប្រជុំ លោកប្រធានអង្គប្រជុំបានថ្លែងអំណរគុណ ចំពោះសមាជិក សមាជិកាអង្គប្រជុំ ដែលបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនៅថ្ងៃនេះ។ សូមជូនពរលោក លោកស្រី បានសម្រេចនូវពរជ័យទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ ជានិរន្តរ៍ និងបានសម្រេចដោយជោគជ័យគ្រប់ភារកិច្ចការងារ ដែលថ្នាក់លើប្រគល់ជូន។

អង្គប្រជុំបានបញ្ចប់សព្វគ្រប់នៅវេលាម៉ោងដប់មួយ និងសាមសិបនាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង ។

បានឃើញ និងឯកភាព

**ប្រធានអង្គប្រជុំ**

ម៉េង ឈាងហេង

អ្នកកត់ត្រា

ឆន ម្នាក់ឡេង

# ឧបសម្ព័ន្ធទី១១
# សេចក្តីជូនដំណឹងលេខ២១៤ ស.ជ.ណស្តីពីការទទួលស្គាល់គម្រោងថវិកាឆ្នាំ២០២៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រដ្ឋបាលខេត្តកណ្ដាល
លេខ ៤១៤ ស.ជ.ណ

ថ្ងៃពុធ ៣ រោច ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
កណ្ដាល ថ្ងៃទី ០៤ ខែ មករា ឆ្នាំ២០២៣

រតនាគារខេត្តកណ្ដាល
ចូល លេខ ០០៤៤
ទទួលថ្ងៃទី ០៥/០១/២០២៣ ម៉ោង ...
បញ្ជូនទៅ ...

**អភិបាលនៃគណៈអភិបាលខេត្តកណ្ដាល**

**ជម្រាបមក**

**លោកប្រធានក្រុមប្រឹក្សា ឃុំវិហារសួគ៌**

**កម្មវត្ថុ៖** ស្ដីពីការទទួលស្គាល់គម្រោងថវិកាឆ្នាំ២០២៣ របស់ រដ្ឋបាលឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល

**យោង ៖**- ព្រះរាជក្រម លេខ នស/រកម/០៣០១/០៥ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងឃុំ សង្កាត់
- អនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាល ស្ដីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- ប្រកាសលេខ ១៨៨៤ ប្រក ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០០២ ស្ដីពីការធ្វើប្រតិភូកម្មអំណាចជូនដល់អភិបាលខេត្ត ក្រុង ក្នុងការជួយគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់
- ប្រកាសអន្តរក្រសួងលេខ ២៤២៣ ប្រក ចុះថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ របស់ក្រសួងមហាផ្ទៃ និងក្រសួងផែនការ
- ប្រកាសណែនាំលេខ ៣៣១ សហវ.ប្រក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០២ ស្ដីពីការរៀបចំ និងការអនុវត្តថវិកាឃុំ សង្កាត់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សារាចរណែនាំលេខ ០០៦ សហវ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីនីតិវិធីបច្ចេកទេសនៃការរៀបចំគម្រោងថវិការបស់ រដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់គ្រប់គ្រងឆ្នាំ២០២៣
- លិខិតលេខ ៦៥៩៧ សហវ.អហក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការបែងចែកចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្ត ជូនរដ្ឋបាលឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣
- លិខិតលេខ ៦៥៩៦ សហវ.អហក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការវិភាជមូលនិធិឃុំ សង្កាត់ទូទាំងប្រទេស សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣
- លិខិតលេខ ៦៥៩៥ សហវ.អហក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ដីពីការវិភាជធនធានបន្ថែមសម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋានជូនរដ្ឋបាលឃុំ សង្កាត់ សម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣
- លិខិតលេខ ០៥៩/២២ សណ. ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០២២ ស្ដីពីសំណើសុំបញ្ជាក់ទទួលស្គាល់គម្រោងថវិកាឆ្នាំ២០២៣ របស់ រដ្ឋបាលឃុំ វិហារសួគ៌

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោកប្រធានក្រុមប្រឹក្សា ជ្រាបថា៖ គម្រោងថវិកា ឆ្នាំ២០២៣ របស់ រដ្ឋបាលឃុំ វិហារសួគ៌ ស្រុកខ្សាច់កណ្ដាល បានដាក់ស្នើសុំការពិនិត្យ និងបញ្ជាក់ទទួលស្គាល់ថវិកា ក្នុងនោះរួមមាន៖

| | | | | |
|---|---|---|---|---|
| ១-ចំណូលថវិកាសរុប | = | 805,966,237 | រៀល | ក្នុងនោះ: |
| -ចំណូលចរន្ត | = | 805,966,237 | រៀល | |
| -ចំណូលមូលធន | = | 00 | រៀល | |
| ២-ចំណាយថវិកាសរុប | = | 805,966,237 | រៀល | ក្នុងនោះ: |
| -ចំណាយចរន្ត | = | 805,966,237 | រៀល | |
| -ចំណាយមូលធន | = | 00 | រៀល | |

រដ្ឋបាលខេត្ត យល់ព្រមតាមការស្នើសុំ របស់ លោកប្រធានក្រុមប្រឹក្សា ឃុំវិហារសួគ៌ ដែលបានរៀបចំគម្រោងចំណូលចំណាយថវិកាជាក់ស្ដែងតាមចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិកាថវិកា របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

សូម លោកប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ ។

**អភិបាលខេត្ត**

គង់ សោភ័ណ្ឌ

**ចម្លងជូន៖**
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកណ្ដាល
- រតនាគារខេត្តកណ្ដាល
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១២
# កំណត់ហេតុអង្គប្រជុំអនុម័តគម្រោងថវិកាសម្រាប់
# ប្រចាំឆ្នាំ២០២៣របស់ក្រុមប្រឹក្សាឃុំវិហារសួគ៌

# ឧបសម្ព័ន្ធទី១៣
# តារាងតម្លៃសេវាសម្រាប់យន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលឃុំវិហារសួគ៌

# ឧបសម្ព័ន្ធទី១៤

## ប័ណ្ណសរសើរជ័យលាភីលេខ២សម្រាប់ការប្រលងប្រណាំងផ្ទៃក្នុងភូមិ ឃុំមានសុវត្ថិភាព ក្នុងវិស័យបរិស្ថានខេត្តកណ្ដាល ឆ្នាំ២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

បាលស្រុកខ្សាច់កណ្ដាល
ខ:......០១០/២៣....ខ្ស.ក

# ប័ណ្ណសរសើរ

រដ្ឋបាលស្រុកខ្សាច់កណ្ដាល សូមកោតសរសើរចំពោះ

**ឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល**

## ជ័យលាភីលេខ ២

**សម្រាប់ការប្រឡងប្រណាំងផ្ដែក្នុងភូមិ ឃុំ**

**មានសុវត្ថិភាពក្នុងវិស័យបរិស្ថានខេត្តកណ្ដាលឆ្នាំ២០២២**

ថ្ងៃ ពុធ ១០កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ខ្សាច់កណ្ដាល ថ្ងៃទី ០១ ខែ មីនា ឆ្នាំ២០២៣
**អភិបាលស្រុកខ្សាច់កណ្ដាល**

ចេង_ឌីណា

Scanned with CamScanner

# ឧបសម្ព័ន្ធទី១៥
# ប័ណ្ណសរសើរជ័យលាភីប្រភេទ១មានស្នាដៃល្អក្នុងការអនុវត្ត
# គោលនយោបាយភូមិ ឃុំមានសុវត្ថិភាពចាប់ពីឆ្នាំ
# ២០១៩-២០២២

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ [illegible]

# លិខិតសរសើរ

សូមសរសើរចំពោះ រដ្ឋបាលឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល នៃខេត្តកណ្ដាល ជ័យលាភីប្រភេទ ២

ដែល មានស្នាដៃល្អក្នុងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំមានសុវត្ថិភាព" ប្រចាំឆ្នាំ ២០១៩។

យោងតាមប្រកាសលេខ ១៤៦១ ប្រក.ថ្ងៃ សុក្រ ១៤កើត ខែ មាឃ ឆ្នាំ កុរ ឯកស័ក ព.ស ២៥៦៣

ត្រូវនឹងថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០២០

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ [illegible] ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០២០

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្ដេចក្រឡាហោម ស ខេង

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ [illegible]

# បណ្ណសរសើរ

សូមសរសើរចំពោះ រដ្ឋបាលឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល ជ័យលាភីប្រភេទ ១

ដែល មានស្នាដៃល្អក្នុងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំមានសុវត្ថិភាព" ប្រចាំឆ្នាំ ២០២០ ។

យោងតាមប្រកាសលេខ [illegible] ប្រ.ក.ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

ត្រូវនឹងថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០២១

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ ជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០២១

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្ដេចក្រឡាហោម ស ខេង

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ ៥៤០ ប.ក

# បណ្ណសរសើរ

សូមសរសើរចំពោះ៖ **រដ្ឋបាលឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល**
**ជ័យលាភីប្រភេទ ១**

ដែល មានស្នាដៃល្អក្នុងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំមានសុវត្ថិភាព" ប្រចាំឆ្នាំ ២០២១ ។

យោងតាមប្រកាសលេខ ២៦៦ ប្រ.ក ថ្ងៃ សុក្រ ១២ កើត ខែ បុស្ស ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

ត្រូវនឹងថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០២២

ថ្ងៃ[illegible] ខែ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០២២

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្ដេចក្រឡាហោម ស ខេង

Scanned with CamScanner

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ
លេខ [illegible] ប.ក

# បណ្ណសរសើរ

សូមសរសើរចំពោះ៖ **រដ្ឋបាលឃុំវិហារសួគ៌ ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល**
**ជ័យលាភីប្រភេទ ១**

ដែល មានស្នាដៃល្អក្នុងការអនុវត្តគោលនយោបាយ "ភូមិ-ឃុំមានសុវត្ថិភាព" ប្រចាំឆ្នាំ ២០២២ ។

យោងតាមប្រកាសលេខ ១២៣៦ ប្រក ថ្ងៃ សុក្រ ៥ រោច ខែ មាឃ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦

ត្រូវនឹងថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០២៣

ថ្ងៃ[illegible] ខែ [illegible] ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២៣

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្ដេចក្រឡាហោម ស ខេង

Scanned with CamScanner

# ឧបសម្ព័ន្ធទី១៦
# លិខិតបញ្ជាក់របស់រដ្ឋបាលឃុំ

# ឧបសម្ព័ន្ធទី១៧
# កម្រងរូបភាពជាមួយលោកមេឃុំ ស្មៀននិងជំនួយការ
# ហិរញ្ញវត្ថុឃុំវិហារសួគ៌


សាលាឃុំវិហារសួគ៌



# ឧបសម្ព័ន្ធទី១៨
# ទិដ្ឋភាពទូទៅក្នុងឃុំវិហារសួគ៌





វត្តព្រះវិហារសួគ៌

វត្តព្រៃលាក់ម្នាស់





ប៉ុស្តិ៍នគរបាលរដ្ឋបាលវិហារសួគ៌




មណ្ឌលសុខភាពវិហារសួគ៌




អនុវិទ្យាល័យនិងបឋមសិក្សាវិហារសួគ៌



សាលាបឋមសិក្សាស្វាយមាស




សាលាបឋមសិក្សាព្រៃចាស់

# ឧបសម្ព័ន្ធទី១៩
# គម្រូឯកសារភាពពាក់ព័ន្ធនឹងសកម្មភាពនានាដែល
# រដ្ឋបាលឃុំវិហារសួគ៌សម្រេចបាន






កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាឃុំ លើកទី១១ អាណត្តិទី៥ ក្នុងឆ្នាំ២០២៣





ការផ្តល់ប័ណ្ណសមធម៌ជូនគ្រួសារក្រីក្រ






ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត





ការចុះចែកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋតាមខ្នងផ្ទះក្នុងឃុំវិហារសួគ៌





ការចុះសម្អាតបរិស្ថាននៅតាមដងផ្លូវ









យុទ្ធនាការរួមគ្នា ដើម្បីសុខភាពល្អ និង បរិស្ថានស្អាត

 

ការចុះធ្វើការផ្សព្វផ្សាយដល់សិស្សានុសិស្សនៅគ្រប់សាលាក្នុងឃុំវិហារសួគ៌ស្ដីអំពី
នំចំណីនិងភេសជ្ជៈគ្រប់ប្រភេទដែលប៉ះពាល់ដល់សុខភាពកុមារ

 

ការចុះធ្វើការផ្សព្វផ្សាយអំពី គោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព
ជូនដល់ប្រជាពលរដ្ឋនៅក្នុងឃុំវិហារសួគ៌




ការផ្តល់សេវាអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានឃុំវិហារសួគ៌

